ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤

របាយការណ៍លទ្ធផលចុងក្រោយ

រៀបចំដោយ
វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ

ខែមករា ឆ្នាំ២០២៥

មាតិកា

ទំព័រ

បុព្វកថា.. i
សេចក្តីថ្លែងអំណរគុណ.. ii
ផែនទីប្រទេសកម្ពុជា.. iii
ជំពូក ១.. ១
    សេចក្តីផ្តើម និងវិធីសាស្រ្តអង្កេត.. ១
    ១.១.សេចក្តីផ្តើម.. ១
    ១.២.គោលបំណងអង្កេត.. ១
    ១.៣.ការជ្រើសរើសសំណាកគំរូ.. ២
    ១.៣.១. ប្រូបាប៊ីលីធីនៃការជ្រើសរើសគំរូ.. ៣
    ១.៣.២. មេគុណនៃការជ្រើសរើសគំរូ.. ៤
    ១.៤.កម្រងសំណួរអង្កេត.. ៤
    ១.៥.ការបណ្តុះបណ្តាលគ្រូបង្គោល.. ៥
    ១.៦.អង្កេតសាកល្បង.. ៦
    ១.៧.ការជ្រើសរើសមន្រ្តី.. ៧
    ១.៨.ការបណ្តុះបណ្តាលមន្រ្តីមូលដ្ឋាន.. ៧
    ១.៩.ប្រតិបត្តិការស្រង់ទិន្នន័យ.. ៨
    ១.១០.ការកែច្នៃទិន្នន័យ.. ៨
    ១.១១.ការរៀបចំតារាងវិភាគ.. ៩
    ១.១២.ការផ្សព្វផ្សាយលទ្ធផល.. ១០
ជំពូក ២.. ១៣
    ទំហំ កំណើន និងការបែងចែកប្រជាជន.. ១៣
    ២.១.ចំនួន និងទំហំប្រជាជនសរុប.. ១៣
    ២.២.កំណើនប្រជាជនប្រចាំឆ្នាំ.. ១៧
    ២.៣.ការបែងចែករបាយប្រជាជន.. ២០
    ២.៤.ដង់ស៊ីតេប្រជាជន.. ២៣
    ២.៥.ការបែងចែកប្រជាជនតាមសាសនា.. ២៥
    ២.៦.ការបែងចែកប្រជាជនតាមទីកន្លែងកំណើត.. ២៦
    ២.៧.ការបែងចែកប្រជាជនតាមភាសាកំណើត.. ២៦
ជំពូក ៣.. ២៧
រចនាសម្ព័ន្ធអាយុ ភេទ និងអាពាហ៍ពិពាហ៍.. ២៧
    ៣.១. សេចក្តីផ្តើម.. ២៧

៣.២. ការវាយតម្លៃទិន្នន័យអាយុ.. ២៧
៣.៣. រចនាសម្ព័ន្ធអាយុ.. ២៨
៣.៤. ផលធៀបអាយុនៅក្នុងបន្ទុក.. ៣៤
៣.៥. ផលធៀបភេទ.. ៣៥
៣.៦. ស្ថានភាពអាពាហ៍ពិពាហ៍ និងអាយុរៀបការលើកដំបូង.. ៣៦
៣.៦.១. ស្ថានភាពអាពាហ៍ពិពាហ៍.. ៣៦
៣.៧. អាយុរៀបការលើកដំបូង.. ៣៩
៣.៨. អាយុរៀបការ.. ៤០
ជំពូក ៤... ៤៣
អក្ខរភាព និងការអប់រំ... ៤៣
៤.១. សេចក្តីផ្តើម.. ៤៣
៤.២. កម្រិតអក្ខរភាព.. ៤៤
៤.៣. អត្រាអក្ខរភាពមនុស្សពេញវ័យ... ៤៦
៤.៤. កម្រិតសិក្សាអប់រំ... ៤៧
៤.៥. អត្រាចូលរៀន... ៥៣
ជំពូក ៥... ៥៥
កម្លាំងពលកម្ម និងការងារ.. ៥៥
៥.១. សេចក្តីផ្តើម.. ៥៥
៥.២. សកម្មជនសេដ្ឋកិច្ច និងកម្លាំងពលកម្ម... ៥៦
៥.៣. មានការងារធ្វើ និងគ្មានការងារធ្វើ... ៦០
៥.៤. ស្ថានភាពការងារ.. ៦២
៥.៥. ផ្នែកនៃការងារ... ៦៥
៥.៦. ចំណាត់ថ្នាក់ការងារតាមមុខរបរ និងសកម្មភាពសេដ្ឋកិច្ច... ៧២
ជំពូក ៦... ៨១
ទេសន្តរប្រវេសន៍... ៨១
៦.១. សេចក្តីផ្តើម.. ៨១
៦.២. ចំនួនជនទេសន្តរប្រវេសន៍.. ៨១
៦.៣. មូលហេតុសម្រាប់ទេសន្តរប្រវេសន៍.. ៨៣
៦.៤. ចរន្តទេសន្តរប្រវេសន៍... ៨៤
៦.៥. រយៈពេលស្នាក់នៅ.. ៨៤
៦.៦. ទេសន្តរប្រវេសន៍តាមក្រុមអាយុ.. ៨៥
៦.៧. ទេសន្តរប្រវេសន៍តាមសកម្មភាពសេដ្ឋកិច្ច... ៨៦
៦.៨. ទេសន្តរប្រវេសន៍តាមកម្រិតសិក្សាអប់រំ... ៨៨
៦.៩. អន្តោប្រវេសន៍.. ៩២

ជំពូក ៧.. ៩៥
លទ្ធភាពមានកូន.. ៩៥
៧.១. សេចក្តីផ្តើម.. ៩៥
៧.២. លទ្ធភាពមានកូនតាមអាយុជាក់លាក់ (ASFR) ៩៦
៧.៣. លទ្ធភាពមានកូនសរុប (TFR) ៩៧
៧.៤. សូចនាករលទ្ធភាពមានកូនផ្សេងទៀត.. ៩៩
៧.៥. គម្លាតកំណើតកូនកើតរស់ (CEB) ៩៩
ជំពូក ៨.. ១០១
មរណភាព.. ១០១
៨.១. សេចក្តីផ្តើម.. ១០១
៨.២. អាត្រាមរណភាពអយុបឋមតាមវិធីសាស្ត្រដោយប្រយោល.. ១០២
៨.៣. មរណភាពមនុស្សពេញវ័យ និងតារាងវដ្តជីវិត.. ១០៣
៨.៤. មរណភាពមាតា.. ១០៥
ជំពូក ៩.. ១០៧
ពិការភាព.. ១០៧
៩.១. សេចក្តីផ្តើម.. ១០៧
៩.២. កម្រិតពិការភាព.. ១០៨
៩.៣. ពិការភាពតាមស្ថានភាពអាពាហ៍ពិពាហ៍... ១១៥
៩.៤. អក្ខរភាព និងកម្រិតសិក្សាអប់រំ.. ១១៧
៩.៥. អត្រាសកម្មភាពសេដ្ឋកិច្ច.. ១២១
ជំពូក ១០.. ១២៣
លំនៅដ្ឋាន ចរិតលក្ខណៈគ្រួសារ និងសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ.. ១២៣
១០.១. លំនៅដ្ឋាន.. ១២៣
១០.២. ចរិតលក្ខណៈគ្រួសារ.. ១២៥
១០.២.១.ចំនួន និងទំហំគ្រួសារ.. ១២៥
១០.២.២. បុរស និងស្ត្រីជាមេគ្រួសារ.. ១២៧
១០.២.៣. ចំនួនបន្ទប់ប្រើប្រាស់ក្នុងគ្រួសារ.. ១៣៩
១០.៣. សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ.. ១៣៩
១០.៣.១. ទឹកសម្រាប់ទទួលទាន.. ១៣៩
១០.៣.២. ប្រភពបំភ្លឺសំខាន់ៗ.. ១៤១
១០.៣.៣. បង្គន់អនាម័យ.. ១៤៣
១០.៣.៤. ឥន្ទនៈសម្រាប់ចម្អិន.. ១៤៦
១០.៣.៥. ការប្រើប្រាស់អ៊ិនធឺណែត.. ១៤៧
១០.៣.៦. សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន.. ១៤៨

ជំពូក ១១ .... ១៥១
សង្ខេប និងសេចក្តីសន្និដ្ឋាន ១៥១
១១.១.សូចនាករប្រជាសាស្ត្រ ១៥១
១១.២. ការបែងចែកប្រជាជន ១៥១
១១.៣. អត្រាភេទ និងរចនាសម្ព័ន្ធអាយុ ១៥១
១១.៤. ស្ថានភាពអាពាហ៍ពិពាហ៍ ១៥២
១១.៥. អក្ខភាព និងការអប់រំ ១៥២
១១.៦. ការចូលរៀន ១៥៣
១១.៧. ការចូលរួមសកម្មភាពសេដ្ឋកិច្ច (កម្លាំងពលកម្ម) ១៥៣
១១.៨. បម្លាស់ទី និងទេសន្តប្រវេសន៍ ១៥៤
១១.៩. លទ្ធភាពបង្កើតកូន ១៥៥
១១.១០. មរណភាព ១៥៦
១១.១១. ពិការភាព ១៥៧
១១.១២. លក្ខណៈផ្ទះសម្បែង និងគ្រួសារ ១៥៧
សន្ទានុក្រម ១៦១
ឧបសម្ព័ន្ធ ១៧៣
តារាងក   កម្រងសំណួរបញ្ជីផ្ទះ ១៧៥
តារាងខ   កម្រងសំណួរគ្រួសារ ១៧៧

តារាង

តារាង ១.៣.១.ចំនួនសំណាកគំរូ បែងចែកតាមរាជធានី ខេត្ត សម្រាប់អង្កេតចន្លោះ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤........ ៣
តារាង ២.១.១.ចំនួនគ្រួសារ ប្រជាជន និងទំហំគ្រួសារមធ្យម តាមរាជធានី ខេត្ត កម្ពុជាឆ្នាំ២០២៤ .... ១៥
តារាង ២.២.១.អត្រាកំណើនប្រជាជនប្រចាំឆ្នាំចុងក្រោយ តាមរាជធានី/ខេត្ត កម្ពុជាឆ្នាំ២០១៩-២០២៤........ ១៩
តារាង ២.៣.១.ភាគរយប្រជាជនសរុបចុងក្រោយ តំបន់ និង ភេទ កម្ពុជាឆ្នាំ ២០១៩-២០២៤........ ២១
តារាង ២. ៤.១.ការបែងចែករបាយផ្ទៃដី និងដង់ស៊ីតេប្រជាជនតាមរាជធានី ខេត្តកម្ពុជា២០១៩-២០២៤........ ២៤
តារាង ២.៥.១.ការបែងចែកភាគរយប្រជាជនតាមសាសនា និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ .... ២៥
តារាង ២.៦.១.ការបែងចែកប្រជាជនតាមទីកន្លែងកើត និងភេទ កម្ពុជាឆ្នាំ២០១៩-២០២៤........ ២៦
តារាង២. ៧.១.ការបែងចែកប្រជាជនតាមភាសាកំណើត និងភេទ កម្ពុជាឆ្នាំ២០១៩-២០២៤ .... ២៦
តារាង ៣.២.១.ការវាយតម្លៃកត់ត្រាអាយុ អង្កេតចន្លោះជំរឿនប្រជាជនកម្ពុជាឆ្នាំ២០២៤........ ២៨
តារាង ៣.៣.១.ការបែងចែកតាមក្រុមអាយុរាយ តាមភេទ តំបន់ កម្ពុជា ឆ្នាំ២០២៤........ ២៩
តារាង ៣.៣.២.ការបែងចែកប្រជាជនតាមក្រុមអាយុ ផលធៀបអាយុក្នុងបន្ទុក មេដ្យាអាយុ និងផលធៀបភេទ កម្ពុជាឆ្នាំ២០១៩ និង២០២៤........ ៣៤
តារាង ៣.៥.១.ការបែងចែកផលធៀបភេទ ក្រុមអាយុ ភេទ កម្ពុជា ២០១៩-២០២៤........ ៣៥
តារាង ៣.៦.១.ស្ថានភាពអាពាហ៍ពិពាហ៍អាយុ១៥ ឆ្នាំឡើង ភេទ និងតំបន់ កម្ពុជា ២០១៩-២០២៤........ ៣៧
តារាង ៣.៧.១.អាយុមធ្យមរៀបការលើកទី១ តាមភេទ និងតំបន់ កម្ពុជា២០១៩-២០២៤........ ៤០
តារាង ៣.៨.១.អាយុមធ្យមរៀបការដំបូង សមាមាត្រធ្លាប់រៀបការ តាមភេទ អាយុ និងតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤........ ៤១
តារាង ៤.២.១.ភាគរយអក្ខរភាពអាយុ ៧ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៤៥
តារាង ៤.២.២.ភាគរយអក្ខរកម្មក្រៅពីភាសាខ្មែរ អាយុ៧ឆ្នាំឡើង តាមភេទ និងទីប្រជុំជន ជនបទ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៤៦
តារាង ៤. ៣.១.ស្ថានភាពអក្ខរភាពប្រជាជនពេញវ័យ (ចេះអាន និងសរសេរ) អាយុ ១៥ឆ្នាំឡើង តាមទីប្រជុំជន ជនបទ និងភេទ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៤៧
តារាង ៤.៤.១.កម្រិតសិក្សាអប់រំប្រជាជនអាយុ ៧ឆ្នាំឡើង តាមក្រុមអាយុ ភេទ តំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៤៩

តារាង ៤.៥.១.ស្ថានភាពចូលរៀនក្រុមអាយុ ៦ឆ្នាំឡើង តាមភេទ អាយុ តំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤........ ៥៤
តារាង ៥.២.១. ស្ថានភាពសកម្មភាពសេដ្ឋកិច្ច អាយុ ៥ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៥៨
តារាង ៥.២.២. អត្រាចូលរួមកម្លាំងពលកម្មអាយុជាក់លាក់ តាមក្រុមអាយុ ភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៥៩
តារាង ៥.៤.១. ភាគរយអ្នកមានការងារធ្វើ តាមស្ថានភាពការងារ អាយុ៥ឆ្នាំឡើង តាមក្រុមអាយុ ភេទ តំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៦៣
តារាង ៥.៥.១. ភាគរយអ្នកមានការងារធ្វើ ៥ឆ្នាំឡើង បែងចែកតាមភេទ ផ្នែកការងារ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ .... ៦៦
តារាង ៥.៦.១. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើ អាយុ៥ឆ្នាំឡើង ទៅតាមមុខរបរ អាជីព ភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៧៣
តារាង ៥.៦.២. ការបែងចែកភាគរយនៃប្រជាជនមានការងារធ្វើ តាមសកម្មភាពការងារ អាយុ ៥ឆ្នាំ ឡើង តាមភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៧៧
តារាង ៥.៦.៣. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើ តាមវិស័យការងារ ភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៨០
តារាង ៦.២.១.ចំនួនប្រជាជនតែងតែរស់នៅកន្លែងសម្ភាសន៍ តាមតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤ .... ៨២
តារាង ៦.២.២. ភាគរយនៃជនទេសន្តប្រវេសន៍តាមលំនៅដ្ឋានមុន ភេទ កម្ពុជា ឆ្នាំ២០១៩-២០២៤........ ៨២
តារាង ៦.៣.១. ភាគរយបែងចែកតាមមូលហេតុសម្រាប់ជនទេសន្តរប្រវេសន៍ តាមភេទ កម្ពុជា ឆ្នាំ២០១៩-២០២៤........ ៨៣
តារាង ៦.៤.១.ភាគរយទេសន្តរប្រវេសន៍តាមចរន្តទីប្រជុំជន ជនបទ តាមភេទ កម្ពុជា ឆ្នាំ២០១៩-២០២៤........ ៨៤
តារាង ៦.៥.១. ភាគរយជនទេសន្តរប្រវេសន៍ក្នុងស្រុក តាមរយៈពេលស្នាក់នៅ តំបន់ កម្ពុជា ឆ្នាំ ២០១៩-២០២៤........ ៨៤
តារាង ៦.៦.១. ភាគរយនៃជនទេសន្តរប្រវេសន៍អាយុ ១០ឆ្នាំឡើង តាមក្រុមអាយុ និងភេទ កម្ពុជាឆ្នាំ២០១៩-២០២៤........ ៨៥
តារាង ៦.៧.១. ភាគរយនៃជនទេសន្តរប្រវេសន៍ក្នុងស្រុក អាយុ ៥ឆ្នាំឡើង តាមសកម្មភាព សេដ្ឋកិច្ច ភេទ និងតំបន់ កម្ពុជាឆ្នាំ២០២៤........ ៨៧
តារាង ៦.៨.១. ភាគរយជនទេសន្តរប្រវេសន៍ក្នុងស្រុក អាយុ ៧ឆ្នាំឡើង តាមកម្រិតសិក្សា ភេទ និងក្រុមអាយុ កម្ពុជាឆ្នាំ២០២៤........ ៨៩
តារាង ៦.៩.១. ភាគរយនៃជនអន្តោប្រវេសន៍អាយុ៥ឆ្នាំឡើង ជាសកម្មភាពសេដ្ឋកិច្ច តាមភេទ និងប្រភេទសកម្មភាព កម្ពុជាឆ្នាំ២០២៤........ ៩២

តារាង ៧.១.១. ប៉ានស្មានអត្រាលទ្ធភាពបង្កើតកូន តាមអាយុជាក់លាក់ និងអត្រាលទ្ធភាពបង្កើតកូនសរុប តាមតំបន់ កម្ពុជាឆ្នាំ២០២៤ ..... ៩៦
តារាង ៧.៣.១.ប៉ាន់ស្មានអត្រាលទ្ធភាពបង្កើតកូនសរុប តាមតំបន់ កម្ពុជាឆ្នាំ២០២៤ តាមវិធីសាស្ត្រដោយប្រយោលផ្សេងៗទៀត ៩៨
តារាង ៧.៥.១. ស្ត្រីតាមគម្លាត និងចំនួនកូនកើតរស់ កម្ពុជា តាមតំបន់ ឆ្នាំ២០២៤ ..... ១០០
តារាង ៨.២.១. អត្រាមរណភាពអាយុបឋម និងអាយុសង្ឃឹមរស់ តាមភេទ និងតំបន់ កម្ពុជា២០២៤ ..... ១០២
តារាង ៨.២.២. អត្រាមរណភាពទារក តាមភេទ តំបន់ កម្ពុជាឆ្នាំ២០២៤ ..... ១០៤
តារាង ៨.៣.១.តារាងវដ្តជីវិត ប្រុស កម្ពុជាឆ្នាំ២០២៤ ..... ១០៤
តារាង ៨.៣.២. តារាងវដ្តជីវិត ស្រី កម្ពុជាឆ្នាំ២០២៤ ..... ១០៥
តារាង ៩.២.១. អត្រាពិការភាពអាយុ ៥ឆ្នាំឡើង បែងចែកតាមគ្រប់កម្រិតពិការភាព ភេទ តំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១០៩
តារាង ៩.២.២. អត្រាពិការភាពអាយុ ៥ឆ្នាំឡើង បែងចែកតាមកម្រិតពិការភាព ភេទ តំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១១០
តារាង ៩.២.៣. បែងចែកភាគរយនៃប្រជាជនពិការ អាយុ ៥ឆ្នាំឡើង តាមប្រភេទពិការ ភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១១២
តារាង ៩.៣.១. ពិការភាពបែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ អាយុ១៥ឆ្នាំឡើង និងភេទ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១១៦
តារាង ៩.៤.១. អត្រាអក្ខរភាពនៃប្រជាជនពិការអាយុ៧ឆ្នាំឡើង តាមភេទ តំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១១៧
តារាង ៩.៤.២. ភាគរយនៃអក្ខរភាពជនពិការអាយុ ៧ឆ្នាំឡើង បានបញ្ចប់ពេញលេញតាមកម្រិតសិក្សា ភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១១៩
តារាង ៩.៥.១. ការបែងចែកភាគរយនៃប្រជាជនពិការអាយុ ៥ឆ្នាំឡើង តាមសកម្មភាពការងារចម្បង ភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១២២
តារាង ១០.១.១. ភាគរយនៃអគារលំនៅដ្ឋាន ជាលំនៅដ្ឋានទាំងមូល ឬដោយផ្នែក និងប្រភេទលំនៅដ្ឋានដ៏ទៃទៀត កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១២៣
តារាង ១០.១.២. ភាគរយនៃអគារជាលំនៅដ្ឋានអចិន្ត្រៃយ៍ តាមចរិតលក្ខណៈនៃសំណង់អគារ កម្ពុជា ឆ្នាំ២០១៩-២០២៤ ..... ១២៤
តារាង ១០.២.១. ចំនួនគ្រួសារធម្មតា ឬគ្រួសារប្រក្រតី និងទំហំមធ្យម កម្ពុជា ឆ្នាំ២០១៩-២០២៤ ..... ១២៥
តារាង ១០.២.២. ចំនួនគ្រួសារ និងប្រជាជន តាមភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១២៦
តារាង ១០.២.៣. ភាគរយនៃគ្រួសារតាមប្រភេទនៃមេគ្រួសារ និងទំហំគ្រួសារ កម្ពុជា ឆ្នាំ២០១៩-២០២៤ ..... ១២៦

តារាង ១០.២.៤. ការបែងចែកភាគរយនៃគ្រួសារ(អាយុ ១០ឆ្នាំឡើង) តាមភេទ និងក្រុមអាយុ កម្ពុជា ឆ្នាំ២០១៩-២០២៤ ..... ១២៨
តារាង ១០.២.៥. ការបែងចែកនៃ១.០០០ គ្រួសារ តាមទំហំគ្រួសារ និងចំនួនសមាជិក ជាសកម្មជនសេដ្ឋកិច្ច សម្រាប់គ្រួសារសរុប កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១២៩
តារាង ១០.២.៦. ការបែងចែកនៃ១.០០០ គ្រួសារ តាមទំហំគ្រួសារ និងចំនួនសមាជិក ជាសកម្មជនសេដ្ឋកិច្ច សម្រាប់បុរសជាមេគ្រួសារសរុប កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១៣១
តារាង ១០.២.៧. ការបែងចែកនៃ១.០០០ គ្រួសារ តាមទំហំគ្រួសារ និងចំនួនសមាជិក ជាសកម្មជនសេដ្ឋកិច្ច សម្រាប់ស្ត្រីជាមេគ្រួសារសរុប កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១៣៣
តារាង ១០.២.៨. ការបែងចែកមេគ្រួសារ ដែលជាសកម្មជនសេដ្ឋកិច្ច និងអសកម្មជនសេដ្ឋកិច្ច អាយុ១០ឆ្នាំឡើង តាមក្រុមអាយុ ភេទ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១៣៥
តារាង ១០.២.៩. ការបែងចែក ១.០០០ គ្រួសារតាមស្ថានភាពលំនៅដ្ឋាន ចំនួនបន្ទប់គ្រប់គ្រងដោយគ្រួសារ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១៣៧
តារាង ១០.៣.១. ការបែងចែកភាគរយគ្រួសារ តាមប្រភពទឹកចម្បងសម្រាប់ទទួលទាន កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១៤០
តារាង ១០.៣.២. ភាគរយនៃគ្រួសារ តាមប្រភពបភ្លឺចម្បងប្រើប្រាស់ កម្ពុជាឆ្នាំ២០១៩-២០២៤ ..... ១៤២
តារាង ១០.៣.៣. ភាគរយនៃគ្រួសារតាមការប្រើប្រាស់ប្រភេទបង្គន់ តំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤ ..... ១៤៥
តារាង ១០.៣.៤. ភាគរយនៃគ្រួសារដែលមានប្រភពទឹកកែលំអរ អគ្គិសនី និងបង្គន់ប្រើប្រាស់ តាមតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤ ..... ១៤៦
តារាង ១០.៣.៥. គ្រួសារតាមប្រភេទឥន្ធនៈប្រើប្រាស់ចម្អិនអាហារតាមលំនៅដ្ឋាន កម្ពុជា ឆ្នាំ២០១៩-២០២៤ ..... ១៤៦
តារាង ១០.៣.៦. ការបែងចែកគ្រួសារ តាមប្រភេទ និងចំនួនឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន កម្ពុជាឆ្នាំ២០២៤ ..... ១៤៩

រូបភាព

រូប ២.១.១.និន្នាការប្រជាជនកម្ពុជាសរុប ពីឆ្នាំ ១៩៦២ ដល់ ២០២៤ ..... ១៤
រូប ២.១.២.ប្រជាជនកម្ពុជា និងតាមរាជធានី ខេត្ត ឆ្នាំ ២០២៤ ..... ១៦
រូប ៣.៣.៣.១.១.ពីរ៉ាមីតអាយុប្រជាជនកម្ពុជា សរុប ២០១៩-២០២៤ ..... ៣២
រូប ៣.៣.៣.១.២.ពីរ៉ាមីតអាយុប្រជាជនកម្ពុជា ទីប្រជុំជន ២០១៩-២០២៤ ..... ៣៣
រូប ៣.៣.៣.១.៣.ពីរ៉ាមីតអាយុប្រជាជនកម្ពុជា ជនបទ ២០១៩-២០២៤ ..... ៣៣
រូប ៣.៦.១. ភាគរយមិនទាន់រៀបការអាយុ ១៥ ឆ្នាំឡើង តាមភេទ២០១៩-២០២៤ ..... ៣៨
រូប ៣.៦.២.ភាគរយបច្ចុប្បន្នរៀបការអាយុ ១៥ ឆ្នាំឡើង តាមភេទ២០១៩-២០២៤ ..... ៣៨
រូប ៣.៦.៣.ភាគរយមេម៉ាយ ឬពោះមាយ លែងលះគ្នា និងរស់នៅផ្សេងគ្នា អាយុ១៥ឆ្នាំឡើង តាមភេទ ២០១៩-២០២៤ ..... ៣៩
រូប ៤.២.១.ភាគរយអក្ខរភាពភាសាខ្មែរអាយុ៧ឆ្នាំឡើង តាមភេទ

កម្ពុជា ឆ្នាំ២០១៩-២០២៤.. ៤៤
រូប ៤.៤.១.ភាគរយប្រជាជនអក្ខរភាពអាយុ៧ឆ្នាំឡើង តាមកម្រិតសិក្សាអប់រំ
កម្ពុជាឆ្នាំ២០១៩-២០២៤.. ៤៨
រូប ៤.៥.១.អត្រាចូលរៀនសាលា ឬគ្រឹះស្ថានអប់រំណាមួយ អាយុ៦ ឆ្នាំឡើង
កម្ពុជា ឆ្នាំ២០២៤.. ៥៣
រូប ៥.២.១.ស្ថានភាពសកម្មភាពសេដ្ឋកិច្ច អាយុ៥ឆ្នាំឡើង តាមភេទ និងតំបន់
កម្ពុជាឆ្នាំ២០១៩-២០២៤.. ៥៧
រូប ៥.២.២. អត្រាចូលរួមក្នុងកម្លាំងពលកម្មអាយុជាក់លាក់ តាមភេទ កម្ពុជា
ឆ្នាំ២០១៩-២០២៤... ៦០
រូប ៥.៣.១.អត្រាមានការងារធ្វើអាយុ ៥ឆ្នាំឡើង តាមភេទ តំបន់ កម្ពុជា
ឆ្នាំ២០១៩-២០២៤... ៦១
រូប ៥.៣.២.អត្រាគ្មានការងារធ្វើអាយុជាក់លាក់ តាមក្រុមអាយុ តំបន់ កម្ពុជាឆ្នាំ២០២៤.. ៦១
រូប ៥.៦.១.ការបែងចែកភាគរយនៃអ្នកមានការងារធ្វើ ៥ឆ្នាំឡើង តាមវិស័យការងារ
ភេទ កម្ពុជាឆ្នាំ២០១៩-២០២៤.. ៨០
រូប ៧.២.១.អត្រាលទ្ធភាពមានកូនតាមអាយុជាក់លាក់ តាមតំបន់ កម្ពុជាឆ្នាំ២០២៤.......... ៩៧
រូប ៧.៣.១.អត្រាលទ្ធភាពមានកូនសរុប តាមតំបន់ កម្ពុជា ២០១៩-២០២៤.................. ៩៨
រូប ៨.២.១.អត្រាមរណភាពអាយុបឋម កម្ពុជាឆ្នាំ២០១៩-២០២៤................................ ១០២
រូប ៨.៤.១.អត្រាមរណភាពមាតា កម្ពុជាឆ្នាំ២០០៨.២០១៤. ២០១៩. និង២០២៤.......... ១០៦
រូប ៩.២.១.អត្រាពិការភាពអាយុ៥ ឆ្នាំឡើង បែងចែកតាមក្រុមអាយុ ភេទ តំបន់ កម្ពុជា
ឆ្នាំ២០២៤.. ១១១
រូប ១០.១.១.ភាគរយនៃអគារជាលំនៅដ្ឋានអចិន្ត្រៃយ៍ តាមចរិតលក្ខណៈ
នៃសំណង់អគារ កម្ពុជាឆ្នាំ២០២៤.. ១២៤
រូប ១០.២.១.ស្ត្រីជាមេគ្រួសារ តាមអាយុ កម្ពុជា ឆ្នាំ២០១៩-២០២៤............................. ១២៧
រូប ១០.២.២.ចំនួនបន្ទប់ដែលគ្រួសារមាន កម្ពុជាឆ្នាំ២០២៤ គិតជាភាគរយ..................... ១៣៩
រូប ១០.៣.២.ភាគរយនៃគ្រួសារ តាមប្រភពបំភ្លឺចម្បង និងតំបន់ កម្ពុជា ឆ្នាំ២០២៤........... ១៤១
រូប ១០.៣.៣.ការបែងចែកភាគរយនៃគ្រួសារដែលមាន ឬមិនមានបង្គន់ប្រើប្រាស់ កម្ពុជាឆ្នាំ
២០២៤... ១៤៣
រូប ១០.៣.៤.ភាគរយនៃគ្រួសារមានបង្គន់ប្រើប្រាស់ តាមប្រភេទ និងតំបន់ កម្ពុជា
ឆ្នាំ២០២៤.. ១៤៤
រូប ១០.៣.៥.ភាគរយនៃគ្រួសារតាមប្រភេទថាមពលប្រើប្រាស់ចម្អិនអាហារ តាម
លំនៅដ្ឋាន កម្ពុជាឆ្នាំ២០២៤.. ១៤៧
រូប ១០.៣.៦.ការបែងចែកភាគរយនៃគ្រួសារតាមការប្រើប្រាស់អ៊ិនធឺណែត តំបន់ កម្ពុជា
ឆ្នាំ២០២៤.. ១៤៨

ផែនទី

ផែនទី ២.១.១.ការបែងចែកចំនួនប្រជាជនតាមរាជធានីខេត្ត.. ១៧
ផែនទី ២.២.១.អត្រាកំណើនប្រជាជនប្រចាំឆ្នាំ តាមរាជធានី ខេត្ត កម្ពុជាឆ្នាំ២០២៤.......... ២០
ផែនទី ២.៣.១.ភាគរយប្រជាជនសរុប តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២៤.................... ២២
ផែនទី ២.៤.១.ដង់ស៊ីតេប្រជាជនតាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២៤.......................... ២៥

បុព្វកថា

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានបង្ហាញនូវសមិទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជាដែលសម្រេចបានក្នុងនីតិកាលទី៧ នៃរដ្ឋសភា និងបានផ្តល់ទឡ្ហីករណ៍ដ៏ជាក់លាក់សម្រាប់វាយតម្លៃពីផែនការយុទ្ធសាស្ត្រជាតិ និងការអភិវឌ្ឍនាពេលអនាគត។ ទិន្នន័យស្ថិតិនេះ គឺជាឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់វាស់វែង និងរៀបចំគោលនយោបាយក្នុងការអភិវឌ្ឍប្រទេសជាតិ។ របាយការណ៍លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ តាមកាលបរិច្ឆេទយោងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ នេះ ជាអង្កេតចន្លោះជំរឿនប្រជាជនលើកទី៣ ដែលបានអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាសាស្ត្រ ក្រោយពីការធ្វើជំរឿនប្រកបដោយជោគជ័យ នៅឆ្នាំ២០១៩ ដែលដឹកនាំអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

លទ្ធផលចុងក្រោយនៃអង្កេតនេះ ត្រូវបានបោះពុម្ពផ្សព្វផ្សាយដើម្បីផ្តល់ជូននូវព័ត៌មាន ស្តីពីរចនាសម្ព័ន្ធប្រជាសាស្ត្រ ស្ថានភាពអប់រំ ស្ថានភាពការងារ លទ្ធភាពមានកូន មរណភាព ចរិតលក្ខណៈផ្ទះសម្បែង ដើម្បីបំពេញតម្រូវការរៀបចំធ្វើគោលនយោបាយអភិវឌ្ឍន៍ជាតិ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក.) គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ កម្មវិធីសុខភាពមាតានិងទារក កម្មវិធីសង្គមកិច្ច និងស្តារនីតិសម្បទាសម្រាប់ជនពិការ និងរៀបចំផែនការអភិវឌ្ឍន៍តាមវិស័យជាច្រើនទៀត ដើម្បីគាំទ្រយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

តាងនាមឱ្យក្រសួងផែនការ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានគាំទ្រយ៉ាងពេញទំហឹង ជំរុញឱ្យការងារនេះសម្រេចបានជោគជ័យគួរជាទីមោទនៈ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ដែលបានផ្តល់ការសហការ និងជំរុញការងារនេះ ហេតុទទួលបានជោគជ័យ។ ជាពិសេស លទ្ធផលដ៏ប្រសើរនេះអាចសម្រេចបានដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃវិទ្យាស្ថានជាតិស្ថិតិ ដែលបានបំពេញកិច្ចការប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់ ហេតុដល់ការងារអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ២០២៤ ទទួលបានជោគជ័យ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា របាយការណ៍លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ២០២៤ នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ អ្នកសិក្សាស្រាវជ្រាវ និងសាធារណជន សម្រាប់ប្រើប្រាស់សំដៅសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព ដែលបម្រើដល់គុណប្រយោជន៍ជាតិនិងប្រជាជនឱ្យកាន់តែល្អប្រសើរឡើង។ T.M

រដ្ឋមន្ត្រី

ប៊ិន ត្រឈៃ

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែមករា ឆ្នាំ២០២៥

សេចក្តីថ្លែងអំណរគុណ

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានបញ្ចប់ប្រកបដោយជោគជ័យ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រី និងភាគីពាក់ព័ន្ធទាំងអស់។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានគាំទ្រយ៉ាងពេញទំហឹង ជំរុញឱ្យការងារនេះសម្រេចបានជោគជ័យគួរជាទីមោទនៈ។ លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដែលបានអនុញ្ញាតឱ្យប្រើប្រាស់ថវិកាជាតិ និងជួយសម្រួលដល់ការផ្តល់ថវិកាបានទាន់ពេលវេលាសម្រាប់ការងារអង្កេតនេះ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តម ប៊ិន ត្រឈៃ រដ្ឋមន្ត្រីក្រសួងផែនការ** ដែលបានគាំទ្រដល់គ្រប់ការងារអង្កេតចន្លោះជំរឿន និងការលើកទឹកដល់មន្ត្រីអនុវត្តន៍គម្រោង។ សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះសមាជិក សមាជិកាទាំងអស់ ដែលបានចំណែក និងផ្តល់ប្រឹក្សាណែនាំដ៏មានតម្លៃធ្វើឱ្យការអង្កេតនេះទទួលបានជោគជ័យ។

ខ្ញុំសូមកោតសរសើរនូវការខិតខំប្រឹងប្រែង និងការគាំទ្របច្ចេកទេសដោយលោក សុក កុសល លោក សាំង ឡុងឌី លោក សំ សារឿន លោក ចឺ ឃាម និង លោក ទ្រី ម៉េងស៊ាង ព្រមទាំងអគ្គនាយករង ប្រធាននាយកដ្ឋាន និងមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន។ សូមថ្លែងអំណរគុណជាពិសេសចំពោះមន្ត្រីសម្ភាសន៍ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្របសម្រួលមូលដ្ឋានដែលបានធ្វើការប្រកបដោយវិជ្ជាជីវៈ និងជំនះលើបញ្ហាប្រឈមនានាក្នុងការប្រមូលទិន្នន័យប្រកបដោយគុណភាព។ ជាចុងក្រោយយើងសូមអរគុណដោយស្មោះចំពោះអ្នកផ្តល់ចម្លើយទាំងអស់ដែលបានផ្តល់ពេលវេលាដ៏មានតម្លៃក្នុងការចូលរួមក្នុងការសម្ភាសន៍សម្រាប់អង្កេតនេះ។

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ

ទ្រី ឫទ្ធា

ផែនទី ព្រះរាជាណាចក្រកម្ពុជា



សេចក្តីផ្តើម និងវិធីសាស្រ្តអង្កេត ១

១.១. សេចក្តីផ្តើម

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ (CIPS) បានធ្វើឡើងក្នុងខែ ឧសភា ឆ្នាំ២០២៤។ ពេលវេលាយោងសម្រាប់អង្កេតគឺចន្លោះអធ្រាត្រនៃថ្ងៃទី៣ ខែឧសភា (00 ម៉ោង)។ នេះជាការអង្កេតចន្លោះជំរឿនប្រជាជនលើកទីបី ដែលត្រូវធ្វើនៅកម្ពុជា (CIPS២០២៤)។ អង្កេតចន្លោះជំរឿនលើកទីមួយ (CIPS២០០៤) ទីពីរ (CIPS២០១៣) និងទីបីត្រូវបានធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០២៤។ អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាក្នុងខែឧសភា ឆ្នាំ២០២៤ ត្រូវបានគ្រោងនឹងធ្វើឡើងយ៉ាងពិតប្រាកដនៅចន្លោះជំរឿនដែលបានធ្វើឡើងក្នុងឆ្នាំ២០១៩ និង២០២៩។ អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រ កម្ពុជាផ្តល់ការប៉ាន់ស្មានកម្រិតជឿជាក់កម្រិតរាជធានី ខេត្ត។ ប្រជាជនគោលដៅដែលបានកំណត់សម្រាប់អង្កេត CIPS២០២៤ គឺជាចំនួនប្រជាជនគ្រួសារប្រក្រតី (គ្រួសារធម្មតា)។ គ្រួសាររស់នៅក្នុងស្ថាប័ន ដូចជា មន្ទីរពេទ្យ ផ្ទះសំណាក់ ប៉ុស្តិ៍ប៉ូលីស និងពន្ធនាគារ ក៏ដូចជាប្រជាជនដែលគ្មានផ្ទះសម្បែង មិនត្រូវបានគ្របដណ្តប់នៅក្នុងអង្កេតនេះទេ។

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ធ្វើឡើងសម្រាប់ធ្វើបច្ចុប្បន្នភាពចំនួនប្រជាជនតាមរាជធានី ខេត្ត កំណើន ស្ថានភាពអាពាហ៍ពិពាហ៍ លទ្ធភាពមានកូន មរណភាព ទេសន្តប្រវេសន៍ អប់រំ ការងារ និងមុខរបរ ពិការភាព ចរិតលក្ខណៈប្រជារាស្រ្តដទៃទៀតដូចជា សម្ភារៈប្រើប្រាស់ក្នុងផ្ទះសម្បែង។

១.២. គោលបំណងអង្កេត

គោលដៅសំខាន់នៃអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ (CIPS២០២៤) ដើម្បីបំពេញតម្រូវការចាំបាច់នៃការប្រើប្រាស់របស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងអ្នកប្រើប្រាស់នូវទិន្នន័យបច្ចុប្បន្នកម្ម និងអាចជឿទុកចិត្តបានទាក់ទងនឹងប្រជាជន សុខភាព និងបញ្ហាសង្គម ដូចជារចនាសម្ព័ន្ធអាយុ ភេទ របស់ប្រជាជន ជាតិពន្ធ (ភាសាកំណើត) សាសនា ពិការភាព ស្ថានភាពអប់រំ មុខវិជ្ជាជំនាញដែលទទួលបាន ស្ថានភាពការងារ វិស័យការងារ ផ្នែកការងារ និងសេដ្ឋកិច្ច សង្គមកិច្ច មានការងារធ្វើ គ្មានការងារធ្វើ អសកម្មជនសេដ្ឋកិច្ច មរណភាពទារក មរណភាពកុមារ មរណភាពមាតា អាយុសង្ឃឹមរស់ ស្ថានភាពអាពាហ៍ពិពាហ៍ កម្រិតលទ្ធភាពមានកូន ចំណាកស្រុកក្នុងនិងក្រៅប្រទេស ចរិតលក្ខណៈផ្ទះសម្បែង ដូចជាគោលដៅក្នុងការប្រើប្រាស់អាគារសំណង់/ការកាន់កាប់លំនៅដ្ឋាន ប្រភពបំភ្លឺចម្បង ប្រភពថាមពលប្រើប្រាស់សម្រាប់ចំអិនអាហារ ទឹកស្អាត គ្រប់គ្រងបង្គន់អនាម័យ ការទុកដាក់កាកសំណល់លាមក ការប្រើប្រាស់គណនីធនាគារ ការប្រើប្រាស់អ៊ីនធើណែត និងទ្រព្យសម្បត្តិដែលគ្រួសារមាន សម្រាប់វិភាគពហុសមាសធាតុក្រីក្រក្នុងចំណោមប្រជាជនកម្ពុជា និងដើម្បីបំពេញតម្រូវការរៀបចំធ្វើគោលនយោបាយអភិវឌ្ឍន៍ជាតិ ដូចជា ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (NSDP) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(CSDGs)

បច្ចុប្បន្នភាពគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ កម្មវិធីសុខភាពមាតានិងទារក កម្មវិធីសង្គមកិច្ច និងស្តារនិតិសម្បទាសម្រាប់ជនពិការ កម្មវិធីនារីតេនះរបស់ក្រសួងកិច្ចការនារី និងរៀបចំផែនការតាមវិស័យជាច្រើនទៀត ដើម្បីគាំទ្រយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។ លើសពីនេះទៀតលទ្ធផលអង្កេតនេះក៏បំពេញតម្រូវការប្រើប្រាស់ទិន្នន័យរបស់ប្រព័ន្ធស្ថិតិជាតិ លេខាធិការដ្ឋានអាស៊ាន និងអន្តរជាតិ ពិសេសទៅទៀត លទ្ធផលអង្កេតផ្តល់ឱ្យរដ្ឋាភិបាលធ្វើរបាយការណ៍អំពីវឌ្ឍនភាពស្ត្រីប្រចាំឆ្នាំជូនអង្គការសហប្រជាជាតិ ។

១.៣. ការជ្រើសរើសសំណាកគំរូ

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ (CIPS) ត្រូវបានជ្រើសរើសសំណាកគំរូជាពីរដំណាក់កាលផ្សេងគ្នា។ ឯកតាជ្រើសរើសសំណាកគំរូដំណាក់កាលទីមួយ គឺមណ្ឌលអង្កេត(EAs) និងឯកតាជ្រើសរើសសំណាកគំរូដំណាក់កាលទីពីរគឺគ្រួសារ។ ចំនួនសំណាកគំរូសរុប ៧៥០ មណ្ឌលអង្កេត (EAs) ត្រូវបានជ្រើសតាមសមាមាត្រប្រូបាប៊ីលីធី ធៀបនឹងទំហំគ្រួសារក្នុងរាជធានី ខេត្តនិមួយៗ និងគ្រួសារចំនួន ២២.៥០០ ជាឯកតាជ្រើសរើសគំរូដំណាក់កាលទីពីរ។ បន្ទាប់ពីការជ្រើសរើសសំណាកគំរូមណ្ឌលអង្កេតរួចប្រតិបត្តិការចុះបញ្ជីគ្រួសារក្នុងមណ្ឌលអង្កេត ត្រូវបានអនុវត្តនៅគ្រប់មណ្ឌលអង្កេតដែលបានជ្រើសរើសទាំងអស់ លទ្ធផលនៃការចុះបញ្ជីគ្រួសារបានប្រើសម្រាប់ជ្រើសរើសគ្រួសារនៅដំណាក់កាលទីពីរ។ ដំណាក់កាលទីពីរ គឺជ្រើសរើសសំណាកគំរូគ្រួសារ ៣០ ស្មើគ្នាតាមប្រព័ន្ធសមាមាត្រនៃប្រូបាប៊ីលីធីជ្រើសរើសសំណាកគំរូលក្ខណៈបន្ទាត់(Linear)។ សំណាកគ្រួសារគំរូសម្រាប់អង្កេត CIPS២០២៤ ត្រូវបានជ្រើសរើសនៅការិយាល័យកណ្តាលមុនពេលប្រតិបត្តិការអង្កេត។ អំឡុងពេលប្រតិបត្តិការអង្កេត មន្ត្រីសម្ភាសន៍ត្រូវបានកំណត់ឱ្យសម្ភាសន៍តែគ្រួសារដែលបានជ្រើសរើសនេះប៉ុណ្ណោះ ដើម្បីជៀសវាងភាពលំអៀងការជំនួសណាមួយមិនត្រូវបានអនុញ្ញាតសម្រាប់គ្រួសារដែលរកមិនឃើញ ឬមិនឆ្លើយតបឡើយ។ ដោយសារទំហំសំណាកគំរូតំណាងឱ្យរាជធានី ខេត្តនិមួយៗ សំណាកគំរូមិនត្រូវបានធ្វើសម្រាប់កម្រិតជាតិឡើយ ហើយមេគុណសំណាកគំរូត្រូវបានគណនា និងបញ្ចូលទៅក្នុងកម្រងទិន្នន័យ ដូច្នេះលទ្ធផលនឹងមានសមាមាត្រនៅថ្នាក់ជាតិ។ មេគុណកែតម្រូវផ្សេងទៀតអាចត្រូវបានប្រើសម្រាប់គ្រួសារបដិសេធចម្លើយ។ វិធីសាស្ត្រគណនាមេគុណអង្កេតត្រូវបានគណនាដោយប្រុងប្រយ័ត្ន ដើម្បីជៀសវាងលំអៀងក្នុងការប្រើមេគុណជ្រើសរើសគំរូ។

តារាង ១.៣.១. ចំនួនសំណាកគំរូ បែងចែកតាមរាជធានី ខេត្ត សម្រាប់អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤

រាជធានី ខេត្ត	ចំនួនគ្រួសារ			ចំនួនមណ្ឌលអង្កេតគំរូ			ចំនួនគ្រួសារគំរូ		
	ទីប្រជុំជន	ជនបទ	សរុប	ទីប្រជុំជន	ជនបទ	សរុប	ទីប្រជុំជន	ជនបទ	សរុប
កម្ពុជា	១.៣២៨.៥០១	២.២២៤.៥២០	៣.៥៥៣.០២១	២៩៣	៤៥៧	៧៥០	៨.៧៩០	១៣.៧១០	២២.៥០០
បន្ទាយមានជ័យ	៦៨.៦៦០	១២០.៩២៨	១៨៩.៥៨៨	១២	១៨	៣០	៣៦០	៥៤០	៩០០
បាត់ដំបង	៤៥.៥៥៦	១៨១.៦៨១	២២៧.២៣៧	៨	២៣	៣១	២៤០	៦៩០	៩៣០
កំពង់ចាម	៣០.៣៨៦	១៨៦.៨១១	២១៧.១៩៧	៧	២៤	៣១	២១០	៧២០	៩៣០
កំពង់ឆ្នាំង	២៨.៥២៣	៩៧.៧៧៦	១២៦.២៩៩	៧	២៣	៣០	២១០	៦៩០	៩០០
កំពង់ស្ពឺ	១១៤.៣៨០	៨១.៥០២	១៩៥.៨៨២	១៩	១២	៣១	៥៧០	៣៦០	៩៣០
កំពង់ធំ	១៦.១១៨	១៤៤.៦៤៨	១៦០.៧៦៦	៥	២៥	៣០	១៥០	៧៥០	៩០០
កំពត	១៣.២៥៨	១៣០.១៤៤	១៤៣.៤០២	៤	២៦	៣០	១២០	៧៨០	៩០០
កណ្ដាល	១៧០.៧៨២	៩៥.០២១	២៦៥.៨០៣	២៤	៨	៣២	៧២០	២៤០	៩៦០
កោះកុង	១២.៣៥៩	១៥.៦៦៨	២៨.០២៧	១៣	១៥	២៨	៣៩០	៤៥០	៨៤០
ក្រចេះ	៩.២៩៧	៧៦.៨៧៩	៨៦.១៧៦	៤	២៥	២៩	១២០	៧៥០	៨៧០
មណ្ឌលគីរី	៧.៥០០	១២.៩០៩	២០.៤០៩	១២	១៦	២៨	៣៦០	៤៨០	៨៤០
ភ្នំពេញ	៤៩៩.២៩៩	-	៤៩៩.២៩៩	៣៥	០	៣៥	១.០៥០	០	១.០៥០
ព្រះវិហារ	៥.៦៥០	៥១.០៦៣	៥៦.៧១៣	៤	២៥	២៩	១២០	៧៥០	៨៧០
ព្រៃវែង	១៤.១៦៨	២៥២.៧៦៦	២៦៦.៩៣៤	៥	២៧	៣២	១៥០	៨១០	៩៦០
ពោធិសាត់	១៧.៦២៤	៨៦.២៣៨	១០៣.៨៦២	៦	២៤	៣០	១៨០	៧២០	៩០០
រតនគីរី	៦.៨៧៧	៤២.៨៦៤	៤៩.៧៤១	៥	២៤	២៩	១៥០	៧២០	៨៧០
សៀមរាប	៦៧.៨៤៥	១៥៦.៨២៧	២២៤.៦៧២	១០	២១	៣១	៣០០	៦៣០	៩៣០
ព្រះសីហនុ	៣៤.០៦០	១៣.៣២១	៤៧.៣៨១	២៤	៥	២៩	៧២០	១៥០	៨៧០
ស្ទឹងត្រែង	៩.៧៦១	២៦.០៧២	៣៥.៨៣៣	៨	២០	២៨	២៤០	៦០០	៨៤០
ស្វាយរៀង	៣៧.២៨៥	៩៥.២០៧	១៣២.៤៩២	៩	២១	៣០	២៧០	៦៣០	៩០០
តាកែវ	៦២.៨៥៦	១៤៥.៨៤២	២០៨.៦៩៨	១០	២១	៣១	៣០០	៦៣០	៩៣០
ឧត្តរមានជ័យ	១៩.៨២៦	៤១.០៦០	៦០.៨៨៦	១១	១៨	២៩	៣៣០	៥៤០	៨៧០
កែប	៧.៧១៤	១.៨៩១	៩.៦០៥	២៦	២	២៨	៧៨០	៦០	៨៤០
ប៉ៃលិន	១៣.០៥០	៤.១២៧	១៧.១៧៧	២០	៨	២៨	៦០០	២៤០	៨៤០
ត្បូងឃ្មុំ	១៥.៦៦៧	១៦៣.២៧៥	១៧៨.៩៤២	៥	២៦	៣១	១៥០	៧៨០	៩៣០

១.៣.១.ប្រូបាប៊ីលីធីនៃការជ្រើសរើសគំរូ

ដោយការបែងចែកសំណាកគំរូមិនផ្អែកតាមសមាមាត្រគ្រួសាររាជធានី ខេត្ត ទីប្រជុំជន និងជនបទ អត្រាឆ្លើយតបអាចមានភាពខុសគ្នាដូចនេះមេគុណអង្កេតត្រូវបានប្រើប្រាស់សម្រាប់ការវិភាគទិន្នន័យ CIPS២០២៤ ដើម្បីធានាបាននូវភាពតំណាងសម្រាប់លទ្ធផលថ្នាក់ជាតិ និងជាពិសេសរាជធានី ខេត្ត។អង្កេត CIPS២០២៤ រៀបចំចំណាត់ជ្រើសរើសថ្នាក់ពីរដំណាក់កាលផ្សេងគ្នា ដូច្នេះមេគុណអង្កេតត្រូវបានគណនាដោយផ្អែកលើប្រូបាប៊ីលីធីជ្រើសរើសសំណាកគំរូដាច់ដោយឡែកពីគ្នាក្នុងដំណាក់កាលនីមួយៗ និងសម្រាប់តំបន់អង្កេតនីមួយៗ។

P_{1hi}-ប្រូបាប៊ីលីធីជ្រើសរើសសំណាកគំរូដំណាក់កាលទីមួយ

$$P_{1hi} = \frac{n_h M_{hi}}{\sum M_{hi}}$$

n_h ចំនួនសំណាកគំរូមណ្ឌលជំរឿនក្នុងតំបន់អង្កេត h,

M_{hi} ចំនួនគ្រួសារក្នុងក្របខ័ណ្ឌសំណាកគំរូក្នុងមណ្ឌលជំរឿន ith

$\sum M_{hi}$ ចំនួនគ្រួសារសរុបក្នុងតំបន់អង្កេត

P_{2hi}-ប្រូបាប៊ីលីធីជ្រើសរើសសំណាកគំរូដំណាក់កាលទីពីរ

$$P_{2hi} = \frac{m_{hi}}{L_{hi}}$$

L_{hi} ចំនួនគ្រួសារដែលបានចុះបញ្ជីនៅក្នុងប្រតិបត្តិការចុះបញ្ជីគ្រួសារក្នុងមណ្ឌលជំរឿន

m_{hi} ចំនួនគ្រួសារបានជ្រើសរើសក្នុងមណ្ឌលជំរឿន

១. ៣.២. មេគុណនៃការជ្រើសរើសគំរូ

មេគុណសំណាកគំរូសម្រាប់គ្រួសារនីមួយៗក្នុងមណ្ឌលជំរឿន i ក្នុងតំបន់អង្កេត h គឺជាចម្រាស់នៃប្រូបាប៊ីលីធីការជ្រើសរើសសំណាកគំរូទាំងពីរដំណាក់កាល៖

$$W_{hi} = \frac{\sum M_{hi} L_{hi}}{m_{hi} n_h M_{hi}}$$

១.៤. កម្រងសំណួរអង្កេត

កម្រងសំណួរគ្រួសារត្រូវបានប្រើប្រាស់ដើម្បីស្រង់ព័ត៌មានពីគ្រប់សមាជិកនៃគ្រួសារអេចិន្ត្រៃយ៍ និងភ្ញៀវរបស់គ្រួសារដែលត្រូវបានជ្រើសរើសសម្ភាសន៏។ ព័ត៌មានមូលដ្ឋានត្រូវបានប្រមូលមានចរឹតលក្ខណះរបស់បុគ្គលម្នាក់ៗ ត្រូវបានស្រង់ចូលរួមមាន អាយុ ភេទ ការអប់រំ និងទំនាក់ទំនងទៅនឹងមេគ្រួសារ។ សម្រាប់កុមារអាយុក្រោម ១៨ឆ្នាំ ស្ថានភាពរស់រានមានជីវិតរបស់ឪពុកម្តាយបានកំណត់។ កម្រងសំណួរអង្កេតត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវសូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងព័ត៌មានចាំបាច់ផ្សេងៗទៀតជាច្រើន សម្រាប់ការតាមដាន និងវាយតម្លៃ ឆ្លើយតបផលប្រយោជន៍របស់ប្រជាជន។ អង្កេតត្រូវបានធានាមិនមានភាពលំអៀងលើយេនឌ័រដោយការជ្រើសរើសភេទសម្រាប់ការរាប់សម្ភាសន៍ និងឆ្លើយសំណួរអង្កេតនេះឡើយ។ បទពិសោធន៍កន្លងមកបានបញ្ជាក់ថាប្រទេសកម្ពុជា មិនមានភាពលំអៀងក្នុងការប្រមូលទិន្នន័យនោះទេ។ អង្កេតបានជ្រើសរើសមន្ត្រីសម្ភាសន៍ និងត្រួតពិនិត្យជាស្ត្រីផងដែរ ហើយពួកគេមានសមត្ថភាពសួរសំណួរទាក់ទងលើលទ្ធភាពបង្កើតកូន និងមរណភាពមាតា មានភាពបិនប្រសព្វ។ កម្រងសំណួរអង្កេតត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីទទួលបានស្ថិតិយេនឌ័រប្រសើរជាងមុន។ ដើម្បីផ្តល់ជាគំនិតខ្លឹមសារនៃកម្រងសំណួរអង្កេតត្រូវបានរៀបចំដូចដែលត្រូវបានសួរនៅក្នុងជំរឿនឆ្នាំ២០១៩។ មានកម្រងសំណួរចំនួនពីរគឺបញ្ជីផ្ទះ **(ទម្រង់ក)** និងកម្រងសំណួរគ្រួសារ (**ទម្រង់ខ**) ។

សំណួរត្រូវឆ្លើយតបដោយមេគ្រួសារមនុស្សដែលពាក់ព័ន្ធ ឬសមាជិកដែលមានទំនួលខុសត្រូវក្នុងគ្រួសារ៖

ទម្រង់ ក: ស្រង់លក្ខណៈពិសេសនៃការកំណត់អត្តសញ្ញាណគ្រួសារដូចជាអាគារ/សំណង់ សំភារៈសំណង់លេចធ្លោដូចជា ជញ្ជាំង ដំបូល និងកម្រាលនៃអាគារ/រចនាសម្ព័ន្ធគ្រួសារ លេខគ្រួសារ ជាពិសេសចំនួនមនុស្សដែលរស់នៅក្នុងគ្រួសារ ។

ទម្រង់ ខ: ស្រង់ឈ្មោះពេញ ទំនាក់ទំនងជាមួយមេគ្រួសារ ភេទ អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ភាសាកំណើត សាសនា ទីកន្លែងកើត ទីកន្លែងពីមុន រយៈពេលស្នាក់នៅ មូលហេតុនៃការធ្វើផ្លាស់ប្តូរលំនៅដ្ឋាន អក្ខរកម្ម និងការអប់រំពេញម៉ោង ពិការភាព សកម្មភាពចម្បង មុខរបរ ស្ថានភាពការងារ ឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម វិស័យការងារ សកម្មភាពសេដ្ឋកិច្ច ការបំពុលបរិស្ថាន ព័ត៌មានលំអិតនៃការមានកូន របស់ស្ត្រីដែលមានអាយុចាប់ពី ១៥ឆ្នាំឡើង ជាពិសេសអ្នកស្លាប់ក្នុងគ្រួសារកាលពី១២ខែកន្លងមក។

ក្រៅពីព័ត៌មានគ្រួសារ សំណួរទាក់ទងនឹងស្ថានភាពលំនៅដ្ឋាន និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះសម្បែងក៏ត្រូវបានប្រមូលផងដែរទាក់ទងពីគ្រួសារធម្មតា៖ កម្មសិទ្ធិកាន់កាប់លំនៅដ្ឋាន ប្រភពបំភ្លឺចម្បង ឥន្ធនៈចម្អិនអាហារ ការប្រើប្រាស់បង្គន់ ប្រភពទឹកផឹកចម្បង ទីតាំងប្រភពទឹកផឹក ចំនួនបន្ទប់ដែលកាន់កាប់ដោយគ្រួសារ ភាពកម្មសិទ្ធិ លើវិទ្យុ/ ទូរទស្សន៍ ទូរស័ព្ទ (ខ្សែ) ទូរស័ព្ទដៃ កុំព្យូទ័រផ្ទាល់ខ្លួន កង់ ម៉ូតូ ឡាន/ ឡានដឹកទំនិញ ត្រាក់ទ័រ និងការប្រើប្រាស់អ៊ីនធឺណិតក៏ត្រូវបានប្រមូលផងដែរ។

១.៥. ការបណ្តុះបណ្តាលគ្រូបង្គោល

មន្ត្រីប្រចាំតំបន់ និងមន្ត្រីជំនួយការតំបន់ របស់វិទ្យាស្ថានជាតិស្ថិតិ (NIS SC) ចំនួន ១៤០នាក់ មន្ត្រីត្រួតពិនិត្យ ២០០នាក់ និងប្រធានមន្ទីរ និងអនុប្រធានមន្ទីរផែនការទាំង ២៥ រាជធានី ខេត្ត ត្រូវបានបំពាក់បំប៉នយ៉ាងល្អិតល្អន់នៅវិទ្យាស្ថានជាតិស្ថិតិ (នាថ្ងៃទី១៩-២៣ ខែមេសា ឆ្នាំ២០២៤) អំពីកម្រងសំណួរតាមគ្រួសារ ខ្លឹមសារ និយមន័យ និងវិធីសាស្ត្រអង្កេត។ ការបណ្តុះបណ្តាលគ្រូបង្គោលនេះជាគន្លឹះសំខាន់ដើម្បីទទួលចំណេះដឹងទូលំទូលាយសម្រាប់អំពីនិតិវិធី ទ្រឹស្តីលំអិតកម្រងសំណួរតាមគ្រួសារ ខ្លឹមសារ និយមន័យសម្រាប់ធ្វើការបណ្តុះបណ្តាលបន្តសម្រាប់មន្ត្រីសម្ភាសន៍ និងត្រួតពិនិត្យនៅតាមខេត្តគោលដៅនិមួយៗ។ ការបណ្តុះបណ្តាលគ្រូបង្គោលនេះផ្តោតជាពិសេសពីរបៀបបំពេញតារាងសំណួរក្នុងតារាង (ខ) កម្រងសំណួរគ្រួសារ តារាងនេះស្រង់លម្អិតសម្រាប់សួរទៅគ្រួសារ សមាជិកគ្រួសារ និងភ្ញៀវផ្ទាល់ដែលបែងចែកជា ៥ ផ្នែកគឺ៖

ផ្នែក១៖ ព័ត៌មានប្រជាសាស្ត្រ សមាជិកពិតប្រាកដ ភ្ញៀវវត្តមានក្នុងយប់ធ្វើអង្កេត និងសមាជិកពិតប្រាកដក្នុងគ្រួសារដែលអវត្តមានក្នុងយប់ធ្វើអង្កេត ព័ត៌មានផ្ទាល់ខ្លួនសមាជិកគ្រួសារម្នាក់ៗ មានឈ្មោះ ភេទ អាយុ ទំនាក់ទំនងជាមួយមេគ្រួសារ ភាសាកំណើត សាសនា ទីកន្លែងកំណើត ការផ្លាស់ប្តូរទីលំនៅ មូលហេតុ នៃការផ្លាស់ប្តូរទីលំនៅ។ល។

ផ្នែក២៖ ព័ត៌មានស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ផ្ទាល់ខ្លួនសមាជិកគ្រួសារម្នាក់ៗ មានព័ត៌មានអំពីការសិក្សា ពិការភាព ស្ថានភាពការងារចំបង ការប្រើប្រាស់ឥណទានធនាគារ ការប្រើប្រាស់ថ្នាំជក់ជាដើម។

ផ្នែក៣៖ ព័ត៌មានស្ដីពីភាពបង្កើតកូនបាននៃស្ត្រីអាយុ ១៥ឆ្នាំឡើង សួរអំពីចំនួនកូនកើត កូនរស់ កូនស្លាប់ និងចំនួនកូនបានកើតនៅរយៈពេល ១២ ខែកន្លងមក។

ផ្នែក៤៖ ព័ត៌មានអំពីស្ថានភាពលំនៅដ្ឋាន ប្រដាប់ប្រើប្រាស់នៅក្នុងផ្ទះសម្បែង និងបរិស្ថាន សួរអំពីផ្ទះផ្ទាល់ខ្លួន ឬផ្ទះជួលគេ ទឹក ភ្លើងអគ្គិសនី អុស ធ្យូង ឧស្ម័ន ហ្គាស បង្គន់អនាម័យ ប្រភពទឹកប្រើប្រាស់សម្រាប់ទទួលទាន ចំនួនបន្ទប់ វិទ្យុ ទូរទស្សន៍ ទូរស័ព្ទ កុំព្យូទ័រ កង់ ម៉ូតូ រថយន្ត ទូទឹកកក ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនត្រជាក់ ទូក កាណូត ត្រាក់ទ័រ។ល។

ផ្នែក៥៖ ព័ត៌មានមនុស្សស្លាប់នៅក្នុងគ្រួសារ សួរអំពីមនុស្សស្លាប់ក្នុងគ្រួសាររយៈពេល ១២ ខែកន្លង។ មូលហេតុនៃការស្លាប់ ការចុះបញ្ជីមរណភាព។

ការបណ្តុះបណ្តាលគ្រូបង្គោលនេះត្រូវបានធ្វើឡើងដោយមានការជជែកវែកញែកពិភាក្សាគ្នា និងដំណោះស្រាយយ៉ាងផុលផុសលើសំណួរនិមួយៗ ដើម្បីជៀសវាងភាពមិនស៊ីសង្វាក់គ្នាក្នុងការបណ្តុះបណ្តាលបន្តក្នុងប្រតិបត្តិការស្រង់ទិន្នន័យជាក់ស្តែង។

១.៦. អង្កេតសាកល្បង

ការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ សម្រាប់អង្កេតសាកល្បងលើកម្រងសំណួរត្រូវបានអនុវត្តមុនពេលចុះប្រតិបត្តការមូលដ្ឋានសម្រាប់អង្កេត CIPS ២០២៤ ជាពីរដំណាក់កាលគឺ លើកទីមួយធ្វើឡើងនៅចន្លោះថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ និងលើកទី២ចន្លោះថ្ងៃទី៣០ ខែមីនា ដល់ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤។ គោលបំណងសំខាន់អង្កេតសាកល្បងលើកម្រងសំណួរនេះ គឺដើម្បីរកភាពស៊ីសង្វាក់គ្នានៃកម្រងសំណួរ និងសេចក្តីណែនាំអង្កេត និងលក្ខណៈបច្ចេកទេសអង្កេតផ្សេងទៀត។ ដំណើរការអង្កេតសាកល្បងលើកម្រងសំណួរធ្វើឡើងក្នុងភូមិចំនួន ៣ ក្នុងខេត្តតាកែវ ដែលមានមន្ត្រីជាថ្នាក់ដឹកនាំបច្ចេកទេសអង្កេត មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ពីវិទ្យាស្ថានជាតិស្ថិតិ ចំនួន ៤១នាក់ចូលរួម។ អង្កេតសាកល្បងលើកម្រងសំណួរលើកទីពីរ មានមន្ត្រីជាថ្នាក់ដឹកនាំបច្ចេកទេសអង្កេត មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ ពីវិទ្យាស្ថានជាតិស្ថិតិ ចំនួន៥០នាក់ចូលរួម ដែលធ្វើឡើងទៅលើភូមិចំនួន ៦ នៃខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។

ការធ្វើអង្កេតសាកល្បងលើកម្រងសំណួរមុនពេលដំណាក់កាលសម្ភាសន៍ជាក់ស្តែង ការធ្វើសាកល្បងលើគំរូត្រូវធ្វើដោយមន្ត្រីត្រួតពិនិត្យអង្កេត ដើម្បីធានាគុណភាពនៃការសម្ភាសន៍របស់មន្ត្រីសម្ភាសន៍ ហើយនិងរយៈពេលក្នុងការបំពេញចូលកម្រងសំណួរសម្ភាសន៍ ការវាយតម្លៃពីការត្រួតពិនិត្យគុណភាពនៃការស្រង់ទិន្នន័យ និងការកែច្នៃទិន្នន័យរួមទាំងការគណនាគម្លាតគំរូដើម្បីវាយតម្លៃលទ្ធផលរបស់អង្កេត។ អង្កេតសាកល្បងត្រូវបានធ្វើឡើងក្នុងទម្រង់លំហាត់សមពេញលេញសម្រាប់ការអង្កេតធំ ខណៈដែលគ្រប់ដំណាក់កាលនៃប្រតិបត្តិការ នឹងត្រូវបានធ្វើអង្កេតសាកល្បងអំពីភាពពលូន និងប្រសិទ្ធិភាពនៃការអនុវត្តន៍អង្កេត។

១.៧. ការជ្រើសរើសមន្ត្រី

ផ្អែកតាមសំណាកគំរូដែលបានជ្រើសរើស ការរាប់សម្ភាសន៍អង្កេតត្រូវប្រើមន្ត្រីសម្ភាសន៍ប្រមាណ ៧៥០ នាក់ និងមន្ត្រីត្រួតពិនិត្យម្នាក់ ត្រួតពិនិត្យកិច្ចការមន្ត្រីសម្ភាសន៍ចំនួនបួននាក់ នឹងត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យសរុបចំនួន២០០នាក់។ មន្ត្រីត្រួតពិនិត្យបានជ្រើសចេញពីវិទ្យាស្ថានជាតិស្ថិតិ និងពីអគ្គនាយកដ្ឋានផ្សេងទៀតចំណុះឱ្យក្រសួងផែនការ។ មន្ត្រីសម្ភាសន៍ទាំង ៧៥០នាក់ ត្រូវបានជ្រើសរើសចេញពីមន្ត្រីមន្ទីរផែនការទាំង ២៥ រាជធានី ខេត្ត។

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ មានមន្ត្រីរាជធានី ខេត្តចំនួន៧៥ នាក់ បានដឹកនាំអង្កេតដោយមានមន្ត្រីប្រចាំតំបន់ និងជំនួយការតំបន់ជាគ្រូបង្គោលមូលដ្ឋាន ១៤០នាក់។ មន្ត្រីដែលមានបទពិសោធន៍ពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីមូលដ្ឋាន ហើយនិងធ្វើការងារត្រួតពិនិត្យមូលដ្ឋាន។ មន្ត្រីប្រចាំតំបន់ និងជំនួយការតំបន់ ដើរតួជាទីប្រឹក្សាបច្ចេកទេសដល់មន្ត្រីអង្កេតទាំងអស់ ហើយត្រូវទទួលខុសត្រូវលើកិច្ចដំណើរការអង្កេតក្នុងខេត្តដែលខ្លួនទទួលបន្ទុក។ ការងារសំខាន់របស់មន្ត្រីប្រចាំតំបន់ និងជំនួយការតំបន់គឺសម្របសម្រួលការងារទាំងអស់ រួមមានការបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ ការចុះត្រួតពិនិត្យការងារដល់ទីកន្លែងនៅមូលដ្ឋាន និងធានាការបែកចែកសម្ភារៈ CIPS ត្រឹមត្រូវ និងការប្រមូលឯកសារបំពេញរួច។

១.៨. ការបណ្តុះបណ្តាលមន្ត្រីមូលដ្ឋាន

ការបណ្តុះបណ្តាល មានគោលបំណងផ្តល់ដល់មន្ត្រីអង្កេតគ្រប់លំដាប់ថ្នាក់នូវចំណេះដឹងអាចដឹកនាំការធ្វើអង្កេតបាន។ មន្ត្រីប្រចាំតំបន់ និងជំនួយការតំបន់ជាគ្រូបង្គោលថ្នាក់កណ្តាលបានណែនាំដល់មន្ត្រីសម្ភាសន៍ប្រមាណ៧៥០នាក់ និងមន្ត្រីត្រួតពិនិត្យប្រមាណ ២០០នាក់ ទទួលការបណ្តុះបណ្តាលគ្រប់ទិដ្ឋភាពទាំងអស់នៃការអង្កេត ជាពិសេសអំពីកម្រងសំណួរ និងខ្លឹមសារ (រាប់បញ្ចូលទាំងការអនុវត្តន៍ជាក់ស្តែង)។ ការបណ្តុះបណ្តាលនេះបានប្រព្រឹត្តទៅនៅមន្ទីរផែនការរាជធានី ខេត្ត ដោយមន្ត្រីប្រចាំតំបន់ និងជំនួយការតំបន់ជាអ្នកសម្របសម្រួលដោយមានជំនួយការពីប្រធានមន្ទីរផែនការខេត្ត/អនុប្រធានមន្ទីរផែនការចំនួនប្រាំថ្ងៃ (ថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤)។ វគ្គបណ្តុះបណ្តាលបានប្រព្រឹត្តទៅក្នុងរយៈពេល ៥ថ្ងៃ ដែលមន្ត្រីអង្កេតគ្រប់លំដាប់ថ្នាក់បានស្តាប់ការណែនាំអំពីគោលបំណងអង្កេត ការពន្យល់ច្បាស់លាស់អំពីទម្រង់បែបបទអង្កេត ការណែនាំអំពីវិធីសាស្ត្រសម្រាប់ការកត់ត្រាព័ត៌មានអង្កេត ការគ្រប់គ្រង និងការត្រួតពិនិត្យគុណភាពអង្កេត។

ការរៀបចំយ៉ាងប្រុងប្រយ័ត្នលើសម្ភារៈ និងឯកសារណែនាំសម្រាប់បណ្តុះបណ្តាល ដើម្បីជួយលើកកម្ពស់គុណភាពការបណ្តុះបណ្តាល។ ក្រៅពីសម្ភារៈបច្ចេកទេស មានការបណ្តុះបណ្តាលពិសេសចំនួនបីធនធានដែលអាចរកបានសម្រាប់ឆ្នាំ២០២៤នេះ រួមមានៈ (១)ការប្រើឌីជីថលដើម្បីគាំទ្រដល់ការបណ្តុះបណ្តាល (២) កំណែបោះពុម្ពទំហំធំនៃកម្រងសំណួរ និង(៣) ការអនុវត្តន៍សម្ភាសន៍ជាក់ស្តែងជាក្រុមតូចៗ។ សម្ភារៈទាំងនេះត្រូវបានរចនាយ៉ាងត្រឹមត្រូវសម្រាប់បម្រើការបណ្តុះបណ្តាលទាំងថ្នាក់កណ្តាល និងមូលដ្ឋាន។

១.៩. ប្រតិបត្តិការស្រង់ទិន្នន័យ

សំណាកគំរូ ឬមណ្ឌលអង្កេត (PSU) ដែលបានជ្រើសរើសនិមួយៗត្រូវបានចុះបញ្ជីនៅមូលដ្ឋានជាក់ស្តែងដើម្បីទទួលបាននូវបញ្ជីពេញលេញដែលមានគ្រួសាររស់នៅក្នុងមណ្ឌលគំរូ ដែលធ្វើបច្ចុប្បន្នភាពរួចរាល់ក្នុងដំណាក់កាលនៃការចុះបញ្ជីគ្រួសារ និងគូសផែនទី ដែលធ្វើឡើងកាលពីអំឡុងខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៤ ដោយមន្ត្រីសម្ភាសន៍ត្រូវគូសព្រាងផែនទីមណ្ឌលសម្ភាសន៍ និងអគារដែលគ្រួសាររស់នៅជាលំនៅដ្ឋានទាំងមូល ឬផ្នែកខ្លះនោះ ត្រូវដាក់លេខដោយប្រើប្រាស់ស្ទីគ័របិទជាប់នឹងអគារហើយដៅចូលក្នុងផែនទីតាមទឹសដៅ ធ្វើដំណើរដើម្បីឱ្យច្បាស់ថាគ្រប់អគារទាំងអស់ដែលមានគ្រួសាររស់នៅ ត្រូវបានដៅចូលក្នុងផែនទីទាំងអស់។ គ្រួសារគំរូចំនួន ៣០ ដូចគ្នាត្រូវបានជ្រើសរើសចេញពីមណ្ឌលអង្កេតនិមួយៗត្រូវអនុវត្តន៍បានកំណត់រួចរាល់។ ជំហាននេះជាជំហានសំខាន់នៃប្រតិបត្តិការស្រង់ទិន្នន័យកម្រងសំណួរគ្រួសារហៅថាទម្រង់ ខ (ក៏មាននៅក្នុងឧបសម្ព័ន្ធ) មន្ត្រីសម្ភាសន៍ ត្រូវសម្ភាសន៍គ្រប់គ្រួសារគំរូទាំង៣០ ដែលបានជ្រើសរើសក្នុងមណ្ឌលអង្កេតរបស់ខ្លួន។ ជាទូទៅមន្ត្រីត្រួតពិនិត្យត្រូវធ្វើការឱ្យបានជិតស្និទ្ធជាមួយមន្ត្រីសម្ភាសន៍ និងអ្នកផ្តល់ចម្លើយដើម្បីទទួលការសហការល្អក្នុងការឆ្លើយតបនឹងសំណួរអង្កេត។ យុទ្ធនាការប្រតិបត្តិការស្រង់ទិន្នន័យ រាប់សម្ភាសន៍គ្រួសារ (ទម្រង់ខ) នេះកំណត់ពេលវេលាយោងម៉ោង ០០ ឈានចូលថ្ងៃទី៣ រហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤។ ក្នុងដំណាក់កាលនេះ មន្ត្រីប្រចាំតំបន់និងជំនួយការតំបន់ ក្នុងតួនាទីជាមន្ត្រីសម្របសម្រួល ត្រូវត្រួតពិនិត្យសកម្មភាពការងារមូលដ្ឋានយ៉ាងជិតដល់ ដើម្បីធានាថាគ្រប់គ្រួសារគំរូទាំងអស់ត្រូវបានសម្ភាសន៍ប្រកបដោយគុណភាព។ រាជធានី ខេត្តនិមួយៗ ត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់ដោយមន្ត្រីសម្របសម្រួលបច្ចេកទេសមូលដ្ឋានទាំងប្រាំមួយ សម្រាប់ការត្រួតពិនិត្យគុណភាពអង្កេត។ មន្ត្រីសម្របសម្រួលបច្ចេកទេសមូលដ្ឋានទាំងប្រាំមួយត្រូវបានបំពាក់បំប៉នយ៉ាងស្ទាត់ជំនាញសម្រាប់ការណែនាំត្រួតពិនិត្យ។ រៀងរាល់សប្តាហ៍ មន្ត្រីសម្របសម្រួលបច្ចេកទេសមូលដ្ឋានទាំងប្រាំមួយ បានបង្កើតតារាងត្រួតពិនិត្យមូលដ្ឋានទិន្នន័យសម្ភាសន៍ដែលបានបញ្ចប់ ដើម្បីតាមដានវឌ្ឍនភាពការងារ និងគុណភាពទិន្នន័យ។ ការកែលម្អត្រូវបានផ្តល់ជូនយ៉ាងទៀងទាត់ដោយមន្ត្រីសម្របសម្រួល និងមន្ត្រីត្រួតពិនិត្យ និងសម្ភាសន៍។ ការស្រង់ទិន្នន័យត្រូវបានបញ្ចប់ដោយជោគជ័យនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤។

១.១០. ការកែច្នៃទិន្នន័យ

គោលបំណងនៃការកែច្នៃទិន្នន័យគឺ ដើម្បីបង្កើនគុណភាពទិន្នន័យតាមរយៈពិនិត្យលើភាពស៊ីសង្វាក់ និងកំហុសឆ្គងអចេតនាលើកម្រងសំណួរ និងតម្រូវឱ្យបានសមស្រប។ ការកែច្នៃទិន្នន័យគឺជាការផ្លាស់ប្តូរទិន្នន័យដែលមិនត្រឹមត្រូវ ឬមិនបានបំពេញបានសមស្របល្អបំផុតអំពីអ្វីដែលជាតម្លៃត្រឹមត្រូវ។ កំហុសឆ្គងមួយចំនួនដែលរកឃើញគឺជាកំហុសដែលបានធ្វើឡើងក្នុងពេលបំពេញការងារ។ មន្ត្រីសម្ភាសន៍ផ្ទាល់អាចចូលរួមចំណែកក្នុងកំហុសដោយការមិនកត់ត្រាចម្លើយរបស់អ្នកឆ្លើយសំណួរបានត្រឹមត្រូវ។ ការបណ្តុះបណ្តាលការកែដៃ និងដាក់លេខកូដត្រូវបានធ្វើឡើង សម្រាប់មន្ត្រីដែលមានបទពិសោធន៍ក្នុងគោលបំណងនៃដំណើរការកែតម្រូវទិន្នន័យមិនស៊ីសង្វាក់ ភាពមិនត្រឹមត្រូវ និងមិនពេញលេញ និងធ្វើអោយប្រសើរឡើងនូវគុណភាពនៃទិន្នន័យដែលប្រមូលបាន។ ចម្លើយមួយចំនួនបានកត់ត្រាជាការរៀបរាប់ដូចជា៖ ទីលំនៅពិតប្រាកដរបស់ភ្ញៀវ ទីកន្លែងនៅ

យប់ធ្វើអង្កេតនៃសមាជិកពិតប្រាកដអវត្តមាននៅយប់ធ្វើអង្កេត ទីកន្លែងកំណើត លំនៅដ្ឋានមុន ប្រធានបទដែលបានសិក្សា មុខរបរនិងវិស័យ។ ទាំងនេះអ្នកត្រូវទទួលខុសត្រូវក្នុងការផ្តល់លេខកូដត្រឹមត្រូវទៅនឹងចម្លើយរៀបរាប់ទាំងនោះ។ សេចក្តីណែនាំនេះផ្តល់ឱ្យអ្នកនូវសុពលភាពលេខកូដសម្រាប់អថេរទាំងអស់នោះ។

មន្ត្រីកែដៃ ៣០ នាក់ និងមន្ត្រីដាក់លេខកូដ ៣០ នាក់ បានបណ្តុះបណ្តាលវិធីសាស្ត្រកែច្នៃ និងអនុវត្តន៍ការងារដោយយកចិត្តទុកដាក់ក្រោមការគ្រប់គ្រងរបស់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ចំនួន ២នាក់ ដែលមានបទពិសោធន៍គ្រប់ជំរឿន និងអង្កេតកន្លងមកជាអ្នកទទួលខុសត្រូវផ្ទាល់។ ការកែច្នៃទិន្នន័យគ្រោងត្រូវបញ្ចប់ក្នុងរយៈពេល ២ ខែគឺដំណាច់ខែមិថុនា ឆ្នាំ២០២៤។ បន្ទាប់ពីធ្វើការកែដៃ និងដាក់លេខកូដនៅការិយាល័យចប់នោះកម្រងសំណួរអង្កេតនឹងត្រូវបញ្ជូនទៅផ្នែកបញ្ចូលទិន្នន័យ ។

ការវាយទិន្នន័យចូលក្នុងកុំព្យូទ័រត្រូវបានអនុវត្តដោយប្រើកម្មវិធី CSPro ដែលអភិវឌ្ឍន៍ដោយការិយាល័យជំរឿនសហរដ្ឋអាមេរិក។ ផ្នែកការវាយបញ្ចូលទិន្នន័យក្នុងកុំព្យូទ័ររួមមានមន្ត្រីចំនួន ៣០នាក់ ធ្វើការងារក្រោមការត្រួតពិនិត្យរបស់មន្ត្រីត្រួតពិនិត្យ២នាក់។ មន្ត្រីទាំងអស់ត្រូវបានបណ្តុះបណ្តាលអំពីនិតិវិធីវាយបញ្ចូលទិន្នន័យយ៉ាងហ្មត់ចត់។ ការសម្អាតទិន្នន័យត្រូវអនុវត្តន៍ក្នុងពេលដំណាលគ្នាដើម្បីផ្តល់នូវប្រយោជន៍ដើម្បីសំអាតទិន្នន័យដែលគ្មានកំហុសជាអតិបរមានិងត្រឹមត្រូវ។ ការទាញតារាងត្រួតពិនិត្យទិន្នន័យទាន់ពេលវេលាជានាបានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ ការកែច្នៃទិន្នន័យត្រូវបានបញ្ចប់នៅក្នុងខែសីហា ឆ្នាំ២០២៤។

១.១១. ការរៀបចំតារាងវិភាគ

ការវិភាគទិន្នន័យអង្កេតអនុវត្តន៍ដោយវិទ្យាស្ថានជាតិស្ថិតិ ដោយផ្អែកតារាងអថេរអាទិភាព និងតារាងបន្ថែមមួយចំនួននឹងត្រូវបានផលិតសម្រាប់ការវិភាគផងដែរ។ ទោះជាយ៉ាងណាការវិភាគអង្កេតមិនត្រូវបានទទួលខុសត្រូវសម្រាប់តែរដ្ឋាភិបាលប៉ុណ្ណោះទេ។ សាកលវិទ្យាល័យ អ្នកប្រជាសាស្ត្រ អ្នកសិក្សាស្រាវជ្រាវ ស្ថាប័នផ្សេងទៀត និងអ្នកប្រើប្រាស់ទិន្នន័យ ក៏អាចប្រើប្រាស់និងវិភាគទិន្នន័យ តាមវិធីសាស្ត្រផ្ទាល់ខ្លួនទៅតាមតម្រូវការនិងចំណាប់អារម្មណ៍របស់ពួកគេ។ ពួកគេនឹងត្រូវបានលើកចិត្តឱ្យទាក់ទងមជ្ឈមណ្ឌលសេវាកម្មព័ត៌មាន (DUSC) សម្រាប់ព័ត៌មានបន្ថែមតារាង ឬរបាយការណ៍ផ្សេងៗ។ ភាពទូលំទូលាយនៃទិន្នន័យ ចំណាត់ថ្នាក់ និងប្រភេទ ផ្សេងៗគ្នាអាចត្រូវបានធ្វើឡើងជាមួយតារាងអង្កេត និងទិន្នន័យកម្រិតបុគ្គលនឹងអនុញ្ញាតឱ្យប្រើប្រាស់ដោយគ្មានដែនកំណត់សម្រាប់ ការសិក្សាក្នុងការវិភាគទិន្នន័យអង្កេត។ តារាងអាទិភាពជាធម្មតាផលិតឡើងផ្អែកលើមូលដ្ឋាននៃអថេរអង្កេតទាំងអស់ ដែលបានបង្ហាញជាទម្រង់តារាងដែលពាក់ព័ន្ធក្នុងការគណនាសូចនាករប្រជាសាស្ត្រ និងសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់ការធ្វើផែនការនិងគោលនយោបាយ។ តារាងភាគច្រើនត្រូវផលិត នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ តារាងទាំងនេះត្រូវបានផលិតបន្ទាប់ពីការសម្អាតទិន្នន័យបញ្ចប់រួចរាល់។ តារាងអាទិភាពបង្កើតបញ្ជីតារាងអាទិភាពដែលបានស្នើសុំ។ ចំនួនតារាងត្រូវបានផលិតប្រហាក់ប្រហែលនឹងជំរឿនឆ្នាំ២០១៩។ តារាងទាំងនេះគ្របដណ្តប់ស្ទើរតែគ្រប់ផ្នែកទាំងអស់នៅក្នុងកម្រងសំណួរអង្កេត និងធ្វើចំណាត់ថ្នាក់ជាប្រភេទនៅទូទាំងតំបន់ទាំងអស់ដែលអ្នកប្រើប្រាស់ទិន្នន័យត្រូវការ។ ទិន្នន័យបន្ថែមដែលអ្នកប្រើស្នើសុំ និងតារាងទិន្នន័យផ្សេងទៀតត្រូវបានបង្កើតឡើងសម្រាប់ការវិភាគស៊ីជម្រៅ។

១.១២. ការផ្សព្វផ្សាយលទ្ធផល

របាយការណ៍បឋមផ្តល់ទំហំប្រជាជនសរុប ដោយតារាងសង្ខេប ត្រូវបានផលិតចេញភ្លាមៗបន្ទាប់ពីការសំអាតទិន្នន័យបញ្ចប់។ របាយការណ៍នេះបង្ហាញចំនួនប្រជាជនសរុប ដោយមានការវិភាគសង្ខេបនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីផ្តល់ព័ត៌មានឈានមុខអំពីការប៉ាន់ស្មានចុងក្រោយ។ ការងារបន្តគឺការរៀបចំរបាយការណ៍លទ្ធផលចុងក្រោយ របាយការណ៍លទ្ធផលរាជធានី ខេត្ត និងរបាយការណ៍វិភាគស៊ីជម្រៅតាមប្រធានបទសំខាន់ៗ។ លទ្ធផលមាននៅក្នុងរបាយការណ៍នេះ ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងបន្ទាន់នៃការប្រើប្រាស់របស់ស្ថាប័នដែលធ្វើការនៅក្នុងផ្នែកសេវាសុខភាពបន្តពូជ និងផែនការគ្រួសារ អប់រំ និងបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវអំពីប្រជាជន និងការអភិវឌ្ឍស្ត្រី និងយេនឌ័រ។ល។ រាជរដ្ឋាភិបាលនឹងរៀបចំអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានអំពីប្រជាជនសម្រាប់ប្រើប្រាស់ក្នុងរយៈពេលយូរអង្វែង ដើម្បីតាមដាន វាយតម្លៃកម្មវិធីនានាទាក់ទងប្រជាជន។

ក. របាយការណ៍តួលេខបណ្តោះអាសន្ន៖ របាយការណ៍នេះផលិតទម្រង់ និងតារាងទិន្នន័យសរុប របាយការណ៍អង្កេតតួលេខបណ្តោះអាសន្នអំពីចំនួនប្រជាជនតាមជានី ខេត្ត ដោយមានបង្ហាញលទ្ធផលសង្ខេបសំខាន់ៗ។

ខ. របាយការណ៍លទ្ធផលចុងក្រោយ៖ ការវិភាគទិន្នន័យលម្អិតទាញចេញ (តារាង ក និង ខ) ចាប់ផ្តើមវិភាគ និងសរសេររបាយការណ៍ក្នុងខែកញ្ញា ឆ្នាំ២០២៤ នឹងត្រូវបោះពុម្ពផ្សព្វផ្សាយនៅខែធ្នូឆ្នាំ២០២៤។

គ. របាយការណ៍លទ្ធផលចុងក្រោយរាជធានី ខេត្ត៖ របាយការណ៍សម្រាប់រាជធានី ខេត្តនីមួយនឹងត្រូវរៀបចំដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិដែលមានបទពិសោធន៍សរសេររបាយការណ៍ជំរឿន និងអង្កេតកន្លងមក។ របាយការណ៍ទាំងនេះត្រូវបានចាប់ផ្តើមវិភាគក្នុងឆ្នាំ២០២៥ និងបោះពុម្ពផ្សព្វផ្សាយនៅត្រីមាសទី២ ឆ្នាំ២០២៥ ។

ឃ. ការវិភាគស៊ីជម្រៅតាមប្រធានបទ៖ របាយការណ៍វិភាគស៊ីជម្រៅចំនួន ១៨ ផ្សេងទៀតសម្រាប់បម្រើតម្រូវការរៀបចំផែនការតាមវិស័យជាច្រើនទៀត ដើម្បីគាំទ្រយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល និងជាធាតុចូលសម្រាប់រៀបចំការតាមដានត្រួតពិនិត្យ និងវាយអំពីតម្រូវការជាតិ តំបន់ និងអន្តរជាតិ ជាពិសេសសមិទ្ធផលសម្រេចបានរបស់រាជរដ្ឋាភិបាលកម្ពុជា និងអន្តរជាតិលើគោលនយោបាយអាទិភាពត្រូវផលិតបន្តបន្ទាប់នៅត្រីមាសទី៣ ឆ្នាំ២០២៥។ របាយការណ៍វិភាគស៊ីជម្រៅនឹងសហការណ៍ផលិតដោយមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិក្រោមជំនួយបច្ចេកទេសពីអ្នកជំនាញអន្តរជាតិ៖

១.អាពាហ៍ពិពាហ៍ និងលទ្ធភាពមានកូន
២.មរណភាព និងមរណភាពមាតា
៣.កំណើនប្រជាជន និងបម្រែបម្រួលរបាយប្រជាជន
៤.សមាសភាពភេទ និងអាយុ
៥.ពិការភាព
៦.ជនជាតិដើមភាគតិច
៧.ទេសន្តប្រវេសន៍
៨.អក្ខរភាព និងការអប់រំ
៩.កម្លាំងពលកម្ម និងការងារ

១០.សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ
១១.ទឹកស្អាត និងអនាម័យ
១២.ចំណោលប្រជាជនកម្ពុជា ២០២៤-២០៥០
១៣.ស្ថានភាពយេនឌ័រនៅកម្ពុជា
១៤.មនុស្សចាស់ និងស្ថានភាពរស់នៅ
១៥.ស្ថានភាពកុមារនៅកម្ពុជា
១៦.ស្ថានភាពកុមារ និងបរិស្ថាន
១៧.សូចនាករសំខាន់នៃប្រជាសាស្ត្រ
១៨.កុមារ និងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ

ទំហំ កំណើន និងការបែងចែកប្រជាជន ២

២.១. ចំនួន និងទំហំប្រជាជនសរុប

លទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជា (CIPS២០២៤) ថ្ងៃ០៣ ខែឧសភា ឆ្នាំ២០២៤ បង្ហាញថាប្រជាជនកម្ពុជាសរុបមានចំនួន ១៧.២៨០.៥៤៣ កើនឡើងពី ១៥.៥៥២.២១១ នៅក្នុងឆ្នាំ២០១៩។ ចំនួនប្រជាជនសរុបកើនឡើង ១.៧២៨.៣៣២ ត្រូវជា ១១,១ ភាគរយ រយៈពេល ៥ឆ្នាំ រវាងឆ្នាំ២០១៩ និង២០២៤។ ចំនួនប្រជាជនប្រុសមាន ៨.៤៩០.៤១៩ នាក់ ស្មើនឹង ៤៩,១ ភាគរយ ខណៈដែលចំនួនប្រជាជនជាស្រីមាន ៨.៧៩០.១២៥ នាក់ ស្មើនឹង ៥០,៩ ភាគរយនៃចំនួនប្រជាជនសរុប។

ជំរឿនលើកដំបូងត្រូវបានធ្វើឡើង បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យពីការគ្រប់គ្រងរបស់បារាំង នៅឆ្នាំ១៩៦២ ដែលប្រជាជនកម្ពុជានៅពេលនោះមាន ៥,៧ លាននាក់។ ទម្រង់ប្រជាសាស្ត្រប្រទេសកម្ពុជាបានផ្លាស់ប្តូរទាំងស្រុងបន្ទាប់ពីជំរឿនលើកដំបូងនោះដោយសារសង្គ្រាម និងភាពចលាចល។ ក្រោយឆ្នាំ១៩៦២ ប្រទេសកម្ពុជាបានធ្វើជំរឿនឆ្នាំ១៩៩៨។ ទោះជាយ៉ាងណាក៏ដោយមានការប៉ាន់ចំនួនប្រជាជនដោយអ្នកជំនាញផ្នែកប្រជាសាស្ត្រសម្រាប់បម្រើផែនការនិងគោលនយោបាយមួយចំនួន។ អង្កេតប្រជាសាស្ត្រឆ្នាំ១៩៧៩-១៩៨០ ត្រូវបានប៉ាន់ប្រមាណប្រជាជនកម្ពុជាមានក្នុងរង្វង់ ៦,៦ លាននាក់។ ក្រោយមកវិទ្យាស្ថានជាតិស្ថិតិ បានដឹកនាំការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៤ បានប៉ាន់ប្រមាណឃើញប្រជាជនរបស់ប្រទេសមានចំនួន ៩,៩ លាននាក់។ ដោយឡែកវិទ្យាស្ថានជាតិស្ថិតិបានធ្វើអង្កេតប្រជាសាស្ត្រក្នុងខែមីនា ឆ្នាំ១៩៩៦ ដែលគ្របដណ្តប់លើគ្រួសារចំនួន ២០.០០០គ្រួសារ ចំនួនប្រជាជនប៉ានស្មានមាន ១០,៧ លាននាក់។ ចំនួនប្រជាជនកម្ពុជាសរុបផ្អែកលើជំរឿនខែមីនាឆ្នាំ១៩៩៨ មានចំនួន ១១,៤ លាននាក់ ចន្លោះជំរឿនឆ្នាំ២០០៨ កម្ពុជាបានធ្វើអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជាឆ្នាំ២០០៤ ប្រជាជនកម្ពុជាកើនដល់ ១២,៨ លាននាក់។ ចំនួនប្រជាជនកម្ពុជាបានកើនឡើងជាលំដាប់ គឺនៅជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០០៨ ប្រជាជនកម្ពុជាកើនដល់ ១៣,៤ លាននាក់ ហើយត្រូវបានធ្វើបច្ចុប្បន្នភាពដោយអង្កេតចន្លោះជំរឿននៃប្រជាជនកម្ពុជាឆ្នាំ២០១៣ ឃើញមានចំនួន ១៤,៧ លាននាក់ លទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ តាមវិធីសាស្ត្រឃើញរាប់ (de-facto) មានចំនួន ១៥,៦ លាននាក់ និងលទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជាឆ្នាំ២០២៤ តាមវិធីសាស្ត្រឃើញរាប់ មានចំនួន ១៧,៣ លាននាក់ ។

រូបទី ២.១.១ និន្នាការប្រជាជនកម្ពុជាសរុប ពីឆ្នាំ១៩៦២ ដល់ ២០២៤



លទ្ធផលអង្កេតចុងក្រោយបានបង្ហាញថាក្នុងចំណោមរាជធានី ខេត្តទាំង២៥ រាជធានីភ្នំពេញ មានប្រជាជនខ្ពស់បំផុតដែលមានចំនួន ២.៣៥២.៨៥១ នាក់ (១៣,៦%) តាមលំដាប់លំដោយខេត្តកណ្តាល ១.៣៥២.១៩៨ (៧,៨%) ព្រៃវែង ១.២៧៧.៨៦៧ (៧,៤%) បាត់ដំបង ១.១៣២.០១៧ (៦,៦%) សៀមរាប ១.០៩៩.៨២៥ (៦,៤%) តាកែវ ១.០៩៧.២៤៣ (៦,៣%) និងខេត្តកំពង់ចាម ១.០៦២.៩១៤ (៦,២%) ចំណែកខេត្តកែបវិញមានប្រជាជនទាបបំផុត ៤៨.៧៧២នាក់ ឬ (០,៣%) ។

តារាង ២.១.១.ចំនួនគ្រួសារ ប្រជាជន និងទំហំគ្រួសារមធ្យម តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២៤

រាជធានី ខេត្ត	ចំនួនគ្រួសារ	ប្រជារាស្ត្រ				ទំហំគ្រួសារមធ្យម (*)
		ទាំងពីរភេទ	បុរស	ស្ត្រី	អត្រាភេទ	
កម្ពុជា	៣.៧៣៥.៦៥៩	១៧.២៨០.៥៤៣	៨.៤៩០.៤១៩	៨.៧៩០.១២៥	៩៦,៦	៤,៦
ទីប្រជុំជន	១.៦០០.១៥១	៧.១៧២.២០៦	៣.៥០៣.៥០៧	៣.៦៦៨.៦៩៩	៩៥,៥	៤,៥
ជនបទ	២.១៣៥.៥០៨	១០.១០៨.៣៣៧	៤.៩៨៦.៩១២	៥.១២១.៤២៥	៩៧,៤	៤,៧
ទំនាបកណ្តាល	១.៨៨៩.០១២	៨.៦៤៦.២០៣	៤.២២៣.៥៦៣	៤.៤២២.៦៣៩	៩៥,៥	៤,៦
ទន្លេសាប	១.១៤៥.០៨៩	៥.៤០៥.៦៩៥	២.៦៥៥.៧១៦	២.៧៤៩.៩៧៨	៩៦,៦	៤,៧
ឆ្នេរ និងសមុទ្រ	២៣៩.១២៨	១.១០៧.៤២៣	៥៥៥.៥៥៩	៥៥១.៨៦៤	១០០,៧	៤,៦
ខ្ពង់រាប និងភ្នំ	៤៦២.៤៣១	២.១២១.២២៣	១.០៥៥.៥៨០	១.០៦៥.៦៤៣	៩៩,១	៤,៦
បន្ទាយមានជ័យ	១៩៦.៦៣៤	៨៩៨.៤៨៤	៤៥០.៥៧៥	៤៤៧.៩០៩	១០០,៦	៤,៦
បាត់ដំបង	២២៣.៤៤៤	១.១៣២.០១៧	៥៥៧.២៨៥	៥៧៤.៧៣២	៩៧,០	៥,១
កំពង់ចាម	២២៦.២៦	១.០៦២.៩១៤	៥១៩.៨៤៣	៥៤៣.០៧១	៩៥,៧	៤,៧
កំពង់ឆ្នាំង	១៣៩.៦៥៣	៦០៤.៨៩៥	២៩៦.៨៣៨	៣០៨.០៥៧	៩៦,៤	៤,៣
កំពង់ស្ពឺ	២០១.៧២៤	៩២៤.១៧៥	៤៥៣.៥៩	៤៧០.៥៨៥	៩៦,៤	៤,៦
កំពង់ធំ	១៦៦.៥១៩	៨០៧.២៥៤	៣៨៨.២៧	៤១៨.៩៨៣	៩២,៧	៤,៨
កំពត	១៤៧.៤០៧	៦៨២.៩៨៧	៣៤៣.៦២៣	៣៣៩.៣៦៤	១០១,៣	៤,៦
កណ្តាល	២៨១.៧៥១	១.៣៥២.១៩៨	៦៥១.៦០៧	៧០០.៥៩១	៩៣,០	៤,៨
កោះកុង	៣០.២៧០	១៤០.៩៦២	៧១.៤៦	៦៩.៥០២	១០២,៨	៤,៧
ក្រចេះ	៩១.២៥៦	៤៤១.០៧៨	២២៤.៤៦២	២១៦.៦១៦	១០៣,៦	៤,៨
មណ្ឌលគីរី	១៩.១២០	៩៣.៦៥៧	៤៨.០០៩	៤៥.៦៤៨	១០៥,២	៤,៩
ភ្នំពេញ	៥៦៥.២៧២	២.៣៥២.៨៥១	១.១៥២.៨១៧	១.២០០.០៣៤	៩៦,១	៤,២
ព្រះវិហារ	៥៥.៩០៨	២៤៩.៩៧៣	១២៤.១៦៧	១២៥.៨០៦	៩៨,៧	៤,៥
ព្រៃវែង	២៦៦.៩៣៩	១.២៧៧.៨៦៧	៦២៤.១៣៤	៦៥៣.៧៣៣	៩៥,៥	៤,៨
ពោធិ៍សាត់	១១៦.០៣៨	៥១៦.០៧២	២៥២.៩៦៤	២៦៣.១០៨	៩៦,១	៤,៤
រតនៈគីរី	៥៦.៤៩៦	២៣៥.៨៥២	១១៧.១៧៧	១១៨.៦៧៦	៩៨,៧	៤,២
សៀមរាប	២២៩.១៧៩	១.០៩៩.៨២៥	៥៣៨.៦៣២	៥៦១.១៩២	៩៦,០	៤,៨
ព្រះសីហនុ	៥០.៣៨២	២៣៤.៧០២	១១៦.១៧៩	១១៨.៥២៣	៩៨,០	៤,៧
ស្ទឹងត្រែង	៣៧.៩២៧	១៧៦.៤៨៨	៨៨.១៧៤	៨៨.៣១៤	៩៩,៨	៤,៧
ស្វាយរៀង	១៣៦.៥៤២	៦១៣.១៥៩	២៩៩.៦៤៨	៣១៣.៥១១	៩៥,៦	៤,៥
តាកែវ	២២៣.៧២៩	១.០៩៧.២៤៣	៥៤២.៥២៧	៥៥៤.៧១៦	៩៧,៨	៤,៩
ឧត្តរមានជ័យ	៥៥.១៦៥	២៦៧.៧០៣	១៣២.៣៧៦	១៣៥.៣២៧	៩៧,៨	៤,៩
កែប	១១.០៦៩	៤៨.៧៧២	២៤.២៩៧	២៤.៤៧៥	៩៩,៣	៤,៤
ប៉ៃលិន	១៨.៤៥៨	៧៩.៤៤៥	៣៨.៧៧៦	៤០.៦៦៩	៩៥,៣	៤,៣
ត្បូងឃ្មុំ	១៨៨.៥១៩	៨៨៩.៩៧	៤៣២.៩៨៧	៤៥៦.៩៨២	៩៤,៧	៤,៧

រូបភាព ២.១.២. ប្រជាជនកម្ពុជាតាមរាជធានី ខេត្ត ឆ្នាំ២០២៤



ផែន ២.១.១ ការបែងចែកចំនួនប្រជាជនតាមរាជធានីខេត្ត ឆ្នាំ២០២៤



២.២ កំណើនប្រជាជនប្រចាំឆ្នាំ

កំណើនចំនួនប្រជាជនត្រូវបានគេប្រើក្នុងន័យដ៏ទូលំទូលាយ ដើម្បីគ្របដណ្ដប់លើការបំរែបំរួលនៃចំនួនប្រជាជនដែលរស់នៅក្នុងប្រទេស ឬតំបន់ ក្នុងអំឡុងពេលជាក់លាក់ដោយមិនគិតថាតើការបំរែបំរួលផ្លាស់ប្ដូរមានភាពវិជ្ជមាន ឬអវិជ្ជមាន បំរែបំរួលការផ្លាស់ប្ដូរនេះត្រូវបានវាស់វែងដោយគិតជាភាគរយ ។

លទ្ធផលចុងក្រោយអង្កេតចន្លោះរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ចំនួនប្រជាជនកម្ពុជាសរុបកើនឡើង ១.៧២៨.៣៣២ នាក់ត្រូវជា ១១,១ ភាគរយ ក្នុងរយៈពេល ៥ ឆ្នាំ ចន្លោះឆ្នាំ២០១៩ និង ២០២៤ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ២,១ ភាគរយ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបន្តកើនឡើងបើទោះបីអត្រានៃលទ្ធភាពមានកូនបន្តធ្លាក់ចុះ និងការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាទៅកាន់ប្រទេសផ្សេង ជាពិសេសប្រទេសជិតខាងនៅតែបន្ត។

រវាងឆ្នាំ ២០១៩ និង ២០២៤ ប្រជាជនថ្នាក់ជាតិបានកើនឡើងមានចំនួន ១.៧២៨.៣៣២ នាក់ នៅក្នុងនោះតំបន់ទីប្រជុំជនបានបញ្ជាក់កំណើនមួយមានមនុស្ស ១.០៣៧.០១២ នាក់ (១៦,៩ ភាគរយ) ចំណែកតំបន់ជនបទវិញបានឃើញកំណើនមួយមានមនុស្ស ៦៩១.៣២០ នាក់ (៧,៣ ភាគរយ) (តារាង ២.២.១)។ ភាគរយនៃប្រជាជនតំបន់ទីប្រជុំជននឹងប្រជាជនសរុបកម្ពុជាក្នុងឆ្នាំ២០១៩ និង២០២៤ ស្មើនឹង ៣៩,៤ និង ៤១,៥ តាមលំដាប់រៀង) (តារាង ២.៣.១)។ ដូច្នេះមាននិន្នាការកំណើននគរូបនីយកម្មនៅកម្ពុជាជាច្រើនឆ្នាំកន្លងមក។

ក្នុងអំឡុងរយៈពេល ២០១៩-២០២៤ អត្រាកំណើនប្រជាជនប្រចាំឆ្នាំមធ្យមនៅក្នុងតំបន់ទីប្រជុំជនមាន ៣,១ ភាគរយ ចំណែកនៅក្នុងតំបន់ជនបទអត្រាកំណើននេះមាន ១,៤ ភាគរយ (តារាង ២.២.១)។ ការផ្លាស់ប្តូរលំនៅដ្ឋានដើរតួសំខាន់មួយក្នុងអត្រាខ្ពស់ជាងគេ ដោយប្រៀបធៀបនៃកំណើនប្រជាជននៅក្នុងតំបន់ទីប្រជុំជន។

អត្រាកំណើនប្រចាំឆ្នាំខ្ពស់បំផុតត្រឹម ២,៦ ភាគរយ ក្នុងមួយឆ្នាំមាននៅតំបន់ទំនាបកណ្តាល ដែលមានខេត្តភាគច្រើននៅភូមិភាគឥសាន្ត និងបន្ទាប់មកតំបន់ទន្លេសាប មានអត្រាកំណើនប្រចាំឆ្នាំមាន ២,២ ភាគរយ។ ដោយឡែកតំបន់ភ្នំ និងឆ្នេរ និងសមុទ្រ មានអត្រាកំណើនប្រចាំឆ្នាំត្រឹមតែ ១,៤ និង ០,៦ ភាគរយប៉ុណ្ណោះតាមលំដាប់រៀង។ មានតែតំបន់ភ្នំ និងឆ្នេរ និងសមុទ្រ ប៉ុណ្ណោះដែលបន្តមានអត្រាកំណើនប្រជាជនប្រចាំឆ្នាំ។

អត្រាកំណើនប្រចាំឆ្នាំខ្ពស់បំផុតត្រឹម ២,៦ ភាគរយ ក្នុងមួយឆ្នាំ មាននៅតំបន់ទំនាបកណ្តាល ដែលមានខេត្តភាគច្រើននៅភូមិភាគឥសាន្ត និងបន្ទាប់មកតំបន់ទន្លេសាបមានអត្រាកំណើន ប្រចាំឆ្នាំមាន ២,២ ភាគរយ។ ដោយឡែកតំបន់ ខ្ពង់រាបនិងភ្នំ និង តំបន់ឆ្នេរនិងសមុទ្រ មានអត្រាកំណើនប្រចាំឆ្នាំត្រឹមតែ ១,៤ និង ០,៦ ភាគរយប៉ុណ្ណោះតាមលំដាប់រៀង។ ទោះបីមានអត្រាកំណើនកើនឡើងក្តី ប៉ុន្តែនៅតំបន់ខ្ពង់រាបនិងភ្នំ និងតំបន់ ឆ្នេរនិងសមុទ្រ ដែលអត្រាកំណើនប្រជាជនប្រចាំឆ្នាំមានការធ្លាក់ចុះបើធៀបនឹងឆ្នាំ២០០៨-២០១៩។

តារាង ២.២.១.អត្រាកំណើនប្រជាជនប្រចាំឆ្នាំចុងក្រោយ តាមរាជធានី/ខេត្ត កម្ពុជាឆ្នាំ២០១៩-២០២៤

រាជធានី/ខេត្ត	ចំនួនប្រជាជនសរុប		អត្រាកំណើនប្រចាំឆ្នាំ	
	២០១៩	២០២៤	២០០៨-២០១៩	២០១៩-២០២៤
សរុប	**១៥.៥៥២.២១១**	**១៧.២៨០.៥៤៣**	**១,៤**	**២,១**
ទីប្រជុំជន	**៦.១៣៥.១៩៤**	**៧.១៧២.២០៦**	**៧,៨**	**៣,១**
ជនបទ	**៩.៤១៧.០១៧**	**១០.១០៨.៣៣៧**	**-១,២**	**១,៥**
ទំនាបកណ្តាល	**៧.៦៤៤.២៩៥**	**៨.៦៤៦.២០៣**	**១,៤**	**២,៦**
ទន្លេសាប	**៤.៨៥២.៩៦៤**	**៥.៤០៥.៦៩៥**	**១,០**	**២,២**
ឆ្នេរ និងសមុទ្រ	**១.០៧២.៤៦៨**	**១.១០៧.៤២៣**	**១**	**០,៦**
ខ្ពង់រាប និងភ្នំ	**១.៩៨២.៤៨៤**	**២.១២១.២២៣**	**២,៤**	**១,៤**
បន្ទាយមានជ័យ	៨៦១.៨៨៣	៨៩៨.៤៨៤	២,២	០,៨
បាត់ដំបង	៩៩៧.១៦៩	១.១៣២.០១៧	-០,៣	២,៥
កំពង់ចាម	៨៩៩.៧៩១	១.០៦២.៩១៤	-០,៣	៣,៣
កំពង់ឆ្នាំង	៥២៧.០២៧	៦០៤.៨៩៥	១	២,៨
កំពង់ស្ពឺ	៨៧៧.៥២៣	៩២៤.១៧៥	១,៨	១,០
កំពង់ធំ	៦៨១.៥៤៩	៨០៧.២៥៤	០,៧	៣,៤
កំពត	៥៩៣.៨២៩	៦៨២.៩៨៧	០,១	២,៨
កណ្តាល	១.២០១.៥៨១	១.៣៥២.១៩៨	-០,៥	២,៤
កោះកុង	១២៥.៩០២	១៤០.៩៦២	០,៦	២,៣
ក្រចេះ	៣៧៤.៧៥៥	៤៤១.០៧៨	១,៥	៣,៣
មណ្ឌលគិរី	៩២.២១៣	៩៣.៦៥៧	៣,៧	០,៣
ភ្នំពេញ	២.២៨១.៩៥១	២.៣៥២.៨៥១	៤,៩	០,៦
ព្រះវិហារ	២៥៤.៨២៧	២៤៩.៩៧៣	៣,៦	-០,៤
ព្រៃវែង	១.០៥៧.៧២០	១.២៧៧.៨៦៧	១,០	៣,៨
ពោធិ៍សាត់	៤១៩.៩៥២	៥១៦.០៧២	០,៥	៤,១
រតនគិរី	២១៧.៤៥៣	២៣៥.៨៥២	៣,៣	១,៦
សៀមរាប	១.០១៤.២៣៤	១.០៩៩.៨២៥	១,១	១,៦
ព្រះសីហនុ	៣១០.០៧២	២៣៤.៧០២	៣,១	-៥,៦
ស្ទឹងត្រែង	១៦៥.៧១៣	១៧៦.៤៨៨	៣,៦	១,៣
ស្វាយរៀង	៥២៥.៤៩៧	៦១៣.១៥៩	០,៨	៣,១
តាកែវ	៩០០.៩១៤	១.០៩៧.២៤៣	០,៦	៣,៩
ឧត្តរមានជ័យ	២៧៦.០៣៨	២៦៧.៧០៣	៣,៦	-០,៦
កែប	៤២.៦៦៥	៤៨.៧៧២	១,៦	២,៧
ប៉ៃលិន	៧៥.១១២	៧៩.៤៤៥	០,៦	១,១
ត្បូងឃ្មុំ	៧៧៦.៨៤១	៨៨៩.៩៧	០,៣	២,៧

នៅកម្រិតរាជធានី/ខេត្ត តាមលទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជាឆ្នាំ២០២៤ នេះអត្រាកំណើនប្រជាជនខ្ពស់ឃើញមាននៅ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ខេត្តពោធិ៍សាត់ (៤,១%) តាកែវ

(៣,៩%) ខេត្តព្រៃវែង (៣,៨%) និងកំពង់ធំ (៣,៤ %) ដែលជាខេត្តដែលមានលទ្ធភាពបង្កើតកូនខ្ពស់ និងស្រូបយកការធ្វើចំណាកស្រុកមកពីបណ្តាខេត្តផ្សេងទៀតសម្រាប់ការតាំងលំនៅថ្មី និងដីកសិកម្ម ឱកាសសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ដោយឡែកខេត្តព្រះសីហនុ អត្រាកំណើនប្រជាជនបានធ្លាក់ចុះខ្ពស់ (៥,៦%) និងខេត្តឧត្តរមានជ័យ និងព្រះវិហារ ក៏មានអត្រាធ្លាក់ចុះតិចជាងមួយភាគរយផងដែរ (០,៦% និង ០,៤%) តាមលំដាប់រៀង។ ទោះបីរាជធានីភ្នំពេញ ជាកន្លែងដែលមានសក្តានុពលចាប់យកឱកាសការងារ សេដ្ឋកិច្ច ការអភិវឌ្ឍ ទេសចរណ៍ អប់រំ សំណង់ និងពិសេសវិស័យឧស្សាហកម្មកាត់ដេរ ប៉ុន្តែអត្រាកំណើនប្រចាំឆ្នាំមានត្រឹមតែ ០.៦% ប៉ុណ្ណោះ ។

ផែនទី ២.២.១. អត្រាកំណើនប្រជាជនប្រចាំឆ្នាំតាមរាជធានីខេត្ត កម្ពុជាឆ្នាំ ២០២៤



២.៣. ការបែងចែករបាយប្រជាជន

តារាង ២.៣.១ ផ្តល់ភាគរយប្រជាជនសរុបចុងក្រោយ តំបន់ និងភេទ អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បង្ហាញថាប្រជាជនកម្ពុជាចូលចិត្តប្រមូលផ្តុំរស់នៅតំបន់ទំនាបកណ្តាលប្រទេសប្រមាណជា ៨.៦៤៦.២០៣នាក់ ត្រូវជា ៥០,៣ ភាគរយ ដោយសារតំបន់ប្រមូលផ្តុំដោយខេត្តធំៗមានការអភិវឌ្ឍខ្ពស់។ តំបន់ទន្លេសាប ជាតំបន់ដែលមានប្រជាជនច្រើនលំដាប់ទី២ ដែលមានប្រជាជនចំនួន ៥.៤០៥.៦៩៥ នាក់ ឬស្មើនឹង ៣១,៣ ភាគរយនៃប្រជាជនសរុប ខណៈដែលតំបន់ខ្ពង់រាប និងភ្នំ ឈរក្នុងលំដាប់លេខរៀងទី ៣ មានប្រជាជន ២.១២១.២២៣នាក់ ឬស្មើ នឹង ១២,៣ ភាគរយ និងតំបន់ឆ្នេរ និងសមុទ្រ ១.១០៧.៤២៣នាក់ ស្មើនឹង ៦,១ ភាគរយ ។

ទម្រង់និន្នាការរបាយប្រជាជនហាក់នៅថេរមិនប្រែប្រួលរវាងឆ្នាំ២០១៩ និងឆ្នាំ២០២៤។ សម្រាប់តំបន់ទំនាបកណ្តាល តំបន់ទន្លេសាប និងតំបន់ខ្ពង់រាបនិងភ្នំ របាយប្រជាជនមានការកើនឡើងដូចគ្នា។ ដោយឡែកតំបន់ឆ្នេរ និងសមុទ្រ របាយប្រជាជនមានការធ្លាក់ចុះបន្តិចបន្តួចបើធៀបនឹងឆ្នាំ២០១៩ ជាពិសេសគឺនៅខេត្តព្រះសីហនុ។

តារាង ២.៣.១. ភាគរយប្រជាជនសរុបចុងក្រោយ តំបន់ និង ភេទ កម្ពុជាឆ្នាំ២០១៩-២០២៤

រាជធានី ខេត្ត	ប្រជាជនឆ្នាំ ២០១៩			ប្រជាជនឆ្នាំ ២០២៤		
	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
សរុប	**១០០**	**១០០**	**១០០**	**១០០**	**១០០**	**១០០**
ទីប្រជុំជន	**៣៩,៤**	**៣៩,៥**	**៣៩,៤**	**៤១,៥**	**៤១,៣**	**៤១,៧**
ជនបទ	**៦០,៦**	**៦០,៥**	**៦០,៦**	**៥៨,៥**	**៥៨,៧**	**៥៨,៣**
ទំនាបកណ្តាល	**៤៩,២**	**៤៨,៦**	**៤៩,៧**	**៥០,៣**	**៥០,០**	**៥០,៦**
ទន្លេសាប	**៣១,២**	**៣១,៤**	**៣១,០**	**៣១,៣**	**៣១,៣**	**៣១,៣**
ឆ្នេរ និងសមុទ្រ	**៦,៩**	**៧,០**	**៦,៨**	**៦,១**	**៦,៣**	**៦,០**
ខ្ពង់រាប និងភ្នំ	**១២,៧**	**១៣,០**	**១២,៥**	**១២,៣**	**១២,៤**	**១២,១**
បន្ទាយមានជ័យ	៥,៥	៥,៧	៥,៤	៥,២	៥,៣	៥,១
បាត់ដំបង	៦,៤	៦,៥	៦,៣	៦,៦	៦,៦	៦,៥
កំពង់ចាម	៥,៨	៥,៧	៥,៩	៦,២	៦,១	៦,២
កំពង់ឆ្នាំង	៣,៤	៣,៣	៣,៤	៣,៥	៣,៥	៣,៥
កំពង់ស្ពឺ	៥,៦	៥,៦	៥,៧	៥,៣	៥,៣	៥,៤
កំពង់ធំ	៤,៤	៤,៤	៤,៤	៤,៧	៤,៦	៤,៨
កំពត	៣,៨	៣,៨	៣,៨	៤,០	៤,០	៣,៩
កណ្តាល	៧,៧	៧,៧	៧,៨	៧,៨	៧,៧	៨,០
កោះកុង	០,៨	០,៨	០,៨	០,៨	០,៨	០,៨
ក្រចេះ	២,៤	២,៥	២,៤	២,៦	២,៦	២,៥
មណ្ឌលគិរី	០,៦	០,៦	០,៦	០,៥	០,៦	០,៥
ភ្នំពេញ	១៤,៧	១៤,៦	១៤,៧	១៣,៦	១៣,៦	១៣,៧
ព្រះវិហារ	១,៦	១,៧	១,៦	១,៤	១,៥	១,៤
ព្រៃវែង	៦,៨	៦,៦	៧,០	៧,៤	៧,៤	៧,៤
ពោធិ៍សាត់	២,៧	២,៧	២,៧	៣,០	៣,០	៣,០
រតនគិរី	១,៤	១,៥	១,៣	១,៤	១,៤	១,៤
សៀមរាប	៦,៥	៦,៦	៦,៥	៦,៤	៦,៣	៦,៤
ព្រះសីហនុ	២,០	២,១	១,៩	១,៤	១,៤	១,៣
ស្ទឹងត្រែង	១,១	១,១	១,០	១,០	១,០	១,០
ស្វាយរៀង	៣,៤	៣,៣	៣,៥	៣,៥	៣,៥	៣,៦
តាកែវ	៥,៨	៥,៧	៥,៩	៦,៣	៦,៤	៦,៣
ឧត្តរមានជ័យ	១,៨	១,៨	១,៧	១,៥	១,៦	១,៥
កែប	០,៣	០,៣	០,៣	០,៣	០,៣	០,៣
ប៉ៃលិន	០,៥	០,៥	០,៥	០,៥	០,៥	០,៥
ត្បូងឃ្មុំ	៥,០	៥,០	៥,០	៥,២	៥,១	៥,២

ភ្នំពេញមានប្រជាជនខ្ពស់បំផុតដែលមានចំនួន ២.៣៥២.៨៥១នាក់ (១៣,៦%) តាមលំដាប់ដោយ ខេត្តកណ្តាល ១.៣៥២.១៩៨ នាក់ (៧,៨%) ព្រៃវែង ១.២៧៧.៨៦៧ នាក់ (៧,៤%) បាត់ដំបង ១.១៣២.០១៧ (៦,៦%) សៀមរាប ១.០៩៩.៨២៥នាក់ (៦,៤ %) តាកែវ ១.០៩៧.២៤៣ (៦,៣ %) និង កំពង់ចាម ១.០៦២.៩១៤ នាក់ (៦,២%) ខណៈខេត្តកែបវិញមានប្រជាជនទាបបំផុត ៤៨.៧៧២ នាក់ឬ (០,៣%) ។

ផែនទី ២.៣.១ ភាគរយប្រជាជនសរុប តាមរាជធានីខេត្ត កម្ពុជា ឆ្នាំ២០២៤



ប្រៀបធៀបទៅឆ្នាំ២០១៩ របាយប្រជាជនកម្ពុជាមានទម្រង់ដូចគ្នានឹងឆ្នាំ២០២៤ដែរគឺ រាជធានីភ្នំពេញ មានប្រជាជនខ្ពស់បំផុតតាមលំដាប់លំដោយខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តតាកែវ និងកំពង់ចាម ហើយខេត្តកែបនៅតែមានប្រជាជនទាបបំផុតជាងគេដដែល។ ប៉ុន្តែភាគរយរបាយប្រជាជន ក្នុងខេត្តសៀមរាប ខេត្តបាត់ដំបង មានការថយចុះបើធៀបនឹងឆ្នាំ២០១៩ ដោយឡែករាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម និងខេត្តតាកែវ របាយប្រជាជនកើនឡើង ។

២.៤. ដង់ស៊ីតេប្រជាជន

ដង់ស៊ីតេប្រជាជន គឺជាសន្ទស្សន៍ដ៏សំខាន់មួយនៃសូចនាករប្រជាសាស្ត្រដែលត្រូវបានវាស់វែងដោយការប្រមូលផ្តុំរបស់ប្រជាជន។ សន្ទស្សន៍ជាចំនួនមនុស្សរស់នៅក្នុងបរិវេណដីក្នុងមួយគីឡូម៉ែត្រការ៉េ។ លទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ដង់ស៊ីតេប្រជាជនកម្ពុជាមាន ៩៧ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ កើនឡើង ១០ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ពី ៨៧ នាក់ នៅឆ្នាំ២០១៩។

តារាង ២.៤.១ បង្ហាញពីដង់ស៊ីតេប្រជាជនតាមតំបន់សម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២៤។ លទ្ធផលចុងក្រោយបានបង្ហាញថា ដង់ស៊ីតេប្រជាជនមានការប្រែប្រួលយ៉ាងខ្លាំងនៅតាមតំបន់ភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។ ជាទូទៅតំបន់ដែលមានផ្ទៃដីធំហើយមានដង់ស៊ីតេប្រជាជនទាបបំផុត ផ្ទុយពីតំបន់ដែលមានផ្ទៃដីតូច ប៉ុន្តែមានដង់ស៊ីតេប្រជាជនខ្ពស់ខ្លាំង។ ដង់ស៊ីតេប្រជាជននៅតំបន់វាលទំនាបមានចំនួនខ្ពស់បំផុត ៣៤៧ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ បន្ទាប់មកតំបន់ទន្លេសាប ៨០ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តំបន់ឆ្នេរ និងសមុទ្រ មាន ៦៤នាក់ ខណៈដែលតំបន់ខ្ពង់រាប និងភ្នំ មានដង់ស៊ីតេទាបជាងគេ ៣១ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េប៉ុណ្ណោះ។

បើធៀបទៅនឹងឆ្នាំ២០១៩ ដង់ស៊ីតេប្រជាជនគ្រប់តំបន់ទាំងអស់ជាពិសេសទំនាបកណ្តាលបានកើនឡើងពីចំនួន ៣០៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ទៅ ៣៤៧នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ឬកើន ៤២ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តំបន់ទន្លេសាបកើន ៨ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ និងតំបន់ឆ្នេរ និងសមុទ្រ ខ្ពង់រាប និងភ្នំ កើន ២នាក់ និង ២នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តាមលំដាប់រៀង។

តារាង ២.៤.១ បង្ហាញពីដង់ស៊ីតេប្រជាជនតាមរាជធានី ខេត្ត ឆ្នាំ២០១៩ និងឆ្នាំ២០២៤។ រាជធានីភ្នំពេញដែលជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា ជាតំបន់ប្រមូលផ្តុំដោយមជ្ឈមណ្ឌលពាណិជ្ជកម្ម សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជាប្រភពទាក់ទាញស្រូបយកការធ្វើចំណាកស្រុកមកពីបណ្តាខេត្តផ្សេងៗ ដោយសារការផ្តល់ប្រភពការងារ និងការរីកចម្រើនខាងវិស័យឧស្សាហកម្មកាត់ដេរ សំណង់ សណ្ឋាគារ ទេសចរណ៍ និងអប់រំ។ល។ នៅរាជធានីភ្នំពេញមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេ ៣.៤៦៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ បន្ទាប់មកខេត្តកណ្តាល តាកែវ ព្រៃវែង កំពង់ចាម ស្វាយរៀង ព្រះសីហនុ ត្បូងឃ្មុំ បន្ទាយមានជ័យ កែប កំពង់ស្ពឺ និងកំពត មានដង់ស៊ីតេប្រជាជនចន្លោះពី ១៤០ នាក់ ទៅ ៤២៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ ចំណែកខេត្តសៀមរាប កំពង់ឆ្នាំង ប៉ៃលិន បាត់ដំបង កំពង់ធំ មានដង់ស៊ីតេប្រជាជនចន្លោះពី ៥៨នាក់ ទៅ១០៧ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ ខេត្តកោះកុង និងខេត្តមណ្ឌលគីរី ជាខេត្តមានដង់ស៊ីតេប្រជាជនទាបជាងគេ ៧នាក់ ទៅ ១៤នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តាមលំដាប់រៀង។ ដង់ស៊ីតេប្រជាជនមានការកើនឡើងគ្រប់រាជធានី ខេត្ត ក្នុងអត្រាតិច ឬច្រើន តាមការរីកចម្រើននៃវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច សង្គម និងវប្បធម៌។

តារាង ២.៤.១. ការបែងចែករបាយផ្ទៃដី និងដង់ស៊ីតេប្រជាជនតាមរាជធានី ខេត្ត កម្ពុជា២០១៩-២០២៤

រាជធានី/ខេត្ត	ចំនួនប្រជាជនសរុប		ដង់ស៊ីតេប្រជាជន/គម២	
	២០១៩	២០២៤	២០១៩	២០២៤
សរុប	**១៥.៥៥២.២១១**	**១៧.២៨០.៥៤៣**	**៨៧**	**៩៧**
ទំនាបកណ្ដាល	**៧.៦៤៤.២៩៥**	**៨.៦៩៤.៩៧៤**	**៣០៥**	**៣៤៧**
ទន្លេសាប	**៤.៨៥២.៩៦៤**	**៥.៤០៥.៦៩៥**	**៧២**	**៨០**
ឆ្នេរ និងសមុទ្រ	**១.០៧២.៤៦៨**	**១.០៥៨.៦៥១**	**៦២**	**៦៤**
ខ្ពង់រាប និងភ្នំ	**១.៩៨២.៤៨៤**	**២.១២១.២២៣**	**២៩**	**៣១**
បន្ទាយមានជ័យ	៨៦១.៨៨៣	៨៩៨.៤៨៤	១២៩	១៣៥
បាត់ដំបង	៩៩៧.១៦៩	១.១៣២.០១៧	៨៥	៩៧
កំពង់ចាម	៨៩៩.៧៩១	១.០៦២.៩១៤	១៩៨	២៣៤
កំពង់ឆ្នាំង	៥២៧.០២៧	៦០៤.៨៩៥	៩៥	១១០
កំពង់ស្ពឺ	៨៧៧.៥២៣	៩២៤.១៧៥	១២៥	១៣២
កំពង់ធំ	៦៨១.៥៤៩	៨០៧.២៥៤	៤៩	៥៨
កំពត	៥៩៣.៨២៩	៦៨២.៩៨៧	១២២	១៤០
កណ្ដាល	១.២០១.៥៨១	១.៣៥២.១៩៨	៣៧៨	៤២៥
កោះកុង	១២៥.៩០២	១៤០.៩៦២	១២	១៤
ក្រចេះ	៣៧៤.៧៥៥	៤៤១.០៧៨	៣៤	៤០
មណ្ឌលគិរី	៩២.២១៣	៩៣.៦៥៧	៦	៧
ភ្នំពេញ	២.២៨១.៩៥១	២.៣៥២.៨៥១	៣.៣៦១	៣.៤៦៥
ព្រះវិហារ	២៥៤.៨២៧	២៤៩.៩៧៣	១៨	១៨
ព្រៃវែង	១.០៥៧.៧២០	១.២៧៧.៨៦៧	២១៧	២៧៣
ពោធិ៍សាត់	៤១៩.៩៥២	៥១៦.០៧២	៣៣	៤១
រតនគិរី	២១៧.៤៥៣	២៣៥.៨៥២	២០	២២
សៀមរាប	១.០១៤.២៣៤	១.០៩៩.៨២៥	៩៨	១០៧
ព្រះសីហនុ	៣១០.០៧២	២៣៤.៧០២	១៦០	១២១
ស្ទឹងត្រែង	១៦៥.៧១៣	១៧៦.៤៨៨	១៥	១៦
ស្វាយរៀង	៥២៥.៤៩៧	៦១៣.១៥៩	១៧៧	២០៧
តាកែវ	៩០០.៩១៤	១.០៩៧.២៤៣	២៥៣	៣០៨
ឧត្តរមានជ័យ	២៧៦.០៣៨	២៦៧.៧០៣	៤៥	៤៣
កែប	៤២.៦៦៥	៤៨.៧៧២	១២៧	១៤៥
ប៉ៃលិន	៧៥.១១២	៧៩.៤៤៥	៩៤	៩៩
ត្បូងឃ្មុំ	៧៧៦.៨៤១	៨៨៩.៩៧០	១៤៨	១៧០

** កំណត់សម្គាល់: គណនាដង់ស៊ីតេប្រជាជនសរុបក្រោយដកផ្ទៃបឹងទន្លេសាប ៣.០០០ គីឡូម៉ែត្រការ៉េ*

ផែនទី ២.៤.១ ដង់ស៊ីតេប្រជាជនតាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០២៤



២.៥. ការបែងចែកប្រជាជនតាមសាសនា

នៅកម្ពុជាប្រមាណជា ៩៧ ភាគរយនៃប្រជាជនកម្ពុជាកាន់ព្រះពុទ្ធសាសនា។ ក្រុមសាសនាដែលធំបន្ទាប់ពីសាសនាព្រះពុទ្ធ គឺសាសនាឥស្លាម មាន ២,៦ ភាគរយ។ គ្រប់តំបន់នៅកម្ពុជាអ្នកកាន់សាសនាព្រះពុទ្ធមានភាគរយខ្ពស់ទាំងអស់។ នៅតំបន់ខ្ពង់រាប និងភ្នំ មានអ្នកកាន់សាសនាផ្សេងទៀតមានជិត ៤ ភាគរយ។

តារាង ២.៥.១ ការបែងចែកភាគរយប្រជាជនតាមសាសនា និងតាមតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤

រាជធានី/ខេត្ត	ប្រជាជនឆ្នាំ២០១៩				ប្រជាជនឆ្នាំ២០២៤			
	ព្រះពុទ្ធ	ឥស្លាម	គ្រឹស្ទ	សាសនាផ្សេងទៀត	ព្រះពុទ្ធ	ឥស្លាម	គ្រឹស្ទ	សាសនាផ្សេងទៀត
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨	(៨)
កម្ពុជា	**៩៧,១**	**២,០**	**០,៣**	**០,៥**	**៩៦,៥**	**២,៦**	**០,៣**	**០,៥**
ទីប្រជុំជន	**៩៧,៧**	**១,៦**	**០,៤**	**០,២**	**៩៦,៧**	**២,៨**	**០,៤**	**០,០**
ជនបទ	**៩៦,៧**	**២,៣**	**០,២**	**០,៨**	**៩៦,៤**	**២,៥**	**០,៣**	**០,៨**
ទំនាបកណ្ដាល	៩៧,៤	២,២	០,៣	០,១	៩៦,៦	៣,០	០,៣	០,០
ទន្លេសាប	៩៨,១	១,៥	០,៣	០,១	៩៧,៦	២,០	០,៥	០,០
ឆ្នេរ និងសមុទ្រ	៩៦,៤	៣,២	០,២	០,០	៩៥,៧	៤,១	០,២	០,០
ខ្ពង់រាប និងភ្នំ	៩៣,៦	២,១	០,៦	០,៦	៩៣,៩	២,០	០,៣	៣,៨

២.៦. ការបែងចែកប្រជាជនតាមទីកន្លែងកំណើត

ទម្រង់ទូទៅដែលជាភស្តុតាងបញ្ជាក់រវាងជំរឿនប្រជាជនឆ្នាំ២០១៩ និងអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ២០២៤ បង្ហាញថាភាគច្រើន(៦៩,៩ ភាគរយ) គឺការរាប់នៅយប់ធ្វើជំរឿនគឺដូចគ្នាផងដែរទីកន្លែងកើត។ ការផ្លាស់ទីលំនៅ(បុគ្គលដែលមិនបានរស់នៅទីកន្លែងកំណើត) ៣០,១ ភាគរយនៅកម្រិតជាតិ។

តារាង ២.៦.១: ការបែងចែកប្រជាជនតាមទីកន្លែងកើត និងភេទ កម្ពុជាឆ្នាំ២០១៩ និង ២០២៤

ទីកន្លែងកើត	២០១៩			២០២៤		
	ទាំងពីរភេទ	បុរស	ស្ត្រី	ទាំងពីរភេទ	បុរស	ស្ត្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
ចំនួន	១៥.៥៥២.២១១	៧.៥៧១.៨៣៧	៧.៩៨០.៣៧៤	១៧.២៨០.៥៤៣	៨.៤៩០.៤១៩	៨.៧៩០.១២៥
សរុប	១០០	១០០	១០០	១០០	១០០	១០០
A. **កើតនៅកម្ពុជា**	៩៩,១	៩៩,០	៩៩,៣	៩៩,៧	៩៩,៦	៩៩,៧
១.ក្នុងខេត្តសម្ភាសន៍	៨៥,៥	៨៤,៦	៨៦,៤	៧២,២	៦៩,២	៧៥,០
២.ទីកន្លែងសម្ភាសន៍	៧៨,៣	៧៦,៥	៨០,០	៦៩,៩	៦៦,៦	៧៣,១
៣.ខេត្តផ្សេងទៀត	១៣,៦	១៤,៤	១២,៩	២៧,៥	៣០,៤	២៤,៧
B. **កើតនៅបរទេស**	០,៩	១,១	០,៧	០,៣	០,៤	០,៣
១.ចំណោមប្រទេសអាស៊ី	០,៨	១,០	០,៧	០,៣១	០,៣៧	០,២៦
២. ប្រទេសផ្សេងទៀត	០,០៤	០,០៦	០,០៣	០,០១	០,០១	០,០១

២.៧ ការបែងចែកប្រជាជនតាមភាសាកំណើត

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានសួរគ្រប់សមាជិកទាំងអស់នៅក្នុងគ្រួសារ អំពីភាសាកំណើតរបស់ខ្លួន។ លទ្ធផលអង្កេតបានបង្ហាញថា ភាសាខ្មែរជាភាសាកំណើតច្រើនលើសលប់នៅក្នុងប្រទេស (៩៦,៤ ភាគរយ)។ អ្នកនិយាយភាសាកំណើតជនជាតិភាគតិចមាន ៣,១ភាគរយ។ អ្នកដែលមានភាសាបរទេសជាភាសាកំណើតរួមមាន ០,៥ភាគរយប៉ុណ្ណោះ ។

តារាង ២.៧.១: ការបែងចែកប្រជាជនតាមភាសាកំណើត និងភេទ កម្ពុជាឆ្នាំ២០១៩-២០២៤

ភាសាកំណើត	ចំនួន			ភាគរយ		
	ទាំងពីរភេទ	បុរស	ស្ត្រី	ទាំងពីរភេទ	បុរស	ស្ត្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
សរុប	១៧.២៨០.៥៤៣	៨.៤៩០.៤១៩	៨.៧៩០.១២៥	១០០	១០០	១០០
ខ្មែរ	១៦.៦៥៧.៩៣៧	៨.១៨៣.៤៣៧	៨.៤៧៤.៤៩៩	៩៦,៤	៩៦,៤	៩៦,៤
វៀតណាម	៥៣.៨៣៥	២៤.៩២២	២៨.៩១៣	០,៣	០,៣	០,៣
ចិន	១០.៤០០	៧.២០២	៣.១៩៨	០,១	០,១	០,០
ឡាវ	១៩.៨៩៤	៩.៣៩៣	១០.៥០១	០,១	០,១	០,១
ថៃ	១.៨០៥	១.៤៣០	៣៧៥	០,០	០,០	០,០
ភាសាផ្សេងទៀត	២.៨១៩	១.៧៣០	១.០៨៨	០,០	០,០	០,០
ភាសាជនជាតិភាគតិច	៥៣៣.៨៥៤	២៦២.៣០៤	២៧១.៥៥០	៣,១	៣,១	៣,១

រចនាសម្ព័ន្ធអាយុ ភេទ និងអាពាហ៍ពិពាហ៍ ៣

៣.១. សេចក្តីផ្តើម

ការផ្លាស់ប្តូររចនាសម្ព័នអាយុ សមាសភាពភេទប្រជាជនជានិន្នាការអន្តរកម្មប្រជាសាស្ត្រកើតឡើងនៅគ្រប់ប្រទេសទាំងអស់នៅលើសកលលោក។ និន្នាការនេះដំបូងគឺការធ្លាក់ចុះមរណភាព និងបន្ទាប់មកបន្តធ្លាក់ចុះលទ្ធភាពបង្កើតកូន។ រចនាសម្ព័ន្ធអាយុ និងភេទរបស់ប្រជាជនត្រូវបានកំណត់ដោយនិន្នាការបច្ចុប្បន្ន និងអតីតកាលនៃលទ្ធភាពបង្កើតកូន មរណភាព និងទេសន្តប្រវេសន៍បានជះឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងនយោបាយ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុបានធ្វើអោយប៉ះពាល់ដល់កម្លាំងពលកម្មអនាគតសេដ្ឋកិច្ចថវិកាសាធារណៈ និងបុគ្គល វប្បធម៌ និងរចនាសម្ព័ន្ធគ្រួសារនៃប្រទេសមួយ ។

អាយុ គឺអថេរដ៏សំខាន់នៃប្រជាជន ដែលអ្នកធ្វើផែនការស្ទើរតែទាំងអស់ត្រូវតែយកចិត្តទុកដាក់លើអថេរមួយនេះ។ ប្រទេសដែលកំពុងអភិវឌ្ឍន៍ និងប្រាក់ចំណូលមធ្យមកម្រិតទាបមួយចំនួនដូចជាប្រទេសកម្ពុជាមានគោលនយោបាយដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងសេដ្ឋកិច្ចដោយបានលើកកម្ពស់ការចុះឈ្មោះចូលរៀន និងធ្វើអោយប្រសើរឡើងនូវការសំរេចបានការសិក្សាអប់រំនៃអ្នកដែលបានចុះឈ្មោះចូលរៀន។

អនុឡោមតាមនិយមន័យរបស់អង្គការសហប្រជាជាតិ អាយុរបស់មនុស្សដែលបានកត់ត្រាក្នុងជំរឿននិងអង្កេតគឺ"ចន្លោះឃ្លាតនៃកាលបរិច្ឆេទកំណើត និងកាលបរិច្ឆេទនៃជំរឿនគិតជាឆ្នាំសុរិយគតិពេញលេញ"។ វាក៏ត្រូវបានចែងថា ព័ត៌មានអំពីអាយុអាចគិតតាមកាលបរិច្ឆេទកំណើត (ថ្ងៃ ខែ ឆ្នាំកំណើត) ឬសួរដោយផ្ទាល់អំពីអាយុនៅខួបកំណើតចុងក្រោយ។

ព័ត៌មានអាយុគិតជាឆ្នាំពេញ ដោយផ្អែកលើខួបកំណើតចុងក្រោយដែលបានទទួលពីអ្នកឆ្លើយតប។ ដូច្នេះវាមានការងាយស្រួលគ្រប់គ្រាន់សម្រាប់សួរពីព័ត៌មានអាយុនេះ ប៉ុន្តែពេលខ្លះពិបាកក្នុងការប្រមូលទិន្នន័យដែលត្រឹមត្រូវអំពីអាយុ គឺនៅពេលដែលមនុស្សមិនចេះអក្សរ ឬមនុស្សចាស់ជរា។ មានជំហានដែលសមស្របសម្រាប់យកមកប្រមូលទិន្នន័យអំពីអាយុអោយមានភាពសុក្រិតតាមតែអាចធ្វើទៅបានពីអ្នកឆ្លើយ។ ប្រតិទិនខ្មែរត្រូវបានយកមកប្រើប្រាស់ដោយមន្រ្តីសម្ភាសន៍ ដើម្បីសួរអោយបាននូវអាយុពេញលេញពីអ្នកឆ្លើយតបចំពោះអ្នកដែលមិនអាចប្រាប់អាយុរបស់ពួកគេបាន។ មន្រ្តីសម្ភាសន៍ត្រូវបានផ្តល់អោយនូវតារាងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិសំខាន់ៗក៏ត្រូវបានប្រើប្រាស់ដើម្បីជួយ អ្នកឆ្លើយអោយនឹកឃើញពីអាយុរបស់ពួកគាត់ឡើងវិញ។

៣.២. ការវាយតម្លៃទិន្នន័យអាយុ

ការប្រមូលទិន្នន័យជាទូទៅ មានកម្រិតលំអៀងដោយសារហេតុផលមួយចំនួន បើទោះបីជាមានការប្រុងប្រយ័ត្ននៅពេលប្រមូលទិន្នន័យក៏ដោយ ដូច្នេះវាមានការចាំបាច់ដើម្បីវាយតម្លៃទិន្នន័យទាំងនោះមុននឹង

យកមកប្រើប្រាស់។ សន្ទស្សន៍បទដ្ឋានប្រជាសាស្ត្រត្រូវបានគណនាសម្រាប់គោលបំណងក្នុងការប្រមូលទិន្នន័យអាយុក្នុងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ ។

ការកត់ត្រាពីអាយុយោងអាចកើតឡើងជំនួសអោយអាយុពិតនៅខ្ទង់ចុងក្រោយ។ គំលាតសន្ទស្សន៍ Myer និងសន្ទស្សន៍ Whipple ត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃទិន្នន័យនិន្នាការរាយការណ៍អំពីអាយុ។

តម្លៃសន្ទស្សន៍សន្ទស្សន៍ Mayer

- ទិន្នន័យមានគុណភាពខ្ពស់ ១០.០
- ទិន្នន័យត្រឹមត្រូវត្រឹមត្រូវ ១០.០ – ១៩.៩
- ទិន្នន័យមានគុណភាពទាប ២០.០ – ៣៩.៩
- ទិន្នន័យមិនអាចប្រើការបាន ៤០.០

តម្លៃសន្ទស្សន៍សន្ទស្សន៍ Whipple

- ទិន្នន័យមានគុណភាពខ្ពស់ ១០៥
- ទិន្នន័យត្រឹមត្រូវត្រឹមត្រូវ ១០៥ – ១០៩.៩
- ទិន្នន័យប្រហាក់ប្រហែល ១១០ – ១២៤.៩
- ទិន្នន័យមានគុណភាពទាប ១២៥ – ១៧៤.៩
- ទិន្នន័យមិនអាចប្រើការបាន ១៧៥

តារាង ៣.២.១. ការវាយតម្លៃកត់ត្រាអាយុ អង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០២៤

ភេទ	សន្ទស្សន៍ Mayer	សន្ទស្សន៍ Whipple	
		0	៥
ទាំងពីរភេទ	៦,៨	១០៣	១១០
ប្រុស	៦,៦	៩៩	១០៧
ស្រី	៧,១	១០៦	១១៣

៣.៣. រចនាសម្ព័ន្ធអាយុ

រចនាសម្ព័ន្ធអាយុត្រូវបានកំណត់ដោយកត្តា ៣ ដែលធ្វើអោយប៉ះពាល់អត្រាកំណើនប្រជាជនដូចជាលទ្ធភាពបង្កើតកូន មរណភាព និងការផ្លាស់ប្តូរលំនៅដ្ឋាន។ ការសិក្សារចនាសម្ព័ន្ធប្រជាជនគឺត្រូវប្រើក្នុងការបែងចែកភាគរយប្រជាជនតាមក្រុមអាយុខុសគ្នា និងការបង្ហាញជាក្រាហ្វិកដែលហៅថា ពីរ៉ាមីតអាយុ ដែលសង្ខេបខ្លីនៃប្រវត្តិប្រជាសាស្ត្ររបស់ប្រជាជន។

តារាង ៣.៣.១. ការបែងចែកតាមក្រុមអាយុរាយតាមភេទ តំបន់កម្ពុជា ២០២៤

អាយុ	សរុប			ទីប្រជុំជន			ជនបទ		
	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)	(១០)
សរុប	**១០០**	**១០០**	**១០០**	**១០០**	**១០០**	**១០០**	**១០០**	**១០០**	**១០០**
០	១,៦	១,៧	១,៤	១,៥	១,៧	១,៣	១,៦	១,៧	១,៥
១	១,៤	១,៣	១,៤	១,២	១,២	១,២	១,៥	១,៥	១,៥
២	១,៧	១,៧	១,៧	១,៧	១,៧	១,៦	១,៧	១,៨	១,៧
៣	១,៩	១,៩	១,៩	១,៧	១,៧	១,៨	២,០	២,០	១,៩
៤	១,៩	២,១	១,៨	១,៩	២,០	១,៨	១,៩	២,១	១,៨
០-៤	**៨,៥**	**៨,៨**	**៨,២**	**៨,០**	**៨,៣**	**៧,៦**	**៨,៨**	**៩,១**	**៨,៦**
៥	១,៨	១,៨	១,៧	១,៨	១,៩	១,៨	១,៨	១,៨	១,៧
៦	១,៩	២,០	១,៧	១,៧	១,៩	១,៥	១,៩	២,១	១,៨
៧	១,៩	២,០	១,៨	១,៨	២,០	១,៦	១,៩	២,០	១,៩
៨	១,៩	២,០	១,៨	១,៩	២,០	១,៨	១,៩	២,០	១,៧
៩	១,៧	១,៧	១,៦	១,៧	១,៧	១,៧	១,៦	១,៨	១,៥
៥-៩	**៩,១**	**៩,៦**	**៨,៥**	**៨,៩**	**៩,៥**	**៨,៤**	**៩,១**	**៩,៧**	**៨,៦**
១០	១,៩	២,០	១,៧	១,៧	១,៨	១,៦	២,០	២,១	១,៨
១១	១,៦	១,៨	១,៥	១,៥	១,៦	១,៤	១,៨	១,៩	១,៦
១២	២,០	២,០	២,០	១,៩	២,០	១,៨	២,១	២,១	២,១
១៣	២,០	២,១	១,៩	១,៩	២,០	១,៨	២,០	២,១	១,៩
១៤	១,៨	១,៩	១,៧	១,៦	១,៧	១,៦	១,៩	២,០	១,៨
១០-១៤	**៩,៣**	**៩,៧**	**៨,៩**	**៨,៦**	**៩,១**	**៨,២**	**៩,៨**	**១០,២**	**៩,៣**
១៥	១,៩	១,៩	១,៨	១,៩	១,៩	១,៩	១,៨	១,៩	១,៨
១៦	១,៨	១,៩	១,៨	១,៨	១,៩	១,៧	១,៨	១,៨	១,៨
១៧	១,៨	១,៨	១,៨	១,៨	១,៩	១,៧	១,៨	១,៧	១,៩
១៨	១,៩	១,៩	១,៩	១,៨	១,៨	១,៩	២,០	២,០	២,០
១៩	១,៧	១,៧	១,៦	១,៧	១,៧	១,៦	១,៧	១,៧	១,៧
១៥-១៩	**៩,១**	**៩,២**	**៩,០**	**៩,០**	**៩,២**	**៨,៨**	**៩,២**	**៩,២**	**៩,២**
២០	១,៨	១,៨	១,៨	១,៨	១,៩	១,៦	១,៨	១,៨	១,៩
២១	១,៦	១,៦	១,៦	១,៦	១,៥	១,៨	១,៥	១,៦	១,៤
២២	១,៧	១,៨	១,៦	១,៥	១,៥	១,៦	១,៩	២,១	១,៧
២៣	១,៦	១,៧	១,៦	១,៦	១,៧	១,៥	១,៧	១,៦	១,៧
២៤	១,៩	១,៩	១,៩	១,៩	១,៩	១,៩	១,៩	២,០	១,៩
២០-២៤	**៨,៦**	**៨,៨**	**៨,៤**	**៨,៤**	**៨,៤**	**៨,៤**	**៨,៨**	**៩,១**	**៨,៥**
២៥	១,៨	១,៨	១,៨	១,៨	១,៧	១,៨	១,៩	១,៩	១,៨
២៦	១,៥	១,៦	១,៤	១,៦	១,៦	១,៦	១,៤	១,៦	១,៣
២៧	១,៤	១,៤	១,៤	១,៤	១,៥	១,៣	១,៥	១,៤	១,៥
២៨	១,៦	១,៧	១,៥	១,៧	១,៨	១,៧	១,៦	១,៧	១,៤
២៩	១,៦	១,៦	១,៦	១,៧	១,៧	១,៨	១,៥	១,៦	១,៥
២៥-២៩	**៨,០**	**៨,២**	**៧,៨**	**៨,១**	**៨,១**	**៨,២**	**៧,៩**	**៨,២**	**៧,៥**
៣០	១,៩	២,០	១,៩	២,០	២,១	២,០	១,៩	១,៩	១,៨
៣១	១,៧	១,៨	១,៧	១,៧	១,៨	១,៦	១,៧	១,៧	១,៧
៣២	២,០	២,១	១,៩	២,២	២,៤	២,១	១,៨	១,៩	១,៧
៣៣	១,៦	១,៧	១,៥	១,៧	១,៩	១,៥	១,៦	១,៧	១,៥
៣៤	១,៦	១,៧	១,៥	១,៧	១,៨	១,៧	១,៥	១,៧	១,៣
៣០-៣៤	**៨,៨**	**៩,៣**	**៨,៤**	**៩,៤**	**៩,៨**	**៨,៩**	**៨,៥**	**៨,៩**	**៨,១**
៣៥	១,៧	១,៧	១,៨	១,៩	១,៨	២,០	១,៦	១,៦	១,៧
៣៦	១,៦	១,៦	១,៧	១,៧	១,៦	១,៧	១,៦	១,៧	១,៦
៣៧	១,៦	១,៦	១,៥	១,៦	១,៧	១,៥	១,៥	១,៥	១,៦
៣៨	១,៨	១,៨	១,៧	២,១	២,២	២,០	១,៦	១,៦	១,៦
៣៩	១,៤	១,៤	១,៤	១,៦	១,៧	១,៦	១,៣	១,២	១,៣

៣៥-៣៩	**៨,២**	**៨,២**	**៨,១**	**៨,៩**	**៩,០**	**៨,៨**	**៧,៦**	**៧,៦**	**៧,៧**
៤០	១,៧	១,៦	១,៨	១,៨	១,៦	២,០	១,៦	១,៦	១,៦
៤១	១,៦	១,៦	១,៥	១,៧	១,៧	១,៦	១,៥	១,៥	១,៥
៤២	១,៧	១,៦	១,៧	១,៨	១,៧	១,៨	១,៦	១,៥	១,៦
៤៣	១,៥	១,៥	១,៥	១,៧	១,៧	១,៦	១,៣	១,៣	១,៣
៤៤	១,៤	១,៥	១,៤	១,៧	១,៨	១,៦	១,២	១,២	១,៣
៤០-៤៤	**៧,៨**	**៧,៧**	**៧,៨**	**៨,៧**	**៨,៥**	**៨,៨**	**៧,២**	**៧,២**	**៧,២**
៤៥	១,៥	១,៥	១,៦	១,៦	១,៥	១,៧	១,៤	១,៤	១,៥
៤៦	០,៨	០,៨	០,៧	០,៧	០,៨	០,៧	០,៨	០,៨	០,៧
៤៧	០,៧	០,៧	០,៧	០,៦	០,៦	០,៦	០,៨	០,៧	០,៨
៤៨	០,៨	០,៧	០,៨	០,៧	០,៧	០,៨	០,៨	០,៨	០,៨
៤៩	០,៨	០,៨	០,៨	០,៧	០,៧	០,៦	០,៨	០,៩	០,៨
៤៥-៤៩	**៤,៥**	**៤,៥**	**៤,៥**	**៤,៤**	**៤,៣**	**៤,៤**	**៤,៦**	**៤,៦**	**៤,៦**
៥០	០,៨	០,៧	០,៩	០,៧	០,៧	០,៨	០,៨	០,៨	០,៩
៥១	០,៨	០,៨	០,៩	០,៨	០,៧	០,៨	០,៩	០,៨	០,៩
៥២	០,៩	០,៩	១,០	១,០	១,០	១,០	០,៩	០,៨	១,០
៥៣	០,៩	០,៩	១,០	០,៩	០,៩	០,៩	០,៩	០,៨	១,០
៥៤	០,៩	០,៩	១,០	០,៩	១,០	០,៩	០,៩	០,៨	១,០
៥០-៥៤	**៤,៤**	**៤,១**	**៤,៧**	**៤,៤**	**៤,២**	**៤,៥**	**៤,៤**	**៤,១**	**៤,៨**
៥៥	០,៩	០,៩	០,៩	០,៩	០,៨	០,៩	០,៩	១,០	០,៩
៥៦	០,៨	០,៨	០,៨	០,៨	០,៩	០,៧	០,៨	០,៧	០,៩
៥៧	០,៧	០,៧	០,៧	០,៦	០,៥	០,៦	០,៨	០,៨	០,៨
៥៨	០,៧	០,៦	០,៨	០,៦	០,៥	០,៦	០,៨	០,៧	០,៩
៥៩	០,៦	០,៦	០,៦	០,៦	០,៦	០,៦	០,៦	០,៦	០,៧
៥៥-៥៩	**៣,៧**	**៣,៦**	**៣,៨**	**៣,៤**	**៣,៤**	**៣,៤**	**៣,៩**	**៣,៧**	**៤,១**
៦០	០,៨	០,៧	០,៩	០,៧	០,៦	០,៨	០,៩	០,៨	០,៩
៦១	០,៧	០,៦	០,៨	០,៦	០,៥	០,៦	០,៧	០,៦	០,៩
៦២	០,៧	០,៧	០,៧	០,៧	០,៦	០,៧	០,៧	០,៧	០,៧
៦៣	០,៧	០,៦	០,៨	០,៧	០,៦	០,៨	០,៧	០,៧	០,៧
៦៤	០,៧	០,៦	០,៨	០,៧	០,៦	០,៧	០,៧	០,៦	០,៨
៦០-៦៤	**៣,៦**	**៣,២**	**៣,៩**	**៣,៤**	**៣,០**	**៣,៧**	**៣,៨**	**៣,៤**	**៤,១**
៦៥	០,៦	០,៥	០,៧	០,៦	០,៥	០,៧	០,៧	០,៦	០,៨
៦៦	០,៥	០,៥	០,៦	០,៦	០,៦	០,៥	០,៥	០,៤	០,៦
៦៧	០,៥	០,៤	០,៦	០,៥	០,៤	០,៥	០,៥	០,៤	០,៦
៦៨	០,៥	០,៤	០,៦	០,៥	០,៤	០,៦	០,៥	០,៤	០,៥
៦៩	០,៣	០,២	០,៤	០,៣	០,៣	០,៤	០,៣	០,២	០,៤
៦៥-៦៩	**២,៥**	**២,១**	**២,៩**	**២,៥**	**២,១**	**២,៨**	**២,៥**	**២,០**	**២,៩**
៧០	០,៤	០,៣	០,៥	០,៤	០,២	០,៦	០,៤	០,៣	០,៥
៧១	០,៣	០,៣	០,៤	០,៣	០,៣	០,៤	០,៤	០,២	០,៥
៧២	០,៤	០,៣	០,៤	០,៤	០,៣	០,៥	០,៣	០,៣	០,៤
៧៣	០,៣	០,២	០,៤	០,៣	០,២	០,៤	០,៣	០,២	០,៤
៧៤	០,៤	០,៣	០,៤	០,៤	០,៤	០,៤	០,៣	០,២	០,៤
៧០-៧៤	**១,៨**	**១,៣**	**២,២**	**១,៩**	**១,៤**	**២,៣**	**១,៧**	**១,២**	**២,១**
៧៥+	**២,៣**	**១,៨**	**២,៨**	**២,២**	**១,៦**	**២,៩**	**២,៣**	**១,៩**	**២,៨**

រូបភាពទី ៣.៣.១.១ ៣.៣.១.២ និង៣.៣.១.៣ បង្ហាញពីពីរ៉ាមីតអាយុប្រជាជន (សរុប ទីប្រជុំជន និងជនបទកម្ពុជា ២០១៩ និង២០២៤) រួមនឹងភាគរយប្រុស និងស្រីដោយក្រុមអាយុ ៥ ឆ្នាំ ចាប់ផ្តើមពីក្រុមអាយុក្មេងបំផុតដែលស្ថិតនៅផ្នែកខាងក្រោម និងបន្តកំណើនអាយុទៅផ្នែកខាងលើនៃពីរ៉ាមីត។ ភាគរយនៃ

ប្រុសគឺបង្ហាញនៅខាងឆ្វេងដៃ និងភាគរយនៃស្រីបង្ហាញនៅខាងស្តាំដៃនៃពីរ៉ាមីត។ តំបន់ស្រមោលក្រាស់លឿងបង្ហាញពីតំណាងភាគរយប្រជាជនឆ្នាំ២០១៩ ខណៈដែលតំបន់គំនូសបន្ទាត់បង្ហាញពីប្រជាជនឆ្នាំ២០២៤។

ប្រៀបធៀបពីរ៉ាមីតអាយុ ឆ្នាំ២០១៩ និង២០២៤ បង្ហាញពីលំនាំស្របគ្នាត្រឹមត្រូវតាមក្រុមនិមួយៗនេះបង្ហាញពីលក្ខណៈពិសេសនៃការបែងចែកអាយុ ដែលជាលទ្ធផលនៃការកែលម្អស្ថានភាពសុខភាពរបស់ប្រទេសរួមផ្សំជាមួយនឹងការធ្លាក់ចុះនៃលទ្ធភាពបង្កើតកូន និងមរណភាពក្នុងអំឡុងពេលនេះ។ សមាមាត្រ (អាយុក្រោម ១៥ ឆ្នាំ) បង្ហាញពីទម្រង់ធម្មតានៃការធ្លាក់ចុះពី ២៩,៤ ភាគរយក្នុងឆ្នាំ២០១៩ មក ២៦,៨ ភាគរយក្នុងឆ្នាំ២០២៤ នេះបង្ហាញពីការធ្លាក់ចុះនៃអត្រាលទ្ធភាពបង្កើតកូនជាមូលហេតុចំបង។ គួរកត់សម្គាល់ថា សមាមាត្រកុមារកម្ពុជាមាន ៤២,៨ នៅឆ្នាំ១៩៩៨ ថយចុះមក ៣៣,៧ នៅឆ្នាំ២០០៨ និងបន្តធ្លាក់ចុះក្នុងមក ២៩,៤ ក្នុងឆ្នាំ២០១៩ ដោយឡែកចន្លោះឆ្នាំ២០១៩-២០២៤ ដែលសមាមាត្រធ្លាក់ដល់ ២៦,៨ ភាគរយ។

ប្រៀបធៀបពីរ៉ាមីតអាយុប្រជាជនឆ្នាំ២០១៩ និងឆ្នាំ២០២៤ បង្ហាញពីទម្រង់ទូទៅនៃការធ្លាក់ចុះលទ្ធភាពមានកូនក្នុងទសវត្សរ៍ចុងក្រោយ ជាមួយការកើនឡើងនៃប្រជាជនក្នុងក្រុមអាយុក្នុងកម្លាំងពលកម្មគ្រប់ក្រុមអាយុលើកលែងតែក្រុមអាយុ២៥-២៩ និង៣៥-៣៩។ ពីរ៉ាមីតក៏បង្ហាញយ៉ាងច្បាស់ពីការកើនឡើងយ៉ាងខ្លាំងនៃសមាមាត្រនៅក្នុងក្រុមអាយុ ៣០-៣៤ និង ៤០-៤៤ ដែលទទួលរងពីអត្រាមានកូនខ្ពស់ ឬការរីកដុះដាលរបស់ទារកក្នុងអំឡុងពេល (១៩៨៥-១៩៩០)។ នៅប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រទេសមានចំណូលមធ្យមកម្រិតទាបមានការកើនឡើងនៃសមាមាត្រក្រុមអាយុស្ថិតក្នុងកម្លាំងពលកម្ម ដោយសារការធ្វើអន្តរកម្មប្រជាសាស្ត្រដែលបម្លែងជា "ផលលាភប្រជាសាស្ត្រ" នៅពេលណាមួយ។ ប៉ុន្តែក្នុងករណីប្រទេសកម្ពុជាវិញបានបង្កឱកាសការងារដ៏ល្អមួយដើម្បីស្រូបយកកំណើនកម្លាំងពលកម្មក្នុងការងារផលិតកម្ម។

រូបភាព ៣.៣.១.១ ពីរ៉ាមីតអាយុប្រជាជនកម្ពុជា សរុប ឆ្នាំ២០១៩-២០២៤



ពីរ៉ាមីតនៅទីប្រជុំជនមានភាពចង្អៀតនៃរបាប្រជាជនក្នុងក្រុមអាយុ ០-៤ ឆ្នាំ ប្រៀបធៀបទៅនឹង៥ឆ្នាំមុននេះបង្ហាញអោយឃើញពីការថយចុះនៃប្រជាជនក្រុមអាយុ ០-៤ ដោយឡែកក្រុមអាយុ ៥-៩ ឆ្នាំ ហាក់មានច្រើនជាងឆ្នាំ២០១៩ នេះអាចមកពីអំឡុងវិតក្បិតកូវីដ អត្រាលទ្ធភាពមានកូនហាក់ឡើងបន្តិចវិញស្របនឹងអ្វីដែលបានបង្ហាញដោយលទ្ធផលអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០២១-២២។ ពីរ៉ាមីតនៅទីប្រជុំជនឆ្នាំ ២០២៤ បង្ហាញពីកាថយចុះនៃក្រុមអាយុយុវជនសម្រាប់ប្រុស ស្រីក្នុងក្រុអាយុអាយុ ២០-៣៩ឆ្នាំ។ មូលហេតុចំបងមួយនៃរូបភាពនេះ អាចបណ្តាលមកពីការវិលត្រឡប់មកលំនៅដ្ឋានអចិន្ត្រៃយ៍របស់ក្រុមកម្មកររោងចក្រកាត់ដេរជាច្រើនសែននាក់ទៅកាន់ជនបទវិញ ដែលភាគច្រើនជាក្មេងស្រី ដោយសារតែការផ្លាស់ប្តូទីតាំងរោងចក្រកាត់ដេរមួយចំនួនក្នុងអំឡុងពេល ឬមុនពេលអង្កេត។ ពីរ៉ាមីតបង្ហាញផងដែរពីការកើនឡើងខ្លាំងនៃសមាមាត្រក្នុងក្រុមអាយុ ៤០-៤៤ ដែលទទួលរងដោយអត្រាលទ្ធភាពបង្កើតកូនខ្ពស់ ឬបន្ទុះក្មេងក្នុងអំឡុងឆ្នាំ(១៩៨៥-១៩៩០)។

រូបភាព ៣.៣.១.២. ពីរ៉ាមីតអាយុប្រជាជន ទីប្រជុំជន កម្ពុជា ឆ្នាំ២០១៩-២០២៤



ពិនិត្យឃើញថាមានភាពខុសគ្នាស្រឡះពីពីរ៉ាមីតរចនាសម្ព័ន្ធអាយុទីប្រជុំជនក្នុងរូប ៣.៣.១.៣ នៅជនបទមានប្រជាជនវ័យក្មេង និងប្រជាជនវ័យចាស់ច្រើន។ ផ្ទុយមកវិញពីរ៉ាមីតនៅជនបទមានការរីកទូលាយនៅក្នុងក្រុមប្រជាជនវ័យក្មេង និងតូចចង្អៀតនៅក្បាលពីរ៉ាមីតមិនដូចនៅទីប្រជុំជនឡើយបញ្ជាក់ថាអត្រាលទ្ធភាពមានកូន និងទេសន្តប្រវេសន៍ចេញខ្ពស់ តែទោះជាយ៉ាងណាក៏ដោយអត្រាលទ្ធភាពមានកូនបានធ្លាក់ចុះបើប្រៀបធៀបនឹងឆ្នាំ២០១៩ពេលគឺ ១៥ ឆ្នាំចុងក្រោយនេះ។ នេះបង្ហាញយ៉ាងច្បាស់ថា តំបន់ជនបទមានប្រជាជនវ័យក្មេងនឹងប្រជាជនវ័យចាស់ច្រើន។ ទម្រង់នេះនេះត្រូវបានកត់សម្គាល់នៅជំរឿននិងអង្កេត។

រូបភាព ៣.៣.១.៣. ពីរ៉ាមីតអាយុប្រជាជន ជនបទ កម្ពុជា ឆ្នាំ២០១៩-២០២៤



រចនាសម្ព័ន្ធអាយុរបស់ប្រជាជនកម្ពុជាកំពុងធ្វើអន្តរកម្មឈានចូលដល់មានវ័យចាស់ ហើយដែលប្រជាជនអាយុលើស ៦០ ឆ្នាំឡើង មានប្រមាណ ១០,១ ភាគរយ ភាគរយនេះកើនពី ៨,៩ ភាគរយនៅឆ្នាំ២០១៩។ តារាងបង្ហាញអំពីមេដ្យានអាយុ ២៨ ឆ្នាំ នៅឆ្នាំ២០២៤ អាយុមេដ្យានប្រជាជនកម្ពុជានៅឆ្នាំ២០១៩ មាន ២៧ឆ្នាំ ដូច្នេះមេដ្យានអាយុប្រជាជនមានអាយុកើនឡើង ១ ឆ្នាំ ក្នុងរយៈពេល៥ឆ្នាំ។ នេះជាលទ្ធផលនៃការថយចុះក្នុងចំណោមប្រជាជនវ័យក្មេងអាយុ ០-១៤ឆ្នាំ ការកើនឡើងអត្រានៃប្រជាជនអាយុ ៦០ ឆ្នាំឡើង ចន្លោះឆ្នាំ២០១៩ និង ២០២៤ ដោយសារការធ្លាក់ចុះចំនួនមធ្យមនៃកំណើតក្នុងស្ត្រីម្នាក់ ហើយជាមួយគ្នានេះផងដែរមានការកើនឡើងនៃអត្រាប្រជាជនក្នុងកម្លាំងពលកម្មអាយុ ១៥-៥៩ ឆ្នាំ។

សមាមាត្រប្រជាជនក្នុងក្រុមអាយុទូទៅបីក្រុម ក្នុងតារាង ៣.៣.២ បង្ហាញថានិន្នាការបានធ្លាក់ចុះក្នុងក្រុមអាយុ (០-១៤ឆ្នាំ) ក្នុងចំណោមប្រជាជនសរុប និងមានកើនឡើងក្នុងក្រុមអាយុកម្លាំងពលកម្ម (១៥-៥៩ឆ្នាំ)។ ជាមួយគ្នានេះ ក៏មានការកើនឡើងនៃសមាមាត្រប្រជាជនវ័យចាស់ (៦០ ឆ្នាំឡើង)ក្នុងអំឡុងពេលកន្លះទសវត្សរ៍ ២០១៩-២០២៤ ផងដែរ។

វិធីសាស្ត្រសាមញ្ញ ពិពណ៌នាអំពីរចនាសម្ព័ន្ធអាយុប្រជាជនត្រូវបានគណនាដោយសន្ទស្សន៍ ហៅថាផលធៀបអាយុអ្នកនៅក្នុងបន្ទុក ជាអត្រាសមាសភាពក្រុមប្រជាជនដែលពឹងអាស្រ័យលើផលិតភាពប្រជាជនដែលជាសកម្មជនសេដ្ឋកិច្ច។ ជាការសន្មត ចំនួនកុមារ (០-១៤ឆ្នាំ) បូកនឹងចំនួនមនុស្សចាស់អាយុ៦០ឆ្នាំឡើង ចែកនឹងចំនួនប្រជាជនអាយុស្ថិតក្នុងកម្លាំងពលកម្ម(១៥-៥៩ឆ្នាំ) គុណនឹង១០០។

តារាង ៣.៣.២. ការបែកចាយប្រជាជនតាមក្រុមអាយុ ផលធៀបអាយុក្នុងបន្ទុក មេដ្យានអាយុ និងផលធៀបភេទ កម្ពុជា ២០១៩-២០២៤

ចរិតលក្ខណៈ	ឆ្នាំ ២០១៩			ឆ្នាំ ២០២៤		
	សរុប	ទីប្រជុំជន	ជនបទ	សរុប	ទីប្រជុំជន	ជនបទ
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
សរុប	១០០	១០០	១០០	១០០	១០០	១០០
០០-១៤	២៩,៤	២៥,៦	៣១,៨	២៦,៨	២៥,៥	២៧,៧
១៥-៥៩	៦១,៧	៦៦,២	៥៨,៩	៦៣,១	៦៤,៥	៦២,០
៦០ ឆ្នាំឡើង	៨,៩	៨,២	៩,៣	១០,១	៩,៩	១០,៣
ផលធៀបអាយុក្នុងបន្ទុក	៦២	៥១,២	៦៩,៩	៥៨,៥	៥៥,០	៦១,២
មេដ្យានអាយុ (ឆ្នាំ)	២៧	២៨	២៦	២៨	២៩	២៨
ផលធៀបភេទ(ប្រុសក្នុងស្រី១០០នាក់)	៩៤,៩	៩៥,៣	៩៤,៦	៩៦,៦	៩៥,៥	៩៧,៤

៣.៤. ផលធៀបអាយុនៅក្នុងបន្ទុក

ជាទូទៅអាយុផលធៀបអាយុក្នុងបន្ទុក តារាង ៣.៣.២. បង្ហាញអំពីនិន្នាការធ្លាក់ចុះរបស់ប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ២០១៩ និងឆ្នាំ២០២៤។ ឆ្នាំ២០២៤ មាន ៥៨,៥ មានន័យថាក្នុងចំណោមមនុស្ស ១០០នាក់ មានមនុស្ស ៥៩នាក់ ជាប្រជាជនមានអាយុក្នុងបន្ទុកពឹងអាស្រ័យ។ ផលធៀបអាយុក្នុងបន្ទុកបានថយចុះពីជំរឿនឆ្នាំ២០១៩ ដែលមានអត្រា ៦២ នាក់។ អត្រាអ្នកនៅក្នុងបន្ទុកនៅទីប្រជុំជនមាន ៥៥នាក់ ក្នុងចំណោមក្រុមអាយុស្ថិតក្នុងកម្លាំងពលកម្ម ១០០នាក់។ អត្រាអ្នកនៅក្នុងបន្ទុកជាទូទៅមានអត្រាខ្ពស់នៅតំបន់ជនបទ។

៣.៥. ផលធៀបភេទ

ព័ត៌មានមូលដ្ឋាននេះត្រូវបានប្រមូលតាំងពីជំរឿនទាំងនៅឆ្នាំ១៩៩៨ ឆ្នាំ២០០៨ និង២០១៩ ជំរឿននៅប្រទេសកម្ពុជាត្រូវបានបញ្ចូលព័ត៌មានបុរស និងស្ត្រី ហើយបានផលិតសម្រាប់ប្រធានបទស្ទើរតែទាំងអស់។ នេះគឺជាតម្រូវការមូលដ្ឋានមួយនៅក្នុងការកសាងផែនការ ដែលអាចជួយកំណត់នូវផលប៉ះពាល់យេនឌ័រក្នុងសកម្មភាពអភិវឌ្ឍន៍ និងជួយឆ្លើយតបដ៏មានប្រសិទ្ធភាពចំពោះបញ្ហាយេនឌ័រ។

ជាទូទៅ ចំនួនកំណើតបុរស និងចំនួនកំណើតស្ត្រីមិនមានសមភាពទេក្នុងពិភពលោក។ ការសិក្សាអំពីការផ្តល់កំណើតកូនបានបង្ហាញថា ចំនួនកំណើតបុរសតែងតែច្រើនជាងចំនួនកំណើតរបស់ស្ត្រី។ ផលធៀបភេទពីកំណើតប្រែប្រួលក្នុងរង្វង់ ១០២ ទៅ ១១០ នៅប្រទេសភាគច្រើន។ ផលធៀបភេទនៅកម្ពុជាដែលបានប៉ាន់ស្មាននៅពេលកើតប្រមាណ ១០៥។

ផលធៀបភេទ ឬអត្រាភេទនៅកម្ពុជាមាន ៩៦,៦ នេះបញ្ជាក់ថាចំនួនស្ត្រីមានច្រើនជាងចំនួនបុរសក្នុងចំណោមប្រជាជនកម្ពុជា។ នៅប្រទេសភាគច្រើនមានផលធៀបភេទស្ថិតក្នុងចន្លោះពី ៩៥ ទៅ ១០៥។ ផលធៀបភេទ ឬអត្រាភេទកម្ពុជា ត្រូវបានកែលំអចាប់តាំងពីឆ្នាំ២០១៩ មក។

តារាង ៣.៥.១ បង្ហាញថាផលធៀបភេទតាមក្រុមអាយុ ៥ ឆ្នាំ ដោយយោងតាមជំរឿនប្រជាជនឆ្នាំ២០១៩ និងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤។ កត់សម្គាល់ថា ផលធៀបភេទក្នុងចំណោមក្មេងប្រុសដែលស្ថិតក្នុងក្រុមអាយុ ០-៤, ៥-៩ និង១០-១៤ឆ្នាំ ផលធៀបភេទមានការប្រែប្រួលគួរកត់សម្គាល់ក្នុងអំឡុងឆ្នាំ២០១៩ និង២០២៤។ នៅក្នុងក្រុមអាយុ ១៥-១៩ ឆ្នាំ ផលធៀបភេទស្ទើរតែដូចគ្នាទាំងក្នុងឆ្នាំ២០១៩ និង២០២៤ ដែលស្ថិតក្នុងកម្រិតខ្ពស់ប្រហែល ១០១។ ចំនួនកំណើតចំណោមក្មេងប្រុសស្លាប់ទាបបន្តរហូតដល់អាយុ២៥-២៩។ នៅក្នុងអាយុវ័យកណ្តាល និងចាស់ ចំនួនស្ត្រីមានចំនួនច្រើនជាងបុរស មូលហេតុអាចដោយសារមរណភាពបុរសខ្ពស់។ អត្រាភេទទាបចាប់ពីអាយុ ៦០ឆ្នាំឡើង ជាលទ្ធផលនៃមរណភាពខ្ពស់ក្នុងចំណោមបុរស និងការនិរន្តេសចេញពីប្រទេសរបស់មនុស្សវ័យចាស់ជាបុរសពីកម្ពុជាក្នុងរបបខ្មែរក្រហម។

តារាង ៣.៥.១ ការបែងចែកផលធៀបភេទក្រុមអាយុ ភេទ កម្ពុជា ២០១៩-២០២៤

ក្រុមអាយុ	ផលធៀបភេទ	
	ឆ្នាំ ២០១៩	ឆ្នាំ ២០២៤
(១)	(២)	(៣)
សរុប	៩៤,៩	៩៦,៦
០ - ៤	១០៥,៩	១០៣,៧
៥-៩	១០៤,៧	១០៨,៩
១០-១៤	១០៤,៧	១០៦,០
១៥ - ១៩	១០១,៦	៩៨,៥
២០ - ២៤	៩៥,០	១០០,៦
២៥ - ២៩	៩៥,៧	១០១,១
៣០ - ៣៤	៩៦,០	១០៦,៦
៣៥ - ៣៩	៩៧,៨	៩៦,៩
៤០ - ៤៤	៩៤,៩	៩៥,០
៤៥ - ៤៩	៩៣,១	៩៥,៦
៥០ - ៥៤	៨៦,៤	៨៥,៧
៥៥ - ៥៩	៨៥,៨	៩០,៩
៦០ ឡើង	៦៦,៣	៦៨,៧

៣.៦. ស្ថានភាពអាពាហ៍ពិពាហ៍ និងអាយុរៀបការលើកដំបូង

៣.៦.១.ស្ថានភាពអាពាហ៍ពិពាហ៍

ស្ថានភាពអាពាហ៍ពិពាហ៍ គឺជាកត្តាសំខាន់នៅក្នុងសក្តានុពលរបស់ប្រជាជនដោយសារវាជះឥទ្ធិពលដល់លទ្ធភាពបង្កើតកូន មរណភាព និងការផ្លាស់ប្តូរលំនៅដ្ឋាន។ តារាង ៣.៦.១ ខាងក្រោមបង្ហាញពីការបែងចែកប្រជាជនប្រុស និងស្រីដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង ទៅតាមប្រភេទស្ថានភាពអាពាហ៍ពិពាហ៍។ ឆ្លើយតបនឹងសំណួរស្តីពីស្ថានភាពអាពាហ៍ពិពាហ៍នៅ CIPS២០១៤ បែងចែកជាក្រុម៖ មិនដែលរៀបការ បច្ចុប្បន្នរៀបការ មេម៉ាយ/ពោះម៉ាយ លែងលះ និងទំនាស់ផ្សេងគ្នា។ មនុស្សម្នាក់ត្រូវបានគេចាត់ទុកថាបច្ចុប្បន្នរៀបការ ប្រសិនបើតាមច្បាប់ ឬទំនៀមទម្លាប់ និងទំនៀមទម្លាប់ក្នុងស្រុកត្រូវបានគេទទួលស្គាល់ថាបានរៀបការ ឬរស់នៅជាមួយអ្នកដែលមានភេទផ្ទុយគ្នាជាប្តី និងប្រពន្ធ។

សង្កេតឃើញថាមានសមាមាត្រនៃប្រជាជនដែលមានអាយុចាប់ពី ១៥ឆ្នាំឡើង បច្ចុប្បន្នរៀបការមានប្រមាណជា ៦១,៣ ភាគរយ ខណៈសមាមាត្រប្រជាជនដែលមិនរៀបការមានចំនួន ២៨,០ និងសមាមាត្រនៃស្ត្រីមេម៉ាយ/ពោះម៉ាយ លែងលះគ្នា និងទំនាស់ផ្សេងគ្នាមាន ១០,៧ ភាគរយ។ ទោះយ៉ាងណាក៏ដោយក្នុងចំណោមស្ត្រីមេម៉ាយ/ពោះម៉ាយ លែងលះគ្នា និងទំនាស់ផ្សេងគ្នា មានភាគរយខ្ពស់ជាងបុរស។ ធៀបទៅឆ្នាំ ២០១៩ សមាមាត្រប្រជាជនអាយុចាប់ពី ១៥ឆ្នាំឡើង បច្ចុប្បន្នរៀបការ បានថយចុះពី ៦៦,២ភាគរយ មក ៦១,៣ ភាគរយ ដោយឡែកភាគរយប្រជាជនមិនដែលរៀបការ កើនឡើងតែ ០,៥ ភាគរយ ដូចគ្នានេះផងដែរ អត្រាមេម៉ាយ/ពោះម៉ាយ លែងលះគ្នា និងទំនាស់ផ្សេងគ្នាកើនឡើងគួរកត់សម្គាល់ពី ៦,៣ ភាគរយ ទៅ ១០,៧ ភាគរយក្នុងឆ្នាំ២០២៤។ និន្នាការនេះបញ្ជាក់ភស្តុតាងថា បុរសមានទំនោរក្នុងការរៀបការម្តងទៀតច្រើនជាងស្ត្រីក្នុងករណីភាគច្រើនដោយសារតែកត្តាជាច្រើនដែលស្ត្រីមានភាពទំនួលខុសត្រូវក្នុងគ្រួសារ ហើយនេះស្ទើរតែជាបាតុភូតទូទាំងពិភពលោក។

សមាមាត្របុរស មិនដែលធ្លាប់រៀបការ និងបច្ចុប្បន្នរៀបការ គឺខ្ពស់ជាងស្ត្រី ដែលផ្ទុយពីមេម៉ាយ លែងលះគ្នា និងទំនាស់ផ្សេងគ្នា ត្រូវបានកត់សម្គាល់ឃើញថាប្រភេទក្រុមអាយុនីមួយៗ ស្ត្រីមានភាគរយខ្ពស់ជាងជាច់ (តារាង ៣.៦.១)។

តារាង ៣.៦.១. ស្ថានភាពអាពាហ៍ពិពាហ៍អាយុ ១៥ ឆ្នាំឡើង ភេទ និងតំបន់ កម្ពុជា ២០១៩- ២០២៤

ស្ថានភាព អាពាហ៍ពិពាហ៍	ឆ្នាំ					
	២០១៩			២០២៤		
	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
សរុប	១០០	១០០	១០០	១០០	១០០	១០០
មិនដែលរៀបការ	២៧,៥	៣១,២	២៤,១	២៨,០	៣១,៥	២៤,៧
បានរៀបហើយ	៦៦,២	៦៥,៩	៦៦,៤	៦១,៣	៦៣,៣	៥៩,៤
មេម៉ាយ/ពោះម៉ាយ	៤,០	១,៥	៦,៣	៦,៣	២,៤	១០,០
លែងលះ	២,២	១,៣	៣,០	៤,០	២,៦	៥,៤
ទំនាស់រស់នៅផ្សេងគ្នា	០,១	០,១	០,២	០,៤	០,៣	០,៥
ទីប្រជុំជន	១០០	១០០	១០០	១០០	១០០,០	១០០
មិនដែលរៀបការ	៣១,១	៣៤,៣	២៨,១	២៩,៩	៣៣,៣	២៦,៨
បានរៀបហើយ	៦២,៥	៦២,៣	៦២,៧	៥៨,៤	៦០,៨	៥៦,៣
មេម៉ាយ/ពោះម៉ាយ	៣,៧	១,៦	៥,៧	៦,៤	២,៤	១០,១
លែងលះ	២,៥	១,៦	៣,៣	៤,៨	៣,១	៦,៣
ទំនាស់រស់នៅផ្សេងគ្នា	០,២	០,២	០,២	០,៥	០,៤	០,៦
ជនបទ	១០០	១០០	១០០	១០០	១០០	១០០
មិនដែលរៀបការ	២៤,៩	២៨,៩	២១,៤	២៦,៦	៣០,៣	២៣,២
បានរៀបហើយ	៦៨,៨	៦៨,៦	៦៩,០	៦៣,៣	៦៥,១	៦១,៧
មេម៉ាយ/ពោះម៉ាយ	៤,២	១,៤	៦,៧	៦,៣	២,៣	១០,០
លែងលះ	១,៩	១,០	២,៧	៣,៥	២,១	៤,៧
ទំនាស់រស់នៅផ្សេងគ្នា	០,១	០,១	០,១	០,៣	០,២	០,៤

រូបភាព ៣.៦.១ បង្ហាញថាមិនដែលរៀបការ ឬនៅលីវក្នុងក្រុមអាយុ ១៥-១៩ ឆ្នាំ ប្រុសមាន ៩៧,៧ និងស្រីមានចំនួន ៩១,៥ ភាគរយ។ ក្នុងក្រុមអាយុ ៣០-៣៤ អត្រាមិនដែលរៀបការ ឬនៅលីវ មនុស្សប្រុសទាំងនោះបានថយចុះមកត្រឹម ២៣,៤ ភាគរយខ្ពស់ជាងច្រើនជាងស្ត្រីប្រមាណ ៩ ភាគរយ។ ប្រជាជនដែលមានអាយុលើស ៥០ឆ្នាំ មិនទាន់រៀបការ គឺភាគច្រើនមិនរៀបការទេក្នុងជីវិតរបស់ពួកគាត់។ ការកើនឡើងមិនដែលរៀបការ ឬនៅលីវ ដោយការកើនឡើងនៃស្ត្រីដែលមិនទាន់រៀបការច្រើនជាងបុរស។ ទោះជាយ៉ាងណាក៏ដោយអត្រារបស់ស្ត្រីមិនដែលរៀបការ ឬនៅលីវមានការធ្លាក់ចុះខ្លាំងប្រហែលអាយុ ២០ ឆ្នាំ។ អត្រារបស់បុរសមិនដែលរៀបការ ឬនៅលីវ មានអត្រាខ្ពស់ជាងអត្រារបស់ស្ត្រីមិនដែលរៀបការ ឬនៅលីវនៅគ្រប់ក្រុមអាយុក្រោម ៣០ឆ្នាំ។ ចាប់ពីក្រុមអាយុ ៣០-៣៤ឆ្នាំទៅ អត្រាទាបស្រាប់នៃបុរសនៅលីវគ្រប់ក្រុមអាយុគឺទាបជាងអត្រារបស់ស្ត្រីទាំងឆ្នាំ២០១៩ និងឆ្នាំ២០២៤។

រូបភាព ៣.៦.១. ភាគរយមិនទាន់រៀបការអាយុ១៥ ឆ្នាំឡើងតាមភេទ ២០១៩-២០២៤



ជាទូទៅអាយុក្នុងការរៀបអាពាហ៍ពិពាហ៍របស់បុរសខ្ពស់។ បុរសស្ទើរតែទាំងអស់បានរៀបការយ៉ាងតិចម្តងក្នុងមួយជីវិតរបស់ពួកគេ។ ក្រុមអាយុ ៤៥-៤៩ បុរសបច្ចុប្បន្នរៀបការមាន ៩៥ភាគរយ ខណៈដែលស្ត្រីស្ថិតក្នុងក្រុមអាយុដូចគ្នាមាន ៧៩,៣ភាគរយ។ ស្រីភាគច្រើនរៀបការមុនបុរស។ នៅក្នុងក្រុមអាយុ ៣៥-៣៩ ដែលជាចំណុចរបត់មួយដែលបង្ហាញនូវភាពខុសគ្នារវាងសមាមាត្ររបស់បុរស និងស្ត្រី។ បន្ទាប់ពីក្រុមអាយុនេះទៅបុរសមានសមាមាត្រខ្ពស់ជាងស្ត្រីដែលបានរៀបការ ហើយគំលាតនៃសមាមាត្រនេះកាន់តែធំទៅៗ។

រូបភាព ៣.៦.២. ភាគរយបច្ចុប្បន្នរៀបការអាយុ១៥ ឆ្នាំឡើងតាមភេទ ២០១៩-២០២៤



អត្រាមេម៉ាយ ឬពោះម៉ាយ គឺមានលក្ខណៈវិជ្ជមានទៅនឹងអាយុ ជាមួយនឹងអត្រាកើនឡើងបន្តិចបន្តួចនៃការកើនឡើងអាយុ។ អត្រាមេម៉ាយ ឬពោះម៉ាយ លែងលះគ្នា និងរស់នៅផ្សេងគ្នា មានប្រមាណ ១០,៧ ភាគរយក្នុងចំណោមប្រជាជនពេញវ័យអាយុ ១៥ ឆ្នាំឡើង បុរសមាន ៥,៣ ភាគរយធៀបនឹងស្ត្រី ១៥,៩ ភាគរយ។ គ្រប់ក្រុមអាយុទាំងអស់ភាគរយស្ត្រីមេម៉ាយ លែងលះគ្នា និងរស់នៅផ្សេងគ្នា មានអត្រាខ្ពស់ជាងបុរស ជាពិសេស ក្រុមអាយុកាន់តែខ្ពស់ (រូបភាព ៣.៦.៣)។ មូលហេតុនៃការខុសគ្នានេះជាទូទៅ គឺបណ្ដាលមកពីមរណភាពខ្ពស់របស់បុរសនៅក្នុងរបបខ្មែរក្រហម រួមផ្សំជាមួយនឹងការរៀបការជាលើកទីពីររបស់បុរសពោះម៉ាយ។

រូបភាព ៣.៦.៣. ភាគរយមេម៉ាយ ឬពោះម៉ាយ លែងលះគ្នា និងរស់នៅផ្សេងគ្នាអាយុ១៥ ឆ្នាំឡើងតាមភេទ ២០១៩-២០២៤



៣.៧.អាយុរៀបការលើកដំបូង

សំណួរដោយផ្ទាល់ពីអាយុរៀបការលើកដំបូងត្រូវបានស្រង់នៅក្នុងអង្កេតនេះផងដែរ ប៉ុន្តែសំណួររំលឹកឡើងវិញពីអាពាហ៍ពិពាហ៍មានការខុសគ្នាខ្លាំង ធៀបនឹងការគណនាដោយប្រយោល ហេតុនេះអាយុរៀបការមធ្យមត្រូវបានប៉ាន់ស្មានដោយវិធីសាស្ត្រប្រយោលពីទិន្នន័យស្ថានភាពអាពាហ៍ពិពាហ៍តាមអាយុ។ អាយុមធ្យមរៀបការលើកទីមួយ SMAM (ត្រូវបានអភិវឌ្ឍដោយ John Hajnal ១៩៥៣) គឺប៉ាន់ស្មាននៃចំនួនមធ្យមអាយុបានរស់នៅតាមក្រុមនៃស្ត្រី ឬបុរសមុនពេលពួកគេរៀបការជាលើកដំបូង ។

SMAM គឺត្រូវបានទាញយកពីសមាមាត្ររបស់ប្រជាជនមិនទាន់រៀបការតាមក្រុមអាយុនីមួយៗបន្តគ្នា។ ការសន្មត់ជាចាំបាច់ដែលទាក់ទងនៅក្នុងការគណនានេះ គឺប្តូរនៅក្នុងសមាមាត្រមិនទាន់រៀបការពីអាយុ X ទៅ X+១ គឺវាស់វែងនៃសមាមាត្រកំណើតក្រុមដែលបានរៀបការនៅអាយុ X។ វិធីសាស្ត្រនេះអាចគណនាជាមធ្យមអាយុរៀបការរបស់ប្រជាជន (បុរស ឬស្ត្រី) អាយុ ១៥ ឆ្នាំឡើង មុនពេលពួកគេដល់អាយុ ៥០ ឆ្នាំ។ ផ្សេងពីនេះទៀតវាផ្តល់ការប៉ាន់ស្មានចំនួនមធ្យម នៃអាយុមិនដែលបានរៀបការដោយបានរៀបការមុនពេលអាយុ ៥០ឆ្នាំ។

ជាមធ្យមអាយុមធ្យមរៀបការលើកទីមួយ SMAM នៅកម្ពុជាត្រូវបានគណនាឃើញ ២៧,៥ សម្រាប់បុរស និង ២៤,២ សម្រាប់ស្ត្រី ផ្អែកលើការបែងចែកអាយុក្នុងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ ប្រជាជនមិនដែលរៀបការនៅកម្ពុជា អាយុមធ្យមរៀបការលើកទីមួយ SMAM តែងតែមានបុរសខ្ពស់ជាងស្ត្រី។ សមាមាត្រខ្ពស់នៃស្ត្រីរៀបការវ័យក្មេងបើប្រៀបធៀបនឹងបុរសដែលមានអាយុដូចគ្នា គឺជាការបង្ហាញបន្ថែមទៀតដែលជាទូទៅស្ត្រី រៀបការនៅវ័យក្មេងជាងបុរស (តារាង ៣.៧.១)។ បើប្រៀបធៀបនឹងឆ្នាំ ២០១៩ អាយុជាមធ្យមនៃអាពាហ៍ពិពាហ៍បានកើនឡើង ០,៥ ឆ្នាំនិង ០,២ ឆ្នាំសម្រាប់បុរសនិងស្ត្រីតាមលំដាប់។

សង្កេតឃើញថាមានភាពខុសគ្នាទីប្រជុំជន-ជនបទ ទាក់ទងនឹង SMAM។ សម្រាប់ទាំងបុរស និងស្ត្រី SMAM នៅតំបន់ទីប្រជុំជន គឺខ្ពស់ជាងតំបន់ជនបទ។ នៅឆ្នាំ២០១៩ SMAM ក្នុងចំណោមបុរសនៅទីប្រជុំជនមានអត្រាខ្ពស់ជាងបុរសនៅជនបទត្រឹម ២,១ ឆ្នាំ។ ភាពខុសគ្នានេះក្នុងចំណោមស្ត្រីនៅទីប្រជុំជននិងស្ត្រីនៅជនបទមានរយៈពេល ៣,១ឆ្នាំ។ បុរសនៅទីប្រជុំជនហាក់ដូចជាមាននិន្នាការរៀបការនៅពេលក្រោយបុរសនៅជនបទ។

តារាង ៣.៧.១. អាយុមធ្យមរៀបការលើកទីមួយតាមភេទ និងតំបន់កម្ពុជា ២០១៩ និង ២០២៤

តំបន់	ឆ្នាំ ២០១៩			ឆ្នាំ ២០២៤		
	ប្រុស	ស្រី	គម្លាតអាយុរៀបការដំបូង	ប្រុស	ស្រី	គម្លាតអាយុរៀបការដំបូង
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
សរុប	២៧,០	២៤,០	៣,០	២៧,៥	២៤,២	៣,៣
ទីប្រជុំជន	២៨,១	២៥,០	៣,១	២៨,៤	២៥,២	៣,២
ជនបទ	២៦,០	២២,៧	៣,៣	២៦,៩	២៣,៤	៣,៥

៣.៨.អាយុរៀបការ

សមាមាត្រអាយុរៀបការរបស់យុវវ័យក្នុងចំណោមប្រុស និងស្រី គឺស្ទើរតែដូចគ្នាទាំង ២០១៩ និង ២០២៤ នៅថ្នាក់ជាតិ។ ទោះយ៉ាងណាក៏ដោយនៅក្នុងតំបន់ទីប្រជុំជន មានការធ្លាក់ចុះតិចតួចដែលត្រូវគ្នានឹងការកើនឡើងបន្តិចបន្តួចនៅតាមតំបន់ជនបទ។ សម្រាប់ទាំងបុរស និងស្ត្រី សមាមាត្ររៀបការជាមួយយុវវ័យដែលមានអាយុពី ១៥-១៩ ឆ្នាំនៅតំបន់ជនបទ គឺខ្ពស់ជាងតំបន់ទីប្រជុំជន (តារាង ៣.៨.១)។ សមាមាត្រដែលបានរៀបការក្នុងចំណោមស្ត្រីដែលមានអាយុពី ២០-២៤ ឆ្នាំនៅតំបន់ជនបទ គឺមានភាគរយខ្ពស់ជាងតំបន់ទីប្រជុំជនដូចគ្នា។

តារាង ៣.៨.១. អាយុមធ្យមរៀបការដំបូង សមាមាត្រធ្លាប់រៀបការ តាមភេទ អាយុ និងតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤

តំបន់	ប្រុស				ស្រី				គម្លាតអាយុរៀបការដំបូង
	អាយុមធ្យមរៀបការដំបូង	ភាគរយអ្នកធ្លាប់រៀបការ			អាយុមធ្យមរៀបការដំបូង)	ភាគរយអ្នកធ្លាប់រៀបការ			
		១៥–១៩	២០-២៤	៤៥-៤៩		១៥–១៩	២០-២៤	៤៥-៤៩	
២០១៩									
សរុប	២៧,០	១,៨	២៦,២	៩៣,៣	២៤,០	៨,២	៤៨,១	៨៤,៨	៣,០
ទីប្រជុំជន	២៨,១	១,៥	២២,០	៨៨,៩	២៥,០	៦,៣	៣៩,៦	៨០,៧	៣,១
ជនបទ	២៦,០	២,០	២៩,៧	៩៦,១	២២,៧	៩,៥	៥៥,៣	៨៧,៣	៣,៣
២០២៤									
សរុប	២៧,៥	២,៣	២៥,៨	៩៨,៧	២៤,២	៩,០	៤៤,២	៩៤,០	៣,៣
ទីប្រជុំជន	២៨,៤	១,៩	២១,៧	៩៧,៧	២៥,២	៦,២	៣៦,៨	៩៣,៤	៣,២
ជនបទ	២៦,៩	២,៥	២៨,៦	៩៩,៣	២៣,៤	១០,៩	៤៩,៤	៩៤,៤	៣,៥

អក្ខរកម្ម និងការអប់រំ ៤

៤.១. សេចក្តីផ្តើម

ការអប់រំមានសារៈសំខាន់សម្រាប់បុគ្គល និងជាធនធានសម្រាប់អភិវឌ្ឍជាតិ។ ការអប់រំជាសិទ្ធពីកំណើតរបស់បុគ្គលម្នាក់ៗ។ ការអប់រំជាការអភិវឌ្ឍសមត្ថភាពមនុស្សជាតិ ដើម្បីលប់បំបាត់វិសមភាពក្នុងសេដ្ឋកិច្ចសង្គម វប្បធម៌ គ្រួសារ/បុគ្គល ច្បាប់ នយោបាយ និងចិត្តវិទ្យា។ ការអប់រំគឺជាប្រទីបនាំផ្លូវ ដើម្បីឱ្យមានសមត្ថភាពស្វែងរកការងារធ្វើ និងមានសិទ្ធិក្នុងការសម្រេចចិត្តបានត្រឹមត្រូវ។ ការអប់រំមានឥទ្ធិពលលើចរិតលក្ខណៈប្រជាសាស្ត្រទាក់ទងនឹងការរៀបការ លទ្ធភាពបង្កើតកូន មរណភាព ការផ្លាស់ប្តូរលំនៅដ្ឋាន និងទាំងការចូលរួមក្នុងកម្លាំងពលកម្ម។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ការអប់រំមានទំនាក់ទំនងជាអវិជ្ជមានរវាងកម្រិតអប់រំរបស់ស្ត្រី និងលទ្ធភាពបង្កើតកូន។ អាយុស្ត្រីនៅពេលរៀបការត្រូវបានទទួលឥទ្ធិពលពីការទទួលបានកម្រិតចូលសិក្សាអប់រំ។ មរណភាពទារក គឺនៅតែជាអថេរទទួលឥទ្ធពលពីស្ថានភាពអប់រំរបស់ម្តាយ។ ជាទូទៅការទទួលបានការសិក្សាអប់រំ បានប្រាប់ឱ្យដឹងអំពីគុណភាពនៃប្រជាជនចេះអក្សរហើយមានសារៈសំខាន់ណាស់ក្នុងការប្រេតិបត្តិកម្មវិធីអភិវឌ្ឍន៍ និងគោលនយោបាយប្រជាជន។

ការអប់រំជាអាទិភាពយ៉ាងសំខាន់ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ ពួកគេស្ថិតក្នុងស្ថានភាពដប្រសើរមួយ ដើម្បីបង្កើតការងារដោយខ្លួនឯង និងសម្រាប់អ្នកដទៃ ដើម្បីទទួលបានការងារជាផ្លូវការផងដែរ។ ការអប់រំត្រូវចាប់ផ្តើមជាចាំបាច់ក្នុងការអភិវឌ្ឍចក្ខុវិស័យនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ២០១៩-២០២៣។ ដើម្បីកំណត់កម្រិតសិក្សា អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានសួរសំណួរអំពីការចូលរៀននៅសាលា និងកម្រិតថ្នាក់ខ្ពស់ចុងក្រោយដែលបានសិក្សា។ សំណួរនេះត្រូវបានសួរគ្រប់មនុស្សទាំងអស់ដែលមានអាយុ ៦ ឆ្នាំឡើង។ សំណួរអំពីអក្ខរភាព និងការសិក្សា ជាផ្នែកសំខាន់មួយនៃកម្រងអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤។

ដើម្បីទទួលបានទិន្នន័យពេញលេញអំពីការសិក្សាពេញម៉ោងរបស់ប្រជាជន សំណួរចំនួន ៦ ត្រូវបានសួរនៅក្នុងអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ដើម្បីប្រមូលព័ត៌មានអំពីអក្ខរភាព និងការសិក្សាពេញម៉ោង។ សំណួរទាក់ទងនឹងអក្ខរភាពភាសាខ្មែរ អក្ខរភាពភាសាដទៃទៀត ការចូលរៀនសាលាថ្នាក់កំពុងរៀនបច្ចុប្បន្ន ថ្នាក់បានបញ្ចប់ខ្ពស់បំផុត និងមុខវិជ្ជាចម្បងដែលបានសិក្សា។ មុខជំនាញសិក្សាថ្មីអំពីសញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈ ត្រូវបានដាក់បញ្ចូលក្នុងអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ មានបំណងដើម្បីបំពេញតម្រូវការចាំបាច់របស់ប្រព័ន្ធអប់រំផ្នែកវិជ្ជាជីវៈ។

និយមន័យអក្ខរភាព គឺជាសមត្ថភាពក្នុងការអាន និងសរសេរ ដោយមានការយល់ដឹងជាភាសាណាមួយ។ អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ព័ត៌មានអំពីអក្ខរភាពជាភាសាខ្មែរ និងអក្ខរភាពភាសាផ្សេងទៀតត្រូវបានប្រមូល។ មនុស្សម្នាក់ដែលមិនអាចអាន និងសរសេរពាក្យសាមញ្ញត្រូវបាន

គេចាត់ទុកថាមិនចេះអក្សរ។ មនុស្សត្រូវបានចាត់ទុកថាមិនចេះអក្សរផងដែរ ប្រសិនបើមនុស្សនោះមានសមត្ថភាពអាន សរសេរតែឈ្មោះ ឬលេខផ្ទាល់ខ្លួន ក៏ដូចជាមនុស្សដែលចេះអានតែមិនចេះសរសេរ ឬក៏ផ្ទុយមកវិញ។ មនុស្សម្នាក់ដែលចេះអាន និងសរសេរ ប៉ុន្តែនៅពេលអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ គាត់មិនអាចអាន និងសរសេរបានទៀតទេ ដោយសារមានបញ្ហារាងកាយ ឬជំងឺ ត្រូវចាត់ទុកថាជាមនុស្សចេះអក្សរផងដែរ។ ឧទាហរណ៍ មនុស្សវ័យចំណាស់ដែលចេះអាន និងសរសេរ ប៉ុន្តែមិនអាចអនុវត្តសកម្មភាពទាំងនេះបានទៀត ដោយសារបញ្ហាភ្នែកខ្សោយ។ ជនពិការដែលអាចអាន និងសរសេរតាមរយៈមធ្យោបាយណាមួយ ដូចជាប្រព័ន្ធប្រៃលសម្រាប់អ្នកពិការភ្នែក ត្រូវបានចាត់ទុកថាជាអ្នកចេះអក្សរ។

៤.២. កម្រិតអក្ខរភាព

លទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បង្ហាញថាអត្រាអក្ខរភាពសម្រាប់ភាសាខ្មែរក្នុងចំណោមប្រជាជនកម្ពុជាអាយុ ៧ ឆ្នាំឡើង បានកើនឡើងពី ៨០,៤ ភាគរយនៅឆ្នាំ២០១៩ ទៅ ៨៥,៦ នៅឆ្នាំ២០២៤។ ក្នុងរយៈពេល ៥ឆ្នាំ អត្រាអក្ខរភាពរបស់ស្ត្រីបានកើនឡើងប្រមាណជា ៤ ភាគរយ បើធៀបទៅនឹងការកើនឡើងប្រមាណ ៦ ភាគរយ សម្រាប់បុរស។ ទោះជាយ៉ាងណាក៏ដោយគំលាតអក្ខរភាពរវាងបុរស និងស្ត្រីនៅមានខ្ពស់នៅជនបទ(៨៦,៨ ភាគរយ សម្រាប់បុរស និង ៧៩,៤ ភាគរយសម្រាប់ស្ត្រី)។ ជាទូទៅវិសមភាពរវាងបុរស និងស្ត្រីលើការអប់រំជាមូលដ្ឋាន គឺជាបញ្ហាចម្បងមួយដែលរាជរដ្ឋាភិបាលគួរតែពិចារណាជាបន្ទាន់។

រូប ៤.២.១.ភាគរយអក្ខរភាពភាសាខ្មែរអាយុ ៧ឆ្នាំឡើង តាមភេទ កម្ពុជា ឆ្នាំ២០១៩-២០២៤



អត្រាអក្ខរភាពតែភាសាខ្មែរ នៅទីប្រជុំជនខ្ពស់ជាងនៅជនបទ ដោយសារកម្រិតនៃការអភិវឌ្ឍរវាងតំបន់ទាំងពីរ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះអត្រាអក្ខរភាពភាសាខ្មែរនៅតែមានគម្លាតខុសគ្នារវាងទីប្រជុំជន និងជនបទដែរ ។

តារាង ៤.២.១. ភាគរយអក្ខរភាពអាយុ ៧ ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤

តំបន់	ប្រជាជនអាយុ ៧ ឆ្នាំឡើង	ចំនួនអក្ខរភាព		ភាគរយអក្ខរភាព	
		ភាសាណាមួយ	តែភាសាខ្មែរ	ភាសាណាមួយ	តែភាសាខ្មែរ
(១)	(២)	(៣)	(៤)	(៥)	(៧)
២០២៤					
សរុប	១៥.១៩០.៤៩២	១៣.១៦៤.០២០	១២.៩៩៧.០៥៣	៨៦,៧	៨៥,៦
ប្រុស	៧.៤១៧.០៣៣	៦.៦៥១.៥៣២	៦.៥៧៥.៩១៣	៨៩,៧	៨៨,៧
ស្រី	៧.៧៧៣.៤៥៩	៦.៥១២.៤៨៨	៦.៤២១.១៤១	៨៣,៨	៨២,៦
ទីប្រជុំជន	៦.៣៤៤.៣៩៩	៥.៧២១.១៤២	៥.៦៥៣.៩២៩	៩០,២	៨៩,១
ប្រុស	៣.០៧៧.១៤៥	២.៨៤១.៣៣៣	២.៨០៨.៨២០	៩២,៣	៩១,៣
ស្រី	៣.២៦៧.២៥៥	២.៨៧៩.៨០៨	២.៨៤៥.១០៩	៨៨,១	៨៧,១
ជនបទ	៨.៨៤៦.០៩៣	៧.៤៤២.៨៧៨	៧.៣៤៣.១២៥	៨៤,១	៨៣,០
ប្រុស	៤.៣៣៩.៨៨៨	៣.៨១០.១៩៩	៣.៧៦៧.០៩៣	៨៧,៨	៨៦,៨
ស្រី	៤.៥០៦.២០៤	៣.៦៣២.៦៧៩	៣.៥៧៦.០៣២	៨០,៦	៧៩,៤
២០១៩					
សរុប	១៣.៤៨៧.៥៩១	១១.៩៤០.៨៣១	១០.៨៤៩.៩៩៩	៨៨,៥	៨០,៤
ប្រុស	៦.៥១០.៧០៥	៥.៩២៨.៧៦២	៥.៣៥០.៤៩៤	៩១,១	៨២,២
ស្រី	៦.៩៧៦.៨៨៦	៦.០១២.០៦៩	៥.៤៩៩.៥០៥	៨៦,២	៧៨,៨
ទីប្រជុំជន	៥.៤០៦.៥៦៧	៥.០៤៣.៤៥៦	៤.៣២២.៩៣១	៩៣,៣	៨០,០
ប្រុស	២.៦១៨.៧៧២	២.៤៨៥.៩០៦	២.០៩៧.៥៥១	៩៤,៩	៨០,១
ស្រី	២.៧៨៧.៧៩៥	២.៥៥៧.៥៥០	២.២២៥.៣៨០	៩១,៧	៧៩,៨
ជនបទ	៨.០៨១.០២៤	៦.៨៩៧.៣៧៥	៦.៥២៧.០៦៨	៨៥,៤	៨០,៨
ប្រុស	៣.៨៩១.៩៣៣	៣.៤៤២.៨៥៦	៣.២៥២.៩៤៣	៨៨,៥	៨៣,៦
ស្រី	៤.១៨៩.០៩១	៣.៤៥៤.៥១៩	៣.២៧៤.១២៥	៨២,៥	៧៨,២

កំណត់សម្គាល់ ៖ ការគណនាអត្រាអក្ខភាពមិនរាប់បញ្ចូលអក្ខភាពមិនបានរាយការណ៍។

ដូចដែលបានរៀបរាប់ខាងលើ អត្រាអក្ខរភាពជាភាសាខ្មែរបានកើនឡើង ប៉ុន្តែអត្រាអក្ខរភាពជាភាសាមួយក្នុងចំណោមប្រជាជនដែលមានអាយុចាប់ពី ៧ ឆ្នាំឡើងទៅ បានថយចុះបន្តិចពី ៨៨,៥ ភាគរយក្នុងឆ្នាំ ២០១៩ មកត្រឹម ៨៦,៧ ភាគរយក្នុងឆ្នាំ២០២៤។ តារាង ៤.២.២ បង្ហាញពីការបែងចែកអត្រាអក្ខរភាពតាមភាសា ភេទ និងលំនៅដ្ឋានកម្ពុជា ២០១៩-២០២៤។ តារាង ៤.២.២ មិនបានបង្ហាញពីអត្រាអក្ខរភាពធ្លាក់ចុះនោះទេ ប៉ុន្តែនៅកម្ពុជា ប្រជាជនមិនចេះតែភាសាខ្មែរមួយមុខនោះទេតែពួកគេចេះភាសាផ្សេងទៀតផងដែរ។ អត្រាអក្ខរភាពជាភាសាខ្មែរ-អង់គ្លេសបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ពី ៥,១ ភាគរយក្នុងឆ្នាំ២០១៩ ដល់ ១១,៧ ភាគរយក្នុងឆ្នាំ២០២៤។ និន្នាការនេះកើតមានឡើងទាំងនៅទីប្រជុំជន និងជនបទ។ ទម្រង់ស្រដៀងគ្នានេះដែរ សម្រាប់សមាមាត្រចេះអាន និងសរសេរភាសាខ្មែរ និងភាសាផ្សេងក្រៅពីភាសាអង់គ្លេសបានកើនឡើងពី ២,៥ ភាគរយក្នុងឆ្នាំ២០១៩ ដល់ ៤,៨ ភាគរយនៅឆ្នាំ២០២៤។

តារាង ៤.២.២. ភាគរយអក្ខរកម្មក្រៅពីភាសាខ្មែរ អាយុ ៧ឆ្នាំឡើង តាមភេទ និងទីប្រជុំជន ជនបទ កម្ពុជា ឆ្នាំ២០១៩-២០២៤

តំបន់	ប្រជាជនអាយុ ៧ ឆ្នាំ ឡើងចេះភាសាណាមួយ	ភាសា			
		ខ្មែរ	ខ្មែរ-អង់គ្លេស	ភាសាខ្មែរ និងភាសាផ្សេងទៀត លើកលែងភាសាអង់គ្លេស	ភាសាណាមួយក្រៅពីភាសាខ្មែរ
(១)	(២)	(៣)	(៤)	(៥)	(៦)
២០២៤					
សរុប	**១៣.១៦៤.០២០**	**៨២,២**	**១១,៧**	៤,៨	១,៣
ប្រុស	៦.៦៥១.៥៣២	៨១,៦	១២,៣	៤,៩	១,១
ស្រី	៦.៥១២.៤៨៨	៨២,៨	១១,២	៤,៦	១,៤
ទីប្រជុំជន	**៥.៧២១.១៤២**	**៧៦,៤**	**១៦,៨**	៥,៦	១,២
ប្រុស	២.៨៤១.៣៣៣	៧៥,៣	១៨,២	៥,៤	១,១
ស្រី	២.៨៧៩.៨០៨	៧៧,៥	១៥,៤	៥,៩	១,២
ជនបទ	**៧.៤៤២.៨៧៨**	**៨៦,៧**	**៧,៩**	៤,១	១,៣
ប្រុស	៣.៨១០.១៩៩	៨៦,៤	៧,៩	៤,៦	១,១
ស្រី	៣.៦៣២.៦៧៩	៨៧,០	៧,៨	៣,៧	១,៦
២០១៩					
សរុប	**១១.៩៤០.៨៣១**	**៩០,៩**	**៥,១**	**២,៥**	**១,៥**
ប្រុស	៥.៩២៨.៧៦២	៩០,២	៥,៥	២,៧	១,៥
ស្រី	៦.០១២.០៦៩	៩១,៥	៤,៦	២,៤	១,៥
ទីប្រជុំជន	**៥.០៤៣.៤៥៦**	**៨៥,៧**	**៩,២**	**២,៨**	**២,៣**
ប្រុស	២.៤៨៥.៩០៦	៨៤,៤	១០,១	៣,០	២,៥
ស្រី	២.៥៥៧.៥៥០	៨៧,០	៨,២	២,៧	២,១
ជនបទ	**៦.៨៩៧.៣៧៥**	**៩៤,៦**	**២,១**	**២,៣**	**០,៩**
ប្រុស	៣.៤៤២.៨៥៦	៩៤,៥	២,២	២,៥	០,៨
ស្រី	៣.៤៥៤.៥១៩	៩៤,៨	២,០	២,២	១,០

កំណត់សម្គាល់ ៖ ការគណនាអត្រាអក្ខភាពមិនរាប់បញ្ចូលអក្ខភាពមិនបានរាយការណ៍។

៤.៣. អត្រាអក្ខរភាពមនុស្សពេញវ័យ

អត្រាអក្ខរកម្មសម្រាប់មនុស្សពេញវ័យ ឬអត្រាអក្ខរកម្មនៃប្រជាជនដែលមានអាយុ ១៥ ឆ្នាំឡើង បានកើនឡើងនៅកម្រិតជាតិក្នុងកំឡុងឆ្នាំ២០១៩-២០២៤ (តារាង ៤.៣.១)។ នៅជនបទអត្រាអក្ខរភាពមនុស្សពេញវ័យហាក់នៅទ្រឹង (៨៣,៨ ភាគរយក្នុងឆ្នាំ២០១៩ និង ៨២,៩ភាគរយនៅឆ្នាំ២០២៤) ស្ត្រីមានភាគរយទាបជាងបុរសនៅចន្លោះឆ្នាំ២០១៩-២០២៤។ នៅទីប្រជុំជនអត្រាអក្ខរភាពមនុស្សពេញវ័យមាន ៩៣,៣ ភាគរយខ្ពស់រួចទៅហើយក្នុងឆ្នាំ២០១៩ ប៉ុន្តែធ្លាក់ចុះតិចតួចមកត្រឹម ៩០,០ ភាគរយនៅឆ្នាំ២០២៤។

ទិន្នន័យអត្រាអក្ខរភាពនៅ កម្ពុជា មានភាពប្រសើរឡើងខ្លាំងក្នុងកន្លះទសវត្សរ៍ចុងក្រោយនេះ។ ក្រុមអាយុកាន់តែក្មេង អត្រាអក្ខរភាពកាន់តែខ្ពស់ហើយគម្លាតរវាងបុរស និងស្ត្រីកាន់តិច។ អត្រាអក្ខរភាពរបស់បុរស និងស្ត្រី គឺមានភាពប្រហាក់ប្រហែលគ្នាក្នុងក្រុមអាយុអាយុក្មេង ប៉ុន្តែមានភាពខុសគ្នាខ្លាំងនៅក្នុងក្រុមអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ។ ទិន្នន័យនេះឆ្លុះបញ្ចាំងពីគុណវិបត្តិនៃការអប់រំកាលពីអតីតកាលដែលស្ត្រី

មិនត្រូវបានយកចិត្តទុកដាក់ដូចបុរស និងបង្ហាញពីរបៀបដែលបង្ហាញពីភាពខុសគ្នាតាមភេទនេះ បានកាត់បន្ថយក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។

តារាង ៤.៣.១. ស្ថានភាពអក្ខរភាពប្រជាជនពេញវ័យ (ចេះអាន និងសរសេរ) អាយុ ១៥ ឆ្នាំឡើង តាមទីប្រជុំជន ជនបទ និងភេទ កម្ពុជា ឆ្នាំ២០១៩-២០២៤

ក្រុមអាយុ	២០១៩			២០២៤		
	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
សរុប						
១៥ +	៨៧,៧	៩០,៩	៨៤,៨	៨៥,៩	៨៩,៧	៨២,៤
១៥-១៩	៩៥,៩	៩៥,៥	៩៦,៣	៩៦,៥	៩៥,៧	៩៧,២
២០-២៤	៩៣,៤	៩៣,២	៩៣,៥	៩៤,៧	៩៣,៦	៩៥,៨
២៥-៥៩	៨៧,៥	៩០,៣	៨៤,៨	៨៦,១	៨៩,៣	៨២,៩
៦០ +	៧៥,២	៨៥,៩	៦៨,១	៦៨,៤	៨១,២	៥៩,៦
ទីប្រជុំជន						
១៥ +	៩៣,៣	៩៥,៣	៩១,៤	៩០,០	៩២,៨	៨៧,៤
១៥-១៩	៩៧,៦	៩៧,៣	៩៧,៩	៩៧,៣	៩៦,៥	៩៨,១
២០-២៤	៩៦,៧	៩៦,៥	៩៦,៨	៩៦,០	៩៥,១	៩៦,៩
២៥-៥៩	៩៣,៦	៩៥,៣	៩២,០	៩០,៦	៩២,៧	៨៨,៦
៦០ +	៨២,៦	៩០,៨	៧៧,០	៧៥,៥	៨៧,១	៦៧,៨
ជនបទ						
១៥ +	៨៣,៨	៨៧,៨	៨០,២	៨២,៩	៨៧,៥	៧៨,៧
១៥-១៩	៩៤,៨	៩៤,៤	៩៥,៣	៩៥,៩	៩៥,១	៩៦,៦
២០-២៤	៩០,៦	៩០,៥	៩០,៧	៩៣,៨	៩២,៧	៩៥,០
២៥-៥៩	៨៣,០	៨៦,៦	៧៩,៦	៨២,៦	៨៦,៨	៧៨,៥
៦០ +	៧១,០	៨៣,១	៦៣,១	៦៣,៥	៧៧,៣	៥៣,៩

៤.៤. កម្រិតសិក្សាអប់រំ

កម្រិតអប់រំគឺជាសូចនាករសំខាន់មួយនៃគុណភាពប្រជាជន។ អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ កម្រិតថ្នាក់បញ្ចប់ពេញលេញខ្ពស់បំផុតសម្រាប់អ្នកដែលធ្លាប់បានចូលរៀននៅសាលា ឬគ្រឹះស្ថានសិក្សា ហើយបច្ចុប្បន្នកំពុងរៀនត្រូវបានប្រមូលក្នុងអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤។ របាយការណ៍វិភាគនេះបានរៀបចំសម្រាប់អ្នកដែលបានរាយការណ៍ពីកម្រិតថ្នាក់ដែលបានបញ្ចប់ពេញលេញ។ កម្រិតថ្នាក់ដែលបានបញ្ចប់ពេញលេញត្រូវបានចំណាត់លេខកូដដូចជា ១= មិនបានបញ្ចប់ថ្នាក់ណាមួយ ២= មិនបានបញ្ចប់បឋមសិក្សា (ថ្នាក់ទី១ ដល់ថ្នាក់ទី៥) ៣= បានបញ្ចប់បឋមសិក្សា (ថ្នាក់ទី៦ ដល់ថ្នាក់ទី៨) ៤= មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៩ ដល់ ១៣ មានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ) ៥= បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញប័ត្រមធ្យមសិក្សាបឋមភូមិ មានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ លេខកូដ ១៤ ដល់ ១៨) ៦= ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត លេខកូដ ១៩ ដល់ ២១) និង៧ = ផ្សេងទៀត ២២។

រូប ៤.៤.១. ភាគរយប្រជាជនអក្ខភាពអាយុ៧ឆ្នាំឡើង តាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ២០១៩-២០២៤



នៅកម្រិតថ្នាក់ជាតិអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ (តារាង ៤.៤.១) បង្ហាញថា ២៩,៥ ភាគរយនៃប្រជាជនអាយុ ៧ ឆ្នាំឡើង ដែលធ្លាប់បានចូលរៀននៅសាលា ឬគ្រឹះស្ថានសិក្សាណាមួយបានបញ្ចប់ថ្នាក់បឋមសិក្សាមាន ១៩,១ ភាគរយ បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ មាន ៧,៥ ភាគរយ បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) មាន៤,០ ភាគរយ។ មានប្រមាណជា ៣៨,៦ ភាគរយនៃប្រជាជនកម្ពុជាអាយុ ៧ ឆ្នាំឡើង មិនបានបញ្ចប់ថ្នាក់បឋមសិក្សាខណៈដែលមានសមាមាត្រតិច (១,២ ភាគរយ) នៃប្រជាជនអក្ខរភាពមិនបានបញ្ចប់ថ្នាក់ណាមួយ។ ប្រៀបធៀបនឹងជំរឿនឆ្នាំ២០១៩ និន្នាការនេះមានការកែលម្អផ្នែកកម្រិតសិក្សាអប់រំក្នុងចំណោមប្រជាជនអក្ខរភាព។ លទ្ធផលបង្ហាញថាសមាមាត្របានធ្លាក់ចុះបន្តិចបន្តួចក្នុងចំណោមប្រជាជនមិនបានបញ្ចប់ថ្នាក់បឋមសិក្សាពី ៤២,៣ ភាគរយ នៅឆ្នាំ២០១៩ មក ៣៨,៦ ភាគរយ នៅឆ្នាំ២០២៤។ ចំណែកឯ អ្នកបានបញ្ចប់មធ្យមសិក្សាទុតិយភូមិ សញ្ញាបត្រទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈបានកើនឡើងពី ២,៩ ភាគរយ ទៅ ៧,៥ ភាគរយ និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) បានកើនពី ២,៨ ភាគរយទៅ ៤,០ ភាគរយ ផងដែរ។

តារាង ៤.៤.១. កម្រិតសិក្សាអប់រំប្រជាជនអាយុ ៧ឆ្នាំឡើង តាមក្រុមអាយុ ភេទ តំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤

តំបន់	ចំនួនអក្ខរភាព	ភាគរយតាមកម្រិតសិក្សាអប់រំ						
		សរុប	គ្មាន	មិនបានបញ្ចប់បឋមសិក្សា	បញ្ចប់បឋមសិក្សា	បញ្ចប់មធ្យមសិក្សាបឋមភូមិ	សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ/សញ្ញាបត្រ	ក្រោយមធ្យមសិក្សា
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)
				២០២៤				
ទាំងពីរភេទ	១២.៩៤៩.៧៣៧	**១០០**	**១,២**	**៣៨,៦**	**២៩,៥**	**១៩,១**	**៧,៥**	**៤,០**
៧-១៤	២.២៧៩.២៦២	១០០	៥,៤	៧៣,៤	២០,៦	០,៥	០,០	០,០
១៥-១៩	១.៥១២.៥៣៧	១០០	០,៤	១៣,៥	៤០,០	៣៩,២	៦,៨	០,៣
២០-២៤	១.៤០១.៣៧៨	១០០	០,១	១៥,៥	៣០,៣	២៦,១	២៣,៤	៤,៥
២៥-៥៩	៦.៦២៦.០៦០	១០០	០,២	៣២,៩	៣១,៧	២០,៥	៧,៩	៦,៦
៦០ +	១.១៣០.៥០០	១០០	១,១	៦៤,០	១៩,៨	១២,៥	១,៧	០,៨
ប្រុស	៦.៥៦៩.០៣៦	**១០០**	**១,៣**	**៣៦,៦**	**២៩,៤**	**១៩,៩**	**៧,៩**	**៤,៩**
៧-១៤	១.១៦៦.៥៥១	១០០	៦,៣	៧៤,៧	១៨,៦	០,៥	០,០	០,០
១៥-១៩	៧៤៣.៥០៦	១០០	០,៤	១៥,៨	៤១,៩	៣៥,៦	៦,១	០,២
២០-២៤	៦៩៤.៦៧៩	១០០	០,០	១៧,៦	៣០,២	២៥,៣	២២,៩	៤,០
២៥-៥៩	៣.៤០១.៥៦១	១០០	០,២	២៨,៩	៣១,១	២២,៦	៨,៩	៨,៣
៦០ +	៥៦២.៧៣៨	១០០	០,៧	៥៥,២	២៤,០	១៦,៥	២,៣	១,២
ស្រី	៦.៣៨០.៧០១	**១០០**	**១,១**	**៤០,៧**	**២៩,៧**	**១៨,៣**	**៧,២**	**៣,១**
៧-១៤	១.១១២.៧១២	១០០	៤,៤	៧២,១	២២,៨	០,៦	០,០	០,០
១៥-១៩	៧៦៩.០៣១	១០០	០,៣	១១,២	៣៨,០	៤២,៧	៧,៤	០,៣
២០-២៤	៧០៦.៦៩៨	១០០	០,១	១៣,៦	៣០,៤	២៦,៩	២៣,៩	៥,០
២៥-៥៩	៣.២២៤.៤៩៨	១០០	០,៣	៣៧,២	៣២,៣	១៨,៤	៧,០	៤,៩
៦០ +	៥៦៧.៧៦២	១០០	១,៤	៧២,៨	១៥,៦	៨,៦	១,២	០,៤
ទីប្រជុំជន	៥.៦៣០.៩៤៨	**១០០**	**១,៣**	**៣២,៦**	**២៨,៧**	**២១,៣**	**៩,៩**	**៦,៣**
៧-១៤	៩០៤.២៤១	១០០	៥,៧	៧៣,២	២០,៨	០,៤	០,០	០,០
១៥-១៩	៦២៥.១៣៦	១០០	០,៧	១០,០	៣៧,៥	៤២,៦	៨,៨	០,៥
២០-២៤	៥៧៣.៣២៦	១០០	០,១	១១,៨	២៥,៦	២៦,៥	២៩,២	៦,៨
២៥-៥៩	៣.០១៥.១៣៧	១០០	០,៣	២៤,៩	៣០,៧	២៣,៣	១០,៦	១០,១
៦០ +	៥១៣.១០៨	១០០	១,១	៥៦,៩	២៣,៣	១៤,៥	២,៦	១,៦
ប្រុស	៧.៣១៨.៧៨៩	**១០០**	**១,១**	**៤៣,៣**	**៣០,២**	**១៧,៤**	**៥,៨**	**២,២**
៧-១៤	១.៣៧៥.០២២	១០០	៥,២	៧៣,៦	២០,៥	០,៦	០,០	០,០
១៥-១៩	៨៨៧.៤០១	១០០	០,១	១៦,០	៤១,៧	៣៦,៨	៥,៣	០,១
២០-២៤	៨២៨.០៥២	១០០	០,០	១៨,២	៣៣,៦	២៥,៩	១៩,៤	៣,០
២៥-៥៩	៣.៦១០.៩២៣	១០០	០,១	៣៩,៧	៣២,៥	១៨,២	៥,៧	៣,៧
៦០ +	៦១៧.៣៩២	១០០	១,០	៦៩,៩	១៦,៩	១០,៩	១,១	០,២
ស្រី	១២.៩៤៩.៧៣៣	**១០០**	**១,២**	**៣៨,៦**	**២៩,៥**	**១៩,១**	**៧,៥**	**៤,០**
៧-១៤	២.២៧៩.២៦២	១០០	៥,៤	៧៣,៤	២០,៦	០,៥	០,០	០,០
១៥-១៩	១.៥១២.៥៣៧	១០០	០,៤	១៣,៥	៤០,០	៣៩,២	៦,៨	០,៣
២០-២៤	១.៤០១.៣៧៨	១០០	០,១	១៥,៥	៣០,៣	២៦,១	២៣,៤	៤,៥
២៥-៥៩	៦.៦២៦.០៦០	១០០	០,២	៣២,៩	៣១,៧	២០,៥	៧,៩	៦,៦
៦០ +	១.១៣០.៥០០	១០០	១,១	៦៤,០	១៩,៨	១២,៥	១,៧	០,៨
ជនបទ	៦.៥៦៩.០៣៦	**១០០**	**១,៣**	**៣៦,៦**	**២៩,៤**	**១៩,៩**	**៧,៩**	**៤,៩**
៧-១៤	១.១៦៦.៥៥១	១០០	៦,៣	៧៤,៧	១៨,៦	០,៥	០,០	០,០
១៥-១៩	៧៤៣.៥០៦	១០០	០,៤	១៥,៨	៤១,៩	៣៥,៦	៦,១	០,២
២០-២៤	៦៩៤.៦៧៩	១០០	០,០	១៧,៦	៣០,២	២៥,៣	២២,៩	៤,០
២៥-៥៩	៣.៤០១.៥៦១	១០០	០,២	២៨,៩	៣១,១	២២,៦	៨,៩	៨,៣

តំបន់	ចំនួនអត្ថភាព	ភាគរយតាមកម្រិតសិក្សាអប់រំ						
		សរុប	គ្មាន	មិនបានបញ្ចប់បឋមសិក្សា	បញ្ចប់បឋមសិក្សា	បញ្ចប់មធ្យមសិក្សាបឋមភូមិ	សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ/សញ្ញាបត្រ	ក្រោយមធ្យមសិក្សា
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)
៦០ +	៥៦២.៧៣៨	១០០	០,៧	៥៥,២	២៤,០	១៦,៥	២,៣	១,២
ប្រុស	**៦.៣៨០.៧០១**	**១០០**	**១,១**	**៤០,៧**	**២៩,៧**	**១៨,៣**	**៧,២**	**៣,១**
៧-១៤	១.១១២.៧១២	១០០	៤,៤	៧២,១	២២,៨	០,៦	០,០	០,០
១៥-១៩	៧៦៩.០៣១	១០០	០,៣	១១,២	៣៨,០	៤២,៧	៧,៤	០,៣
២០-២៤	៧០៦.៦៩៨	១០០	០,១	១៣,៦	៣០,៤	២៦,៩	២៣,៩	៥,០
២៥-៥៩	៣.២២៤.៤៩៨	១០០	០,៣	៣៧,២	៣២,៣	១៨,៤	៧,០	៤,៩
៦០ +	៥៦៧.៧៦២	១០០	១,៤	៧២,៨	១៥,៦	៨,៦	១,២	០,៤
ស្រី	**៥.៦៣០.៩៤៨**	**១០០**	**១,៣**	**៣២,៦**	**២៨,៧**	**២១,៣**	**៩,៩**	**៦,៣**
៧-១៤	៩០៤.២៤១	១០០	៥,៧	៧៣,២	២០,៨	០,៤	០,០	០,០
១៥-១៩	៦២៥.១៣៦	១០០	០,៧	១០,០	៣៧,៥	៤២,៦	៨,៨	០,៥
២០-២៤	៥៧៣.៣២៦	១០០	០,១	១១,៨	២៥,៦	២៦,៥	២៩,២	៦,៨
២៥-៥៩	៣.០១៥.១៣៧	១០០	០,៣	២៤,៩	៣០,៧	២៣,៣	១០,៦	១០,១
៦០ +	៥១៣.១០៨	១០០	១,១	៥៦,៩	២៣,៣	១៤,៥	២,៦	១,៦
២០១៩								
ទាំងពីរភេទ	**១១.៤៨៨.៩៣៤**	**១០០**	**១,១**	**៤២,៣**	**២៩,១**	**២១,៨**	**២,៩**	**២,៨**
៧-១៤	២.២៧២.២០៦	១០០	៥,៥	៧៤,៣	១៩,៦	០,៦	០,០	០,០
១៥-១៩	១.៣២៤.៨៣៩	១០០	០,២	១៦,៧	៤០,៨	៣៩,៩	២,៤	០,០
២០-២៤	១.១៣៧.៩០៩	១០០	០,១	២២,០	៣១,៩	៣៣,៥	៩,៣	៣,២
២៥-៥៩	៥.៨០៥.៧៦៧	១០០	០,០	៣៧,៥	៣០,៥	២៤,០	៣,១	៤,៨
៦០ +	៩៤៨.២១៣	១០០	០,០	៥៥,២	២៣,៨	១៩,០	១,០	០,៩
ប្រុស	**៥.៧៣២.១៨៧**	**១០០**	**១,២**	**៣៩,៧**	**២៩,១**	**២៣,៤**	**៣,២**	**៣,៥**
៧-១៤	១.១៥៤.៤៤៤	១០០	៥,៨	៧៥,៣	១៨,៣	០,៦	០,០	០,០
១៥-១៩	៦៦៤.០៧០	១០០	០,២	១៨,៥	៤១,២	៣៧,៩	២,១	០,០
២០-២៤	៥៥២.៨៩៤	១០០	០,១	២២,២	៣០,៨	៣៤,៣	៩,៧	៣,០
២៥-៥៩	២.៩១៦.៦៦៩	១០០	០,០	៣២,៥	៣០,៥	២៧,៣	៣,៧	៦,០
៦០ +	៤៤៤.១១០	១០០	០,០	៤៧,៩	២៧,៧	២១,៥	១,៤	១,៤
ស្រី	**៥.៧៥៦.៧៤៧**	**១០០**	**១,១**	**៤៤,៨**	**២៩,២**	**២០,២**	**២,៥**	**២,២**
៧-១៤	១.១១៧.៧៦២	១០០	៥,២	៧៣,២	២០,៨	០,៧	០,០	០,០
១៥-១៩	៦៦០.៧៦៩	១០០	០,២	១៤,៨	៤០,៥	៤១,៨	២,៧	០,០
២០-២៤	៥៨៥.០១៥	១០០	០,០	២១,៨	៣៣,០	៣២,៨	៨,៩	៣,៥
២៥-៥៩	២.៨៨៩.០៩៨	១០០	០,០	៤២,៥	៣០,៦	២០,៨	២,៥	៣,៦
៦០ +	៥០៤.១០៣	១០០	០,០	៦១,៧	២០,៣	១៦,៨	០,៧	០,៥
ទីប្រជុំជន	**៤.៨៧៩.៧១២**	**១០០**	**០,៩**	**៣២,៩**	**២៨,០**	**២៧,៧**	**៤,៨**	**៥,៧**
៧-១៤	៧៧៤.៨៩៨	១០០	៥,២	៧២,៧	២១,២	០,៨	០,០	០,០
១៥-១៩	៥២៤.៣២៣	១០០	០,២	១៣,៣	៣៦,៣	៤៥,៦	៤,៦	០,០
២០-២៤	៥៣៨.៧២១	១០០	០,០	១៦,៣	២៧,៥	៣៦,៥	១៤,២	៥,៥
២៥-៥៩	២.៦៥៧.៦២២	១០០	០,០	២៦,៦	២៨,៩	៣០,៨	៤,៧	៩,០
៦០ +	៣៨៤.១៤៤	១០០	០,០	៤៦,៣	២៥,៥	២៤,០	២,០	២,១
ប្រុស	**២.៤១៤.៦០៩**	**១០០**	**០,៩**	**៣០,០**	**២៧,១**	**២៩,៧**	**៥,៣**	**៦,៩**

តំបន់	ចំនួនអត្តភាព	ភាគរយតាមកម្រិតសិក្សាអប់រំ						
		សរុប	គ្មាន	មិនបាន បញ្ចប់ បឋមសិក្សា	បញ្ចប់បឋម សិក្សា	បញ្ចប់មធ្យម សិក្សា បឋមភូមិ	សញ្ញាបត្រ មធ្យមសិក្សា ទុតិយភូមិ/ សញ្ញាបត្រ	ក្រោយមធ្យម សិក្សា
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)
៧-១៤	៣៩៤.០១៦	១០០	៥,៥	៧៣,៦	២០,២	០,៧	០,០	០,០
១៥-១៩	២៥៨.៨៥៦	១០០	០,២	១៤,៤	៣៦,៧	៤៤,៤	៤,៣	០,០
២០-២៤	២៥៨.៧០៧	១០០	០,១	១៦,១	២៦,០	៣៧,៧	១៥,១	៥,១
២៥-៥៩	១.៣២៨.៧៨៨	១០០	០,០	២១,៧	២៧,៤	៣៤,២	៥,៦	១១,១
៦០ +	១៧៤.២៤២	១០០	០,០	៣៨,៩	២៨,០	២៦,៩	២,៨	៣,៤
ស្រី	**២.៤៦៥.១០៣**	**១០០**	**០,៨**	**៣៥,៧**	**២៨,៩**	**២៥,៨**	**៤,៣**	**៤,៤**
៧-១៤	៣៨០.៨៨២	១០០	៥,០	៧១,៨	២២,៣	០,៩	០,០	០,០
១៥-១៩	២៦៥.៤៧១	១០០	០,២	១២,២	៣៥,៨	៤៦,៨	៥,០	០,០
២០-២៤	២៨០.០១៤	១០០	០,០	១៦,៥	២៨,៨	៣៥,៤	១៣,៣	៥,៩
២៥-៥៩	១.៣២៨.៨៣៤	១០០	០,០	៣១,៥	៣០,៣	២៧,៤	៣,៩	៦,៨
៦០ +	២០៩.៩០២	១០០	០,០	៥២,៥	២៣,៥	២១,៦	១,៤	១,០
ជនបទ	**៦.៦០៩.២២២**	**១០០**	**១,៣**	**៤៩,២**	**២៩,៩**	**១៧,៣**	**១,៤**	**០,៨**
៧-១៤	១.៤៩៧.៣០៨	១០០	៥,៧	៧៥,១	១៨,៧	០,៥	០,០	០,០
១៥-១៩	៨០០.៥១២	១០០	០,៣	១៨,៩	៤៣,៨	៣៦,១	០,៩	០,០
២០-២៤	៥៩៩.១៨៨	១០០	០,១	២៧,១	៣៦,០	៣០,៨	៤,៩	១,១
២៥-៥៩	៣.១៤៨.១៤៥	១០០	០,០	៤៦,៧	៣១,៩	១៨,៣	១,៧	១,៤
៦០ +	៥៦៤.០៦៩	១០០	០,០	៦១,៣	២២,៦	១៥,៦	០,៤	០,១
ប្រុស	**៣.៣១៧.៥៧៨**	**១០០**	**១,៤**	**៤៦,៨**	**៣០,៥**	**១៨,៨**	**១,៦**	**១,០**
៧-១៤	៧៦០.៤២៨	១០០	៦,០	៧៦,១	១៧,៤	០,៥	០,០	០,០
១៥-១៩	៤០៥.២១៤	១០០	០,៣	២១,២	៤៤,០	៣៣,៨	០,៨	០,០
២០-២៤	២៩៤.១៨៧	១០០	០,១	២៧,៦	៣៥,០	៣១,៣	៤,៩	១,០
២៥-៥៩	១.៥៨៧.៨៨១	១០០	០,០	៤១,៦	៣៣,០	២១,៥	២,១	១,៨
៦០ +	២៦៩.៨៦៨	១០០	០,០	៥៣,៦	២៧,៦	១៨,០	០,៦	០,១
ស្រី	**៣.២៩១.៦៤៤**	**១០០**	**១,២**	**៥១,៧**	**២៩,៤**	**១៥,៩**	**១,២**	**០,៦**
៧-១៤	៧៣៦.៨៨០	១០០	៥,៤	៧៣,៩	២០,១	០,៦	០,០	០,០
១៥-១៩	៣៩៥.២៩៨	១០០	០,២	១៦,៦	៤៣,៦	៣៨,៥	១,១	០,០
២០-២៤	៣០៥.០០១	១០០	០,០	២៦,៦	៣៦,៩	៣០,៤	៤,៩	១,២
២៥-៥៩	១.៥៦០.២៦៤	១០០	០,០	៥១,៨	៣០,៨	១៥,១	១,៤	០,៩
៦០ +	២៩៤.២០១	១០០	០,០	៦៨,៣	១៨,១	១៣,៤	០,២	០,០

កំណត់សម្គាល់ ៖ មិនរាប់បញ្ចូលកម្រិតសិក្សាមិនបានរាយការណ៍ និងកម្រិតសិក្សាផ្សេងទៀត។

តារាង ៤.៤.១ បានបង្ហាញថា ៧៣,៤ ភាគរយនៃប្រជាជនក្នុងអាយុ ៧-១៤ ឆ្នាំ មិនបានបញ្ចប់ថ្នាក់បឋមសិក្សា និង ២០,៦ ភាគរយ បានបញ្ចប់កម្រិតបឋមសិក្សា។ ក្រុមអាយុ ១៥-១៩ ឆ្នាំ ជាទូទៅគួរបញ្ចប់ថ្នាក់កម្រិតបឋមសិក្សា ពិនិត្យឃើញថា ១៣,៥ ភាគរយ ក្នុងក្រុមអាយុ ១៥-១៩ ឆ្នាំ នៅមិនទាន់បានបញ្ចប់កម្រិតបឋមសិក្សា អាចដោយមូលហេតុចុះឈ្មោះចូលរៀនយឺត ឬត្រួតថ្នាក់ ឬបានឈប់រៀន។ ក្នុងក្រុមអាយុ

១៥-១៩ ឆ្នាំដែល មាន ៤០,០ ភាគរយ និង ៣៩,២ ភាគរយ បានបញ្ចប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ តាមលំដាប់រៀង។

គួរកត់សម្គាល់ផងដែរ ចំណោមប្រជាជនក្នុងក្រុមអាយុ ២០-២៤ ឆ្នាំ មិនបានបញ្ចប់កម្រិតបឋមសិក្សា មាន ១៥,៥ ភាគរយ បានបញ្ចប់កម្រិតបឋមសិក្សា ៣០,៣ ភាគរយ បញ្ចប់មធ្យមសិក្សាបឋមភូមិ ២៦,១ ភាគរយ បញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) ២៣,៤ ភាគរយ និង ៤,៥ ភាគរយ បានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត។ ប្រជាជនអក្ខរភាពអាយុ ២៥ឆ្នាំឡើង សង្កេតឃើញថាសមាមាត្រភាគរយច្រើនលើសលប់ដែលមិនបានបញ្ចប់បឋមសិក្សា។ បើប្រៀបធៀបទៅឆ្នាំ២០១៩ កម្រិតសិក្សានៃប្រជាជនមានលក្ខណៈប្រសើរឡើងច្រើន ដោយសារការថយចុះគួរឲ្យកត់សម្គាល់ក្នុងកម្រិតមិនបានចូលរៀន និងបានបញ្ចប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ/សញ្ញាបត្រនិងក្រោយមធ្យមសិក្សា ក្នុងនោះសមាមាត្រប្រុសមានអត្រាខ្ពស់ជាងស្ត្រី ។

ជំនាញសញ្ញាបត្រច្ចេកទេស និងវិជ្ជាជីវៈ

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤នេះ កម្រិតសិក្សាអប់រំបានប្រមូលទិន្នន័យពីកម្រិតជំនាញសញ្ញាបត្រច្ចេកទេស និងវិជ្ជាជីវៈដែលជាការផ្តល់អនុសាសន៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ។ គុណវុឌ្ឍដែលអាចចូលរៀនកម្រិតសញ្ញាបត្រច្ចេកទេស និងវិជ្ជាជីវៈកម្រិត១ (បានបញ្ចប់មធ្យមសិក្សាបឋមភូមិថ្នាក់ទី៩) ឬបានបញ្ចប់វគ្គស្ពានចម្លងបន្តជំនាញសមមូល ឬមានវិញ្ញាបនបត្រវិជ្ជាជីវៈ រួមទាំងបទពិសោធន៍ការងាររយៈពេល១ឆ្នាំ យ៉ាងតិច(តែត្រូវឆ្លងកាត់ធ្វើតេស្ត)។ សញ្ញាបត្រច្ចេកទេស និងវិជ្ជាជីវៈកម្រិត២ គុណវុឌ្ឍដែលអាចបានចូលរៀនសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត២បាន ខណៈដែលមានសញ្ញាបត្រច្ចេកទេស និងវិជ្ជាជីវៈកម្រិត១។ សញ្ញាបត្រច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ លុះត្រាតែមានសញ្ញាបត្រច្ចេកទេសនិងវិជ្ជាជីវៈកម្រិត២ ឬមានគុណវុឌ្ឍសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត២ រួមទាំងបទពិសោធន៍ការងាររយៈពេល២ឆ្នាំលើមុខវិជ្ជាដដែលអនុញ្ញាតិឱ្យធ្វើតេស្តចូលរៀន។ តាមរយៈការប្រមូលទិន្នន័យអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានបង្ហាញថា ក្នុងចំណោមប្រជាជនអាយុ១៧ឆ្នាំឡើងកំពុងនៅរៀនសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត១ កម្រិត២ និងកម្រិត៣ មានប្រហាក់ប្រហែល (១.៦៥៧នាក់ ១.០១២នាក់ និង៤.៨៦០នាក់) តាមលំដាប់រៀង។

ដោយឡែកអ្នកបានបញ្ចប់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត ១, ២ និងកម្រិត៣ ក្នុងចំណោមប្រជាជនអាយុ១៧ឆ្នាំឡើង មានប្រហាក់ប្រហែល (៩.២៦០នាក់ ៦.៩៣៧នាក់ និង ២៩.២៥០នាក់) តាមលំដាប់រៀងគ្នា។

៤.៥. អត្រាចូលរៀន

សំណួរអំពីការចូលរៀនសាលា ឬគ្រឹះស្ថានសិក្សាត្រូវបានស្រង់គ្រប់មនុស្សទាំងអស់ទាំងអ្នកចេះអាន និងសរសេរ និងអនក្ខរជន។ សំណួរនេះត្រូវបានរាប់បញ្ចូលផងដែរ សម្រាប់កុមារអាយុក្រោម ៦ ឆ្នាំ។ ចម្លើយសំណួរនេះត្រូវបានចាត់ថ្នាក់ជា (i) "មិនដែលចូលសាលា ឬគ្រឹះស្ថានសិក្សាសោះ" សំដៅលើមនុស្សទាំងឡាយណាដែលមិនធ្លាប់បានចូលរៀនក្នុងសាលា ឬគ្រឹះស្ថានសិក្សាណាមួយពេញលេញ (ii) "បច្ចុប្បន្ន" សំដៅលើមនុស្សទាំងឡាយណាដែលកំពុងរៀននៅសាលា ឬគ្រឹះស្ថានសិក្សាណាមួយក្នុងពេលធ្វើអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ និង (iii) "អតីតកាល" សំដៅលើមនុស្សទាំងឡាយណាដែលធ្លាប់បានរៀននៅសាលា ឬគ្រឹះស្ថានសិក្សាណាមួយកាលពីអតីតកាល។

ផ្អែកលើសំណួរអង្កេតចន្លោះជំរឿន ប្រជាជនជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ តើបច្ចុប្បន្នអ្នកធ្លាប់ចូលសាលា ឬគ្រឹះស្ថានសិក្សាណាមួយដែរឬទេ? លទ្ធផលបានបង្ហាញថា អត្រាប្រជាជនបច្ចុប្បន្នកំពុងនៅរៀនមានការធ្លាក់ចុះ តាមការកើនឡើងនៃក្រុមអាយុ ដោយ ៩៤,១ ភាគរយ ធ្លាក់មក ៨០,៨ ភាគរយ សម្រាប់កុមារក្នុងក្រុមអាយុ ៦-១១ ឆ្នាំ និង ១២-១៤ឆ្នាំ តាមលំដាប់រៀង។

រូប ៤.៥.១. អត្រាចូលរៀនសាលា ឬគ្រឹះស្ថានអប់រំណាមួយ អាយុ ៦ ឆ្នាំឡើង កម្ពុជា ឆ្នាំ២០២៤



សមាមាត្របច្ចុប្បន្នកំពុងរៀន មានទាបជាងទៅតាមក្រុមអាយុផ្សេងៗទៀត បើធៀបនឹងក្រុមអាយុវ័យក្មេងអាយុ ៦-១១ឆ្នាំ នៅឆ្នាំ២០២៤ (តារាង ៤.៥.១) អត្រាបច្ចុប្បន្នកំពុងនៅរៀនបានចាប់ផ្តើមធ្លាក់ចុះយ៉ាងខ្លាំងបន្ទាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ នេះអាចនិយាយបានថា នៅកម្រិតអាយុនេះមានសិស្សកាន់តែ

ច្រើនបានបោះបង់ការសិក្សា ឬឈប់រៀន។ មានទាបជាងមួយភាគបួននៃក្រុមអាយុ ២៥ ឆ្នាំ មិនដែលចូលសាលាឬគ្រឹះស្ថានសិក្សាណាមួយសោះ។ អត្រាបច្ចុប្បន្ននៅរៀនតាមសាលា ឬគ្រឹះស្ថានសិក្សារបស់ក្មេងស្រីមានអត្រាខ្ពស់ជាងក្មេងប្រុសបន្តិច គ្រប់ក្រុមអាយុទាំងអស់ នេះជាសញ្ញាដ៏ល្អលើយេនឌ័រផ្នែកសិក្សាអប់រំ។ តារាង ៤.៥.១ បានបង្ហាញផងដែរ បច្ចុប្បន្នកុមារនៅតំបន់ទីប្រជុំជនច្រើនជាងកុមារនៅតំបន់ជនបទ ដែលបច្ចុប្បន្នកំពុងរៀននៅស្ទើរគ្រប់ក្រុមអាយុទាំងអស់។

តារាង ៤.៥.១. ស្ថានភាពចូលរៀនក្រុមអាយុ ៦ ឆ្នាំឡើង តាមភេទ អាយុ តំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤

តំបន់	ស្ថានភាពចូលរៀន ២០១៩			ស្ថានភាពចូលរៀន ២០២៤		
	មិនដែលសោះ	បច្ចុប្បន្ន	អតីតកាល	មិនដែលសោះ	បច្ចុប្បន្ន	អតីតកាល
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
ទាំងពីរភេទ	**១២,៥**	**២៥,៨**	**៦១,៦**	**៩,៩**	**២៤,២**	**៦៥,៩**
០៦ - ១១	៨,០	៩០,៦	១,៤	៤,៩	៩៤,១	១,០
១២ - ១៤	២,៨	៩១,៦	៥,៦	១,៥	៩០,៨	៧,៧
១៥ - ១៧	៤,៥	៦៧,៦	២៧,៩	២,១	៦២,៥	៣៥,៥
១៨ - ២៤	៧,៥	២០,៧	៧១,៨	៣,០	២២,១	៧៤,៩
២៥+	១៦,៥	០,៧	៨២,៧	១៤,១	០,៤	៨៥,៥
ប្រុស	**៩,៩**	**២៧,២**	**៦២,៩**	**៧,១**	**២៥,០**	**៦៧,៨**
០៦ - ១១	៨,៤	៩០,១	១,៥	៥,៣	៩៣,៣	១,៤
១២ - ១៤	៣,២	៩០,៤	៦,៤	១,៩	៨៨,៦	៩,៤
១៥ - ១៧	៥,០	៦៦,២	២៨,៨	២,៥	៦០,៥	៣៧,០
១៨ - ២៤	៧,៨	២២,១	៧០,១	៣,៥	២១,៥	៧៥,០
២៥+	១២,២	០,៨	៨៦,៩	៩,៤	០,៦	៩០,០
ស្រី	**១៤,៩**	**២៤,៦**	**៦០,៥**	**១២,៦**	**២៣,៤**	**៦៤,០**
០៦ - ១១	៧,៦	៩១,១	១,៣	៤,៣	៩៥,០	០,៧
១២ - ១៤	២,៤	៩២,៨	៤,៧	១,០	៩៣,០	៦,០
១៥ - ១៧	៣,៩	៦៩,១	២៧,០	១,៦	៦៤,៤	៣៤,០
១៨ - ២៤	៧,៤	១៩,៣	៧៣,៣	២,៥	២២,៧	៧៤,៨
២៥+	២០,៤	០,៦	៧៩,០	១៨,៣	០,២	៨១,៤
ទីប្រជុំជន	**៧,៩**	**២៤,០**	**៦៨,១**	**៧,០**	**២៤,៥**	**៦៨,៤**
០៦ - ១១	៦,៨	៩១,៥	១,៧	៥,១	៩៣,៨	១,១
១២ - ១៤	២,២	៩២,១	៥,៧	១,២	៩២,៤	៦,៤
១៥ - ១៧	៣,១	៦៩,១	២៧,៨	១,៥	៦៩,៦	២៨,៨
១៨ - ២៤	៤,៤	២៥,៣	៧០,៣	២,១	២៨,២	៦៩,៧
២៥+	៩,៩	១,០	៨៩,០	៩,៥	០,៥	៩០,០
ជនបទ	**១៥,៦**	**២៧,១**	**៥៧,៣**	**១២,០**	**២៤,០**	**៦៤,០**
០៦ - ១១	៨,៧	៩០,២	១,២	៤,៧	៩៤,៣	១,០
១២ - ១៤	៣,១	៩១,៤	៥,៥	១,៧	៨៩,៧	៨,៦
១៥ - ១៧	៥,៣	៦៦,៧	២៨,០	២,៤	៥៧,៤	៤០,២
១៨ - ២៤	១០,១	១៧,០	៧២,៩	៣,៦	១៨,០	៧៨,៤
២៥+	២១,២	០,៥	៧៨,៣	១៧,៥	០,៤	៨២,១

កម្លាំងពលកម្ម និងការងារ ៥

៥.១. សេចក្តីផ្តើម

ការវិភាគសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជា តាមរយៈជំរឿន និងអង្កេត បានឆ្លុះបញ្ចាំងអំពីពលកម្ម និងការងាររបស់ប្រជាជន ដែលជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយសេដ្ឋកិច្ច និងផែនការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។ គោលនយោបាយ និងផែនការទាំងនេះ បានចូលរួមចំណែកក្នុងការពង្រឹងគុណភាពធនធានមនុស្ស ការបង្កើនផលិតភាព និងការកាត់បន្ថយភាពមិនមានការងារធ្វើ និងមានការងារធ្វើមិនគ្រប់គ្រាន់។

គោលបំណងសំខាន់ក្នុងការស្រង់ទិន្នន័យនៃសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជា គឺដើម្បីធ្វើចំណាត់ថ្នាក់ប្រជាជនជាពីរប្រភេទផ្សេងគ្នា ដូចជា សកម្មជនសេដ្ឋកិច្ច (សម្រាប់អ្នកដែលស្ថិតក្នុងកម្លាំងពលកម្ម) និងអសកម្មជនសេដ្ឋកិច្ច (សម្រាប់អ្នកដែលមិនស្ថិតក្នុងកម្លាំងពលកម្ម)។ សំណួរដែលពាក់ព័ន្ធមួយចំនួន ដែលត្រូវបានធ្វើការសាកសួរបន្ថែម គឺដើម្បីធ្វើការបែងចែកប្រភេទមុខរបរសំខាន់ៗរបស់អ្នកដែលមានការងារធ្វើ ទៅតាមក្រុមអាជីព សកម្មភាពការងារ វិស័យការងារ និងស្ថានភាពការងារ។

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានស្រង់ព័ត៌មានពីគ្រប់គ្រួសារសម្ភាសន៍គំរូ សម្រាប់គ្រប់សមាជិកដែលមានអាយុ ៥ឆ្នាំឡើង ស្តីពីស្ថានភាពការងារ។ បង្គោលសំណួរដែលត្រូវបានសួរពាក់ព័ន្ធនឹងស្ថានភាពការងារនៅក្នុងតារាងសំណួរទម្រង់ ខ នៃកម្រងសំណួរគ្រួសារផ្នែក២ រួមមាន៖

- បង្គោល ៦ កត់ត្រាអំពីសកម្មភាពសេដ្ឋកិច្ចចម្បង
- បង្គោល ៧ កត់ត្រាអំពីប្រភេទអាជីព និងមុខរបរ
- បង្គោល ៨ កត់ត្រាអំពីស្ថានភាពការងារ និងឋានៈការងារ
- បង្គោល ៩ កត់ត្រាអំពីសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យ (កសិកម្ម ឧស្សាហកម្ម ឬសេវាកម្ម)
- បង្គោល ១០ កត់ត្រាអំពីផ្នែកនៃការងារ។

អង្កេតចន្លោះជំរឿនឆ្នាំ ២០២៤ ត្រូវបានចាប់ផ្តើមធ្វើឡើងនៅម៉ោង ០០ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ សម្រាប់ការប្រមូលទិន្នន័យ។ សំណួរសម្រាប់កម្លាំងពលកម្ម និងការងារ គឺត្រូវបានគិតក្នុងរយៈពេល ១២ខែ មុនថ្ងៃចាប់ផ្តើមធ្វើអង្កេតដែលជារយៈពេលយោង។ អ្នកដែលត្រូវបានកំណត់ថាមានការងារធ្វើ គឺអ្នកទាំងឡាយណាដែលបានធ្វើការយ៉ាងតិចប្រាំមួយខែ (១៨៣ថ្ងៃ) ឬលើសប្រាំមួយខែ ក្នុងរយៈពេលយោង។ កម្លាំងពលកម្មរាប់បញ្ចូលទាំងអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ។

អ្នកមានការងារធ្វើរួមមាន (១) អ្នកដែលស្ថិតក្នុងការងារដែលមានប្រាក់ខែក្នុងស្ថាប័នសាធារណៈ ឬឯកជន (២) អ្នកដែលធ្វើការ ដើម្បីប្រាក់ឈ្នួល បៀវត្សរ៍ កម្រៃ ឬចំណូលគ្រួសារជាសាច់ប្រាក់ ឬជារបស់ក្នុងរយៈពេលយោង (៣) អ្នកដែលមិនបានធ្វើការណាមួយ ដើម្បីប្រាក់ឈ្នួល ឬកម្រៃ ក្នុងរយៈពេលយោង ប៉ុន្តែគាត់មានការងារដែលអាចត្រឡប់ទៅធ្វើការវិញ ឧទាហរណ៍ អ្នកធ្វើការតាមរដូវ ដូចជា កសិករ ឬអ្នកនេសាទ អ្នកឈប់សម្រាកពីការងារដោយសារជំងឺ ឬសម្រាកគ្មានប្រាក់ឈ្នួល អ្នកមិនអាចធ្វើការបានដោយសារបាតុកម្ម ឬបិទទ្វារគ្រឹះស្ថានដែលគាត់កំពុងធ្វើការ និង (៤) អ្នកដែលធ្វើអាជីវកម្មផ្ទាល់ខ្លួន ដូចជាដំណើរការហាងលក់ទំនិញផ្ទាល់ខ្លួន លក់ចំណីហូបចុក វេជ្ជបណ្ឌិត មេធាវី។ល។

អសកម្មជនសេដ្ឋកិច្ច រួមមាន (១) អ្នកដែលធ្វើការងារផ្ទះ សំដៅដល់អ្នកដែលបានចំណាយពេលច្រើនក្នុងរយៈពេលយោងធ្វើកិច្ចការផ្ទះ (២) សិស្ស និងនិស្សិត ដែលបានចំណាយពេលភាគច្រើនលើការសិក្សានៅសាលារៀន ឬគ្រឹះស្ថានសិក្សា (៣) អ្នកដែលនៅក្នុងបន្ទុក សំដៅលើទារក និងកុមារដែលមិនទាន់បានចូលរៀននៅសាលា អ្នកពិការអចិន្ត្រៃយ៍ដែលមិនអាចធ្វើការងារបាន អ្នកជម្ងឺដែលមិនអាចធ្វើការងារបាន ឬចាស់ជរា។ អ្នកដែលមិនអាចចាត់ថ្នាក់ប្រភេទអសកម្មជនសេដ្ឋកិច្ចណាមួយ និងជាអ្នកនៅក្នុងបន្ទុកផ្សេងទៀត ក៏ត្រូវបានរាប់បញ្ចូលផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកទាំងនេះបានស្វែងរកការងារធ្វើ ឬអាចធ្វើការងារបាន អ្នកនោះត្រូវបានចាត់ទុកជាអ្នកគ្មានការងារធ្វើ និងមិនមែនជាអ្នកក្នុងបន្ទុកទៀតឡើយ។ (៤) អ្នកដែលមានអចលនទ្រព្យសម្រាប់ជួល អ្នកចូលនិវត្តន៍ ឬទទួលកម្រៃជើងសារដទៃទៀត អ្នកដែលបានចូលនិវត្តន៍ពីការងារ ហើយភាគច្រើនអ្នកទាំងនេះមិនបានធ្វើការងារផ្សេងទេ (ឧទាហរណ៍ អ្នកដែលភាគច្រើនមិននៅក្នុងប្រភេទការងារណាមួយ ឬចូលរួមក្នុងការងារប្រភេទផ្សេងទៀត ដូចជាការដាំដុះ អាជីវកម្ម ឬពាណិជ្ជកម្ម ជាដើម)។ នេះក៏បានរួមបញ្ចូល អ្នកដែលរស់ក្នុងវិស័យកសិកម្ម ឬមិនមែនកសិកម្ម អ្នកជួល ឬទទួលភាគលាភ អ្នកដែលមិនមានការងារ ឬគ្មានការងារធ្វើ និងអ្នកផ្សេងទៀតដែលអាចរស់ និងចាយវាយប្រចាំថ្ងៃបាន ដោយមិនពុំចាំបាច់មានការងារធ្វើ និង (៥) ប្រភេទដទៃទៀត រួមមានអ្នកដែលភាគច្រើនមិនមែនជាសកម្មជនសេដ្ឋកិច្ច និងអ្នកដែលមិនចាត់បញ្ចូលក្នុងចំណាត់ថ្នាក់ទាំងបួនប្រភេទខាងលើ។

៥.២. សកម្មជនសេដ្ឋកិច្ច និងកំលាំងពលកម្ម

អត្រាចូលរួមកម្លាំងពលកម្ម (LFPR) ត្រូវបានកំណត់ដោយចំនួនមនុស្សដែលស្ថិតក្នុងកម្លាំងពលកម្ម (រួមមានអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ) ចែកនឹងចំនួនមនុស្សសរុបដែលមានចរិតលក្ខណៈដូចគ្នា ហើយគុណនឹង១០០។ វាត្រូវបានបែងចែកតាមក្រុមអាយុ ភេទ និងតំបន់។

សកម្មជនសេដ្ឋកិច្ចជាផ្នែកមួយនៃកម្លាំងពលកម្មក្នុងការបង្កើតផលិតផលទំនិញ និងសេវាកម្ម ដែលត្រូវបានរាប់បញ្ចូលទាំងអ្នកកំពុងធ្វើការងារពេលបច្ចុប្បន្ន និងអ្នកគ្មានការងារធ្វើ នៅរយៈពេលយោងក្នុងពេលស្រង់ទិន្នន័យអង្កេតចន្លោះជំរឿន។ តារាង ៥.២.១ បានបង្ហាញអោយឃើញថា សកម្មភាពសេដ្ឋកិច្ចសរុបនៅថ្នាក់ជាតិបានកើនឡើងបន្តិចត្រឹម ០,៩ ភាគរយ ក្នុងរយៈពេល ៥ឆ្នាំ គិតចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ ២០២៤។ ភាគរយបុរសក្នុងសកម្មភាពនេះបានកើនឡើង ២,២ ភាគរយ ប៉ុន្តែភាគរយស្ត្រីមានការថយចុះត្រឹម ០,៤ ភាគរយ។

រូប ៥.២.១. ស្ថានភាពសកម្មភាពសេដ្ឋកិច្ចអាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤



ក្នុងតារាង ៥.២.១ អសកម្មជនសេដ្ឋកិច្ច គឺរួមមានមនុស្សអាយុ ៥ ឆ្នាំឡើង ដែលមិនធ្វើការ ហើយមិនមានការងារធ្វើក្នុងរយៈពេលយោង។ ក្នុងឆ្នាំ២០២៤ អសកម្មជនសេដ្ឋកិច្ច ដែលជាមនុស្សស្រី មាន ៤១,៤ ភាគរយ ខ្ពស់ជាងមនុស្សប្រុសមានត្រឹម ៣២,៦ ភាគរយ។ បើប្រៀបទៅឆ្នាំ ២០១៩ ភាគរយស្ត្រីបានកើនប្រមាណ ០,៤ ភាគរយ។

តារាង ៥.២.១. ស្ថានភាពសកម្មភាពសេដ្ឋកិច្ច អាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤

ស្ថានភាពសកម្មភាព	២០១៩			២០២៤		
	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
ចំនួន						
សរុប						
សកម្មភាពសេដ្ឋកិច្ច	៨.៧៤៩.៥៨៧	៤.៤៥៣.៥៣១	៤.២៩៦.០៥៦	៩.៩៥០.៦៩៧	៥.២១៩.៨៥៨	៤.៧៣០.៨៣៩
មានការងារធ្វើ	៨.៦២៦.៧៧៧	៤.៣៩៦.៨៥០	៤.២២៩.៩២៧	៩.៥៧៩.១៥៤	៥.០៥១.០៣០	៤.៥២៨.១២៤
គ្មានការងារធ្វើ	១២២.៨១០	៥៦.៦៨១	៦៦.១២៩	៣៧១.៥៤៣	១៦៨.៨២៧	២០២.៧១៦
អសកម្មជនសេដ្ឋកិច្ច	៥.៣៥២.៤៦៥	២.៣៧២.៣៤៣	២.៩៨០.១២២	៥.៨៦៨.៩១៥	២.៥២៦.៨០១	៣.៣៤២.១១៣
ទីប្រជុំជន						
សកម្មភាពសេដ្ឋកិច្ច	៣.៤២៥.៧៤៤	១.៨០០.២៨៧	១.៦២៥.៤៥៧	៤.០១៥.៣០៥	២.១២៦.៨០៨	១.៨៨៨.៤៩៦
មានការងារធ្វើ	៣.៣៦២.៣៥៧	១.៧៧១.១៧៤	១.៥៩១.១៨៣	៣.៨៤៥.១១៨	២.០៤៦.៤៤៩	១.៧៩៨.៦៦៨
គ្មានការងារធ្វើ	៦៣.៣៨៧	២៩.១១៣	៣៤.២៧៤	១៧០.១៨៧	៨០.៣៥៩	៨៩.៨២៨
អសកម្មជនសេដ្ឋកិច្ច	២.១៩៧.១២៦	៩២៩.៣២៣	១.២៦៧.៨០៣	២.៥៨៥.៥៦៥	១.០៨៤.៤៣៥	១.៥០១.១៣០
ជនបទ						
សកម្មភាពសេដ្ឋកិច្ច	៥.៣២៣.៨៤៣	២.៦៥៣.២៤៤	២.៦៧០.៥៩៩	៥.៩៣៥.៣៩២	៣.០៩៣.០៤៩	២.៨៤២.៣៤៣
មានការងារធ្វើ	៥.២៦៤.៤២០	២.៦២៥.៦៧៦	២.៦៣៨.៧៤៤	៥.៧៣៤.០៣៦	៣.០០៤.៥៨១	២.៧២៩.៤៥៥
គ្មានការងារធ្វើ	៥៩.៤២៣	២៧.៥៦៨	៣១.៨៥៥	២០១.៣៥៦	៨៨.៤៦៨	១១២.៨៨៨
អសកម្មជនសេដ្ឋកិច្ច	៣.១៥៥.៣៣៩	១.៤៤៣.០២០	១.៧១២.៣១៩	៣.២៨៣.៣៤៩	១.៤៤២.៣៦៦	១.៨៤០.៩៨៣
ភាគរយ						
សរុប						
សកម្មភាពសេដ្ឋកិច្ច	៦២,០	៦៥,២	៥៩,០	៦២,៩	៦៧,៤	៥៨,៦
មានការងារធ្វើ	៦១,២	៦៤,៤	៥៨,១	៦០,៦	៦៥,២	៥៦,១
គ្មានការងារធ្វើ	០,៩	០,៨	០,៩	២,៤	២,២	២,៥
អសកម្មជនសេដ្ឋកិច្ច	៣៨,០	៣៤,៨	៤១,០	៣៧,១	៣២,៦	៤១,៤
ទីប្រជុំជន						
សកម្មភាពសេដ្ឋកិច្ច	៦០,៩	៦៦,០	៥៦,២	៦០,៨	៦៦,២	៥៥,៧
មានការងារធ្វើ	៥៩,៨	៦៤,៩	៥៥,០	៥៨,៣	៦៣,៧	៥៣,១
គ្មានការងារធ្វើ	១,១	១,១	១,២	២,៦	២,៥	២,៧
អសកម្មជនសេដ្ឋកិច្ច	៣៩,១	៣៤,០	៤៣,៨	៣៩,២	៣៣,៨	៤៤,៣
ជនបទ						
សកម្មភាពសេដ្ឋកិច្ច	៦២,៨	៦៤,៨	៦០,៩	៦៤,៤	៦៨,២	៦០,៧
មានការងារធ្វើ	៦២,១	៦៤,១	៦០,២	៦២,២	៦៦,៣	៥៨,៣
គ្មានការងារធ្វើ	០,៧	០,៧	០,៧	២,២	២,០	២,៤
អសកម្មជនសេដ្ឋកិច្ច	៣៧,២	៣៥,២	៣៩,១	៣៥,៦	៣១,៨	៣៩,៣

សម្គាល់ ៖ ភាគរយនៃស្ថានភាពសកម្មភាពសេដ្ឋកិច្ចត្រូវបានគណនាមិនរាប់បញ្ចូលសកម្មភាពសំខាន់ដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

អត្រាសកម្មភាពសេដ្ឋកិច្ច ឬអត្រាចូលរួមកម្លាំងពលកម្ម (LFPR) ក្នុងចំណោមប្រជាជនអាយុក្រោម ១៥ ឆ្នាំ បាននៅបន្តធ្លាក់ចុះ ចាប់ពី ៣,១ ភាគរយ (ឆ្នាំ២០០៨) ២,១ ភាគរយ (២០១៩) មក ២ ភាគរយ (ឆ្នាំ២០២៤) អាចបណ្តាលមកពីការរីកចម្រើនលើគ្រប់វិស័យរបស់ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្នផងដែរ

វាអាចពាក់ព័ន្ធជាមួយគោលនយោបាយលុបបំបាត់ពលកម្មកុមារ។ បើធៀបទៅជំរឿនឆ្នាំ២០១៩ អត្រាចូលរួមកម្លាំងពលកម្ម (LFPR) របស់ប្រជាជនអាយុ ១៥ ឆ្នាំឡើងទាំងពីរភេទ បានថយចុះប្រមាណ ០,៩ ភាគរយ។ ទោះបីជាយ៉ាងណាក៏ដោយ ភាគរយរបស់ប្រជាជននៅក្រុមអាយុ ១៥-៥៩ ឆ្នាំ មានការកើនឡើង ក្នុងខណៈពេលដែលអត្រាមានការធ្លាក់ចុះគួរកត់សម្គាល់សម្រាប់ក្រុមអាយុ ៦០ ឆ្នាំឡើង។

តារាង ៥.២.២. អត្រាចូលរួមកម្លាំងពលកម្មអាយុជាក់លាក់ (ភាគរយ) តាមក្រុមអាយុ ភេទ និងតំបន់ កម្ពុជាឆ្នាំ២០១៩-២០២៤

ក្រុមអាយុ	អត្រាសកម្មភាពសេដ្ឋកិច្ច					
	២០១៩			២០២៤		
	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
សរុប						
៥ ឆ្នាំឡើង	**៦២,០**	**៦៥,២**	**៥៩,០**	**៦២,៩**	**៦៧,៤**	**៥៨,៦**
១៥ ឆ្នាំឡើង	**៧៩,១**	**៨៤,៤**	**៧៤,៣**	**៧៨,២**	**៨៤,៨**	**៧២,០**
៥ - ១៤	២,១	២,៥	១,៦	២,០	២,៦	១,៣
១៥ - ២៤	៥៨,៤	៥៨,៩	៥៧,៩	៦០,១	៦៣,១	៥៧,២
២៥ - ៥៩	៩០,៧	៩៦,៣	៨៥,៤	៩១,២	៩៧,០	៨៥,៦
៦០ ឆ្នាំឡើង	៦០,៧	៧២,៥	៥២,៨	៥១,២	៦៥,០	៤១,៨
ទីប្រជុំជន						
៥ ឆ្នាំឡើង	**៦០,៩**	**៦៦,០**	**៥៦,២**	**៦០,៨**	**៦៦,២**	**៥៥,៧**
១៥ ឆ្នាំឡើង	**៧៤,៧**	**៨១,៨**	**៦៨,១**	**៧៤,៨**	**៨២,៥**	**៦៧,៨**
៥ - ១៤	១,៧	២,០	១,៤	១,៦	២,៣	០,៨
១៥ - ២៤	៥៥,៨	៥៥,៩	៥៥,៧	៥៤,០	៥៦,១	៥២,០
២៥ - ៥៩	៨៦,៤	៩៤,៤	៧៨,៧	៨៩,០	៩៦,៤	៨១,៨
៦០ ឆ្នាំឡើង	៤៨,២	៦២,០	៣៨,៩	៤៣,៩	៥៨,០	៣៤,៥
ជនបទ						
៥ ឆ្នាំឡើង	**៦២,៨**	**៦៤,៨**	**៦០,៩**	**៦៤,៤**	**៦៨,២**	**៦០,៧**
១៥ ឆ្នាំឡើង	**៨២,២**	**៨៦,៣**	**៧៨,៦**	**៨០,៦**	**៨៦,៥**	**៧៥,១**
៥ - ១៤	២,៣	២,៨	១,៨	២,២	២,៧	១,៦
១៥ - ២៤	៦០,៣	៦១,១	៥៩,៤	៦៤,៤	៦៧,៨	៦០,៩
២៥ - ៥៩	៩៣,៨	៩៧,៨	៩០,២	៩២,៩	៩៧,៥	៨៨,៥
៦០ ឆ្នាំឡើង	៦៧,៩	៧៨,៧	៦០,៨	៥៦,៣	៦៩,៧	៤៦,៨

តារាង ៥.២.២ បង្ហាញថា អត្រាសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជនភេទប្រុស នៅគ្រប់ក្រុមអាយុ ជាពិសេសចាប់ពីអាយុ ១៥ ឆ្នាំឡើង ច្រើនជាងអត្រារបស់ប្រជាជនភេទស្រី ក្នុងឆ្នាំ២០២៤ ដែលនិន្នាការនេះស្រដៀងទៅនឹងឆ្នាំ២០១៩។ បន្ថែមពីនេះ អត្រាសកម្មភាពសេដ្ឋកិច្ចនៅតំបន់ជនបទ គឺខ្ពស់ជាងអត្រានៅតំបន់ទីប្រជុំជន ទាំងបុរស និងស្ត្រី នៅគ្រប់ក្រុមអាយុទាំងអស់ ដែលអាចចូលរួមសកម្មភាពសេដ្ឋកិច្ច។ នេះប្រហែលជាអាចមកពីអត្រាចូលរួមខ្ពស់ក្នុងការងារកសិកម្មនៅជនបទ និងអត្រាចូលរួមក្នុងការសិក្សាខ្ពស់របស់កុមារនៅទីប្រជុំជន ហើយអាចមានកត្តារួមផ្សំមួយចំនួនទៀត។ តារាងនេះក៏បានបង្ហាញទៀតថា អត្រាចូលរួមកម្លាំងពលកម្មបុរស គឺខ្ពស់ជាងស្ត្រី ទាំងពីរតំបន់។ បើប្រៀបទៅនឹងក្រុមអាយុផ្សេងទៀត អត្រារបស់បុរស និងស្ត្រីនៅក្រុមអាយុ ១៥-២៤ឆ្នាំ នៅតំបន់ជនបទ មានភាគរយខ្ពស់ជាងនៅតំបន់ទីប្រជុំជន គួរអោយកត់សម្គាល់។

រូប ៥.២.២. អត្រាអ្នកចូលរួមក្នុងកម្លាំងពលកម្មអាយុជាក់លាក់ តាមភេទ កម្ពុជា ឆ្នាំ២០១៩ - ២០២៤



៥.៣. មានការងារធ្វើ និងគ្មានការងារធ្វើ

សូចនាករ ដែលសំខាន់សម្រាប់ចូលរួមធ្វើការវាយតម្លៃលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម គឺ "មានការងារធ្វើ"។ ការវិភាគអំពីការផ្លាស់ប្តូរសក្តានុពលនៃការងារ បានអនុញ្ញាតឲ្យយើងវាយតម្លៃផលប៉ះពាល់នៃការផ្លាស់ប្តូរសេដ្ឋកិច្ច សង្គម និងដាក់ចេញនូវគោលនយោបាយការងារឲ្យសមស្របទៅនឹងលក្ខខណ្ឌសេដ្ឋកិច្ច សង្គម។ ក្រោយពីការរីករាលដាលនៃជម្ងឺកូវីដ១៩ ត្រូវបានបញ្ចប់ សេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមងើបឡើងវិញបន្តិចម្តងៗ។ ដូចនេះ កម្លាំងពលកម្មមានការផ្លាស់ប្តូររចនាសម្ព័ន្ធ ដើម្បីរក្សានូវស្ថេរភាពសេដ្ឋកិច្ច និងបន្តនូវការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឲ្យកាន់តែប្រសើរឡើង។

ស្របជៀងនឹងជំរឿនប្រជាជនឆ្នាំ២០១៩ កម្លាំងពលកម្មភាគច្រើនគឺជាអ្នកមានការងារធ្វើ ហើយអ្នកដែលមិនមានការងារធ្វើមានចំនួនតិច។ កម្លាំងពលកម្មត្រូវបានធ្វើការវិភាគចរិតលក្ខណៈមូលដ្ឋាន ទៅតាមអាយុ ភេទ វិស័យការងារ ស្ថានភាពការងារ និងស្ថានភាពទូទៅនៃកម្លាំងពលកម្មនៅក្នុងប្រទេស។

អត្រាមានការងារធ្វើត្រូវបានកំណត់ជាភាគរយនៃអ្នកមានការងារធ្វើ ទៅនឹងចំនួនប្រជាជនសរុបនៅក្នុងកម្លាំងពលកម្ម ដែលក្នុងឆ្នាំ២០១៩ មាន ៩៨,៦ ភាគរយ និងក្នុងឆ្នាំ២០២៤ មាន ៩៦,៣ ភាគរយ នៅទូទាំងប្រទេស ។

រូប ៥.៣.១. អត្រាមានការងារធ្វើ អាយុ ៥ ឆ្នាំឡើង តាមភេទ តំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤



អត្រាគ្មានការងារធ្វើ ជាផលធៀបនៃចំនួនអ្នកគ្មានការងារធ្វើ ក្នុងចំណោមកម្លាំងពលកម្មសម្រាប់ ១០០នាក់។ អត្រាគ្មានការងារធ្វើក្នុងក្រុមអាយុ ១៥ ឆ្នាំឡើង នៅកម្ពុជាឆ្នាំ២០២៤ មាន ២,៨ ភាគរយ មានការកើនឡើងបន្តិចដែលនៅឆ្នាំ២០១៩ មាន ១,៣ ភាគរយ។

រូប ៥.៣.២. អត្រាគ្មានការងារធ្វើអាយុជាក់លាក់ តាមក្រុមអាយុ តំបន់ កម្ពុជា ឆ្នាំ២០២៤



៥.៤. ស្ថានភាពការងារ

ស្ថានភាពការងារចំនួនប្រាំ ត្រូវបានប្រមូលក្នុងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ ដែលសមស្របទៅតាមគោលការណ៍សកម្មភាពជំរឿន ដូចជា និយោជក និយោជិតទទួលប្រាក់ឈ្នួល អ្នកធ្វើការងារប្រើទុនផ្ទាល់ខ្លួន អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងផ្សេងទៀត។ ការវិភាគទិន្នន័យនៃស្ថានភាពការងារ គឺត្រូវបានបង្ហាញក្នុងតារាងទិន្នន័យដែលបែងចែកតាមតំបន់ និងភេទ។

តារាង ៥.៤.១ នៃលទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានបង្ហាញឲ្យឃើញថា ភាគរយនៃអ្នកធ្វើការប្រើទុនផ្ទាល់ខ្លួន និងអ្នកធ្វើការអោយគ្រួសារមិនយកប្រាក់ឈ្នួល បានថយចុះមកត្រឹម ៤៨,៣ ភាគរយ បើធៀបទៅនឹងឆ្នាំ២០១៩ (៦៧,៧ ភាគរយ)។ ផ្ទុយទៅវិញ សមាមាត្រនៃនិយោជិតយកប្រាក់ឈ្នួល បានកើនឡើងប្រមាណ ១៩,២ ភាគរយ រវាងឆ្នាំ២០១៩- ២០២៤។

ភាគរយនៃអ្នកធ្វើការដោយប្រើទុនផ្ទាល់ខ្លួនជាបុរស (៣៧,៦ ភាគរយ) មានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងភាគរយរបស់ស្ត្រី (៣៥,៣ ភាគរយ)។ ស្ត្រីដែលធ្វើការអោយគ្រួសារដោយមិនទទួលប្រាក់ឈ្នួល គឺមាន ១៦,៧ ភាគរយ ទោះបីជាភាគរយនេះ ទាបជាងភាគរយស្ត្រី (៣៥,៤ ភាគរយ) នៅឆ្នាំ២០១៩ ក៏នៅតែខ្ពស់ជាងភាគរយបុរសមានត្រឹមតែ ៧,៤ ភាគរយ។ សមាមាត្ររបស់និយោជិតទទួលប្រាក់ឈ្នួលដែលជាបុរស គឺខ្ពស់ជាងស្ត្រី ទាំងនៅក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២៤។ អ្វីដែលគួរអោយចាប់អារម្មណ៍ ភាគរយស្មើគ្នារបស់បុរស និងស្ត្រី ដែលធ្វើជានិយោជក (០,៩ ភាគរយ)។

ក្នុងចំណោមប្រជាជនធ្វើការងារនៅឆ្នាំ២០២៤ ភាគរយនៃនិយោជិតយកប្រាក់ឈ្នួល គឺខ្ពស់ជាងភាគរយនៃអ្នកធ្វើការដោយប្រើទុនផ្ទាល់ខ្លួនទាំងនៅតំបន់ទីប្រជុំជន និងជនបទ ប៉ុន្តែនេះគឺមានភាពខុសគ្នាជាមួយនឹងឆ្នាំ២០១៩ ដែលភាគរយនេះខ្ពស់នៅទីប្រជុំជន ហើយទាបនៅជនបទ។ សមាមាត្ររបស់ស្ត្រីដែលធ្វើការអោយគ្រួសារដោយមិនយកប្រាក់ឈ្នួល គឺខ្ពស់ជាងសមាមាត្ររបស់បុរស ទាំងពីរតំបន់ (នៅទីប្រជុំជនមានស្ត្រី ៧,៨ ភាគរយ និងជាបុរស ៣,៥ ភាគរយ ហើយនៅជនបទមាន ២២,៥ ភាគរយជាស្ត្រី និង១០ ភាគរយ ជាបុរស)។ ស្ត្រីនៅតំបន់ជនបទ (២២,៥ ភាគរយ) ដែលបានធ្វើការអោយគ្រួសារដោយមិនយកប្រាក់ឈ្នួល មានសមាមាត្រខ្ពស់ជាងនៅតំបន់ប្រជុំជន (៧,៨ ភាគរយ)។ នេះបានឆ្លុះបញ្ចាំងអំពីបញ្ហាយេនឌ័រ នៅក្នុងស្ថានភាពការងារ ដូចជាការធ្វើការងារអោយគ្រួសារមិនយកប្រាក់កម្រៃ និងនិយោជិតទទួលប្រាក់ឈ្នួល ទាំងនៅក្នុងកម្រិតជាតិ និងតំបន់។

តារាង ៥.៤.១. ភាគរយអ្នកមានការងារធ្វើតាមស្ថានភាពការងារ អាយុ ៥ ឆ្នាំឡើង តាមក្រុមអាយុ ភេទ តំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤

ក្រុមអាយុ	ចំនួនអ្នកមានការងារធ្វើ	ស្ថានភាពការងារ					
		សរុប	និយោជក	និយោជិតយកប្រាក់ឈ្នួល	អ្នកធ្វើការប្រើទុនផ្ទាល់ខ្លួន	អ្នកធ្វើការអោយគ្រួសារមិនយកប្រាក់ឈ្នួល	ផ្សេងទៀត
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)
២០១៩							
សរុប							
ទាំងពីរភេទ	**៨.៦២៦.៧៧៧**	**១០០**	**០,៦**	**៣១,៥**	**៤២,៧**	**២៥,០**	**០,២**
ក្រោម ១៥ ឆ្នាំ	៥៩.៨៤៥	១០០	០,៧	២៣,០	៣០,១	៤២,៧	៣,៥
១៥ – ៥៩	៧.៧៥៤.៣៧២	១០០	០,៦	៣៣,៩	៤០,៣	២៥,០	០,២
៦០ ឆ្នាំឡើងទៅ	៨១២.៥៦០	១០០	០,៦	៨,៩	៦៥,៩	២៤,៣	០,២
ប្រុស	**៤.៣៩៦.៨៥០**	**១០០**	**០,៧**	**៣៣,៦**	**៥០,៣**	**១៥,១**	**០,៣**
ក្រោម ១៥ ឆ្នាំ	៣៧.៣៨៨	១០០	០,៧	១៩,៧	៣៥,៦	៣៨,៦	៥,៤
១៥ – ៥៩	៣.៩៦៩.៦៧៥	១០០	០,៧	៣៥,៨	៤៧,៧	១៥,៦	០,២
៦០ ឆ្នាំឡើងទៅ	៣៨៩.៧៨៧	១០០	០,៨	១៣,៣	៧៧,៧	៧,៩	០,៣
ស្រី	**៤.២២៩.៩២៧**	**១០០**	**០,៥**	**២៩,៣**	**៣៤,៧**	**៣៥,៤**	**០,១**
ក្រោម ១៥ ឆ្នាំ	២២.៤៥៧	១០០	០,៨	២៨,៤	២១,០	៤៩,៦	០,២
១៥ – ៥៩	៣.៧៨៤.៦៩៧	១០០	០,៥	៣២,០	៣២,៥	៣៤,៨	០,១
៦០ ឆ្នាំឡើងទៅ	៤២២.៧៧៣	១០០	០,៤	៤,៩	៥៥,១	៣៩,៥	០,១
ទីប្រជុំជន							
ទាំងពីរភេទ	**៣.៣៦២.៣៥៧**	**១០០**	**០,៨**	**៥៣,១**	**៣៣,៧**	**១២,២**	**០,២**
ក្រោម ១៥ ឆ្នាំ	១៦.០០៨	១០០	១,០	៤៦,៩	២៩,២	២០,៧	២,១
១៥ – ៥៩	៣.១១២.៨៨៤	១០០	០,៨	៥៥,៦	៣១,៦	១១,៨	០,២
៦០ ឆ្នាំឡើងទៅ	២៣៣.៤៦៥	១០០	១,០	១៩,៣	៦២,៣	១៧,១	០,៣
ប្រុស	**១.៧៧១.១៧៤**	**១០០**	**០,៩**	**៥៤,៨**	**៣៦,៥**	**៧,៦**	**០,៣**
ក្រោម ១៥ ឆ្នាំ	៩.៥៩៤	១០០	០,៩	៣៩,៧	៣៦,៨	១៩,៣	៣,៣
១៥ – ៥៩	១.៦៣៩.២៦០	១០០	០,៩	៥៧,០	៣៤,២	៧,៧	០,២
៦០ ឆ្នាំឡើងទៅ	១២២.៣២០	១០០	១,២	២៦,៦	៦៦,៥	៥,៤	០,៣
ស្រី	**១.៥៩១.១៨៣**	**១០០**	**០,៧**	**៥១,២**	**៣០,៦**	**១៧,៤**	**០,១**
ក្រោម ១៥ ឆ្នាំ	៦.៤១៤	១០០	១,១	៥៧,៧	១៧,៩	២២,៩	០,៤
១៥ – ៥៩	១.៤៧៣.៦២៤	១០០	០,៧	៥៤,១	២៨,៦	១៦,៤	០,១
៦០ ឆ្នាំឡើងទៅ	១១១.១៤៥	១០០	០,៧	១១,៣	៥៧,៨	៣០,១	០,២
ជនបទ							
ទាំងពីរភេទ	**៥.២៦៤.៤២០**	**១០០**	**០,៥**	**១៧,៧**	**៤៨,៤**	**៣៣,៣**	**០,២**
ក្រោម ១៥ ឆ្នាំ	៤៣.៨៣៧	១០០	០,៧	១៤,២	៣០,៤	៥០,៨	៤,០
១៥ – ៥៩	៤.៦៤១.៤៨៨	១០០	០,៥	១៩,៤	៤៦,២	៣៣,៨	០,១
៦០ ឆ្នាំឡើងទៅ	៥៧៩.០៩៥	១០០	០,៥	៤,៧	៦៧,៤	២៧,២	០,២
ប្រុស	**២.៦២៥.៦៧៦**	**១០០**	**០,៥**	**១៩,៤**	**៥៩,៦**	**២០,២**	**០,៣**
ក្រោម ១៥ ឆ្នាំ	២៧.៧៩៤	១០០	០,៦	១២,៨	៣៥,១	៤៥,២	៦,២
១៥ – ៥៩	២.៣៣០.៤១៥	១០០	០,៥	២០,៩	៥៧,២	២១,២	០,២
៦០ ឆ្នាំឡើងទៅ	២៦៧.៤៦៧	១០០	០,៦	៧,២	៨២,៩	៩,០	០,៣
ស្រី	**២.៦៣៨.៧៤៤**	**១០០**	**០,៤**	**១៦,១**	**៣៧,២**	**៤៦,២**	**០,១**

ក្រោម ១៥ ឆ្នាំ	១៦.០៤៣	១០០	០,៧	១៦,៧	២២,២	៦០,៣	០,១
១៥ – ៥៩	២.៣១១.០៧៣	១០០	០,៤	១៧,៩	៣៥,០	៤៦,៦	០,០
៦០ ឆ្នាំឡើងទៅ	៣១១.៦២៨	១០០	០,៤	២,៦	៥៤,១	៤២,៩	០,១
២០២៤							
សរុប							
ទាំងពីរភេទ	**៩.៥៧៩.១៥៤**	**១០០**	**០,៩**	**៥០,៧**	**៣៦,៥**	**១១,៨**	**០,១**
ក្រោម ១៥ ឆ្នាំ	៥០.១០៥	១០០	០,៣	៥៣,៦	១៣,៣	៣១,៦	១,២
១៥ – ៥៩	៨.៧០១.៥៩៨	១០០	០,៩	៥៤,០	៣៣,៦	១១,៤	០,១
៦០ ឆ្នាំឡើងទៅ	៨២៧.៤៥១	១០០	០,៧	១៦,២	៦៨,៤	១៤,៧	០,១
ប្រុស	**៥.០៥១.០៣០**	**១០០**	**០,៩**	**៥៣,៩**	**៣៧,៦**	**៧,៤**	**០,២**
ក្រោម ១៥ ឆ្នាំ	៣៣.៩៤១	១០០	០,៤	៥០,២	១៤,៥	៣៣,០	១,៨
១៥ – ៥៩	៤.៥៨២.២៤៩	១០០	០,៩	៥៧,១	៣៤,៣	៧,៥	០,២
៦០ ឆ្នាំឡើងទៅ	៤៣៤.៨៤០	១០០	១,១	២១,៤	៧៣,៤	៤,០	០,១
ស្រី	**៤.៥២៨.១២៤**	**១០០**	**០,៩**	**៤៧,១**	**៣៥,៣**	**១៦,៧**	**០,១**
ក្រោម ១៥ ឆ្នាំ	១៦.១៦៤	១០០	០,០	៦០,៨	១០,៨	២៨,៥	០,០
១៥ – ៥៩	៤.១១៩.៣៤៩	១០០	០,៩	៥០,៥	៣២,៨	១៥,៧	០,១
៦០ ឆ្នាំឡើងទៅ	៣៩២.៦១១	១០០	០,២	១០,៤	៦២,៨	២៦,៦	០,០
ទីប្រជុំជន							
ទាំងពីរភេទ	**៣.៨៤៥.១១៨**	**១០០**	**១,១**	**៦០,៩**	**៣២,៣**	**៥,៥**	**០,២**
ក្រោម ១៥ ឆ្នាំ	១៣.៤៦៦	១០០	០,០	៦៦,០	៩,៩	២១,១	៣,០
១៥ – ៥៩	៣.៥៥០.០០៥	១០០	១,១	៦៣,៨	២៩,៨	៥,១	០,២
៦០ ឆ្នាំឡើងទៅ	២៨១.៦៤៧	១០០	១,២	២៣,៦	៦៥,២	៩,៩	០,០
ប្រុស	**២.០៤៦.៤៤៩**	**១០០**	**១,១**	**៦៣,៤**	**៣១,៨**	**៣,៥**	**០,២**
ក្រោម ១៥ ឆ្នាំ	៩.៧៧៩	១០០	០,០	៦១,៥	១៣,៥	២០,៩	៤,១
១៥ – ៥៩	១.៨៨៥.៤៨៧	១០០	១,០	៦៦,០	២៩,២	៣,៥	០,២
៦០ ឆ្នាំឡើងទៅ	១៥១.១៨៤	១០០	២,០	៣០,១	៦៥,៤	២,៥	០,០
ស្រី	**១.៧៩៨.៦៦៨**	**១០០**	**១,១**	**៥៨,១**	**៣២,៩**	**៧,៨**	**០,១**
ក្រោម ១៥ ឆ្នាំ	៣.៦៨៨	១០០	០,០	៧៨,០	០,៣	២១,៧	០,០
១៥ – ៥៩	១.៦៦៤.៥១៨	១០០	១,១	៦១,៤	៣០,៥	៧,០	០,១
៦០ ឆ្នាំឡើងទៅ	១៣០.៤៦៣	១០០	០,៤	១៦,០	៦៥,១	១៨,៦	០,០
ជនបទ							
ទាំងពីរភេទ	**៥.៧៣៤.០៣៦**	**១០០**	**០,៧**	**៤៣,៩**	**៣៩,៣**	**១៦,០**	**០,១**
ក្រោម ១៥ ឆ្នាំ	៣៦.៦៣៨	១០០	០,៤	៤៩,១	១៤,៦	៣៥,៤	០,៦
១៥ – ៥៩	៥.១៥១.៥៩៣	១០០	០,៨	៤៧,២	៣៦,២	១៥,៧	០,១
៦០ ឆ្នាំឡើងទៅ	៥៤៥.៨០៤	១០០	០,៤	១២,៣	៧០,០	១៧,១	០,១
ប្រុស	**៣.០០៤.៥៨១**	**១០០**	**០,៨**	**៤៧,៥**	**៤១,៥**	**១០,០**	**០,២**
ក្រោម ១៥ ឆ្នាំ	២៤.១៦២	១០០	០,៦	៤៥,៦	១៤,៩	៣៧,៩	០,៩
១៥ – ៥៩	២.៦៩៦.៧៦២	១០០	០,៨	៥០,៨	៣៨,០	១០,៣	០,២
៦០ ឆ្នាំឡើងទៅ	២៨៣.៦៥៧	១០០	០,៧	១៦,៧	៧៧,៧	៤,៧	០,២
ស្រី	**២.៧២៩.៤៥៥**	**១០០**	**០,៧**	**៣៩,៨**	**៣៦,៩**	**២២,៥**	**០,១**
ក្រោម ១៥ ឆ្នាំ	១២.៤៧៦	១០០	០,០	៥៥,៧	១៣,៩	៣០,៥	០,០
១៥ – ៥៩	២.៤៥៥.៨៣១	១០០	០,៨	៤៣,២	៣៤,៣	២១,៦	០,១
៦០ ឆ្នាំឡើងទៅ	២៦២.១៤៨	១០០	០,២	៧,៥	៦១,៧	៣០,៥	០,០

សម្គាល់ ៖ មិនរាប់បញ្ចូលស្ថានភាពការងារដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

៥.៥. ផ្នែកនៃការងារ

ផ្នែកនៃការងារនៅក្នុងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ ត្រូវបានវិភាគជាភាគរយទៅលើប្រាំបីផ្នែករួមមាន ផ្នែករដ្ឋាភិបាល ផ្នែកអង្គភាពស្វយ័ត ផ្នែកសហគ្រាសឯកជនខ្មែរ ផ្នែកសហគ្រាសឯកជនបរទេស ផ្នែកស្ថាប័នមិនយកប្រាក់ចំណេញ ផ្នែកគ្រួសារ ផ្នែកស្ថានទូត/ស្ថាប័នអន្តរជាតិ/ភ្នាក់ងារអភិវឌ្ឍន៍ និងផ្នែកផ្សេងទៀត។

តារាង ៥.៥.១ បានបង្ហាញពីភាគរយនៃអ្នកមានការងារធ្វើ ដែលមានអាយុ ៥ ឆ្នាំឡើង ដោយបែងចែកតាមភេទ អាយុ ផ្នែកការងារ តំបន់ នៅកម្ពុជាឆ្នាំ២០១៩-២០២៤។ យោងតាមតារាងនេះ ប្រជាជននៅកម្ពុជាមានការងារធ្វើ ភាគច្រើននៅក្នុងផ្នែកសហគ្រាសឯកជនខ្មែរ (៧២,៦ ភាគរយ)។ បន្ទាប់មកទៀត អ្នកមានការងារនៅសហគ្រាសឯកជនបរទេស (២០,៥ ភាគរយ) នៅរដ្ឋាភិបាល (៥,៣ ភាគរយ) និងនៅក្នុងផ្នែកការងារទាំង ៥ ផ្សេងទៀត (១,៥ ភាគរយ)។ បើធៀបទៅនឹងឆ្នាំ២០១៩ អ្នកដែលធ្វើការក្នុងផ្នែកសហគ្រាសឯកជនខ្មែរ គឺមានសមាមាត្រទាបជាង ប៉ុន្តែផ្ទុយទៅវិញ អ្នកដែលធ្វើការក្នុងផ្នែកសហគ្រាសឯកជនបរទេស គឺមានសមាមាត្រខ្ពស់ជាង។

តារាង ៥.៥.១ ក៏បានបង្ហាញទៀតថា បុរស (៧៥,៨ ភាគរយ) ធ្វើនៅផ្នែកសហគ្រាសឯកជនកម្ពុជា គឺ ខ្ពស់ជាងស្ត្រី ដែលមានត្រឹមតែ ៦៩,២ ភាគរយ។ ដូចគ្នានេះដែរ បុរសធ្វើនៅក្នុងជួររាជរដ្ឋាភិបាល មានភាគរយខ្ពស់ជាងស្ត្រី ៣,២ ភាគរយ។ ផ្ទុយពីនេះ ស្ត្រីមានភាគរយខ្ពស់ក្នុងផ្នែកសហគ្រាសបរទេស (២៥,៥ ភាគរយ) បើធៀបទៅនឹងបុរស (១៦ ភាគរយ)។ ទំនោរនេះក៏បានកើតមានឡើងកាលពីជំរឿនប្រជាជនឆ្នាំ២០១៩ ផងដែរ។ អ្នកធ្វើការនៅក្នុងផ្នែកសហគ្រាសឯកជនខ្មែរ មាន ៧៦,៩ ភាគរយនៅតំបន់ជនបទ ខ្ពស់ជាងនៅតំបន់ប្រជុំជន (៦៦,៣ ភាគរយ) ប៉ុន្តែទំនោរនេះ គឺខុសគ្នាសម្រាប់អ្នកធ្វើការក្នុងផ្នែករដ្ឋាភិបាល និងផ្នែកសហគ្រាសឯកជនបរទេស ដែលភាគរយនៅតំបន់ទីប្រជុំជន ខ្ពស់ជាងនៅតំបន់ជនបទ។ អ្វីដែលគួរអោយចាប់អារម្មណ៍ ស្ត្រី (២១ ភាគរយ) ដែលធ្វើការនៅតំបន់ជនបទផ្នែកសហគ្រាសឯកជនបរទេស ក្នុងឆ្នាំ២០២៤ គឺមានភាពខុសគ្នាគួរអោយកត់សម្គាល់ បើធៀបទៅនឹងឆ្នាំ២០១៩ មានត្រឹមតែ ៨,៥ ភាគរយ។

តារាង ៥.៥.១. ភាគរយអ្នកមានការងារធ្វើ ៥ ឆ្នាំឡើង បែងចែកតាមភេទ ផ្នែកការងារ និងតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤

ក្រុមអាយុ	ចំនួនអ្នកមានការងារធ្វើ	សរុប	វិស័យការងារ							
			រដ្ឋាភិបាល	អង្គភាពស្វយ័ត	សហគ្រាសឯកជនកម្ពុជា	សហគ្រាសបរទេស	ស្ថាប័នមិនយកប្រាក់ចំណេញ	ផ្នែកគ្រួសារ	ស្ថានទូតស្ថាប័នអន្តរជាតិ	ផ្សេងទៀត
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)	(១០)	(១១)
២០១៩										
សរុប										
ទាំងពីរភេទ	**៨.៦២៦.៧៧៧**	**១០០**	**៤,៩**	**០,៥**	**៧៨,៧**	**១២,៨**	**០,៥**	**២,៥**	**០,០**	**០,១**
៥ – ១៤	៥៩.៨៤៥	១០០	០,៧	០,៣	៧៣,៧	៧,៥	១៣,៩	២,៤	០,០	១,៤
១៥ – ៥៩	៧.៧៥៤.៣៧២	១០០	៥,០	០,៥	៧៧,៥	១៤,០	០,៤	២,៤	០,០	០,១
៦០ ឆ្នាំឡើងទៅ	៨១២.៥៦០	១០០	៤,៣	០,៤	៩០,៤	០,៨	០,៨	៣,២	០,០	០,១
ប្រុស	**៤.៣៩៦.៨៥០**	**១០០**	**៦,៧**	**០,៧**	**៨០,១**	**៩,០**	**០,៩**	**២,៣**	**០,០**	**០,១**
៥ – ១៤	៣៧.៣៨៨	១០០	០,៦	០,៣	៦៧,៥	៥,១	២២,១	២,១	០,០	២,២
១៥ – ៥៩	៣.៩៦៩.៦៧៥	១០០	៦,៨	០,៧	៧៩,៦	៩,៩	០,៧	២,៣	០,០	០,១
៦០ ឆ្នាំឡើងទៅ	៣៨៩.៧៨៧	១០០	៧,២	០,៥	៨៧,១	០,៩	១,២	២,៩	០,០	០,១
ស្រី	**៤.២២៩.៩២៧**	**១០០**	**៣,០**	**០,៣**	**៧៧,២**	**១៦,៦**	**០,១**	**២,៦**	**០,០**	**០,០**
៥ – ១៤	២២.៤៥៧	១០០	០,៨	០,៣	៨៤,១	១១,៥	០,២	២,៩	០,០	០,១
១៥ – ៥៩	៣.៧៨៤.៦៩៧	១០០	៣,២	០,៣	៧៥,៣	១៨,៤	០,១	២,៥	០,០	០,០
៦០ ឆ្នាំឡើងទៅ	៤២២.៧៧៣	១០០	១,៦	០,២	៩៣,៥	០,៨	០,៥	៣,៣	០,០	០,០

សម្គាល់ ៖ មិនរាប់បញ្ចូលផ្នែកការងារដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៥.១. ភាគរយអ្នកមានការងារធ្វើ ៥ ឆ្នាំឡើង បែងចែកតាមភេទ ផ្នែកការងារ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ក្រុមអាយុ	ចំនួនអ្នកមានការងារធ្វើ	សរុប	វិស័យការងារ							
			រដ្ឋាភិបាល	អង្គភាពស្វយ័ត	សហគ្រាសឯកជនកម្ពុជា	សហគ្រាសបរទេស	ស្ថាប័នមិនយកប្រាក់ចំណេញ	ផ្នែកគ្រួសារ	ស្ថានទូតស្ថាប័នអន្តរជាតិ	ផ្សេងទៀត
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)	(១០)	(១១)
២០១៩										
ទីប្រជុំជន										
ទាំងពីរភេទ	**៣.៣៦២.៣៥៧**	**១០០**	**៧,៦**	**០,៧**	**៦៦,៤**	**២២,៧**	**០,៦**	**១,៨**	**០,១**	**០,១**
៥ – ១៤	១៦.០០៨	១០០	១,៤	០,៤	៦២,៤	១៧,៧	១៤,៧	២,៥	០,០	០,៨
១៥ – ៥៩	៣.១១២.៨៨៤	១០០	៧,៦	០,៧	៦៥,១	២៤,៣	០,៥	១,៨	០,១	០,១
៦០ ឆ្នាំឡើងទៅ	២៣៣.៤៦៥	១០០	៨,៨	០,៦	៨៤,២	២,១	១,៤	២,៨	០,១	០,១
ប្រុស	**១.៧៧១.១៧៤**	**១០០**	**១០,១**	**០,៩**	**៧០,០**	**១៦,១**	**០,៩**	**១,៨**	**០,១**	**០,១**
៥ – ១៤	៩.៥៩៤	១០០	១,២	០,៤	៥៨,៨	១១,៩	២៤,២	២,០	០,១	១,៣
១៥ – ៥៩	១.៦៣៩.២៦០	១០០	១០,០	០,៩	៦៩,៤	១៧,២	០,៨	១,៧	០,១	០,១
៦០ ឆ្នាំឡើងទៅ	១២២.៣២០	១០០	១៣,៤	០,៨	៧៩,៤	២,០	១,៦	២,៦	០,១	០,១
ស្រី	**១.៥៩១.១៨៣**	**១០០**	**៤,៨**	**០,៥**	**៦២,៥**	**៣០,១**	**០,២**	**១,៩**	**០,១**	**០,០**
៥ – ១៤	៦.៤១៤	១០០	១,៧	០,៥	៦៧,៩	២៦,២	០,៤	៣,២	០,០	០,១
១៥ – ៥៩	១.៤៧៣.៦២៤	១០០	៤,៩	០,៥	៦០,៤	៣២,២	០,១	១,៨	០,១	០,០
៦០ ឆ្នាំឡើងទៅ	១១១.១៤៥	១០០	៣,៨	០,៣	៨៩,៦	២,១	១,១	៣,០	០,០	០,១

សម្គាល់ ៖ មិនរាប់បញ្ចូលផ្នែកការងារដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៥.១. ភាគរយអ្នកមានការងារធ្វើ ៥ ឆ្នាំឡើង បែងចែកតាមភេទ ផ្នែកការងារ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ក្រុមអាយុ	ចំនួនអ្នកមានការងារធ្វើ	សរុប	វិស័យការងារ							
			រដ្ឋាភិបាល	អង្គភាពស្វយ័ត	សហគ្រាសឯកជនកម្ពុជា	សហគ្រាសបរទេស	ស្ថាប័នមិនយកប្រាក់ចំណេញ	ផ្នែកគ្រួសារ	ស្ថានទូតស្ថាប័នអន្តរជាតិ	ផ្សេងទៀត
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)	(១០)	(១១)
២០១៩										
ជនបទ										
ទាំងពីរភេទ	**៥.២៦៤.៤២០**	**១០០**	**៣,២**	**០,៤**	**៨៦,៥**	**៦,៤**	**០,៥**	**២,៩**	**០,០**	**០,១**
៥ – ១៤	៤៣.៨៣៧	១០០	០,៥	០,២	៧៧,៩	៣,៨	១៣,៦	២,៤	០,០	១,៦
១៥ – ៥៩	៤.៦៤១.៤៨៨	១០០	៣,៣	០,៤	៨៥,៨	៧,២	០,៤	២,៨	០,០	០,១
៦០ ឆ្នាំឡើងទៅ	៥៧៩.០៩៥	១០០	២,៤	០,៣	៩២,៩	០,៤	០,៦	៣,៣	០,០	០,១
ប្រុស	**២.៦២៥.៦៧៦**	**១០០**	**៤,៥**	**០,៥**	**៨៧,០**	**៤,៣**	**០,៩**	**២,៧**	**០,០**	**០,១**
៥ – ១៤	២៧.៧៩៤	១០០	០,៤	០,២	៧០,៥	២,៨	២១,៣	២,១	០,០	២,៥
១៥ – ៥៩	២.៣៣០.៤១៥	១០០	៤,៥	០,៥	៨៦,៧	៤,៧	០,៧	២,៧	០,០	០,១
៦០ ឆ្នាំឡើងទៅ	២៦៧.៤៦៧	១០០	៤,៤	០,៤	៩០,៦	០,៣	១,០	៣,១	០,០	០,១
ស្រី	**២.៦៣៨.៧៤៤**	**១០០**	**២,០**	**០,៣**	**៨៦,១**	**៨,៥**	**០,១**	**៣,០**	**០,០**	**០,០**
៥ – ១៤	១៦.០៤៣	១០០	០,៥	០,២	៩០,៦	៥,៦	០,២	២,៨	០,០	០,១
១៥ – ៥៩	២.៣១១.០៧៣	១០០	២,១	០,៣	៨៤,៩	៩,៧	០,០	៣,០	០,០	០,០
៦០ ឆ្នាំឡើងទៅ	៣១១.៦២៨	១០០	០,៨	០,២	៩៤,៩	០,៤	០,៣	៣,៥	០,០	០,០

សម្គាល់ ៖ មិនរាប់បញ្ចូលផ្នែកការងារដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៥.១. ភាគរយអ្នកមានការងារធ្វើ ៥ ឆ្នាំឡើង បែងចែកតាមភេទ ផ្នែកការងារ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ក្រុមអាយុ	ចំនួនអ្នកមានការងារធ្វើ	សរុប	វិស័យការងារ							
			រដ្ឋាភិបាល	អង្គភាពស្វយ័ត	សហគ្រាសឯកជនកម្ពុជា	សហគ្រាសបរទេស	ស្ថាប័នមិនយកប្រាក់ចំណេញ	ផ្នែកគ្រួសារ	ស្ថានទូតស្ថាប័នអន្តរជាតិ	ផ្សេងទៀត
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)	(១០)	(១១)
២០២៤										
សរុប										
ទាំងពីរភេទ	**៩.៥៧៩.១៥៤**	**១០០**	**៥,៣**	**០,៧**	**៧២,៦**	**២០,៥**	**០,១**	**០,៧**	**០,០**	**០,០**
៥ – ១៤	៥០.១០៥	១០០	០,៤	១,០	៨២,២	១២,៦	២,៩	០,៨	០,០	០,០
១៥ – ៥៩	៨.៧០១.៥៩៨	១០០	៥,២	០,៨	៧០,៨	២២,៤	០,១	០,៧	០,០	០,០
៦០ ឆ្នាំឡើងទៅ	៨២៧.៤៥១	១០០	៦,១	០,៤	៩១,២	១,៤	០,៣	០,៤	០,០	០,១
ប្រុស	**៥.០៥១.០៣០**	**១០០**	**៦,៨**	**០,៩**	**៧៥,៨**	**១៦,០**	**០,២**	**០,៣**	**០,០**	**០,០**
៥ – ១៤	៣៣.៩៤១	១០០	០,៦	០,៨	៨៥,៣	៩,០	៤,៣	០,០	០,០	០,០
១៥ – ៥៩	៤.៥៨២.២៤៩	១០០	៦,៥	០,៩	៧៤,៦	១៧,៤	០,១	០,៣	០,០	០,០
៦០ ឆ្នាំឡើងទៅ	៤៣៤.៨៤០	១០០	៩,៦	០,៦	៨៧,១	១,៩	០,៥	០,២	០,០	០,១
ស្រី	**៤.៥២៨.១២៤**	**១០០**	**៣,៦**	**០,៥**	**៦៩,២**	**២៥,៥**	**០,១**	**១,១**	**០,០**	**០,០**
៥ – ១៤	១៦.១៦៤	១០០	០,០	១,៣	៧៥,៨	២០,៣	០,០	២,៦	០,០	០,០
១៥ – ៥៩	៤.១១៩.៣៤៩	១០០	៣,៧	០,៦	៦៦,៦	២៧,៩	០,១	១,២	០,០	០,០
៦០ ឆ្នាំឡើងទៅ	៣៩២.៦១១	១០០	២,៣	០,២	៩៥,៧	០,៩	០,២	០,៧	០,០	០,០

សម្គាល់ ៖ មិនរាប់បញ្ចូលផ្នែកការងារដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៥.១. ភាគរយអ្នកមានការងារធ្វើ ៥ ឆ្នាំឡើង បែងចែកតាមភេទ ផ្នែកការងារ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ក្រុមអាយុ	ចំនួនអ្នកមានការងារធ្វើ	សរុប	វិស័យការងារ							
			រដ្ឋាភិបាល	អង្គភាពស្វយ័ត	សហគ្រាសឯកជនកម្ពុជា	សហគ្រាសបរទេស	ស្ថាប័នមិនយកប្រាក់ចំណេញ	ផ្នែកគ្រួសារ	ស្ថានទូតស្ថាប័នអន្តរជាតិ	ផ្សេងទៀត
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)	(១០)	(១១)
២០២៤										
ទីប្រជុំជន										
ទាំងពីរភេទ	**៣.៨៤៥.១១៨**	**១០០**	**៧,១**	**១,២**	**៦៦,៣**	**២៤,៤**	**០,១**	**០,៨**	**០,០**	**០,០**
៥ – ១៤	១៣.៤៦៦	១០០	១,៦	១,៦	៨៣,១	៨,៣	៥,៤	០,០	០,០	០,០
១៥ – ៥៩	៣.៥៥០.០០៥	១០០	៧,០	១,២	៦៤,៧	២៦,២	០,១	០,៨	០,០	០,០
៦០ ឆ្នាំឡើងទៅ	២៨១.៦៤៧	១០០	៨,៩	១,២	៨៦,៤	២,៣	០,៣	០,៧	០,០	០,២
ប្រុស	**២.០៤៦.៤៤៩**	**១០០**	**៩,៣**	**១,៤**	**៧១,៣**	**១៧,៣**	**០,២**	**០,៤**	**០,១**	**០,០**
៥ – ១៤	៩.៧៧៩	១០០	២,២	២,៣	៨៥,៨	២,៣	៧,៤	០,០	០,០	០,០
១៥ – ៥៩	១.៨៨៥.៤៨៧	១០០	៩,០	១,៤	៧០,៥	១៨,៥	០,១	០,៤	០,១	០,០
៦០ ឆ្នាំឡើងទៅ	១៥១.១៨៤	១០០	១២,៩	១,៨	៨០,៩	៣,១	០,៤	០,៦	០,០	០,៤
ស្រី	**១.៧៩៨.៦៦៨**	**១០០**	**៤,៧**	**០,៩**	**៦០,៦**	**៣២,៤**	**០,១**	**១,៣**	**០,០**	**០,០**
៥ – ១៤	៣.៦៨៨	១០០	០,០	០,០	៧៥,៩	២៤,១	០,០	០,០	០,០	០,០
១៥ – ៥៩	១.៦៦៤.៥១៨	១០០	៤,៨	០,៩	៥៨,១	៣៤,៩	០,១	១,៣	០,០	០,០
៦០ ឆ្នាំឡើងទៅ	១៣០.៤៦៣	១០០	៤,៤	០,៥	៩២,៧	១,៣	០,១	០,៩	០,០	០,០

សម្គាល់ ៖ មិនរាប់បញ្ចូលផ្នែកការងារដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៥.១. ភាគរយអ្នកមានការងារធ្វើ ៥ ឆ្នាំឡើង បែងចែកតាមភេទ ផ្នែកការងារ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ក្រុមអាយុ	ចំនួនអ្នកមានការងារធ្វើ	សរុប	វិស័យការងារ							
			រដ្ឋាភិបាល	អង្គភាពស្វយ័ត	សហគ្រាសឯកជនកម្ពុជា	សហគ្រាសបរទេស	ស្ថាប័នមិនយកប្រាក់ចំណេញ	ផ្នែកគ្រួសារ	ស្ថានទូតស្ថាប័នអន្តរជាតិ	ផ្សេងទៀត
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)	(១០)	(១១)
២០២៤										
ជនបទ										
ទាំងពីរភេទ	**៥.៧៣៤.០៣៦**	**១០០**	**៤,០**	**០,៤**	**៧៦,៩**	**១៧,៩**	**០,២**	**០,៦**	**០,០**	**០,០**
៥ – ១៤	៣៦.៦៣៨	១០០	០,០	០,៧	៨១,៩	១៤,២	២,០	១,១	០,០	០,០
១៥ – ៥៩	៥.១៥១.៥៩៣	១០០	៣,៩	០,៥	៧៥,១	១៩,៨	០,១	០,៦	០,០	០,០
៦០ ឆ្នាំឡើងទៅ	៥៤៥.៨០៤	១០០	៤,៧	០,០	៩៣,៧	១,០	០,៣	០,៣	០,០	០,០
ប្រុស	**៣.០០៤.៥៨១**	**១០០**	**៥,០**	**០,៥**	**៧៨,៨**	**១៥,២**	**០,២**	**០,២**	**០,០**	**០,០**
៥ – ១៤	២៤.១៦២	១០០	០,០	០,២	៨៥,១	១១,៧	៣,០	០,០	០,០	០,០
១៥ – ៥៩	២.៦៩៦.៧៦២	១០០	៤,៨	០,៦	៧៧,៥	១៦,៧	០,២	០,២	០,០	០,០
៦០ ឆ្នាំឡើងទៅ	២៨៣.៦៥៧	១០០	៧,៨	០,០	៩០,៤	១,៣	០,៥	០,០	០,០	០,០
ស្រី	**២.៧២៩.៤៥៥**	**១០០**	**២,៨**	**០,៣**	**៧៤,៨**	**២១,០**	**០,១**	**១,០**	**០,០**	**០,០**
៥ – ១៤	១២.៤៧៦	១០០	០,០	១,៧	៧៥,៨	១៩,២	០,០	៣,៣	០,០	០,០
១៥ – ៥៩	២.៤៥៤.៨៣១	១០០	៣,០	០,៣	៧២,៤	២៣,១	០,១	១,១	០,០	០,០
៦០ ឆ្នាំឡើងទៅ	២៦២.១៤៨	១០០	១,២	០,០	៩៧,២	០,៧	០,២	០,៦	០,០	០,០

សម្គាល់ ៖ មិនរាប់បញ្ចូលផ្នែកការងារដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

៥.៦. ចំណាត់ថ្នាក់ការងារតាមមុខរបរ និងសកម្មភាពសេដ្ឋកិច្ច

ព័ត៌មានសកម្មភាពសេដ្ឋកិច្ច និងមុខរបររបស់អ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ (បានធ្វើការងារពីមុន) ដែលទទួលបានពីអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ត្រូវបានយកមកដាក់លេខកូដនៅការិយាល័យកណ្តាល ដោយអនុវត្តតាមចំណាត់ថ្នាក់បទដ្ឋានអន្តរជាតិនៃសកម្មភាពសេដ្ឋកិច្ច និងចំណាត់ថ្នាក់បទដ្ឋានអន្តរជាតិនៃមុខរបរជំនាន់ទី៤។ តារាង ៥.៦.១ បង្ហាញពីការបែងចែកអាជីព និងតារាង ៥.៦.២ បង្ហាញពីការបែងចែកសកម្មភាពសេដ្ឋកិច្ចរបស់អ្នកមានការងារធ្វើ ទៅតាមភេទ និងតំបន់នៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២៤។ យើងសង្កេតថាភាគរយនៃផ្នែកកសិកម្មមានការធ្លាក់ចុះដល់ភាគរយប្រហាក់ប្រហែលនឹងភាគរយនៃផ្នែកសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ។ ដូចនេះ វិស័យកសិកម្មក៏មានការធ្លាក់ចុះពី ៥៤,៧ ភាគរយ (ឆ្នាំ២០១៩) ដល់ ៣៤,៥ ភាគរយ (ឆ្នាំ២០២៤) ក្នុងតារាង ៥.៦.២ ដែលយើងសង្កេតឃើញថា និន្នាការនេះមានការធ្លាក់ចុះជាលំដាប់ក្នុងរង្វង់ ១៧,៦ ភាគរយ ចាប់ពីឆ្នាំ២០០៨ មកឆ្នាំ២០១៩ និងបន្តធ្លាក់ចុះពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤ ក្នុងរង្វង់ ២០,២ ភាគរយ។ នេះឆ្លុះបញ្ចាំងថាប្រទេសកម្ពុជាកំពុងតែឆ្ពោះទៅជាប្រទេសដែលមានសេដ្ឋកិច្ចមិនពឹងផ្អែកលើវិស័យកសិកម្មជាចម្បង។

នៅឆ្នាំ២០២៤ ភាគរយអ្នកធ្វើការផ្នែកកសិកម្មមានការធ្លាក់ចុះដល់ ៣០ ភាគរយ ដែលស្ទើរតែស្មើទៅនឹងភាគរយរបស់អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ (២៥,៩ ភាគរយ) ហើយភាគរយអ្នកផ្តល់សេវាកម្ម និងលក់ បានកើនឡើងដល់ ១៩,១ ភាគរយ។ នេះ គឺជាមុខរបរជំនាញ ដែលភាគច្រើនអ្នកមានការងារបានធ្វើនៅក្នុងសេដ្ឋកិច្ចកម្ពុជា ហើយវាក៏បានឆ្លុះបញ្ចាំងថា ទីផ្សារការងារជំនាញនៅកម្ពុជា បានងើបឡើង ប៉ុន្តែការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញការងារនៅតែត្រូវការបន្ថែម ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារប្រកួតប្រជែងអោយកាន់តែប្រសើរ។

ក្នុងចំណោមក្រុមមុខរបរចម្បងទាំងប្រាំបួន ក្រុមមុខរបរចំនួនបី ដែលសមាមាត្ររបស់ស្ត្រីខ្ពស់ជាងបុរស គឺរួមមាន ក្រុមមុខរបរជំនាញកសិកម្ម ព្រៃឈើ និងនេសាទ ជំនាញទាក់ទងនឹងសេវាកម្ម និងលក់ ហើយនឹងជំនាញជាស្មៀន។ ទោះបីជាក្រុមមុខរបរចំនួនពីរ មានភាពខុសគ្នាក្នុងកម្រិតទាប ក៏អាជីពផ្នែកសេវាកម្ម និងលក់ មានភាពខុសគ្នារហូតដល់ ១០,៤ ភាគរយ រវាងអ្នកធ្វើការបុរស និងស្ត្រី។

នៅទីប្រជុំជន ភាគច្រើននៃអ្នកមានការងារធ្វើ មានមុខរបរជាអ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ (៣០,៤ ភាគរយ) អ្នកផ្តល់សេវាកម្ម និងលក់ (២៧,៥ ភាគរយ) និងអ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១១,៩ ភាគរយ)។ ចំណែកនៅតំបន់ជនបទ កសិកម្មនៅតែដើរតួយ៉ាងសំខាន់ (៤២,០ ភាគរយ) ទោះបីជាភាគរយនៃអ្នកធ្វើកសិកម្មក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះគួរអោយកត់សម្គាល់ បន្ទាប់មកផ្នែសិប្បកម្ម (២២,៩ ភាគរយ) និងផ្នែកសេវាកម្ម និងលក់ដូរ (១៣,៤ ភាគរយ)។

បើធៀបនឹងឆ្នាំ២០១៩ អ្នកមានការងារធ្វើភាគច្រើន មានមុខរបរជំនាញកសិកម្ម ព្រៃឈើ និងនេសាទ និងអ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ ដែលមានភាគរយប្រហាក់ប្រហែលគ្នា ខណៈពេលដែលមុខរបរផ្សេងទៀតមានការកើនឡើង។

តារាង ៥.៦.១. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើអាយុ ៥ ឆ្នាំឡើង ទៅតាមមុខរបរ អាជីព ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤

ក្រុមអាជីព		ភាគរយនៃអ្នកមានការងារធ្វើ					
ក្រុម	បរិយាយ	២០១៩			២០២៤		
		ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)
សរុប							
ចំនួនអ្នកមានការងារធ្វើ		**៨.៥៣៦.៣៥៨**	**៤.៣១៥.៧៦២**	**៤.២២០.៥៩៦**	**៩.៤៩៥.៣៦៧**	**៤.៩៧៦.៥០៥**	**៤.៥១៨.៨៦៣**
	សរុប	១០០	១០០	១០០	១០០	១០០	១០០
១	អ្នកគ្រប់គ្រង	០,៩	១,១	០,៦	២,៣	៣,១	១,៤
២	អ្នកមានវិជ្ជាជីវៈជំនាញ	៣,៥	៤,២	២,៩	៤,៣	៤,៤	៤,៣
៣	អ្នកបច្ចេកទេស និងវិជ្ជាជីវៈពាក់ព័ន្ធ	១,៤	២,០	០,៨	២,០	២,៦	១,៣
៤	អ្នកធ្វើការខាងស្មៀន	៣,៣	៣,៨	២,៧	១,៦	១,៥	១,៨
៥	អ្នកផ្តល់សេវាកម្ម និងលក់	១២,៦	១០,១	១៥,១	១៩,១	១៤,១	២៤,៥
៦	អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	៥៣,៤	៥២,០	៥៤,៩	៣០,០	២៩,៥	៣០,៥
៧	អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ	១៦,៦	១៥,១	១៨,១	២៥,៩	២៦,៨	២៤,៨
៨	ការីម៉ាស៊ីន រោងចក្រ ផ្នែកបញ្ជា និងអ្នកផ្គុំតម្លើង	២,៣	៤,០	០,៥	៤,៣	៧,៣	១,០
៩	អ្នកធ្វើការមុខរបរងាយៗ	៦,០	៧,៦	៤,៤	១០,៦	១០,៧	១០,៤

សម្គាល់ ៖ មិនរាប់បញ្ចូលមុខរបរដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៦.១. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើអាយុ ៥ ឆ្នាំឡើង ទៅតាមមុខរបរ អាជីព ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ក្រុមអាជីព		ភាគរយនៃអ្នកមានការងារធ្វើ					
ក្រុម	បរិយាយ	២០១៩			២០២៤		
		ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)
ទីប្រជុំជន							
ចំនួនអ្នកមានការងារធ្វើ		៣.៣០៧.៧៧៤	១.៧២២.៤៣២	១.៥៨៥.៣៤២	៣.៧៩៦.៦៥៥	២.០០៤.១៥៥	១.៧៩២.៥០០
	សរុប	១០០	១០០	១០០	១០០	១០០	១០០
១	អ្នកគ្រប់គ្រង	១,៥	១,៧	១,៣	៣,៧	៤,៧	២,៥
២	អ្នកមានវិជ្ជាជីវៈជំនាញ	៥,៣	៥,៨	៤,៧	៦,០	៦,២	៥,៩
៣	អ្នកបច្ចេកទេស និងវិជ្ជាជីវៈពាក់ព័ន្ធ	២,៥	៣,៣	១,៦	៣,២	៤,២	២,១
៤	អ្នកធ្វើការខាងស្មៀន	៧,៣	៨,៣	៦,២	២,២	២,០	២,៤
៥	អ្នកផ្តល់សេវាកម្ម និងលក់	២២,៨	១៨,៣	២៧,៧	២៧,៥	២១,៤	៣៤,៤
៦	អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	២០,៨	២០,៩	២០,៧	១១,៩	១២,២	១១,៥
៧	អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ	២៨,១	២៤,៧	៣១,៨	៣០,៤	៣០,០	៣០,៨
៨	ការីម៉ាស៊ីន រោងចក្រ ផ្នែកបញ្ជា និងអ្នកផ្គុំតម្លើង	៤,២	៧,៣	០,៨	៦,៥	១១,១	១,៣
៩	អ្នកធ្វើការមុខរបរងាយៗ	៧,៥	៩,៦	៥,២	៨,៨	៨,៣	៩,៣

សម្គាល់ ៖ មិនរាប់បញ្ចូលមុខរបរដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៦.១. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើអាយុ ៥ ឆ្នាំឡើង ទៅតាមមុខរបរ អាជីព ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ក្រុមអាជីព		ភាគរយនៃអ្នកមានការងារធ្វើ					
ក្រុម	បរិយាយ	២០១៩			២០២៤		
		ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)
ជនបទ							
ចំនួនអ្នកមានការងារធ្វើ		៥.២២៨.៥៨៤	២.៥៩៣.៣៣០	២.៦៣៥.២៥៤	៥.៦៩៨.៧១៣	២.៩៧២.៣៥០	២.៧២៦.៣៦៣
	សរុប	១០០	១០០	១០០	១០០	១០០	១០០
១	អ្នកគ្រប់គ្រង	០,៥	០,៧	០,២	១,៤	២,០	០,៧
២	អ្នកមានវិជ្ជាជីវៈជំនាញ	២,៥	៣,១	១,៩	៣,២	៣,២	៣,២
៣	អ្នកបច្ចេកទេស និងវិជ្ជាជីវៈពាក់ព័ន្ធ	០,៧	១,២	០,៣	១,២	១,៥	០,៨
៤	អ្នកធ្វើការខាងស្មៀន	០,៧	០,៩	០,៥	១,៣	១,២	១,៤
៥	អ្នកផ្តល់សេវាកម្ម និងលក់	៦,១	៤,៧	៧,៥	១៣,៤	៩,២	១៨,១
៦	អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	៧៤,១	៧២,៦	៧៥,៤	៤២,០	៤១,១	៤៣,០
៧	អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ	៩,៣	៨,៧	៩,៩	២២,៩	២៤,៧	២០,៩
៨	ការីម៉ាស៊ីន រោងចក្រ ផ្នែកបញ្ជា និងអ្នកផ្គុំតម្លើង	១,១	១,៨	០,៣	២,៨	៤,៨	០,៨
៩	អ្នកធ្វើការមុខរបរងាយៗ	៥,១	៦,៣	៤,០	១១,៨	១២,៤	១១,២

សម្គាល់ ៖ មិនរាប់បញ្ចូលមុខរបរដែលមិនបានរាយការណ៍ និងកងកម្លាំងប្រដាប់អាវុធ។

តារាង ៥.៦.២ បានបង្ហាញពីការបែងចែកភាគរយនៃប្រជាជនអាយុ ៥ឆ្នាំឡើង ដែលមានការងារធ្វើទៅតាមសកម្មភាពសេដ្ឋកិច្ច។ លទ្ធផលចុងក្រោយនៃជំរឿនប្រជាជនឆ្នាំ២០១៩ បានបង្ហាញអោយឃើញថា វិស័យកម្មន្តសាល ពាណិជ្ជកម្មលក់ដុំលក់រាយ ជួសជុលយានយន្ត និងទោចក្រយានយន្ត សំណង់ និងសេវាកម្មផ្សេងទៀត មានការកើនឡើង ក្នុងខណៈពេលដែលសមាមាត្រការងារក្នុងវិស័យកសិកម្មមានការថយចុះ ហើយនិន្នាការនេះបាននាំអោយរចនាសម្ព័ន្ធសេដ្ឋកិច្ចប្រទេសកម្ពុជាកំពុងតែផ្លាស់ប្តូរទៅកេឧស្សាហកម្មទំនើប និងសម័យភាវូបនីយកម្ម។ និន្នាការនេះក៏នៅតែបន្តរកើតមាននៅក្នុងឆ្នាំ២០២៤ លើកលែងតែសមាមាត្រការងារក្នុងវិស័យដែលពាក់ព័ន្ធនឹងសិល្បៈ ការកំសាន្ត និងការសប្បាយប៉ុណ្ណោះ ដែលបានធ្លាក់ចុះ (តារាង ៥.៦.២)។ លើសពីនេះ តារាងនេះបានបង្ហាញថា សមាមាត្រក្នុងវិស័យកសិកម្ម មានការថយចុះក្នុងរង្វង់ ២០,២ ភាគរយ ក្នុងរយៈ ៥ ឆ្នាំកន្លងមកនេះ។ សមាមាត្រនៃវិស័យកម្មន្តសាល បានកើនឡើងដល់ ១៧,៨ ភាគរយ បន្ទាប់មកវិស័យពាណិជ្ជកម្មលក់ដុំលក់រាយ ជួសជុលយានយន្ត និងទោចក្រយានយន្តបានកើនដល់ ១៣,៨ ភាគរយ ហើយវិស័យសំណង់ បានកើនដល់ ៨,២ ភាគរយ។ ក្នុងចំណោមវិស័យទាំងអស់ វិស័យនៃសកម្មភាពសេវាកម្មដទៃទៀត សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក និងសកម្មភាពអង្គការ និងស្ថាប័នអន្តរជាតិ បានកើនឡើង ២ ភាគរយ ០,៨ ភាគរយ និង០,១ ភាគរយ តាមលំដាប់រៀង បើធៀបទៅនឹងឆ្នាំ២០១៩ សម្រាប់វិស័យទាំងបីនេះ។

តារាង ៥.៦.២. ការបែងចែកភាគរយនៃប្រជាជនមានការងារធ្វើ តាមសកម្មភាពការងារ អាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤

ប្រភេទសកម្មភាព		ភាគរយនៃអ្នកមានការងារធ្វើ					
ផ្នែក	បរិយាយ	២០១៩			២០២៤		
		ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)
សរុប							
ចំនួនអ្នកមានការងារធ្វើ		៨.៦១២.៣៦៧	៤.៣៨៨.១៩៥	៤.២២៤.១៧២	៩.៥៧៩.១៥៤	៥.០៥១.០៣០	៤.៥២៨.១២៤
	សរុប	១០០	១០០	១០០	១០០	១០០	១០០
ក	កសិកម្ម ព្រៃឈើ និងនេសាទ	៥៤.៧	៥៣.០	៥៦.៥	៣៤.៥	៣៤.០	៣៥.១
ខ	រុករករ៉ែ និងថ្ម	០.១	០.១	0,0**	១.១	១.២	១.០
គ	ផលិតកម្ម	១៣.៣	៩.៣	១៧.៤	១៧.៨	១៣.១	២២.៩
ឃ	អគ្គិសនី ឧស្ម័ន ចំហាយទឹក និងការផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់	០.២	០.៣	០.១	០.១	០.២	០.០
ង	ការផ្គត់ផ្គង់ទឹក លូទឹក ការគ្រប់គ្រងសំរាម និងសកម្មភាពបង្ការ	០.១	០.១	០.១	០.៤	០.៦	០.៣
ច	សំណង់	៥.២	៨.១	២.២	៨.២	១៣.០	២.៩
ឆ	ពាណិជ្ជកម្មលក់ដុំ និងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត	១០.៧	៨.៩	១២.៦	១៣.៨	១០.៦	១៧.៤
ជ	ដឹកជញ្ជូន និងឃ្លាំង	២.៥	៤.៤	០.៦	៤.៣	៧.៥	០.៨
ឈ	សកម្មភាពសេវាកម្មទីស្នាក់អាស្រ័យ និងម្ហូបអាហារ	១.៨	១.៤	២.១	៥.៣	៣.៨	៧.០
ញ	ព័ត៌មាន និងគមនាគមន៍	០.១	០.២	០.១	០.៤	០.៥	០.២
ដ	សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង	០.៧	០.៩	០.៦	១.៤	១.៨	១.០
ឋ	អចលនទ្រព្យ	០.៥	០.៦	០.៥	០.១	០.១	០.១
ឌ	សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស	២.២	២.៦	១.៩	០.៧	០.៦	០.៧
ឍ	សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ	៣.០	៤.៩	១.១	១.៧	១.៨	១.៥
ណ	រដ្ឋបាលសាធារណៈ និងការការពារ សន្តិសុខសង្គម	១.៨	១.៩	១.៧	៣.៣	៥.០	១.៤
ត	ការសិក្សាអប់រំ	០.៦	០.៦	០.៦	២.០	១.៨	២.៣
ថ	សកម្មភាពសុខាភិបាល និងការងារសង្គម	០.៧	០.៧	០.៧	០.៨	០.៨	០.៧
ទ	សិល្បៈ ការកំសាន្ត និងការសប្បាយ	១.៧	២.០	១.៤	១.២	១.១	១.៣
ធ	សកម្មភាពសេវាកម្មដទៃទៀត	០.០	០.០	០.០	២.០	២.០	២.១
ន	សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក	០.០	០.០	០.០	០.៨	០.៥	១.១
ប	សកម្មភាពអង្គការ និងស្ថាប័នអន្តរជាតិ	០.០	០.០	០.០	០.១	០.១	០.១

សម្គាល់ ៖ មិនរាប់បញ្ចូលសកម្មភាពសេដ្ឋកិច្ចដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៦.២. ការបែងចែកភាគរយនៃប្រជាជនមានការងារធ្វើ តាមសកម្មភាពការងារ អាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ប្រភេទសកម្មភាព		ភាគរយនៃអ្នកមានការងារធ្វើ					
ផ្នែក	បរិយាយ	២០១៩			២០២៤		
		ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)
ទីប្រជុំជន							
ចំនួនអ្នកមានការងារធ្វើ		៣,៣៩២,១០៣	១,៧៦៥,១១០	១,៥៨៦,៩៩៣	៣,៨៤៥,១១៨	២,០៤៦,៤៤៩	១,៧៩៨,៦៦៨
	សរុប	១០០	១០០	១០០	១០០	១០០	១០០
ក	កសិកម្ម ព្រៃឈើ និងនេសាទ	៥៤.៧	៥៣.០	៥៦.៥	១៣.៥	១៣.៨	១៣.២
ខ	រុករករ៉ែ និងថ្ម	០.១	០.១	០.០**	១.១	១.១	១.០
គ	ផលិតកម្ម	១៣.៣	៩.៣	១៧.៤	២២.៩	១៦.៤	៣០.៤
ឃ	អគ្គិសនី ឧស្ម័ន ចំហាយទឹក និងការផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់	០.២	០.៣	០.១	០.២	០.៣	០.១
ង	ការផ្គត់ផ្គង់ទឹក លូទឹក ការគ្រប់គ្រងសំរាម និងសកម្មភាពបង្ការ	០.១	០.១	០.១	០.៦	០.៧	០.៥
ច	សំណង់	៥.២	៨.១	២.២	៧.៤	១២.៣	១.៨
ឆ	ពាណិជ្ជកម្មលក់ដុំ និងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត	១០.៧	៨.៩	១២.៦	១៨.៤	១៤.៦	២២.៨
ជ	ដឹកជញ្ជូន និងឃ្លាំង	២.៥	៤.៤	០.៦	៦.៨	១១.៧	១.២
ឈ	សកម្មភាពសេវាកម្មទីស្នាក់អាស្រ័យ និងម្ហូបអាហារ	១.៨	១.៤	២.១	៨.៣	៦.២	១០.៧
ញ	ព័ត៌មាន និងគមនាគមន៍	០.១	០.២	០.១	០.៧	១.០	០.៤
ដ	សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង	០.៧	០.៩	០.៦	២.០	២.៤	១.៥
ឋ	អចលនទ្រព្យ	០.៥	០.៦	០.៥	០.១	០.១	០.១
ឌ	សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស	២.២	២.៦	១.៩	១.២	១.០	១.៣
ឍ	សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ	៣.០	៤.៩	១.១	២.៦	២.៧	២.៥
ណ	រដ្ឋបាលសាធារណៈ និងការការពារ សន្តិសុខសង្គម	១.៨	១.៩	១.៧	៥.១	៧.៤	២.៤
ត	ការសិក្សាអប់រំ	០.៦	០.៦	០.៦	២.៣	១.៩	២.៨
ថ	សកម្មភាពសុខាភិបាល និងការងារសង្គម	០.៧	០.៧	០.៧	១.០	១.១	១.០
ទ	សិល្បៈ ការកំសាន្ត និងការសប្បាយ	១.៧	២.០	១.៤	១.៥	១.៤	១.៥
ធ	សកម្មភាពសេវាកម្មដទៃទៀត	០.០	០.០	០.០	៣.០	២.៧	៣.៤
ន	សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក	០.០	០.០	០.០	១.១	០.៧	១.៤
ប	សកម្មភាពអង្គការ និងស្ថាប័នអន្តរជាតិ	០.០	០.០	០.០	០.២	០.២	០.២

សម្គាល់ ៖ មិនរាប់បញ្ចូលសកម្មភាពសេដ្ឋកិច្ចដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

តារាង ៥.៦.២. ការបែងចែកភាគរយនៃប្រជាជនមានការងារធ្វើ តាមសកម្មភាពការងារ អាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩ - ២០២៤ (ត)

ប្រភេទសកម្មភាព		ភាគរយនៃអ្នកមានការងារធ្វើ					
ផ្នែក	បរិយាយ	២០១៩			២០២៤		
		ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)
ជនបទ							
ចំនួនអ្នកមានការងារធ្វើ		៥,២៦០,២៦៤	២,៦២៣,០៨៥	២,៦៣៧,១៧៩	៥,៧៣៤,០៣៦	៣,០០៤,៥៨១	២,៧២៩,៤៥៥
	សរុប	១០០	១០០	១០០	១០០	១០០	១០០
ក	កសិកម្ម ព្រៃឈើ និងនេសាទ	៥៤.៧	៥៣.០	៥៦.៥	៤៨.៦	៤៧.៨	៤៩.៥
ខ	រុករករ៉ែ និងថ្ម	០.១	០.១	០.០**	១.១	១.២	១.០
គ	ផលិតកម្ម	១៣.៣	៩.៣	១៧.៤	១៤.៣	១០.៩	១៨.០
ឃ	អគ្គិសនី ឧស្ម័ន ចំហាយទឹក និងការផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់	០.២	០.៣	០.១	០.១	០.១	០.០
ង	ការផ្គត់ផ្គង់ទឹក លូទឹក ការគ្រប់គ្រងសំរាម និងសកម្មភាពបង្ការ	០.១	០.១	០.១	០.៤	០.៥	០.២
ច	សំណង់	៥.២	៨.១	២.២	៨.៨	១៣.៤	៣.៧
ឆ	ពាណិជ្ជកម្មលក់ដុំ និងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត	១០.៧	៨.៩	១២.៦	១០.៧	៧.៩	១៣.៨
ជ	ដឹកជញ្ជូន និងឃ្លាំង	២.៥	៤.៤	០.៦	២.៧	៤.៦	០.៥
ឈ	សកម្មភាពសេវាកម្មទីស្នាក់អាស្រ័យ និងម្ហូបអាហារ	១.៨	១.៤	២.១	៣.៣	២.១	៤.៦
ញ	ព័ត៌មាន និងគមនាគមន៍	០.១	០.២	០.១	០.១	០.២	០.១
ដ	សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង	០.៧	០.៩	០.៦	១.១	១.៤	០.៧
ឋ	អចលនទ្រព្យ	០.៥	០.៦	០.៥	០.០	០.១	០.០
ឌ	សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស	២.២	២.៦	១.៩	០.៣	០.៤	០.២
ឍ	សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ	៣.០	៤.៩	១.១	១.០	១.១	០.៩
ណ	រដ្ឋបាលសាធារណៈ និងការការពារ សន្តិសុខសង្គម	១.៨	១.៩	១.៧	២.២	៣.៤	០.៨
ត	ការសិក្សាអប់រំ	០.៦	០.៦	០.៦	១.៨	១.៧	២.០
ថ	សកម្មភាពសុខាភិបាល និងការងារសង្គម	០.៧	០.៧	០.៧	០.៦	០.៦	០.៦
ទ	សិល្បៈ ការកំសាន្ត និងការសប្បាយ	១.៧	២.០	១.៤	១.០	០.៩	១.២
ធ	សកម្មភាពសេវាកម្មដទៃទៀត	០.០	០.០	០.០	១.៤	១.៤	១.៣
ន	សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក	០.០	០.០	០.០	០.៦	០.៣	០.៩
ប	សកម្មភាពអង្គការ និងស្ថាប័នអន្តរជាតិ	០.០	០.០	០.០	០.១	០.០	០.១

សម្គាល់ ៖ មិនរាប់បញ្ចូលសកម្មភាពសេដ្ឋកិច្ចដែលមិនបានរាយការណ៍សម្រាប់ជំរឿនឆ្នាំ២០១៩។

រូប ៥.៦.១ បង្ហាញពីភាគរយការងារតាមវិស័យការងារចំនួនបី គឺវិស័យការងារចម្បង (កសិកម្ម) វិស័យការងារទីពីរ (ឧស្សាហកម្ម) និងវិស័យការងារទីបី (សេវាកម្ម)។ វិស័យការងារចម្បង គឺទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ចផ្នែក **ក** ដែលមានក្នុងតារាង ៥.៦.២។ ផ្នែកទីពីរ គឺមានសកម្មភាពសេដ្ឋកិច្ចរួមចាប់ពីផ្នែក **ខ** ដល់ **ច** ចំណែកផ្នែកទីបី គឺចាប់ពីផ្នែក **ឆ** ដល់ **ប**។

តារាង ៥.៦.៣ បង្ហាញពីភាគរយនៃអ្នកមានការងារធ្វើ តាមវិស័យការងារ (កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម) ដែលបែងចែកតាមភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩-២០២៤។ តារាងបង្ហាញអោយឃើញថា ប្រជាជនកម្ពុជាធ្វើការក្នុងវិស័យទីបី (សេវាកម្ម) មាន ៣៧,៩ ភាគរយ ខ្ពស់ជាងវិស័យចម្បង (កសិកម្ម) ដែលបានធ្លាក់ចុះដល់ ៣៤,៥ ភាគរយ ចំណែកវិស័យទីពីរ (ឧស្សាហកម្ម) មាន ២៧,៦ ភាគរយ ក្នុងឆ្នាំ២០២៤។ និន្នាការនេះ មានភាពផ្ទុយគ្នាពីឆ្នាំ២០១៩ ដែលវិស័យចម្បង (៥៤,៧ ភាគរយ) គឺខ្ពស់ជាងគេ បន្ទាប់មកវិស័យទីបី (២៦,៥ ភាគរយ) និងទីពីរ (១៨,៨ ភាគរយ)។

រូប ៥.៦.១. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើ ៥ ឆ្នាំឡើង តាមវិស័យការងារ ភេទ កម្ពុជា ឆ្នាំ២០១៩-២០២៤



តារាង ៥.៦.៣. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើ តាមវិស័យការងារ ភេទ និងតំបន់កម្ពុជាឆ្នាំ២០១៩-២០២៤

វិស័យការងារ	សរុប			ទីប្រជុំជន			ជនបទ		
	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី	ទាំងពីរភេទ	ប្រុស	ស្រី
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)	(៩)	(១០)
២០១៩									
សរុប	១០០	១០០	១០០	១០០	១០០	១០០	១០០	១០០	១០០
វិស័យចម្បង	៥៤,៧	៥៣	៥៦,៥	២១,៤	២១,៣	២១,៤	៧៥,៩	៧៤,៣	៧៧,៦
វិស័យទីពីរ	១៨,៨	១៨	១៩,៧	៣១,១	២៨,៦	៣៤	១១	១០,៨	១១,២
វិស័យទីបី	២៦,៥	២៩	២៣,៨	៤៧,៥	៥០,១	៤៤,៦	១៣,១	១៤,៩	១១,៣
២០២៤									
សរុប	១០០	១០០	១០០	១០០	១០០	១០០	១០០	១០០	១០០
វិស័យចម្បង	៣៤,៥	៣៤,០	៣៥,១	១៣,៥	១៣,៨	១៣,២	៤៨,៧	៤៧,៩	៤៩,៥
វិស័យទីពីរ	២៧,៦	២៨,១	២៧,១	៣២,២	៣០,៩	៣៣,៦	២៤,៦	២៦,២	២២,៨
វិស័យទីបី	៣៧,៩	៣៧,៩	៣៧,៨	៥៤,៣	៥៥,៣	៥៣,២	២៦,៨	២៦,០	២៧,៧

ទេសន្តរប្រវេសន៍ ៦

៦.១. សេចក្តីផ្តើម

ទេសន្តរប្រវេសន៍ត្រូវបានកំណត់ជាដំណើរការផ្លាស់ប្តូរទីកន្លែងរស់នៅ ពីទីតាំងភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត។ នៅពេលដែលចលនាស្ថិតនៅក្នុងប្រទេសតែមួយត្រូវបានចាត់ទុកថាជាការធ្វើទេសន្តរប្រវេសន៍ក្នុងស្រុក ហើយករណីពាក់ព័ន្ធនឹងការផ្លាស់ប្តូរប្រទេសហៅថា ការធ្វើទេសន្តរប្រវេសន៍អន្តរជាតិ។ ការរួមបញ្ចូល គ្នាជាមួយលទ្ធភាពបង្កើតកូន មរណភាព និងទេសន្តរប្រវេសន៍បានកំណត់នូវទំហំ និងអត្រាកំណើនប្រជាជនក៏ដូចជារចនាសម្ព័ន្ធ និងចរិតលក្ខណៈ។ ប្រធានបទនេះមានសារៈសំខាន់ និងចំណាប់អារម្មណ៍ មិនសម្រាប់តែប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អ្នកសេដ្ឋកិច្ច អ្នកសង្គមកិច្ច អ្នកភូមិសាស្ត្រ មនុស្សសាស្ត្រ អ្នកវិទ្យាសាស្ត្រនយោបាយ អ្នកច្បាប់ និងអ្នកធ្វើគោលនយោបាយ អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រងសាធារណៈផងដែរ។

ទេសន្តរប្រវេសន៍ គឺជាចលនាភូមិសាស្ត្ររបស់ប្រជាជនឆ្លងកាត់ព្រំដែន ដែលបានបញ្ជាក់សម្រាប់គោលបំណងតាំង ទីលំនៅអចិន្ត្រៃយ៍ ឬពាក់កណ្តាលអចិន្ត្រៃយ៍។ ទន្ទឹមនឹងការកើត និងការស្លាប់ ទេសន្តរប្រវេសន៍គឺជាសមាសធាតុនៃការបម្រែបម្រួលប្រជាជន។ ពាក្យ "អន្តោប្រវេសន៍" និង "និរប្រវេសន៍" ត្រូវបានប្រើដើម្បីសំដៅទៅលើការផ្លាស់ប្តូររវាងប្រទេស (ទេសន្តរប្រវេសន៍អន្តរជាតិ)។ ពាក្យស្របគ្នា "ទេសន្តរប្រវេសន៍ក្នុងស្រុក" និង "ទេសន្តរប្រវេសន៍ក្រៅស្រុក" ត្រូវបានប្រើប្រាស់សម្រាប់ទេសន្តរប្រវេសន៍ក្នុងប្រទេស។ សម្រាប់គោលបំណងនៃការវិភាគនេះទេសន្តរប្រវេសន៍ សំដៅទៅលើមនុស្សណាម្នាក់ដែលបានផ្លាស់ទៅកន្លែងរាប់សម្មាសន៍យ៉ាងហោចណាស់ពីភូមិផ្សេងទៀត (ឬពីប្រទេសផ្សេងទៀត) ដែលជាទីលំនៅចុងក្រោយរបស់មនុស្សនោះ។

៦.២. ចំនួនជនទេសន្តរប្រវេសន៍

យោងតាមលទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ២០២៤ ស្ទើរតែ ៦៣ ភាគរយនៃប្រជាជនកម្ពុជាមិនដែលមានទីលំនៅដ្ឋានផ្សេងក្រៅពីកន្លែងធ្វើសម្ភាសន៍ (តារាង ៦.២.១)។ នៅតំបន់ទីប្រជុំជនមានតិចជាងជនបទ (៥៩,៧ ភាគរយ និង ៦៦,១ ភាគរយ)។ និយាយដោយឡែកភាគរយនៃទេសន្តរប្រវេសន៍នៅកម្ពុជាមាន ៣៧ ភាគរយ តំបន់ទីប្រជុំជនមាន ៤៣ ភាគរយ និងនៅតំបន់ជនបទមាន ២៣ ភាគរយ។ លទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជាឆ្នាំ២០២៤ ភាគរយនៃជនទេសន្តរប្រវេសន៍ក្នុងចំណោមប្រជាជនបានកើនឡើង។ ក្នុងរយៈពេល ៥ ឆ្នាំ ភាគរយនៃប្រជាជនតែងតែរស់នៅកន្លែងតែមួយបានថយចុះទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ។ និន្នាការនេះដូចគ្នា រវាងប្រុស និង ស្រី។

តារាង ៦.២.១. ចំនួនប្រជាជនតែងតែរស់នៅកន្លែងសម្ភាសន៍ តាមតំបន់ កម្ពុជាឆ្នាំ ២០១៩-២០២៤

តំបន់	ឆ្នាំ	ទាំងពីរភេទ		ប្រុស		ស្រី	
		ចំនួន	ភាគ	ចំនួន	ភាគ	ចំនួន	ភាគ
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)	(៨)
សរុប	២០១៩	១២.២១៤.៥៤២	៧៨.៥	៥.៨១៩.៦៨២	៧៩.៩	៦.៣៩៤.៨៦០	៨០,១
	២០២៤	១០.៨៧៧.៣០៤	៦២,៩	៥.០៦៥.៥៩៦	៥៩,៧	៥.៨១១.៧០៩	៦៦,១
ទីប្រជុំជន	២០១៩	៣.៩៦៧.១៥៥	៦៤,៧	១.៨៩២.៨៣៤	៦៣,២	២.០៧៤.៣២១	៦៦,០
	២០២៤	៤.០៧៤.១៤៧	៥៦,៨	១.៨៩៨.៣៨៥	៥៤,២	២.១៧៥.៧៦២	៥៩,៣
ជនបទ	២០១៩	៨.២៤៧.៣៨៧	៨៧,៦	៣.៩២៦.៨៤៨	៨៥,៨	៤.៣២០.៥៣៩	៨៩,៣
	២០២៤	៦.៨០៣.១៥៨	៦៧,៣	៣,១៦៧,២១១	៦៣,៥	៣.៦៣៥.៩៤៧	៧១,០

សម្គាល់ ៖ មិនរាប់បញ្ចូលទេសន្តរប្រវេសន៍ដែលលំនៅដ្ឋានពីមុនមិនបានរាយការណ៍។

ការវិភាគទិន្នន័យនៅក្នុងរបាយការណ៍នេះមិនអាចពន្យល់ពីនិន្នាការបានក្បោះក្បាយឡើយ។ តម្រូវឲ្យមានការវិភាគស៊ីជម្រៅ ដោយការពិចារណាក្នុងការបង្កើតតារាងជាមួយអថេរផ្សេងទៀតដើម្បីឲ្យកាន់តែយល់ច្បាស់អំពីស្ថានភាពនៃការធ្វើទេសន្តរប្រវេសន៍ សម្រាប់របាយការណ៍នេះ មានសារៈសំខាន់ណាស់ក្នុងការបញ្ជាក់ពីចលនាទេសន្តរប្រវេសន៍ ដែលមាននិន្នាការធ្លាក់ចុះនៅកម្ពុជា។

តារាង ៦.២.២. ភាគរយនៃជនទេសន្តរប្រវេសន៍តាមទីលំនៅមុន ភេទ កម្ពុជា ឆ្នាំ២០១៩-២០២៤

កន្លែងរស់នៅពីមុន	ទាំងពីរភេទ		ប្រុស		ស្រី	
	២០១៩	២០២៤	២០១៩	២០២៤	២០១៩	២០២៤
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
ចំនួនទេសន្តរប្រវេសន៍	៣.៣១៨.៤០២	៦.៤០៣.២៣៩	១.៧៤២.៣១១	៣.៤២៤.៨២៣	១.៥៧៦.០៩១	២.៩៧៨.៤១៦
សរុប	១០០	១០០	១០០	១០០	១០០	១០០
ក្នុងខេត្តសម្ភាសន៍	៣៧,១	៤៨,៥	៣៨,០	៤៩,៣	៣៦,១	៤៧,៦
ក្នុងខេត្តផ្សេងទៀត	៥៨,៨	៤៤,៩	៥៧,៦	៤៣,៣	៦០,២	៤៦,៧
ក្រៅប្រទេសកម្ពុជា	៤,១	៦,៦	៤,៤	៧,៤	៣,៧	៥,៧

សម្គាល់៖ មិនរាប់បញ្ចូលទេសន្តរប្រវេសន៍ដែលលំនៅដ្ឋានពីមុនមិនបានរាយការណ៍ (៩៦៨ នាក់) ។

យោងតាមលទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ ចំនួនទេសន្តរប្រវេសន៍ភាគច្រើនទាំងពីរភេទមានទីលំនៅពីមុននៅខេត្តផ្សេងទៀត (៤៨,៥ ភាគរយ)។ ម្យ៉ាងទៀតចលនាទេសន្តរប្រវេសន៍ដែលកំពុងលេចធ្លោនាបច្ចុប្បន្នគឺរវាងខេត្ត និងខេត្ត។ ទោះជាយ៉ាងណាក៏ដោយជំរឿនលើកមុនបានបង្ហាញថា នៅឆ្នាំ២០១៩ ចលនាទេសន្តរប្រវេសន៍ដែលលេចធ្លោជាងគេ គឺរវាងខេត្ត និងខេត្ត។ ជាក់ស្តែងនិន្នាការទេសន្តរប្រវេសន៍ពីក្នុងខេត្តទៅខេត្តផ្សេងទៀត។ និន្នាការនេះបានកើតមានក្នុងចំណោមទាំងប្រុស និងស្រី។

ដូចក្នុងករណីមុនដែរ ការពន្យល់និន្នាការនេះ តម្រូវឲ្យមានការវិភាគបន្ថែមទៀតដោយរួមបញ្ចូលអថេរផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយវាអាចបង្ហាញសម្មតិកម្មទាក់ទងនឹងដំណើរការនៃការរីកចម្រើននៅតំបន់ទីប្រជុំជន។ សមាសធាតុទេសន្តរប្រវេសន៍នៃនគរូបនីយកម្មតែងផ្សារភ្ជាប់ជាមួយចលនាទាក់ទងនឹងចម្ងាយឆ្ងាយ។ ចលនានេះបង្ហាញពីទម្រង់នៃការកើនឡើងទេសន្តរប្រវេសន៍រវាងខេត្តមួយទៅខេត្តមួយផ្សេងទៀត ក៏ដូចជាការធ្វើទេសន្តរប្រវេសន៍ពីជនបទទៅទីប្រជុំជន ដែលមានចម្ងាយឆ្ងាយជំនួសឲ្យចលនាពីខេត្តមួយទៅខេត្តមួយផ្សេងទៀត គឺពីជនបទទៅជនបទក្នុងខេត្តតែមួយ។

៦.៣. មូលហេតុសម្រាប់ទេសន្តរប្រវេសន៍

ជំរឿនប្រជាជនកម្ពុជា ក៏បានបញ្ចូលនូវសំណួរស្តីពីមូលហេតុទាក់ទងនឹងទេសន្តរប្រវេសន៍ផងដែរ។ តារាង ៦.៣.១ បានបង្ហាញព័ត៌មានតាមអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ និងជំរឿនឆ្នាំ២០១៩។ មូលហេតុចម្បងសម្រាប់ទេសន្តរប្រវេសន៍ផ្តល់ដោយអ្នកសម្ភាសន៍នៅក្នុងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ និងជំរឿនឆ្នាំ២០១៩ គ្រួសារផ្លាស់ទីលំនៅ។ មូលហេតុសម្រាប់ទេសន្តរប្រវេសន៍នេះអនុវត្តចំពោះសមាជិកគ្រួសារដែលបានផ្លាស់ទៅកន្លែងសម្ភាសន៍ពីទីលំនៅមុន ដោយសារគ្រួសារទាំងមូលបានផ្លាស់ទីលំនៅ។ ឧទាហរណ៍ បើសមាជិកគ្រួសារណាម្នាក់ (ជាពិសេសមេគ្រួសារ) បានធ្វើទេសន្តរប្រវេសន៍ទៅកន្លែងផ្សេងទៀត ដោយសារប្តូរទីកន្លែងការងាររបស់គាត់ មូលហេតុនៃទេសន្តរប្រវេសន៍ គឺការប្តូរទីកន្លែងធ្វើការ។ សម្រាប់សមាជិកដ៏ទៃទៀតនៃគ្រួសារនេះ ក៏ត្រូវបានផ្លាស់ប្តូរទីលំនៅជាមួយគាត់ មូលហេតុសម្រាប់ទេសន្តរប្រវេសន៍ គឺគ្រួសារផ្លាស់ទីលំនៅ។ មូលហេតុដោយសារអាពាហ៍ពិពាហ៍ គឺជាករណីដូចគ្នានេះដែរ។ ទេសន្តរប្រវេសន៍ស្រីមានសមាមាត្រខ្ពស់ចំពោះមូលហេតុនេះ ភាគរយនៃទេសន្តរប្រវេសន៍ ដោយសារមូលហេតុដ៏ទៃទៀតខ្ពស់ក្នុងចំណោមប្រុស រួមមានការប្តូរកន្លែងការងារ ការស្វែងរកការងារ និងអាពាហ៍ពិពាហ៍។

តារាង ៦.៣.១. ភាគរយបែងចែកតាមមូលហេតុសម្រាប់ជនទេសន្តរប្រវេសន៍តាមភេទ កម្ពុជា ឆ្នាំ២០១៩-២០២៤

កន្លែងរស់នៅពីមុន	ទាំងពីរភេទ		ប្រុស		ស្រី	
	២០១៩	២០២៤	២០១៩	២០២៤	២០១៩	២០២៤
(១)	(២)	(៣)	(៤)	(៥)	(៦)	(៧)
ចំនួនទេសន្តរប្រវេសន៍	៣.៣៣៧.៦៦៩	៦.៤០៣.២៣៩	១.៧៥២.១៥៥	៣.៤២៤.៨២៣	១.៥៨៥.៥១៤	២.៩៧៨.៤១៦
សរុប	១០០	១០០	១០០	១០០	១០០	១០០
ប្តូរកន្លែងធ្វើការ	១០,៨	៦,៩	១២,៤	៧,៨	៩,១	៥,៩
ស្វែងរកការងារធ្វើ	១៩,៤	២៥,៤	១៩,៥	២៦,៥	១៩,៤	២៤,១
ការសិក្សា	២,៦	៣,៤	២,៩	៣,៣	២,៣	៣,៦
រៀបអាពាហ៍ពិពាហ៍	១៩,៧	២៤,០	២៤,០	២៩,៦	១៤,៩	១៧,៥
គ្រួសារផ្លាស់លំនៅដ្ឋាន	៣៨,៩	៣៣,២	៣៣,៥	២៧,១	៤៤,៩	៤០,២
មាតុភូមិនិវត្តន៍/ មកភូមិ	០,៦	០,២	០,៦	០,២	០,៧	០,៣
គ្រោះធម្មជាតិ	០,១	០,១	០,១	០,១	០,១	០,១
តម្រូវឲ្យផ្លាស់ប្តូរទីកន្លែង	០,១	០,១	០,១	០,១	០,១	០,១
តម្រូវឲ្យផ្លាស់ប្តូរទីកន្លែង	០,៣	០,៣	០,៣	០,២	០,៣	០,៣
អសន្តិសុខ	០,៧	០,៤	០,៦	០,៣	០,៨	០,៥
កូនកំព្រា	២,១	៣,៧	១,៧	២,៥	២,៥	៥,០
បាត់បង់ដីធ្លី/ បាត់បង់ទី	០,២	០,២	០,២	០,២	០,២	០,១
មកលេង	២,៣	០,៧	១,៦	០,៦	៣,១	០,៩
មូលហេតុផ្សេងៗ	១,៨	១,៣	២,៣	១,៤	១,៣	១,២
មិនបានរាយការណ៍	០,២	០,០	០,២	០,០	០,២	០,០

សម្គាល់ ៖ * នៅអង្កេតចន្លោះជំរឿន ២០២៤ បូកបន្ថែម តម្រូវឲ្យផ្លាស់ទីកន្លែងដោយសារសង់ទំនប់វារីអគ្គិសនី និងតម្រូវឲ្យផ្លាស់ទីកន្លែងដោយសារប៉ះគម្រោង។

៦.៤. ចរន្តទេសន្តរប្រវេសន៍

មូលហេតុចម្បងសម្រាប់ទេសន្តរប្រវេសន៍ផ្តល់ដោយអ្នក សម្ភាសន៍នៅក្នុងអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ និងជំរឿនឆ្នាំ២០១៩ គ្រួសារផ្លាស់ទីលំនៅ។ ឆ្នាំ២០១៩ ចរន្តទេសន្តរប្រវេសន៍ភាគច្រើនគឺពីជនបទទៅទីប្រជុំជន ឈរក្នុងលំដាប់ទី១ និងទីប្រជុំជនទៅទីប្រជុំជនឈរលំដាប់ទី២។ ដោយឡែកអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ មានការផ្លាស់ប្តូរទម្រង់គួរឲ្យកត់សម្គាល់គឺទេសន្តរប្រវេសន៍ពីជនបទទៅជនបទ និងទីប្រជុំជនទៅទីប្រជុំជនក្លាយជាចរន្តដ៏សំខាន់នាពេលបច្ចុប្បន្ន ហើយក៏ធ្វើទេសន្តរប្រវេសន៍ទីប្រជុំជនទៅទីប្រជុំជនផងដែរ។ ការប្រែប្រួលនេះរំលេចនូវនិន្នាការដ៏ខ្លាំងនៃការធ្វើនគរូបនីយកម្មទីប្រជុំជន។

យោងតាមអង្កេតចចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ភាគច្រើននៃទេសន្តរប្រវេសន៍បានរស់នៅកន្លែងសម្ភាសន៍យ៉ាងហោចណាស់ ៥ ឆ្នាំមុនពេលធ្វើអង្កេតចន្លោះជំរឿន ៦៤,០ភាគរយ។ សមាមាត្រអ្នកដែលរស់នៅទីលំនៅបច្ចុប្បន្ន របស់ពួកគេពី ២០+ ឆ្នាំ មុនពេលធ្វើអង្កេតចន្លោះជំរឿន ២៦,៧ ភាគរយ។

ប្រជាជនភាគច្រើនបានធ្វើទេសន្តរប្រវេសន៍ក្នុងអាយុធ្វើការ ចន្លោះពី ២០-៣៩ ឆ្នាំ។ យោងតាមលទ្ធផលអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ ជិតពាក់កណ្តាលនៃទេសន្តរប្រវេសន៍ ស្ថិតក្នុងក្រុមអាយុនេះ ទាំងប្រុស និងស្រី។ គួរកត់សម្គាល់ថា ប្រជាជនអាយុ ១០ឆ្នាំឡើង មាន ៥៧,៨ ភាគរយ ស្ថិតក្នុងក្រុមអាយុកម្លាំងពលកម្ម ការបែងចែកអាយុជន ទេសន្តរប្រវេសន៍មានភាពប្រហាក់ប្រហែលគ្នាជាមួយប្រជាជនទូទៅ។ ភាគរយខ្ពស់នៃទេសន្តរប្រវេសន៍ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅជនបទ ជាពិសេសវិស័យកសិកកម្ម(៤១ភាគរយ), រុករករ៉ែ និងថ្ម(១៥,៥ភាគរយ) ពាណិជ្ជកម្មលក់យានយន្តដុំ និងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត (១១,៦ភាគរយ) និងសំណង់ (១១,០ ភាគរយ) ។

ជាទូទៅ ជនទេសន្តរប្រវេសន៍ភាគច្រើនមានកម្រិតសិក្សាអប់រំទាបជាងប្រជាជនមិនបានធ្វើទេសន្តរប្រវេសន៍។ ក្នុងចំណោមប្រជាជន ២៨,២ ភាគរយបានបញ្ចប់ការសិក្សាបឋម ខណៈដែលមានតែ ២៨,៩ ភាគរយក្នុងចំណោមជនទេសន្តរប្រវេសន៍។ ប្រមាណ ១៨,២ ភាគរយនៃចំនួនប្រជាជនទូទៅបានបញ្ចប់មធ្យមសិក្សាបឋមភូមិ និង ១៩,៦ភាគរយ សម្រាប់ជនទេសន្តរប្រវេសន៍។

១១.៩. លទ្ធភាពបង្កើតកូន

លទ្ធភាពបង្កើតកូនជាចំនួនកូនកើតរស់ដែលស្ត្រីម្នាក់ៗបានបង្កើត។ លទ្ធភាពមានកូនផ្សេងពីសមត្ថភាពបង្កើតកូនដែលកំណត់ដោយលក្ខណៈជីវសាស្ត្រអំពីសមត្ថភាពដែលស្ត្រីអាចមានកូន។ លទ្ធភាពមានកូនកំណត់ដោយកត្តាភូមិសាស្ត្រដែលហៅថាអថេរមធ្យម អាយុនៅពេលរៀបការ (ការប្រើប្រាស់មធ្យោបាយពន្យាកំណើត រយៈពេលបំបៅដោះកូន។ល។) លទ្ធភាពមានកូនប៉ះពាល់ដោយកត្តាចម្បងជាច្រើនទៀត ដូចជាកត្តាសង្គមវប្បធ៌ម បរិស្ថាន សេដ្ឋកិច្ច និងសុខភាព។

នៅកម្ពុជា អត្រាកំណើតដុល(CBR)ឆ្នាំ២០២៤ មាន ២០,៦ ក្នុងចណោម ១.០០០ នាក់កំណើតរស់ និងមាន ៧៦ កំណើតរស់ក្នុងចំណោមស្ត្រីវ័យបន្តពូជ (១៥-៤៩ឆ្នាំ) ១.០០០ នាក់។ អត្រាលទ្ធភាពបង្កើតកូនសរុប (TFR)នៅកម្ពុជាឆ្នាំ២០២៤ មានជាង២នាក់ ទៅតាមវិធីសាស្ត្រគណនា ក្នុងចំណោមស្ត្រីអាយុវ័យបន្តពូជម្នាក់។

បច្ចុប្បន្ន ការធ្លាក់ចុះលទ្ធភាពបង្កើតកូនគួរឱ្យកត់សម្គាល់នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបានកំពុងជួបប្រទះស្ថានភាពផ្ទុយគ្នានឹងប្រជាជនវ័យចាស់។ ដោយឡែកនៅកម្ពុជាកំណើនទារកនៅទសវត្សរ៍ឆ្នាំ១៩៨០ ១៩៩០ និងឆ្នាំ២០០០ បានក្លាយជាចលករជម្រុញកំណើនពលកម្មនាពេលបច្ចុប្បន្នដែលហៅថាឱកាស ឬភាគលាភប្រជាសាស្ត្រ។ ការបើកឱកាសនេះបានកើតឡើងបន្ទាប់ពីការមានការធ្លាក់ចុះក្នុងកម្លាំងពលកម្មដែលជាផ្នែកមួយនៃចំនួនប្រជាជនសរុបខុសពីធម្មតា។ ដោយសារការធ្លាក់ចុះលទ្ធភាពបង្កើតកូននាបច្ចុប្បន្ន ក៏នៅមិនទាន់ស្ថិតក្នុងកម្រិតភាគរយនៃប្រជាជនវ័យចាស់ខ្ពស់ឡើយ។ ដំណើរការកំណើនសេដ្ឋកិច្ចនិងសង្គមកិច្ចត្រូវផ្សារភ្ជាប់នឹងការកើនឡើងសេដ្ឋកិច្ចខ្ពស់ ជាពិសេស ប្រសិនបើការអភិវឌ្ឍបានផ្សារភ្ជាប់នឹងការវិនិយោគលើវិស័យសុខាភិបាល និងការអប់រំ។ នៅពេលរចនាសម្ព័ន្ធអាយុផ្លាស់ទៅក្នុងបរិបទដែលប្រជាជនវ័យចាស់កើនឡើងក្នុងកម្រិតមួយខ្ពស់នោះ ការទទួលបានឱកាស ឬភាគលាភប្រជាសាស្ត្រក៏នឹងត្រូវបានបិទបន្តិចម្តងៗផងដែរ។

រាជរដ្ឋាភិបាល និងសង្គមទាំងមូលគួរទាញយកផលប្រយោជន៍ពីសមាសភាពអាយុដែលជាអំណោយផលសម្រាប់ការវិនិយោគដើម្បីទទួលបាននូវកំណើនសេដ្ឋកិច្ចខ្ពស់។ ភាគលាភប្រជាសាស្ត្រតែងទទួលបានការចាប់អារម្មណ៍ ជាពិសេសក្នុងចំណោមអ្នករៀបចំផែនការ អ្នកគ្រប់គ្រង និងអ្នកនយោបាយក្នុងរយៈពេលប៉ុន្មាននឆ្នាំខាងមុខនេះ។

១០.១០. មរណភាព

មរណភាពសំដៅលើការស្លាប់ដែលកើតឡើងក្នុងចំណោមប្រជាជន។ ប្រូបាប៊ីលីតេនៃការស្លាប់ក្នុងអំឡុងពេលណាមួយទទួលរងដោយឥទ្ធិពលកត្តាជាច្រើនដូចជាអាយុ ភេទ ការអប់រំ សេវាសុខភាព និងស្ថានភាពសេដ្ឋកិច្ចជាដើម។ អត្រាមរណភាពឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីកម្រិតជីវភាពរស់នៅ និងសេវាសុខភាពសាធារណៈរបស់ប្រជាជននៃប្រទេសមួយ។

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ អត្រាមរណភាពទារកមានក្នុងរង្វង់ ១៣,០ នាក់ក្នុងចំណោម ១០០០ កំណើតរស់ក្នុងនោះទារកប្រុសស្លាប់ខ្ពស់ជាងទារកស្រី ៧ នាក់ក្នុងចំណោម ១០០០ កំណើតរស់(ស្លាប់ ១៦,៦ នាក់ ទល់នឹង ១០,០ នាក់)។ អត្រាមរណភាពទារក និងកុមារអាយុក្រោម ៥ ឆ្នាំ មានខ្ពស់នៅជនបទ (១៣,៥ នាក់ និង ២១,៧ នាក់ក្នុង ១.០០០ កំណើតរស់តាមលំដាប់រៀង) ជាងទីប្រជុំជន (១១,៤ នាក់ និង ១៨,៩ នាក់ក្នុង ១.០០០ កំណើតរស់តាមលំដាប់រៀង)។

អត្រាមរណភាពទារកបានថយចុះពី ១៧,៦ នាក់ចំណោម ១.០០០ កំណើតរស់នៅឆ្នាំ២០១៩ មក ១៣ នាក់ ក្នុងចំណោម ១.០០០ កំណើតរស់នៅឆ្នាំ២០២៤។ អត្រាមរណកុមារអាយុក្រោម ៥ ឆ្នាំបានថយចុះពី ២៨,១ នាក់ក្នុងចំណោម ១.០០០ កំណើតរស់មក ២១,៧ នាក់ក្នុងចំណោម ១.០០០ កំណើតរស់។

យោងតាមអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ទិន្នន័យដោយផុល (មិនកែតម្រូវ) ត្រូវបានគណនាឃើញផលធៀប ឬអត្រាមរណភាពមាតាមាន ១៣៤ ក្នុងចំណោម ១០០.០០០ កំណើតរស់។

តាមរយៈការគណនាមរណភាពនិងតារាងវដ្តជីវិតក្នុងឆ្នាំ២០២៤ អាយុសង្ឃឹមរស់សម្រាប់មនុស្សប្រុសមាន ៧៤,៩ ឆ្នាំ ខណៈដែលមនុស្សស្រីមាន ៧៨,៩ ឆ្នាំ ។

១១.១១. ពិការភាព

ជាលើកទីមួយហើយដែលសំណួរអំពីពិការក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ សម្រាប់មនុស្សអាយុ ៥ ឆ្នាំឡើង ត្រូវបានបញ្ចូលទៅក្នុងតារាងសំណួរអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ (បង្គោល ៤ នៃតារាងសំណួរគ្រួសារផ្នែក២៖ ផ្នែកសេដ្ឋកិច្ច និងសង្គម)។ ក្នុងចំណោមប្រជាជនពិការទាំងអស់ ១.៦៤០.២៥៩ នាក់ក្នុងនោះពិការខ្លះៗ មាន ៧៣,១ ភាគរយ ពិការខ្លាំងមាន ២១,៩ ភាគរយ និងពិការមិនអាចធ្វើអ្វីបានសោះមាន ៥,០ ភាគរយ ។

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ អត្រាពិការភាពនៅកម្ពុជាកើនឡើងនៅគ្រប់កម្រិតនៃពិការ ពេលអាយុកើនឡើង (រូប ៩.២.១) អត្រាពិការកើនពី ១,២ ភាគរយ សម្រាប់ក្រុមអាយុ ៥-១៤ ឆ្នាំ ទៅ ៥២,១ ភាគរយ សម្រាប់ក្រុមអាយុ ៦០ ឆ្នាំឡើង។ ជនពិការបានចាប់ផ្ដើមកើនយ៉ាងខ្លាំងនៅក្នុងក្រុមអាយុវ័យកណ្ដាលពី ២,៣ ភាគរយ សម្រាប់ក្រុមអាយុ ១៥-៣៤ ឆ្នាំ ទៅ ១១,២ ភាគរយ សម្រាប់អាយុ ៣៥-៥៩ ឆ្នាំ និងកើនឡើងដល់ ៥២,១ ភាគរយ ក្នុងចំណោមប្រជាជនអាយុ ៦០ ឆ្នាំ ឡើង ។

ស្ថានភាពអាពាហ៍ពិពាហ៍ក្នុងចំណោមប្រជាជនមានពិការណាមួយ អាយុ ១៥ ឆ្នាំឡើង ភាគច្រើនបានរៀបការ មានក្នុងអត្រា ៦០,៦ ភាគរយ មេម៉ាយប្ដីស្លាប់ ឬពោះម៉ាយប្រពន្ធស្លាប់មាន ២៣,៤ ភាគរយ មេម៉ាយ ឬពោះម៉ាយ លែងលះមាន ៥,៣ ភាគរយ និងទំនាស់រស់នៅផ្សេងគ្នា មាន ០,៦ ភាគរយ ។ ទោះយ៉ាងណាក៏ដោយ មានស្ត្រីមេម៉ាយ ប្ដីស្លាប់ ឬលែងលះគ្នា និងទំនាស់រស់នៅផ្សេងគ្នាច្រើនជាងបុរសនៅគ្រប់កម្រិតតំបន់ ។

អត្រាប្រជាជនជាបុរសដែលចេះអាន និងសរសេរខ្ពស់ជាងស្ត្រី នៅគ្រប់កម្រិតពិការភាព។ អត្រានៃប្រជាជនដែលមានពិការណាមួយដែលបានបញ្ចប់ថ្នាក់ពេញលេញមានលក្ខណៈទាបនៅឡើយ។ ប្រមាណជា ៥៧,៥ ភាគរយនៃប្រជាជនកម្ពុជា មានកម្រិតពិការណាមួយមិនបានបញ្ចប់ថ្នាក់បឋមសិក្សា ម្យ៉ាងទៀតមានសមាមាត្រតិចតួចប៉ុណ្ណោះ (២,២ ភាគរយ) នៃប្រជាជនអក្ខរភាពមិនធ្លាប់បានបញ្ចប់ថ្នាក់ណាមួយ ។

ភាគរយនៃប្រជាជនមានកម្រិតពិការណាមួយមានការងារធ្វើមាន ៤៩,៥ ភាគរយ ក្នុងនោះបុរសមាន ៦០,១ ភាគរយ ដែលខ្ពស់ជាងស្ត្រីមានតែ ៤១,៦ ភាគរយ។ លើសពីនេះ អត្រាសកម្មភាពសេដ្ឋកិច្ចដុលនៃប្រជាជនទូទៅមាន ៦០,៦ ភាគរយ ដែលខ្ពស់ជាងអត្រាសកម្មសេដ្ឋកិច្ចដុលនៃប្រជាជនដែលមានពិការណាមួយ។

១១.១២. លក្ខណៈផ្ទះសម្បែង និងគ្រួសារ

ចំនួនខ្នងផ្ទះក្នុងប្រទេសកម្ពុជាបានកើនឡើងពី ៣.១៨១.៣៧២ នៅឆ្នាំ២០១៩ ដល់ ៣.៧៣៥.៦៥៩ នៅឆ្នាំ២០២៤។ កំណើននេះគិតជាភាគរយ មាន ១៧,៤ ភាគរយ ក្នុងកន្លះទសវត្សរ៍ ឆ្នាំ ២០១៩-២០២៤។ នៅប្រទេសកម្ពុជាទាំងមូល សំណង់សម្រាប់ប្រើប្រាស់ជាលំនៅដ្ឋាន មាននិន្នាការធ្លាក់ចុះពី ៩៣,២ ភាគរយ នៅឆ្នាំ ២០១៩ មក ៨៦,៨ ភាគរយ នៅឆ្នាំ២០២៤ ។

ផ្អែកទៅលើសម្ភារៈសំណង់ដំបូល និងជញ្ជាំងមាន ៩១,៦ ភាគរយនៃលំនៅដ្ឋាន និងផ្នែកនៃអគារ គឺជាប្រភេទអគារអចិន្ត្រៃយ៍ជាប់បានយូរ។ ប្រមាណ ៨,០ ភាគរយ នៃអគារ គឺជាប្រភេទសំណង់ជាប់បានមធ្យម និង ០,៤ ភាគរយ នៃអគារគឺជាប្រភេទបណ្តោះអាសន្ន។ នៅតំបន់ជនបទ ប្រមាណ ១០,២ ភាគរយនៃរចនាសម្ព័ន្ធសំណង់លំនៅដ្ឋាន ប្រើសម្ភារៈជាប់ជាមធ្យម និង ០,៥ ភាគរយនៃរចនាសម្ព័ន្ធសំណង់លំនៅដ្ឋានប្រើសម្ភារៈបណ្តោះអាសន្ន។

គ្រួសារប្រក្រតី ឬធម្មតា

អង្កេតចន្លោះជំរឿនឆ្នាំ២០២៤ បានស្រង់យកតែគ្រួសារប្រក្រតី ឬធម្មតាប៉ុណ្ណោះ។ ទំហំគ្រួសារគិតជាមធ្យមក្នុងមួយគ្រួសារបានកើនឡើងពី ៤,៣ នាក់ នៅឆ្នាំ២០១៩ ទៅ ៤,៦ នាក់ នៅឆ្នាំ២០២៤។ នៅទីប្រជុំជន ទំហំសមាជិកគ្រួសារបានកើនឡើង ០,១ នាក់ ក្នុងរយៈពេលកន្លះទសវត្សរ៍នេះ និងតំបន់ជនបទ ០,៥ នាក់។

ភាគរយនៃគ្រួសារមានស្ត្រីជាមេគ្រួសារពុំមានការប្រែប្រួលឡើយ កន្លះទសវត្សរ៍នេះ បានស្ថិតនៅក្នុងរង្វង់ប្រមាណ ២៧ ភាគរយ។ ភាគច្រើនស្ត្រីជាមេគ្រួសារទាំងនោះ មានក្នុងក្រុមអាយុ ៣០ ដល់ ៥៩ឆ្នាំ។ ស្ត្រីដែលជាមេគ្រួសារនៅលំដាប់អាយុនេះបានកើនឡើងបន្តិច នៅឆ្នាំ ២០១៩ មាន ៥៧,៧ ភាគរយ និងឆ្នាំ២០២៤ មាន ៥៨,០ ភាគរយ។ អង្កេតចន្លោះជំរឿនឆ្នាំ២០២៤ បានបង្ហាញថាប្រមាណ ១៨,៩ ភាគរយនៃមេគ្រួសារ ជាគ្រួសារពោះម៉ាយ/មេម៉ាយ លែងលះ ទំនាស់រស់នៅផ្សេងគ្នា នៅលីវ ឬមិនទាន់រៀបការ ៣,៨ ភាគរយ និងបានរៀបការហើយ ៧៧,៣ ភាគរយ។

ជាទូទៅ គ្រួសារភាគច្រើន (៥០,១ ភាគរយ) កាន់កាប់លំនៅដ្ឋានមួយបន្ទប់តែប៉ុណ្ណោះ ហើយគ្រួសារដែលកាន់កាប់លំនៅដ្ឋាន ពីរបន្ទប់មាន ៣១,៤ ភាគរយ គ្រួសារកាន់កាប់លំនៅដ្ឋានមានបីបន្ទប់ ១២,៤ ភាគរយ និងគ្រួសារកាន់កាប់លំនៅដ្ឋាន មានបួនបន្ទប់ឡើងទៅ មាន ៦,១ ភាគរយ។

ប្រភពទឹកស្អាតសម្រាប់ពិសារ

ដូចនៅក្នុងជំរឿនឆ្នាំ២០១៩ ព័ត៌មានស្តីពីសម្ភារៈ និងប្រដាប់ប្រដាប្រើប្រាស់ដែលគ្រួសារក៏ត្រូវប្រមូលក្នុងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ដែរ។ មានប្រមាណ ៨៧ ភាគរយនៃគ្រួសារកម្ពុជាមានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់ នៅឆ្នាំ២០២៤។ ដោយឡែក សមាមាត្រនេះមាន ៧៣ ភាគរយ នៅឆ្នាំ២០១៩។ នៅតំបន់ទីប្រជុំជនមានភាគរយច្រើនជាងគេនៃគ្រួសារដែលមានប្រភពទឹកស្អាតសម្រាប់ទទួលទាន មាន ៩២ ភាគរយ នៅជនបទមានតែ ៨៤ ភាគរយ។

ប្រភពបំភ្លឺ

អគ្គិសនី (រួមមានថាមពលអគ្គិសនី ម៉ាស៊ីនភ្លើង និងទាំងពីរប្រភេទ) ដែលត្រូវប្រើប្រាស់ធ្វើជាប្រភពបំភ្លឺមាន ៩៣,៩ ភាគរយនៃគ្រួសារនៅកម្ពុជាឆ្នាំ២០២៤ បានកើនឡើងខ្ពស់ ប្រៀបធៀបនឹងឆ្នាំ២០១៩ មាន ៨៤,០ ភាគរយ។ ប្រមាណ ៩៨,៧ ភាគរយ នៃគ្រួសារនៅតំបន់ទីប្រជុំជនប្រើអគ្គិសនីសម្រាប់បំភ្លឺ ចំណែកឯគ្រួសារនៅជនបទមានប្រមាណ ៩០,៣ ភាគរយ។

ការប្រើប្រាស់បង្គន់អនាម័យ

ប្រមាណ ៩៣,១ ភាគរយនៃគ្រួសារសរុបនៅក្នុងប្រទេសកម្ពុជាឆ្នាំ២០២៤ មានការកែលម្អស្ថានភាពក្នុងការប្រើប្រាស់បង្គន់អនាម័យនៅតាមទីកន្លែងដែលគេរស់នៅ ចំណែកឯឆ្នាំ២០១៩ មាន ៨២,៨ ភាគរយប៉ុណ្ណោះ។ សម្រាប់នៅទីប្រជុំជនក្នុងឆ្នាំ២០២៤ ការប្រើប្រាស់បង្គន់មាន ៩៦,៣ ភាគរយនៃគ្រួសារ និង ៩០,៧ ភាគរយ នៅជនបទ។ ក្នុងនោះប្រមាណ ៧០,២ ភាគរយនៃគ្រួសារមានបង្គន់អនាម័យនៅតំបន់ជនបទប្រើប្រាស់បង្គន់ដងទឹកចាក់ ឬចុចបង្ហូរទឹកតភ្ជាប់ទៅរណ្ដៅ (Pit) ចំណែកឯនៅទីប្រជុំជនមានត្រឹមតែ ៣៤,៧ ភាគរយ។ ប្រមាណ ៣២,២ ភាគរយនៃគ្រួសារនៅទីប្រជុំជនបានប្រើប្រាស់បង្គន់ដងទឹកចាក់ ឬចុចបង្ហូរទឹក តភ្ជាប់ទៅបណ្ដាញលូសាធារណៈ និងនៅ ជនបទមាន ២,៩ ភាគរយ។

ឥន្ធនៈចម្អិនអាហារ

ជំរឿនឆ្នាំ២០១៩ និងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ បានបង្ហាញថាការប្រើឧសសម្រាប់ចម្អិនអាហារមានការធ្លាក់ចុះជាលំដាប់នៅថ្នាក់ជាតិ ក៏ដូចជា នៅតំបន់ទីប្រជុំជន និងជនបទផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ឧសនៅតែជាថាមពលចម្បងសម្រាប់ប្រជាជន ដែលរស់នៅតំបន់ជនបទមាន ៥៤,៥ ភាគរយ នៅឆ្នាំ២០២៤។

ទ្រព្យសម្បត្តិរបស់គ្រួសារ

ព័ត៌មានអំពីប្រភេទ និងចំនួនសម្ភារៈប្រើប្រាស់ក្នុងគ្រួសារត្រូវបានប្រមូលក្នុងជំរឿនឆ្នាំ២០១៩ និងអង្កេតចន្លោះជំរឿនឆ្នាំ២០២៤។ ព័ត៌មាននេះផ្ដល់នូវការប៉ាន់ស្មានសូចនាករនៃស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន។ អង្កេតចន្លោះជំរឿនឆ្នាំ២០២៤ បង្ហាញថាភាគរយ នៃគ្រួសារដែលមានទូរស័ព្ទដៃប្រើមានរហូតដល់ ៩៦,១ ភាគរយ ទោចក្រយានយន្ត មាន ៨៥,៨ ភាគរយ និងកង់មាន ៥០,៧ ភាគរយ។ គ្រួសារនៅកម្ពុជា យ៉ាងហោចណាស់មានសមាជិកម្នាក់បានប្រើប្រាស់អ៊ីនធឺណែត (រាប់ទាំងនៅផ្ទះ ទូរស័ព្ទដៃ ទីសាធារណៈ និងនៅកន្លែងធ្វើការ) មាន ៨៥,៧ ភាគរយ នៅតំបន់ទីប្រជុំជនមាន ៨៧,០ ភាគរយ និងមាន ៨៤,៨ ភាគរយនៅតំបន់ជនបទ។ ការកើនឡើងនៃភាពជាម្ចាស់របស់គ្រួសារលើកម្មសិទ្ធទ្រព្យសម្បត្តិដែលរៀបរាប់ខាងលើឆ្លុះបញ្ចាំងនូវការផ្លាស់ប្ដូរជាវិជ្ជមាននូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

សន្ទានុក្រម

អាគារ

ជារចនាសម្ព័ន្ធទោលមួយដែលសង់លើដី។ ជួនកាលផ្គុំឡើងដោយវត្ថុធាតុជាច្រើនហើយប្រើប្រាស់សម្រាប់ជាលំនៅដ្ឋានស្នាក់នៅ ឬសហគ្រាស ដូចជាហាងលក់ទំនិញ កន្លែងពាណិជ្ជកម្ម ការិយាល័យ រោងជាង រោងចក្រ សាលារៀន កន្លែងកំសាន្ត កន្លែងធ្វើការ ឃ្លាំង ។ល។ អាគារអាចប្រើប្រាស់ក្នុងគោលបំណងច្រើនប្រភេទ ដូចជាលំនៅដ្ឋានស្នាក់នៅផង និងហាងលក់ទំនិញ ឬអាចជារោងជាងផង ឬជាលំនៅដ្ឋានស្នាក់នៅផង និងកន្លែងធ្វើការផង។

ទីប្រជុំជន

ការធ្វើចំណាត់ថ្នាក់តំបន់ទីប្រជុំជនឡើងវិញនៅកម្ពុជាឆ្នាំ២០២០ ត្រូវបានអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិក្នុងអំឡុងខែមិថុនា ដល់ខែកក្កដាឆ្នាំ២០២០ ដោយប្រើប្រាស់សំណុំទិន្នន័យចុងក្រោយនៃជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ ការសិក្សានេះបានត្រូវបានផ្តល់អនុសាសន៍អំពីចំណាត់ថ្នាក់ទីប្រជុំជននេះដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបីយ៉ាងគឺលើទំហំប្រជាជន ដង់ស៊ីតេប្រជាជន និងអ្នកធ្វើការក្នុងវិស័យមិនមែនកសិកម្មនៅកម្រិតឃុំ។ បន្ទាប់ពីបានគិតគ្រប់ជ្រុងជ្រោយយ៉ាងយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធក្នុងការសិក្សា និងពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ផ្អែកលក្ខណៈវិនិច្ឆ័យដូចខាងក្រោមទៅលើឃុំនីមួយៗ ដើម្បីចាត់ថ្នាក់ជាទីប្រជុំជន ឬជនបទ ៖

១. ទិដ្ឋភាពសេដ្ឋកិច្ច និងប្រជាសាស្រ្ត

ទំហំប្រជាជនសរុបក្នុងឃុំចាប់ពី ២០០០ នាក់ឡើង
ដង់ស៊ីតេប្រជាជនក្នុងឃុំចាប់ពី ២០០ នាក់ក្នុង ១ គីឡូម៉ែត្រការ៉េ
អ្នកធ្វើការក្នុងវិស័យមិនមែនវិស័យកសិកម្មលើសពី ៥០ ភាគរយ

២. ទិដ្ឋភាពលក្ខខណ្ឌរដ្ឋបាល

ទីប្រជុំជនដែលបានកំណត់ផ្អែកលើមូលដ្ឋាននៃរដ្ឋបាលតាមច្បាប់ ឬត្រូវបានទទួលស្គាល់ដោយអនុក្រឹត និង ច្បាប់។ ប្រភេទទី ១ ជាទីប្រជុំជនត្រូវបានគេស្គាល់ថាជាទីប្រជុំជនដែលជាក្រុង។ ទីប្រជុំជនទាំងនេះត្រូវបានទទួលស្គាល់ដោយច្បាប់របស់រាជរដ្ឋាភិបាលដូចជារាជធានី និងក្រុងជាដើម ដោយមិនគិតពីទិដ្ឋភាពសេដ្ឋកិច្ច និងប្រជាសាស្រ្តឡើយ។

៣. ទិដ្ឋភាពជាក់ស្តែង និងការពិគ្រោះយោបល់

បន្ទាប់ពីបានគិតគូគ្រប់ជ្រុងជ្រោយយ៉ាងយកចិត្តទុកដាក់ លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធក្នុងការសិក្សាខាងលើ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ បានចុះពិនិត្យស្ថានភាពជាក់ស្តែងលើបណ្តាឃុំដែលចាត់ចូលក្នុងលក្ខណៈ

វិនិច្ឆ័យ និងបានចូលរួមពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសប្រធានមន្ទីរផែនការ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធមួយចំនួនជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ អង្គការ UNICEF អង្គការ UNFPA និង UNHABTAT ។

ជនបទ

តំបន់ផ្សេងពីតំបន់ទីប្រជុំជន គឺជាតំបន់ជនបទ។

អត្រាកំណើនប្រចាំឆ្នាំបែប Exponential

$$r_{EXP} = \ln\left(\frac{X_n}{X_0}\right)/n$$

X_o = ចំនួនប្រជាជនឆ្នាំគោល

X_n = ចំនួនប្រជាជនឆ្នាំចុងគ្រា

n = ចំនួនឆ្នាំរវាង X_o and X_n

ដង់ស៊ីតេប្រជាជន

ត្រូវបានគណនាដោយផលចែកនៃចំនួនប្រជាជន ទៅនឹងផ្ទៃដីសរុបនៅក្នុងតំបន់ជាក់លាក់មួយ។ ដង់ស៊ីតេប្រជាជន គឺជាសន្ទស្សន៍ដ៏សំខាន់មួយនៃសូចនាករប្រជាសាស្ត្រដែលត្រូវបានវាស់វែង សិក្សាពីការប្រមូលផ្តុំរបស់ប្រជាជន។ សន្ទស្សន៍នេះគិតពីចំនួនមនុស្សរស់ក្នុងបរិវេណដីក្នុងមួយគីឡូម៉ែត្រការ៉េ។

សន្ទស្សន៍ Myer

សន្ទស្សន៍ Myer គឺជារង្វាស់ពិនិត្យលើអាយុ លេខខ្ទង់ចុងក្រោយ។ ការកត់ត្រា ឬរាយការណ៍អាយុជំនួសអ្នកដទៃត្រូវបានសំដៅទៅលើអាយុដែលជាចំណង់ចំណូលចិត្តនៃអាយុខ្ទង់ (ដូចជាអាយុ ដែលបញ្ចប់នៅលេខ ០ ឬ ៥)។ ទ្រឹស្តី សន្ទស្សន៍ Myer លាតសន្ធឹងពីអប្បបរមា ០ នៅពេលដែលមិនមានចំណូលចិត្ត និងចៀសវាងតួលេខជាក់លាក់ណាមួយដល់ចំនួនអតិបរមា ៩០ នៅពេលដែលមនុស្សគ្រប់វ័យត្រូវបានគេរាយការណ៍នៅក្នុងខ្ទង់តែមួយ។

តម្លៃសន្ទស្សន៍សន្ទស្សន៍ Myer

ទិន្នន័យមានភាពត្រឹមត្រូវខ្ពស់បើតូចជាង ១០,០

ទិន្នន័យត្រឹមត្រូវត្រឹមត្រូវ ១០,០ – ១៩,៩

ទិន្នន័យមានគុណភាពទាប ២០,០០ – ៣៩,៩

ទិន្នន័យមិនអាចប្រើការបានបើធំជាង ៤០,០

សន្ទស្សន៍ Whipple

ទិន្នន័យអាយុជាទូទៅមិនមានភាពត្រឹមត្រូវ ១០០ ភាគរយនោះទេ ដោយសារហេតុផលជាច្រើន ចាំបាច់ត្រូវវាយតម្លៃវាមុនពេលប្រើប្រាស់។ យោងតាមលទ្ធផលអង្កេតក្រោយជំរឿនមួយចំនួនភាពមិនស៊ីគ្នានៅកម្ពុជាមានកម្រិតទាប។ សន្ទស្សន៍ Whipple ត្រូវបានគណនាសម្រាប់ពិនិត្យគុណភាពទិន្នន័យអាយុ។ សន្ទស្សន៍របស់ Whipple គឺជារង្វាស់ចំ ណង់ចំណូលចិត្តសម្រាប់អាយុដែលបញ្ចប់នៅក្នុងលេខ 0 និង ៥។ ជួររបស់វាគឺចាប់ពី ១០០ បង្ហាញថាគ្មានចំណូលចិត្ត លេខ 0 និង ៥ ដល់ ៥០០ បង្ហាញថាមានតែ 0 និង ៥ ប៉ុណ្ណោះដែលត្រូវបានគេរាយការណ៍។

តម្លៃសន្ទស្សន៍ Whipple

ទិន្នន័យមានភាពត្រឹមត្រូវខ្ពស់បើតូចជាង ១០៥

ទិន្នន័យត្រឹមត្រូវត្រឹមត្រូវ ១០៥ – ១០៩,៩

ទិន្នន័យប្រហាក់ប្រហែល ១១០ – ១២៤,៩

ទិន្នន័យមានគុណភាពទាប ១២៥ – ១៧៤,៩

ទិន្នន័យមិនអាចប្រើការបានបើធំជាង ១៧៥

អាយុ

ជាចំនួនឆ្នាំពេញលេញនៃអាយុគិតដល់ថ្ងៃខួបកំណើតចុងក្រោយ។

ពីរ៉ាមីតប្រជាជន

ពីរ៉ាមីតប្រជាជនបង្ហាញជាលក្ខណៈក្រាហ្វិកតាមក្រុមអាយុ និងភេទប្រជាជន។ ជួរផ្ដេកបង្ហាញពីចំនួន ឬសមាមាត្រនៃបុរស និងស្ត្រីសម្រាប់ក្រុមអាយុនីមួយៗ ផលបូកនៃក្រុមអាយុ និងភេទទាំងអស់ ពីរ៉ាមីតប្រជាជនស្មើនឹង ១០០ ភាគរយ។

មេដ្យានអាយុ

មុនពេលគណនាមេដ្យានអាយុ យើងត្រូវបែងចែកចំនួនប្រជាជនជាចំនួនពីរក្រុមដែលមានទំហំស្មើៗគ្នា (៥០ភាគរយ ទល់នឹង ៥០ភាគរយ) គឺក្រុមដែលអាយុតិចជាង និងក្រុមមួយទៀតមានអាយុច្រើនជាងមេដ្យាន។

$$\text{មេដ្យាន} = \left[L + \frac{(N/២ - C)}{f_m} \right] X\, I$$

N = ចំនួនប្រជាជនសរុប

L = ដែនកំណត់ទាបនៃថ្នាក់មេដ្យាន

f_m = ចំនួននៃថ្នាក់មេដ្យាន (frequency of median class)

C = ប្រេកង់តគ្នានៃថ្នាក់មុនមេដ្យាន

I = ចន្លោះថ្នាក់

ផលធៀបភេទ ឬអត្រាភេទ

ជាផលចែកនៃចំនួនបុរស និងចំនួនស្ត្រីគុណនឹង ១០០ បកស្រាយពីចំនួនបុរសក្នុងចំណោមស្ត្រី ១០០ នាក់។

ផលធៀបអាយុក្នុងបន្ទុក

ជាភាគរយនៃប្រជាជនក្នុងក្រុមអាយុក្មេង (អាយុ ០-១៤ ឆ្នាំ) និងក្រុមអាយុចាស់ ៦០+) ឆ្នាំធៀបទៅនឹងចំនួនប្រជាជនដែលមានអាយុកម្លាំងពលកម្មពី ១៥-៥៩ ឆ្នាំ។ ផលធៀបអាយុក្នុងបន្ទុកនេះអាចគណនាដាច់ដោយឡែកពីគ្នារវាងផលធៀបអាយុក្នុងបន្ទុកវ័យក្មេង និងអាយុក្នុងបន្ទុកវ័យចាស់។

អាយុមធ្យមនៃការរៀបការ Singulate Mean Age at Marriage (SMAM)

អាយុមធ្យមនៃការរៀបការលើកដំបូងត្រូវបានប្រើប្រាស់សម្រាប់ប្រជាជនដែលបានចាត់ថ្នាក់តាមអាយុ និងស្ថានភាពអាពាហ៍ពិពាហ៍ផ្តល់នូវទិន្នន័យតែមួយគត់ស្តីពីស្ថានភាពអាពាហ៍ពិពាហ៍។ វាប្រៀបធៀបសមាមាត្រអាយុជាក់លាក់របស់អ្នកដែលមិនដែលរៀបការជាមួយអ្នកដែលរៀបការហើយ គិតពីអាយុមធ្យមដែលការផ្លាស់ប្តូរត្រូវបានធ្វើឡើង។ សម្រាប់ព័ត៌មានលម្អិតនៃវិធីសាស្ត្រដែលបង្កើតឡើងដោយ John Hajnal ។

$$SMAM = \frac{d + \sum 5_5 S_x - 50 * S_{50}}{1 - S_{50}}$$

d = អាយុរៀបការទាបបំផុត = ១៥

∑ ៥៥Sx = សរុបសមាមាត្រប្រជាជនមិនដែលរៀបការក្រុមអាយុ ៥ ឆ្នាំ

S៥០ = សមាមាត្រប្រជាជនមិនដែលរៀបការនៅអាយុ ៥០ ឆ្នាំ

អក្ខរភាព

មនុស្សត្រូវបានចាត់ទុកថាមិនចេះអក្សរផងដែរ បើមនុស្សនោះមានសមត្ថភាពអានសរសេរតែឈ្មោះ ឬលេខផ្ទាល់ខ្លួន ក៏ដូចជាមនុស្សដែលចេះអានតែមិនចេះសរសេរ ឬក៏ផ្ទុយទៅវិញ។ មនុស្សម្នាក់ដែលចេះអាន និងសរសេរប៉ុន្តែនៅពេលជំរឿនគាត់មិនអាចអាន និងសរសេរបានទៀតទេ ដោយសារតែមានបញ្ហារាងកាយឬជំងឺ ត្រូវបានចាត់ទុកថាជាមនុស្សចេះអក្សរផងដែរ។ ឧទាហរណ៍ មនុស្សវ័យចំណាស់ដែលចេះអាន និងសរសេរ ប៉ុន្តែមិនអាចអនុវត្តសកម្មភាពទាំងនេះបានទៀតដោយសារបញ្ហាភ្នែកខ្សោយ។ ជនពិការដែលអាចអាន និងសរសេរតាមរយៈមធ្យោបាយណាមួយ ដូចជាប្រព័ន្ធប្រៃលសម្រាប់អ្នកពិការភ្នែក ត្រូវបានចាត់ទុកថាជាអ្នកចេះអក្សរ។ តាមនិយមន័យកុមារទាំងអស់ដែលមានអាយុតិចជាង ៦ ឆ្នាំទាំងអស់ត្រូវបានចាត់ទុកថាអនក្ខរភាព។

អត្រាអក្ខរភាពទូទៅ

ជាភាគរយនៃប្រជាជនចេះអក្សរធៀបទៅនឹងចំនួនសរុបប្រជាជនទាំងអស់ ដោយមិនរាប់បញ្ចូលចំនួនក្មេងដែលមានអាយុ ០-៦ ឆ្នាំ។

អត្រាអក្ខរភាពមនុស្សពេញវ័យ

ជាភាគរយប្រជាជនអក្ខរភាពមានអាយុ ១៥ ឆ្នាំឡើង ធៀបនឹងចំនួនសរុបប្រជាជនអាយុ ១៥ ឆ្នាំឡើង។

កម្រិតសិក្សាអប់រំ

កម្រិតថ្នាក់ដែលបានបញ្ចប់ពេញលេញត្រូវបានធ្វើចំណាត់ដូចជា ១= មិនបានបញ្ចប់ថ្នាក់ណាមួយ (០ និង ៨៨) ២= មិនបានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ១ ដល់ ៥) ៣= បានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ៦ ដល់ ៨) ៤= មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៩ ដល់ ១៣) ៥= បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញប័ត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ ១៤ ដល់ ១៨) ៦= ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត ១៩ ដល់ ២១) និង ៧= ផ្សេងទៀត ២២។

ប្រជាជនសកម្មសេដ្ឋកិច្ច

ជាចំនួនប្រជាជនមានការងារធ្វើ និងប្រជាជនគ្មានការងារធ្វើ ដោយឈរលើមូលដ្ឋានសកម្មភាពសំខាន់ៗរបស់គាត់នៅក្នុងរយៈពេលមួយឆ្នាំមុនពេលជំរឿន។

ប្រជាជនអសកម្មសេដ្ឋកិច្ច

ប្រជាជនផ្សេងក្រៅពីប្រជាជនសកម្មសេដ្ឋកិច្ច នៅក្នុងរយៈពេលមួយឆ្នាំមុនជំរឿន។

អត្រាចូលរួមកម្លាំងពលកម្ម

អត្រាចូលរួមកម្លាំងពលកម្ម (LFPR) ត្រូវបានកំណត់ជាចំនួនមនុស្សដែលស្ថិតក្នុងកម្លាំងពលកម្មមានការងារធ្វើ និងគ្មានការងារធ្វើ តាមអាយុ ភេទ និងតំបន់ ចែកនឹងចំនួនមនុស្សសរុបក្នុងចរិតលក្ខណៈដូចគ្នា ហើយគុណនឹង ១០០។

អត្រាសកម្មជនសេដ្ឋកិច្ចនៃក្រុមអាយុធ្វើការងារ

ភាគរយប្រជាជនសកម្មសេដ្ឋកិច្ចធៀបទៅនឹងចំនួនសរុបប្រជាជនអាយុ ១៥-៦៤ ឆ្នាំ។

អត្រាសកម្មជនសេដ្ឋកិច្ចតាមអាយុ

ជាភាគរយប្រជាជនដែលជាសកម្មជនសេដ្ឋកិច្ចក្នុងក្រុមអាយុណាមួយ ធៀបទៅនឹងចំនួនប្រជាជនសរុបនៅក្នុងក្រុមអាយុតាមអាយុជាក់លាក់។

មានការងារធ្វើ

រួមមានប្រជាជនដែលដូចនៅក្នុងប្រភេទខាងក្រោមបានធ្វើក្នុងរយៈពេល ៦ ខែ (១៨៣ថ្ងៃ) ឬលើស ក្នុងរយៈពេលមួយឆ្នាំ មុនជំរឿន ៖

(i) ប្រជាជនដែលមានការងារមានប្រាក់ឈ្នួល(ឧទាហរណ៍ ធ្វើការងារនៅផ្នែកសាធារណៈ ឬអង្គភាពឯកជន ជាដើម) (ii) ប្រជាជនដែលនៅក្នុងពេលធ្វើជំរឿន កំពុងមានការងារធ្វើ និងបានធ្វើពីមុនមក ដោយទទួល ប្រាក់ឈ្នួល ប្រាក់ខែ ប្រាក់ចំណេញ ឬទទួលបានពីគ្រួសារ ជាប្រាក់ ឬជារបស់។ (iii) ប្រជាជនដែលមិនមាន ការងារធ្វើ ដើម្បីទទួលប្រាក់ឈ្នួល ឬប្រាក់ចំណេញ នៅក្នុងអំឡុងពេលជំរឿន ទោះបីពួកគេមានការងារធ្វើពី មុន តែអាចត្រឡប់ទៅធ្វើការវិញ (ឧទាហរណ៍ ចប់រដូវ ដូចជាកសិករ ឬអ្នកនេសាទ) ប្រជាជនឈប់សម្រាក ដោយមានជំងឺ ឬឈប់សម្រាកដោយគ្មានប្រាក់ ប្រជាជនមិនធ្វើការដោយសារមានបញ្ហាកូដកម្ម ឬអង្គភាព ដែលពួកគេធ្វើការត្រូវបានបិទ (iv) ប្រជាជនធ្វើការ ដោយខ្លួនឯង (ឧទាហរណ៍ បើកហាងលក់ទំនិញដោយ ខ្លួនឯង លក់គ្រឿងហូបចុក ជាវេជ្ជបណ្ឌិត មេធាវី ជាដើម)។

អត្រាមានការងារធ្វើ

អត្រាមានការងារធ្វើ ជាផលធៀបនៃចំនួនអ្នកមានការងារធ្វើក្នុងចំណោមកម្លាំងពលកម្ម (សកម្មជន សេដ្ឋកិច្ច) សម្រាប់ ១០០នាក់។

គ្មានការងារធ្វើ

ជាមនុស្សដែលគ្មានការងារ ប៉ុន្តែបានស្វែងរកការងារ ឬត្រៀមធ្វើការងារបានរយៈពេល ៦ ខែ ឬលើស (បើសិនជាមានការងារ) នៅក្នុងអំឡុងពេលមួយឆ្នាំ មុនពេលជំរឿន។

អត្រាគ្មានការងារធ្វើ

អត្រាគ្មានការងារធ្វើ ជាផលធៀបនៃចំនួនអ្នកគ្មានការងារធ្វើ (បានធ្វើការពីមុនបូកមិនដែលធ្វើការសោះ) ក្នុងចំណោមកម្លាំងពលកម្ម (សកម្មជនសេដ្ឋកិច្ច) សម្រាប់ ១០០នាក់។

អាជីពការងារ ឬ វិស័យឧស្សាហកម្ម សេដ្ឋកិច្ច

វិស័យឧស្សាហកម្ម (ផ្នែកមួយនៃសកម្មភាពសេដ្ឋកិច្ច) សំដៅលើសកម្មភាពរបស់សហគ្រាស ឬគ្រឹះស្ថាន ដែលបុគ្គលធ្វើការក្នុងនោះ។ ការងារត្រូវបានរៀបចំជាក្រុមទៅតាមវិស័យដូចខាងក្រោម ៖

វិស័យទីមួយ ៖ ក្រុម A មានកសិកម្ម ព្រៃឈើ និងនេសាទ។

វិស័យទីពីរ ៖ ក្រុម B ដល់ F មានរ៉ែ និងរ៉ែថ្ម រោងចក្រ សហគ្រាស អគ្គិសនី ឧស្ម័នហ្គាស ការផ្គត់ផ្គង់ចំហាយ និងខ្យល់ត្រជាក់ការផ្គត់ផ្គង់ទឹក ទឹកសំអុយ ការគ្រប់គ្រងកាកសំណល់ និងសកម្មភាពកែច្នៃឡើងវិញសំណង់។

វិស័យទីបី ៖ G ទៅ U មានពាណិជ្ជកម្មលក់ដុំ និងលក់រាយ ជួសជុលទោចក្រយានយន្ត និងរថយន្ត ដឹកជញ្ជូន និងការរក្សាទុក សកម្មភាពស្នាក់នៅ និងសេវាកម្មម្ហូបអាហារ ព័ត៌មាន និងការទំនាក់ទំនង គមនាគមន៍ សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង ដីធ្លី និងផ្ទះសំបែង សកម្មភាពផ្នែកវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស សកម្មភាពរដ្ឋបាល និងសេវាកម្មផ្គត់ផ្គង់រដ្ឋបាល សាធារណៈ និងការពារជាតិ សន្តិសុខសង្គម អប់រំ សកម្មភាព សុខភាព និងការងារសង្គម វិចិត្រសិល្បៈ ការកំសាន្ត និងការលំហែ សកម្មភាពសេវាផ្សេងៗ សកម្មភាពការប្រើប្រាស់សេវាគ្រួសារជានិយោជក សកម្មភាពអង្គការ និងអង្គការក្រៅប្រទេស។

ទេសន្តរប្រវេសន៍ (ផ្លាស់លំនៅដ្ឋាន)

ទេសន្តរប្រវេសន៍ត្រូវបានកំណត់ជាដំណើរការផ្លាស់ប្តូរទីកន្លែងរស់នៅ ពីទីតាំងភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត។ នៅពេលដែលចលនាស្ថិតនៅក្នុងប្រទេសតែមួយ ត្រូវបានចាត់ទុកថាជាការធ្វើទេសន្តរប្រវេសន៍ក្នុងស្រុកហើយករណីពាក់ព័ន្ធនឹងការផ្លាស់ប្តូរប្រទេស ហៅថាការធ្វើទេសន្តប្រវេសន៍អន្តរជាតិ។

ទេសន្តប្រវេសន៍ចូល

អត្រាធ្វើទេសន្តរប្រវេសន៍ចំណូលស្រុក គឺជាសមមាត្រនៃចំនួនជនអន្តោប្រវេសន៍ដែលមកដល់គោលដៅមួយក្នុងចំណោមប្រជាជន ១០០នាក់ នៅគោលដៅនោះ ក្នុងឆ្នាំណាមួយជាក់លាក់។

ទេសន្តប្រវេសន៍ចេញ

អត្រាធ្វើទេសន្តរប្រវេសន៍ចំណាកស្រុក "ការធ្វើចំណាកស្រុកក្រៅប្រទេស" គឺជាសមមាត្រនៃចំនួនជនទេសន្តរប្រវេសន៍ដែលទៅដល់គោលដៅមួយក្នុងចំណោមប្រជាជន ១០០នាក់ នៅគោលដៅនោះ ក្នុងឆ្នាំមួយជាក់លាក់។

យេនឌ័រ

សំដៅលើតួនាទីឥរិយាបទ និងគុណតម្លៃនានាដែលវប្បធម៌ និងសង្គមដាក់កំណត់ឲ្យស្ត្រី និងបុរសអនុវត្តដោយឡែកពីគ្នា។

ទំហំគ្រួសារមធ្យម

ជាចំនួនមនុស្សមធ្យមដែលរស់ក្នុងគ្រួសារធម្មតា ឬប្រក្រតី (មិនរាប់បញ្ចូលគ្រួសារស្ថាប័ន គ្រួសារគ្មានផ្ទះសំបែង គ្រួសាររស់លើទូក និង ប្រជាជនឆ្លងកាត់)។

មេគ្រួសារ

សម្រាប់គោលបំណងជំរឿន មេគ្រួសារគឺជាមនុស្សដែលត្រូវបានទទួលស្គាល់ពីសមាជិកក្នុងគ្រួសារ។ មេគ្រួសារជាប្រុស ឬស្រី ជាទូទៅគាត់ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងគ្រួសារ និងធ្វើការសម្រេចចិត្តក្នុងនាមឲ្យគ្រួសារ។ មេគ្រួសារ មិនចាំបាច់ត្រូវតែជាមនុស្សចាស់ទេ ប៉ុន្តែគាត់អាចជាស្ត្រី ក្មេងស្រី ឬក្មេងប្រុសនៃ

សមាជិកគ្រួសារ។ ឈ្មោះអ្នកដែលត្រូវទទួលស្គាល់នៅក្នុងគ្រួសារថាជាមេគ្រួសារ ត្រូវបានរាយការណ៍នៅក្នុងជំរឿន។ សម្រាប់គោលបំណងជំរឿន ក្នុងករណីអវត្តមានមេគ្រួសារ អ្នកផ្សេងដែលទទួលខុសត្រូវក្នុងការចាត់ចែងគ្រប់គ្រងការងារទាំងអស់របស់មេគ្រួសារ ត្រូវបានចាត់ទុកថាជាមេគ្រួសារ។

ក្រុមគ្រួសារ

ជាក្រុមមនុស្សមួយក្រុមដែលរស់នៅរួមគ្នា និងហូបចុកអាហារចេញពីចង្ក្រានតែមួយ វៀរលែងតែអ្នកដែលមានការងារពិសេសមិនអាចទៅហូបចុកជាមួយបាន។

កំណើតរស់

សំដៅទៅលើការកើតចេញ ឬការវះយកចេញពីផ្ទៃម្តាយនូវទារក។ ពេលកើតចេញមកទារកមានដង្ហើម ឬបង្ហាញនូវភាពមានជីវិត ដូចជាជីពចរនូវដើរ ឬមានចលនាសាច់ដុំ។ ចលនានីមួយៗនេះ បញ្ជាក់ថាមានកំណើតរស់។

លទ្ធភាពមានកូន

លទ្ធភាពមានកូនជាចំនួនកូនជាក់ស្តែងដែលស្ត្រីម្នាក់ ឬក្រុមស្ត្រីបានបង្កើតក្នុងមួយជីវិតរបស់គាត់។

អត្រាលទ្ធភាពបង្កើតកូនដុល (CBR)

អត្រាអត្រាលទ្ធភាពបង្កើត (ត្រូវបានហៅថា អត្រាលទ្ធភាពបង្កើតកូនដុល) បង្ហាញពីផលធៀបចំនួនកំណើតរស់ក្នុងចំណោមប្រជាជនសរុប ១.០០០នាក់ នៅឆ្នាំណាមួយជាក់លាក់។

អត្រាលទ្ធភាពបង្កើតកូនទូទៅ (GFR)

អត្រាលទ្ធភាពបង្កើតកូនទូទៅ (ត្រូវបានហៅថា អត្រាលទ្ធភាពបង្កើតកូន) បង្ហាញពីផលធៀបចំនួនកំណើតរស់ក្នុងចំណោមស្ត្រីដែលស្ថិតក្នុងអាយុបន្តពូជពី ១៥ ដល់ ៤៩ ឆ្នាំ ក្នុង ១.០០០នាក់ នៅឆ្នាំណាមួយជាក់លាក់។ អត្រាលទ្ធភាពបង្កើតកូនទូទៅមានលក្ខណៈសុក្រឹតជាងការវាស់វែងអត្រាលទ្ធភាពបង្កើតកូនដុល។

អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR)

អត្រាលទ្ធភាពបង្កើតកូនត្រូវបានគណនាសម្រាប់ក្រុមអាយុជាក់លាក់ ដើម្បីមើលឃើញពីភាពខុសគ្នានៃឥរិយាបទនៃលទ្ធភាពបង្កើតកូននៅក្នុងក្រុមអាយុខុសគ្នា ឬសម្រាប់ការប្រៀបធៀបតាមពេលវេលា។

អត្រាលទ្ធភាពបង្កើតកូនសរុប (TFR)

អត្រាលទ្ធភាពបង្កើតកូនសរុប ជាចំនួនកូនដែលស្ត្រីអាចទទួលបានក្នុងអំឡុងពេលនៃជីវិតរបស់នាង បើនាងបង្កើតកូនពេញមួយជីវិតរបស់នាង តាមការវាស់វែងអត្រាលទ្ធភាពបង្កើតកូនតាមក្រុមអាយុជាក់លាក់

ដោយពួកគេស្លាប់មុនពេលឆ្លងកាត់អាយុបន្តពូជ។ ដូច្នេះ អត្រាលទ្ធភាពបង្កើតកូនសរុបជាចំនួនកំណើតរបស់ស្ត្រីដែលនឹងមាន បើនាងមានអត្រាកំណើតជាក់លាក់ក្នុងអំឡុងពេលបន្តពូជរបស់នាង គឺជាផលបូកនៃអត្រាកំណើតនៃអាយុជាក់លាក់។

អត្រាលទ្ធភាពបង្កើតកូនជំនួស (GRR)

អត្រាលទ្ធភាពបង្កើតកូនជំនួស ជាចំនួនកូនស្រីជាមធ្យមដែលបានកើតពីស្ត្រី (ឬក្រុមស្ត្រី) ក្នុងមួយជីវិតរបស់នាង បើនាងឆ្លងកាត់ឆ្នាំបង្កើតកូនដោយអនុលោមតាមអត្រាកំណើតជាក់លាក់នៃអាយុដែលបានផ្តល់ឱ្យ។ អត្រានេះដូចនឹង TFR លើកលែងតែវារាប់បញ្ចូលតែកូនស្រី ហើយវាស់វែង "បង្កើតកូន" ស្ត្រីដែលបង្កើតជាកូនស្រី។

អត្រាមរណភាពដុល (CDR)

ជាផលធៀបរវាងចំនួនប្រជាជនទទួលមរណភាពនៅឆ្នាំណាមួយជាក់លាក់ ទៅនឹងប្រជាជនសរុបនៅឆ្នាំដូចគ្នាគុណនឹង ១.០០០។

អត្រាមរណភាពតាមអាយុជាក់លាក់ (ASDR)

អត្រាមរណភាពក៏អាចត្រូវបានគណនាសម្រាប់ក្រុមអាយុជាក់លាក់ ដើម្បីប្រៀបធៀបអត្រាមរណភាពសម្រាប់អាយុខុសគ្នា ឬអាយុដូចគ្នា។ ការប្រៀបធៀបអាចត្រូវបានធ្វើរវាងប្រទេស ឬតំបន់។ ដោយសារអត្រាមរណភាពមានភាពខុសគ្នាខ្លាំងពីភេទ និងជាតិពន្ធ អត្រាមរណភាពតាមអាយុត្រូវបានផ្តល់ឲ្យដាច់ដោយឡែកពីគ្នាសម្រាប់បុរស និងស្ត្រី និងសម្រាប់ក្រុមជាតិពន្ធផ្សេងៗគ្នានៅក្នុងចំណោមប្រជាជន។ អត្រាមរណភាពតាមអាយុជាក់លាក់ជាផលធៀបចំនួនស្លាប់តាមក្រុមអាយុជាក់លាក់ ទៅនឹងចំនួនប្រជាជនតាមក្រុមអាយុជាក់លាក់ ក្នុងជំណោមប្រជាជន ១.០០០នាក់។

អត្រាមរណភាពទារក (IMR)

អត្រាមរណភាពទារក ជាផលធៀបចំនួនមរណភាពរបស់ទារកអាយុក្រោម ១ ឆ្នាំ ក្នុងចំណោម ១.០០០ កំណើតរស់ នៅឆ្នាំដែលបានផ្តល់ឲ្យ។

អត្រាមរណភាពកុមារ (CMR)

អត្រាមរណភាពកុមារ ជាផលធៀបចំនួនមរណភាពកុមារអាយុចន្លោះ ១-៤ ឆ្នាំ ក្នុងចំណោមកុមារអាយុចន្លោះ ១-៤ ឆ្នាំ ក្នុងចំណោម ១.០០០នាក់ នៅឆ្នាំដែលបានផ្តល់ឲ្យ។

អត្រាមរណភាពមាតា (MMR)

ជាផលធៀបនៃចំនួនស្ត្រីដែលបានទទួលមរណភាពក្នុងអំឡុងពេលមានផ្ទៃពោះ អំឡុងពេលប្រសូត ឬក្នុងរយៈពេល ៤១ ថ្ងៃ ក្រោយពេលប្រសូត ក្នុងចំណោម ១០០.០០០ កំណើតរស់។

ការកំណត់អំពីពិការភាព

អនុសញ្ញាសិទ្ធិជនពិការត្រូវបានកំណត់ថាពិការភាព ជាលទ្ធផលអន្តរកម្មនៃមុខងាររវាងមនុស្សទូទៅ និងការចុះខ្សោយនៃរាងកាយ (លក្ខខណ្ឌសុខភាព) ក្នុងបរិយាកាសប្រចាំថ្ងៃរបស់ពួកគេ និងឧបសគ្គក្នុងការចូលរួមពេញលេញ និងប្រសិទ្ធភាពមូលដ្ឋានស្មើភាពគ្នា ក្នុងការចូលរួមកិច្ចការសង្គម។ ការកំណត់និយមន័យនេះ គឺស្របនឹង ICF ការលើកឡើងថា ពិការភាពមិនមែនបញ្ហាវេជ្ជសាស្ត្រ ឬបញ្ហាលក្ខខណ្ឌសង្គមនោះទេ។ និយមន័យនេះបានឆ្លុះបញ្ចាំងពីទស្សនទាននៃពិការជាប្រភេទជំងឺធ្វើឲ្យមានការពិបាកបំពេញមុខងារ ពិការភាពវាស់វែងត្រូវឆ្លុះបញ្ចាំងតាមប្រភេទលំបាក ញែកដាច់ដោយឡែកពីគ្នា។ ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ បានអនុវត្តតាមកម្រងសំណួរពិការភាពដែលបានកំណត់តាមបទដ្ឋានក្រុមការងារវ៉ាស៊ីនតោនដែលបានអនុវត្តន៍ដោយ ICF ។ កម្រងសំណួរដែលបានអនុវត្តន៍ រួមមានប្រាំមួយសំណួរតាមមុខងារលំបាកប្រាំមួយ ដូចជាលំបាកក្នុងការមើល ទោះបីប្រើវ៉ែនតាក្តី លំបាកក្នុងការស្តាប់ ទោះបីប្រើគ្រឿងជំនួយស្តាប់ លំបាកក្នុងការដើរ ឬឡើងជណ្តើរ លំបាកក្នុងការចងចាំ ឬការគិត លំបាកក្នុងការថែទាំខ្លួនឯង ដូចជាងូតទឹក ស្លៀកពាក់ និងលំបាកក្នុងការទំនាក់ទំនងជាមួយអ្នកដទៃ ហើយកម្រិតនៃការលំបាកមានគ្មានលំបាក លំបាកខ្លះ លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់។

ក្រុមការងារវ៉ាស៊ីនតោនបានកំណត់កម្រងសំណួរខ្លីអំពីពិការភាព ផ្តោតលើការវាស់វែងកម្រិតមុខងារលំបាកដែលជួបប្រទះនៅក្នុងប្រតិបត្តិសកម្មភាពមូលដ្ឋាន ប្រចាំថ្ងៃជាជាងលក្ខខណ្ឌសុខភាព ឬការចុះខ្សោយនៃរាងកាយ។ ការវាស់វែងនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើការប្រៀបធៀបជាអន្តរជាតិ ដោយរួមមានកម្រងសំណួរជាមូលដ្ឋានប៉ុណ្ណោះ ជាជាងសកម្មភាពស្មុគស្មាញដែលទទួលឥទ្ធិពលដោយវប្បធម៌ និងកត្តាសេដ្ឋកិច្ច សង្គមកិច្ចក្នុងបរិយាកាសនៅជុំវិញ។

ក្រុមការងារវ៉ាស៊ីនតោនស្តីពីស្ថិតិពិការបានផ្តល់អនុសាសន៍ថា ជនពិការត្រូវបានកំណត់ថាមានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានទាំងអស់ យ៉ាងហោចណាស់មានមួយក្នុងចំណោមមុខងារលំបាកទាំងប្រាំមួយ។

សំណួរពិការភាពប្រើក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ សម្រាប់មនុស្សអាយុ ៥ ឆ្នាំឡើង រួមមាន ៖

១. តើអ្នកមានលំបាកមើលដែរឬទេ ទោះបីពាក់វ៉ែនតាក៏ដោយ?
ក. ទេ មិនលំបាកទេ
ខ. បាទ លំបាកខ្លះដែរ
គ. បាទ លំបាកខ្លាំង
ឃ. មិនអាចមើលឃើញសោះ

២. តើអ្នកមានលំបាកស្តាប់ដែរឬទេ ទោះបីប្រើឧបករណ៍ជំនួយក៏ដោយ?
ក. ទេ មិនលំបាកទេ

ខ. បាទ លំបាកខ្លះដែរ
គ. បាទ លំបាកខ្លាំង
ឃ. មិនអាចស្តាប់ឮសោះ

៣. តើអ្នកមានលំបាកក្នុងការផ្លាស់ទី ឬឡើងជណ្តើរដែរឬទេ?
ក. ទេ មិនលំបាកទេ
ខ. បាទ លំបាកខ្លះដែរ
គ. បាទ លំបាកខ្លាំង
ឃ. មិនអាចផ្លាស់ទី ឬឡើងជណ្តើរបានសោះ

៤. តើអ្នកមានលំបាកក្នុងការចងចាំ ឬការគិតដែរឬទេ?
ក. ទេ មិនលំបាកទេ
ខ. បាទ លំបាកខ្លះដែរ
គ. បាទ លំបាកខ្លាំង
ឃ. មិនអាចចងចាំ ឬគិតអ្វីបានសោះ

៥. តើអ្នកមានលំបាកក្នុងការថែទាំខ្លួន ឬស្លៀកពាក់ដែរឬទេ?
ក. ទេ មិនលំបាកទេ
ខ. បាទ លំបាកខ្លះដែរ
គ. បាទ លំបាកខ្លាំង
ឃ. មិនអាចធ្វើអ្វីបានទាំងអស់

៦. តើអ្នកមានលំបាកក្នុងការនិយាយ ឬទំនាក់ទំនងគ្នាដែរឬទេ?
ក. ទេ មិនលំបាកទេ
ខ. បាទ លំបាកខ្លះដែរ
គ. បាទ លំបាកខ្លាំង
ឃ. មិនអាចធ្វើអ្វីបានទាំងអស់

ឧបសម្ព័ន្ធ

សម្ងាត់បំផុត

តារាង ក

រាជរដ្ឋាភិបាលកម្ពុជា
អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជា
ខែ ឧសភា ឆ្នាំ ២០២៤

ទំព័រលេខ...
ចំនួនទំព័រសរុបដែលបានប្រើសម្រាប់មណ្ឌលអង្កេតនេះ............

ព័ត៌មានសម្គាល់

	រាជធានី/ខេត្ត	ក្រុង/ស្រុក/ខណ្ឌ	ឃុំ/សង្កាត់	ភូមិ	មណ្ឌលអង្កេតលេខ	ចំនួនគ្រួសារក្នុងភូមិ	ចំនួនគ្រួសារចុះបញ្ជី	1= ទីប្រជុំជន 2= ជនបទ
ឈ្មោះ								
លេខកូដ								

ព័ត៌មានអគារ និងគ្រួសារ

លេខបន្ទាត់	អគារលេខ	គ្រួសារលេខ	សម្ភារៈចម្បងក្នុងការសាងសង់អគារ (ចុះលេខកូដ) ជញ្ជាំង	ដំបូល	កម្រាល	គោលដៅក្នុងការប្រើប្រាស់អគារ 1= លំនៅដ្ឋាន 2= លំនៅដ្ឋាន និងហាងលក់ទំនិញ 3= លំនៅដ្ឋាន និងរោងជាង 4= លំនៅដ្ឋាន និងគ្រឹះស្ថានណាមួយ	ឈ្មោះមេគ្រួសារ	ភេទ 1= ប្រុស 2= ស្រី	ចំនួនមនុស្សដែលរស់នៅជាប្រចាំក្នុងគ្រួសារ ប្រុស	ស្រី	សរុប	សំណាកគំរូលេខ (គូសរង្វង់)
1	2	3	4	5	6	7	8	9	10	11	12	13
1												
2												
3												
4												
5												
6												
7												
8												
9												
0												

លេខកូដបង្គោល 4 សម្ភារៈធ្វើជញ្ជាំង	លេខកូដបង្គោល 5 សម្ភារៈធ្វើដំបូល	លេខកូដបង្គោល 6 សម្ភារៈធ្វើកម្រាល
1= ឫស្សី/ស្លឹក/ស្បូវ/ស្មៅ/ត្រែង/បបុស	1= ឫស្សី/ស្លឹក/ស្បូវ/ស្មៅ	1= ដី/ដីឥដ្ឋ
2= ដី	2= ក្បឿង	2= ក្តារឈើ/ទោបឬស្សី
3= ក្តារឈើ/ក្តារបន្ទះ	3= ក្តារឈើ/ក្តារបន្ទះ	3= បេតុង/ឥដ្ឋ/ថ្ម
4= បេតុង/ឥដ្ឋ/ថ្ម	4= បេតុង/ឥដ្ឋ/ថ្ម	4= ថ្មដុស
5= ស័ង្កសី/អាលុយមីញ៉ូម/បន្ទះលោហៈធាតុផ្សេងៗ	5= ស័ង្កសី/អាលុយមីញ៉ូម/បន្ទះលោហៈធាតុផ្សេងៗ	5= ក្តារខាត់
6= ហ្វីប្រូស៊ីម៉ង់ត៍	6= ហ្វីប្រូស៊ីម៉ង់ត៍	6= ឥដ្ឋ/ឥដ្ឋការ៉ូ
7= សំភារៈប្រើប្រាស់ហើយ/ជំនួស/បន្ថែម/បិទបាំង	7= បន្ទះប្លាស្ទិក/បន្ទះដំរ៍/បិទបាំង	7= ផ្សេងទៀត (សូមបញ្ជាក់)...........................
8= ផ្សេងទៀត (សូមបញ្ជាក់)...........................	8= ផ្សេងទៀត (សូមបញ្ជាក់)...........................	

ឈ្មោះអ្នកសម្ភាសន៍...

/ /

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ

ឈ្មោះអ្នកត្រួតពិនិត្យ...

/ /

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ

រាជរដ្ឋាភិបាលកម្ពុជា

អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជា

ខែ ឧសភា ឆ្នាំ ២០២៤

តារាង ខ តារាងសំណួរគ្រួសារ

ព័ត៌មានសម្គាល់ | **សម្ងាត់បំផុត**

	រាជធានី/ខេត្ត	ក្រុង/ស្រុក/ខណ្ឌ	ឃុំ/សង្កាត់	ភូមិ	មណ្ឌលអង្កេតលេខ	1= ទីប្រជុំជន 2= ជនបទ	អគារលេខ	គ្រួសារសំណាកគំរូលេខ	នាមត្រកូល និង នាមខ្លួនមេគ្រួសារ
ឈ្មោះ									
លេខកូដ									

ឈ្មោះមន្ត្រីសម្ភាសន៍៖...
ថ្ងៃខែឆ្នាំសម្ភាសន៍៖...
ហត្ថលេខា៖..

ឈ្មោះមន្ត្រីត្រួតពិនិត្យ៖...
ថ្ងៃខែឆ្នាំត្រួតពិនិត្យ៖..
ហត្ថលេខា៖...

ព័ត៌មានសម្គាល់

☐ ចំនួនតារាងដែលបានប្រើប្រាស់ក្នុងគ្រួសារ

ឈ្មោះ	រាជធានី/ខេត្ត	ក្រុង/ស្រុក/ខណ្ឌ	ឃុំ/សង្កាត់	ភូមិ	មណ្ឌលអង្កេតលេខ	1= ទីប្រជុំជន 2= ជនបទ	អគារលេខ	គ្រួសារសំណាកគំរូលេខ	នាមត្រកូល និង នាមខ្លួនមេគ្រួសារ
លេខកូដ									

សំណួរគ្រួសារផ្នែក ១ ៖ ព័ត៌មានបុគ្គល

ព័ត៌មានសម្រាប់មនុស្សគ្រប់រូប						សម្រាប់កុមារអាយុ 0-14 ឆ្នាំ	សម្រាប់មនុស្សទាំងអស់	សម្រាប់អ្នករៀបការ	សម្រាប់មនុស្សក្រៅពីអ្នកមិនទាន់រៀបការ	ព័ត៌មានសម្រាប់មនុស្សគ្រប់រូប							
លេខរៀង	នាមត្រកូល និងនាមខ្លួន		ទំនាក់ទំនងជាមួយមេគ្រួសារ	ភេទ	អាយុ					ភាសាកំណើត	សាសនា	ទីកន្លែងកំណើត		លំនៅដ្ឋានពីមុន/ ករណីកូដ2 ក្នុងបង្គោល(3) សូមចុះទីតាំងរស់នៅបច្ចុប្បន្ន		តើអ្នកបានស្នាក់នៅភូមិនេះបានប៉ុន្មានឆ្នាំហើយ?	មូលហេតុនៃការផ្លាស់លំនៅដ្ឋាន
	សូមចុះឈ្មោះសមាជិកគ្រួសារ អចិន្ត្រៃយ៍ និងភ្ញៀវដោយចាប់ផ្តើមពីមេគ្រួសារ	តើ (ឈ្មោះ) មានវត្តមានក្នុងគ្រួសារក្នុងយប់អង្កេតឬទេ? 1=បាទ/ចាស 2= ទេ	(ចុះលេខកូដ)	1= ប្រុស 2= ស្រី	គិតជាឆ្នាំពេញ (ចុះលេខកូដ)	តើកូនរស់នៅជាមួយម្តាយបង្កើតឬទេ? (សូមអានកំណត់សម្គាល់ខាងក្រោម)	ស្ថានភាពអាពាហ៍ពិពាហ៍ (ចុះលេខកូដ)	បើរៀបការ តើបានចុះសំបុត្រអាពាហ៍ពិពាហ៍ឬទេ? 1=បាទ/ចាស 2= ទេ	អាយុនៅពេលរៀបការលើកទីមួយជាឆ្នាំពេញ (សួរតែអ្នកមានលេខកូដ 2, 3, 4, 5 ក្នុងបង្គោល 8)	(ចុះលេខកូដ)	(ចុះលេខកូដ)	- បើកើតក្នុងភូមិនេះ សូមចុះលេខកូដ 1 - បើកើតក្នុងភូមិផ្សេង សូមសរសេរឈ្មោះ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត - បើកើតនៅក្រៅប្រទេសកម្ពុជា សូមសរសេរឈ្មោះប្រទេស	កូដទីតាំង	- បើរស់នៅរហូតក្នុងភូមិនេះតាំងពីកើតមក សូមចុះលេខកូដ 1 រួចរំលងទៅបង្គោល 1(ក) នៃផ្នែក 2 ៖ សេដ្ឋកិច្ច និងសង្គមកិច្ច - បើកើតក្នុងភូមិផ្សេង សូមសរសេរឈ្មោះឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត - បើរស់នៅក្រៅប្រទេសកម្ពុជា សូមសរសេរឈ្មោះប្រទេសនោះ	កូដទីតាំង	(ចុះលេខកូដ)	(ចុះលេខកូដ)
1	2	3	4	5	6	7	8	9	10	11	12	13(ក)	14(ខ)	14(ក)	14(ខ)	15	16
1																	
2																	
3																	
4																	
5																	
6																	
7																	
8																	
9																	
0																	

លេខកូដបង្គោល 4 ទំនាក់ទំនងជាមួយមេគ្រួសារ
1= មេគ្រួសារ
2= ប្រពន្ធ/ប្តី
3= កូនប្រុស/កូនស្រី
4= ឪពុក/ម្តាយ
5= ចៅ
6= សាច់ញាតិផ្សេងទៀត
7= អ្នកមិនមែនជាសាច់ញាតិ

លេខកូដបង្គោល 6 អាយុ
000= តិចជាង ១ ឆ្នាំ
001= 1 ឆ្នាំ
002= 2 ឆ្នាំ
....
....
120= 120 ឆ្នាំ

លេខកូដបង្គោល 7
សូមសរសេរលេខរៀងរបស់ម្តាយបង្កើត បើរស់នៅក្នុងគ្រួសារនេះជាមួយកុមារអាយុ 0-14 ឆ្នាំ។
បើមិនរស់នៅជាមួយ សូមសរសេរ "0" ។

លេខកូដបង្គោល 8
1= មិនដែលរៀបការ ឬនៅលីវ
2= រៀបការហើយ (កំពុងរស់នៅជាមួយគ្នា)
3= មេម៉ាយប្តីស្លាប់ ពោះម៉ាយប្រពន្ធស្លាប់
4= មេម៉ាយ ពោះម៉ាយលះលែងគ្នា
5= ទំនាស់រស់នៅផ្សេងគ្នា

លេខកូដបង្គោល 11 ភាសាកំណើត
01= ខ្មែរ
02= វៀតណាម
03= ចិន
04= ឡាវ
05= ថៃ
06= បារាំង
07= អង់គ្លេស
08= កូរ៉េ
09= ជប៉ុន
10= ចារ៉ាយ
11= ចាម
12= កាតែ
13= គ្រឹង
14= គួយ
15= គ្រឹង
16= លុន
17= ពួនង
18= ព្រៅ
19= ទំពួន
20= ស្ទៀង
21= ចារ៉ាង
22= គ្រូល
23= រ៉ដែរ
24= លួន
25= ម៉ិល
26= ខូញ
27= ពរ
28= ស្ទុយ
29= ភាសាកំណើតផ្សេងទៀត

លេខកូដបង្គោល 12
1= ព្រះពុទ្ធ
2= ឥស្លាម
3= គ្រឹស្តសាសនា
4= សាសនាផ្សេងទៀត

លេខកូដបង្គោល 15 រយៈពេលស្នាក់នៅ
00= តិចជាង 1 ឆ្នាំ
01= 1 ឆ្នាំទៅតិចជាង 2 ឆ្នាំ
02= 2 ឆ្នាំទៅតិចជាង 3 ឆ្នាំ
....
10= 10 ឆ្នាំទៅតិចជាង 11 ឆ្នាំ
....
20= 20 ឆ្នាំទៅតិចជាង 21 ឆ្នាំ
....
120= 120 ឆ្នាំទៅតិចជាង 121 ឆ្នាំ

លេខកូដបង្គោល 16 មូលហេតុនៃការផ្លាស់លំនៅដ្ឋាន
1= ប្តូរកន្លែងធ្វើការ
2= ស្វែងរកការងារធ្វើ
3= បន្តការសិក្សា
4= រៀបអាពាហ៍ពិពាហ៍
5= គ្រួសារផ្លាស់លំនៅដ្ឋាន
6= បាត់បង់ដីធ្លី/លំនៅដ្ឋាន
7= គ្រោះថ្នាក់ធម្មជាតិ
8= ត្រូវបានផ្លាស់ទីកន្លែងដោយសារការសាងសង់ទំនប់
9= ត្រូវបានផ្លាស់ទីកន្លែងដោយសារគម្រោងផ្សេងៗ
10= អសន្តិសុខ
11= មាតុភូមិនិវត្ត/មកស្រុកកំណើតវិញ
12= កូនកំព្រា
13= មកលេង
14= ផ្សេងទៀត (សូមបញ្ជាក់)

សំណួរគ្រួសារផ្នែក ២ ៖ សេដ្ឋកិច្ច និងសង្គមកិច្ច

លេខរៀង	ព័ត៌មានសម្រាប់មនុស្សអាយុ ៥ ឆ្នាំឡើង: អក្ខរភាព: តើ (ឈ្មោះ) ចេះអាន និងសរសេរ និងយល់ភាសាខ្មែរឬទេ? 1=បាទ/ចាស 2=ទេ	អក្ខរភាព: តើ (ឈ្មោះ) ចេះអាន និងសរសេរ និងយល់ភាសាផ្សេងឬទេ? បើមានតើភាសាអ្វី? (ចុះលេខកូដ)	រយៈពេលសិក្សាពេញលេញ: តើ (ឈ្មោះ) ធ្លាប់បានចូលរៀនក្នុងសាលា ឬគ្រឹះស្ថានអប់រំឬទេ? (ចុះលេខកូដ)	តើបច្ចុប្បន្នកំពុងរៀនថ្នាក់ទីប៉ុន្មាន?		តើ (ឈ្មោះ) ទទួលកម្រិតសិក្សាខ្ពស់បំផុតទីប៉ុន្មាន?		មុខវិជ្ជាចម្បងនៃការសិក្សា សម្រាប់តែលេខកូដ 15 ដល់ 20 ក្នុងបង្គោល 3(ខ) ឬ 3(គ) លេខកូដផ្សេងទៀត សូមរំលងទៅបង្គោល 4				ការលំបាក សម្រាប់មនុស្សអាយុ 5 ឆ្នាំឡើង: លេខកូដការលំបាក 1= ទេ មិនពិបាកអ្វីទាំងអស់ 2= បាទ/ចាស ពិបាកខ្លះដែរ 3= បាទ/ចាស ពិបាកខ្លាំង 4= មិនអាចធ្វើបានសោះតែម្តង (សូមមើលកំណត់សម្គាល់ខាងក្រោម)						បើ(ឈ្មោះ) មានលំបាកមួយ ឬច្រើនក្នុងបង្គោល៤ តើ(ឈ្មោះ) មានប័ណ្ណពិការភាពដែរឬទេ? 1= មាន 2= គ្មាន	សកម្មភាពការងារចម្បងក្នុងរយៈពេល 12 ខែកន្លងមក សម្រាប់អាយុ 5 ឆ្នាំឡើង (ចុះលេខកូដ)	អាជីព/មុខរបរ សម្រាប់អាយុ 5 ឆ្នាំឡើង សូមសរសេរឈ្មោះអាជីព/មុខរបរជាអក្សរ		ស្ថានភាពការងារ/ឋានៈការងារ (ចុះលេខកូដ)	សកម្មភាពសេដ្ឋកិច្ច (កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម) សម្រាប់អាយុ 5 ឆ្នាំឡើង សូមសរសេរឈ្មោះសកម្មភាពការងារជាអក្សរ		ការងារក្នុងផ្នែកណាមួយដែលបានបម្រើ (ចុះលេខកូដ)	តើ (ឈ្មោះ) មានប័ណ្ណបសសដែរឬទេ? 1= មាន 2= គ្មាន
								ការពិពណ៌នា	កូដមុខវិជ្ជា			1	2	3	4	5	6			អាជីព/មុខរបរ	កូដមុខរបរ		សកម្មភាពសេដ្ឋកិច្ច	កូដសកម្មភាព		
1	2(ក)	2(ខ)	3(ក)	3(ខ)		3(គ)		3(ឃ)				4						5	6	7		8	9		10	11
1																										
2																										
3																										
4																										
5																										
6																										
7																										
8																										
9																										
0																										

លេខកូដបង្គោល 2(ខ)
1= គ្មានភាសាផ្សេង
2= វៀតណាម
3= ចិន
4= ឡាវ
5= ថៃ
6= បារាំង
7= អង់គ្លេស
8= ចាម
9= ភាសាផ្សេងទៀត

លេខកូដបង្គោល 3(ក)
1= មិនដែលសោះ
2= បច្ចុប្បន្នកំពុងរៀន
3= បានរៀនពីអតីតកាល

លេខកូដសម្រាប់បង្គោល 3(ខ) និង 3(គ)
បើលេខកូដ 1 ក្នុងបង្គោល 3(ក) សូមគូសសញ្ញា (-) ក្នុងបង្គោល 3(ខ) 3(គ)
បើលេខកូដ 3 ក្នុងបង្គោល 3(ក) សូមគូសសញ្ញា (-) ក្នុងបង្គោល 3(ខ)
បើលេខកូដ 2 ក្នុងបង្គោល 3(ក) សូមចុះលេខកូដដូចខាងក្រោម៖

លេខកូដបង្គោល 3(ខ)
00= មតេយ្យ
01= ថ្នាក់ទី 1
02= ថ្នាក់ទី 2
....
12=ថ្នាក់ទី 12
101= ថ្នាក់ទី10/សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១
112= ថ្នាក់ទី 11/សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២
123= ថ្នាក់ទី 12/សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣
17= បរិញ្ញាបត្ររង/សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស
18= បរិញ្ញាបត្របរិញ្ញាបត្របច្ចេកវិទ្យាឯកទេសសញ្ញាបត្រវិស្វករ
19=កំពុងរៀនបរិញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា /ឯកទេស
20= កំពុងរៀនថ្នាក់បណ្ឌិត/បណ្ឌិតបច្ចេកវិទ្យា /ឯកទេស
21= កំពុងរៀនមុខវិជ្ជាផ្សេងទៀត

លេខកូដបង្គោល 3(គ)
13= មានសញ្ញាបត្របឋមភូមិ
14= បញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
15= សញ្ញាប័ត្រ បច្ចេកទេស និងវិជ្ជាជីវៈ១
16= សញ្ញាប័ត្របច្ចេកទេស និងវិជ្ជាជីវៈ២
17= សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣
18= សញ្ញាបត្របរិញ្ញាបត្ររង/សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស
19= សញ្ញាបត្របរិញ្ញាបត្រ/ បរិញ្ញាបត្រ បច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ
20= សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស
21= សញ្ញាបត្រថ្នាក់បណ្ឌិត/ បណ្ឌិតបច្ចេកវិទ្យា/ឯកទេស
22-ផ្សេងទៀត (បញ្ជាក់)
88= មិនបានបញ្ចប់ថ្នាក់ណាមួយ

សំណួរបង្គោល 4 ប្រភេទការលំបាក
តើអ្នកមានការលំបាកដូចម្តេច............
4..1= ក្នុងការមើល ទោះបីពាក់វ៉ែនតាក៏ដោយ?
4.2= ក្នុងការស្តាប់ ទោះបីប្រើឧបករណ៍ជំនួយស្តាប់ក៏ដោយ?
4.3= ក្នុងការដើរ ឬឡើងជណ្តើរ?
4.4= ក្នុងការចងចាំ ឬសញ្ជឹងគិត?
4..5= ក្នុងការថែទាំខ្លួនឯង ដូចជាងូតទឹក ឬស្លៀកពាក់?
4..6= ក្នុងការនិយាយ ដូចជាយល់ដឹងពីអ្នកដទៃ ឬឲ្យអ្នកដទៃយល់ពីអ្នក?

លេខកូដបង្គោល 6 សកម្មភាពចម្បងក្នុងរយៈពេល 12 ខែកន្លងមក
1= មានការងារធ្វើ (សូមបំពេញបង្គោល 7 ដល់ 10)
2= គ្មានការងារធ្វើ (បានធ្វើការងារនៅពេលណាមួយពីមុនមក) (សូមបំពេញបង្គោល 7 ដល់ 10 សម្រាប់ការងារចុងក្រោយ)
3= គ្មានការងារធ្វើ (ពីមុនមកមិនដែលធ្វើការងារណាមួយសោះ)
4= អ្នកធ្វើការងារផ្ទះ
5= សិស្ស/និស្សិត
6= អ្នកនៅក្នុងបន្ទុក
7= អ្នកជួលអចលនវត្ថុ និវត្តន៍ជន ឬទទួលប្រាក់ចំណូលផ្សេងទៀត
8= ផ្សេងទៀត
(សម្រាប់លេខកូដ 3 ដល់ 8 សូមគូសសញ្ញា (-) ក្នុងបង្គោល 7 ដល់ 10)

លេខកូដបង្គោល 8 ស្ថានភាពការងារ
1= និយោជក
2= និយោជិតទទួលប្រាក់ឈ្នួល
3= អ្នកធ្វើការងារប្រើទុនផ្ទាល់ខ្លួន
4= អ្នកធ្វើការងារឲ្យគ្រួសារមិនយកប្រាក់ឈ្នួល
5= ផ្សេងទៀត (សូមបញ្ជាក់)

លេខកូដបង្គោល 10 ផ្នែកការងារ
1= រដ្ឋាភិបាល
2= អង្គភាពស្វយ័ត
3= ឯកជនខ្មែរ
4= ឯកជនបរទេស
5= ស្ថាប័នមិនយកប្រាក់ចំណេញ
6= គ្រួសារ
7= ស្ថានទូត/ស្ថាប័នអន្តរជាតិ/ភ្នាក់ងារអភិវឌ្ឍន៍
8= ផ្សេងទៀត (សូមបញ្ជាក់)

សំណួរគ្រួសារផ្នែក ២ ៖ សេដ្ឋកិច្ច និងសង្គមកិច្ច (ត)

ព័ត៌មានសម្រាប់មនុស្សគ្រប់រូប

លេខរៀង	តើ (ឈ្មោះ) មានប្រើតទានធនាគារដែរឬទេ? 1= បាទ/ចាស 2= ទេ	តើ (ឈ្មោះ) ដាក់ប្រាក់បញ្ញើធនាគារដែរឬទេ? 1= បាទ/ចាស 2= ទេ	តើ (ឈ្មោះ) ទូទាត់សាច់ប្រាក់តាមទូរស័ព្ទដែរឬទេ? 1= បាទ/ចាស 2= ទេ	តើ (ឈ្មោះ) បច្ចុប្បន្នជក់ថ្នាំជក់(បារីផលិត បារីម៉ូរដៃ ខ្សៀដក់ថ្នាំជក់ ឬទេ? 1= បាទ/ចាស (បំពេញលេខកូដខាងក្រោម) 2= ទេ (រំលងទៅសំណួរទី២០)	បច្ចុប្បន្នអ្នកជក់បារីប៉ុន្មានដើមជាមធ្យម ក្នុងមួយថ្ងៃ?		ថ្លៃចំណាយក្នុងរយៈពេលក្នុងមួយថ្ងៃ (គិតជារៀល)		តើ (ឈ្មោះ)បច្ចុប្បន្នជក់បារីអេឡិចត្រូនិចដែរឬទេ? 1= បាទ/ចាស (បំពេញលេខកូដខាងក្រោម) 2= ទេ (រំលងទៅផ្នែកទី៣)	ក្នុងរយៈពេល 30 ថ្ងៃកន្លងទៅ តើអ្នកបានប្រើបារីអេឡិចត្រូនិច ឬផលិតផលវេប ប៉ុន្មានថ្ងៃ? 1= ១-២ថ្ងៃ 2= ៣-៥ថ្ងៃ 3= ៦-៩ថ្ងៃ 4= ១០-១៩ថ្ងៃ 5= ២០-២៩ថ្ងៃ 6= ៣០ថ្ងៃ	ក្នុងរយៈពេល 30 ថ្ងៃកន្លងមក តើអ្នកបានចំណាយលើបារីអេឡិចត្រូនិចឬផលិតផលវេបប៉ុន្មាន (គិតជារៀល)?	តើអ្នកទិញបារីអេឡិចត្រូនិក ឬផលិតផលវេប ដោយរបៀបណា? 1= ការបញ្ជាទិញតាមអ៊ីនធឺណិត 2= ការទិញពីមនុស្សទៅមនុស្ស
					បារីផលិត	បារីម៉ូរដៃ	បារីផលិត	បារីម៉ូរដៃ				
1	12	13	14	15	16	17	18	19	20	21	22	23
1												
2												
3												
4												
5												
6												
7												
8												
9												
0												

សំណួរគ្រួសារផ្នែក ៣ ៖ ព័ត៌មានអំពីលទ្ធភាពមានកូនរបស់ស្ត្រីអាយុពី ១៥ ឆ្នាំឡើង ដែលបានកត់ត្រាក្នុងបង្គោល ១ ផ្នែក ១ ៖ ព័ត៌មានបុគ្គល

លេខរៀង	នាមត្រកូល និងនាមខ្លួន	លេខរៀងស្ត្រីក្នុងបង្គោល 1 ផ្នែក 1	ព័ត៌មានអំពីលទ្ធភាពមានកូន ចំនួនក្មេងកើត (ចុះចំនួនជាលេខពីរខ្ទង់ដូចជា 01, 02, ..., 10, 11 ។ល។ បើគ្មាន ចុះ "00")						ព័ត៌មានអំពីលទ្ធភាពមានកូន ក្នុងរយៈពេល 12 ខែកន្លងមក ចំពោះស្ត្រី អាយុ 15 - 49 ឆ្នាំ			
			តើអ្នកស្រីបានបង្កើតកូនរស់បានប៉ុន្មាននាក់?		មានកូនប៉ុន្មាននាក់ដែលនៅរស់?		មានកូនប៉ុន្មាននាក់ដែលបានស្លាប់?		ក្នុង 12 ខែកន្លងមក តើអ្នកស្រីបានបង្កើតកូនប៉ុន្មាននាក់? សូមចុះចំនួនកូនដែលបានកើត បើមិនបានបង្កើតកូន សូមចុះលេខ "0" រួចសួរទៅស្ត្រីបន្ទាប់		តើមានអ្នកណាជួយក្នុងពេលសម្រាលកូននេះ? (ចុះលេខកូដ)	តើអ្នកបានចុះសំបុត្រកំណើតកូនដែលទើបកើតនេះជាមួយអាជ្ញាធរឃុំ/សង្កាត់ឬទេ? (ចុះលេខកូដ)
1	2	3	4		5		6		7		8	9
			(ក) ប្រុស	(ខ) ស្រី	(ក) ប្រុស	(ខ) ស្រី	(ក) ប្រុស	(ខ) ស្រី	(ក) ប្រុស	(ខ) ស្រី		
1												
2												
3												
4												
5												
6												
7												
8												
9												
0												

លេខកូដបង្គោល 8		លេខកូដបង្គោល 9
1= វេជ្ជបណ្ឌិត	4= ឆ្មបបុរាណ (TBA)	1= បាទ/ចាស
2= គិលានុបដ្ឋាក/យិកា	5= ផ្សេងទៀត (សូមបញ្ជាក់)	2= ទេ
3= ពេទ្យឆ្មប	6= គ្មាន	

សំណួរគ្រួសារផ្នែក ៤៖ ស្ថានភាពលំនៅដ្ឋាន ផ្ទះសម្បែង និងបរិស្ថាន

លេខរៀង	សំណួរ	លេខកូដចម្លើយ	ចម្លើយ (ចុះលេខកូដ)
1	តើអ្នកកាន់កាប់លំនៅដ្ឋាននេះ តាមមូលដ្ឋានអ្វី?	1= ផ្ទះផ្ទាល់ខ្លួន 2= ផ្ទះជួល 3= មិនមែនម្ចាស់ផ្ទះតែជួលមិនបង់ប្រាក់ឈ្នួល 4= មូលដ្ឋានផ្សេងទៀត (សូមបញ្ជាក់)..........	
2	ប្រភពបំភ្លឺចម្បង	1= អគ្គិសនីបណ្ដាញ 2= ម៉ាស៊ីនភ្លើង 3= អគ្គិសនីបណ្ដាញ និងម៉ាស៊ីនភ្លើង 4= ប្រេងកាត 5= ទៀន 6= អាគុយ ថ្មពិល 7= ផ្សេងទៀត (សូមបញ្ជាក់)..........	
3	ប្រភពថាមពលចម្បងប្រើប្រាស់សម្រាប់ចម្អិនអាហារ	1= ឧស 2= ធ្យូងឈើ ធ្យូងថ្ម 3= ប្រេងកាត 4= ហ្គាស/ឧស្ម័ន 5= អគ្គិសនី 6= គ្មាន 7= ផ្សេងទៀត (សូមបញ្ជាក់)..........	
4	ប្រភេទបង្គន់ប្រើប្រាស់ដោយគ្រួសារ	1= គ្មានបង្គន់, 2=បង្គន់ដងទឹកចាក់ ឬចុចបង្ហូរទឹក តភ្ជាប់ទៅបណ្ដាញលូសាធារណៈ, 3= បង្គន់ដងទឹកចាក់ ឬចុចបង្ហូរទឹកតភ្ជាប់ទៅអាងស្តុក (septic tank), 4=បង្គន់ដងទឹកចាក់ ឬចុចបង្ហូរទឹកតភ្ជាប់ទៅរណ្ដៅ (Pit), 5= បង្គន់ដងទឹកចាក់ ឬចុចបង្ហូរទឹកតភ្ជាប់ទៅរណ្ដៅភ្លោះ (Twin Pits), 6=បង្គន់ដងទឹកចាក់ ឬចុចបង្ហូរទឹកតភ្ជាប់ទៅប្រឡាយ/លូ ចំហ, 7= បង្គន់ដងទឹកចាក់ ឬចុចបង្ហូរទឹក មិនដឹងបង្ហូរទៅកន្លែងណា, 8=បង្គន់អាកាស (បង្គន់ខ្ពស់មានសុវត្ថិភាពពីទឹកជំនន់) តភ្ជាប់ទៅរណ្ដៅ (Sky Latrine), 9=បង្គន់រណ្ដៅស្ងួតមានផែនបង្គន់សម្រាប់បត់ជើង, 10=បង្គន់រណ្ដៅស្ងួតគ្មានផែនបង្គន់សម្រាប់បត់ជើង, 11=បង្គន់ភ្ជាប់ទៅធុងបណ្ដែតទឹក/បង្គន់បណ្ដែតទឹក (Container based sanitation), 12=បង្គន់មាត់ទឹក/លើទឹក/បង្គន់លើដីបង្ហូរចូលផ្ទាល់ទៅប្រភពទឹកលើដី (Hanging toilet), 13=បង្គន់ផ្សេងទៀត (សូមបញ្ជាក់)................	
5	តើគ្រួសារមានបង្គន់រួមជាមួយគ្រួសារដទៃទៀតឬទេ?	1= ប្រើរួមជាមួយគ្រួសារដទៃទៀត 2= ទេប្រើតែសមាជិកគ្រួសារ	
6	តើបង្គន់/កន្លែងស្តុកលាមក (បង្គន់ធុង/បង្គន់រណ្ដៅ) ធ្លាប់ស្តារឬទេ?	(សម្រាប់បង្គន់លេខកូដ 3, 4, 5, 8 និង 11 ក្នុងចម្លើយសំណួរទី4) 1= ធ្លាប់ស្តារ 2= មិនដែលស្តារ (រំលងទៅសំណួរ 8)	
7	តើបង្គន់ដែលបានស្តារទុកដាក់នៅកន្លែងណា?	1= ស្តារដោយអ្នកផ្តល់សេវាទៅកន្លែងប្រព្រឹត្តកម្មទឹកស្អុយ 2= ស្តារដោយអ្នកផ្តល់សេវា តែមិនដឹងចោលកន្លែងណា 3= យកទៅកប់ក្នុងរណ្ដៅ 4= វាលស្រែ ក្នុងទឹក ឬកន្លែងផ្សេងទៀត	
8	ប្រភពផ្គត់ផ្គង់ទឹកចម្បងសម្រាប់ទទួលទាន (ផឹក)	1= ទឹកបំពង់បណ្ដាញក្នុងលំនៅដ្ឋាន 2= ទឹកបំពង់បណ្ដាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន 3= ទឹកបំពង់សាធារណៈ 4= អណ្ដូងស្នប់/អណ្ដូងខួង 5= អណ្ដូងជីកមានគម្របការពារ 6= អណ្ដូងជីកគ្មានគម្របការពារ 7= ទឹកចេញក្រោមដីមានការការពារ 8= ទឹកចេញក្រោមដីគ្មានការការពារ 9= ទឹកភ្លៀង 10= ទិញទឹកឡានស៊ីទែន 11= ទិញទឹកធុងរទេះ 12= ទឹកលើដី (ទឹកទន្លេ/ស្ទឹង/ព្រែក/បឹង/ស្រះ/អូរ/ត្រពាំង) 13= ទឹកដប/ទឹកពិសាដប 14= ផ្សេងទៀត (សូមបញ្ជាក់)..........	
9	រយៈពេលទៅមក ដើម្បីយកទឹកមកផឹក សម្រាប់គ្រួសារ	1= ទឹកនៅក្នុងលំនៅដ្ឋាន 2= ចំណាយតិចជាង 30 នាទី 3= ចំណាយច្រើនជាង 30 នាទី 4= មិនដឹង	
10	តើគ្រួសារតែងតែមានទឹកផឹកគ្រប់គ្រាន់ នៅពេលត្រូវការផឹក?	1= គ្រប់គ្រាន់ 2= មិនគ្រប់គ្រាន់	
11	ចំនួនបន្ទប់ដែលគ្រប់គ្រងដោយគ្រួសារ	ចំនួនបន្ទប់	|___|___|
12	តើសមាជិកគ្រួសារណាម្នាក់មានដីកម្មសិទ្ធិកសិកម្មឬទេ?	1= មាន 2= គ្មាន	
13	តើគ្រួសារមានប្រភេទប័ណ្ណសមធម៌ដូចរៀបរាប់ណាមួយដែរឬទេ?	1= ក្រ១ 2= ក្រ២ 3=គ្មាន	
14	តើគ្រួសារអ្នកមានប័ណ្ណគ្រួសារងាយរងហានិភ័យដែរឬទេ?	1= មាន 2= គ្មាន	
15	តើសមាជិកគ្រួសារណាម្នាក់មានប្រើប្រាស់អ៊ីនធឺណែតឬទេ? (រាប់ទាំងនៅផ្ទះ ទូរស័ព្ទដៃ ទីសាធារណៈ និងកន្លែងធ្វើការ)	1= មាន 2= គ្មាន	

វិទ្យុ/ម៉ាញ៉េ	ទូរទស្សន៍	ទូរស័ព្ទលើតុ	ទូរស័ព្ទដៃ	កុំព្យូទ័រផ្ទាល់ខ្លួន និងកុំព្យូទ័រលើតុ	កង់	ម៉ូតូ	ទូទឹកកក	ម៉ាស៊ីនបោកខោអាវ	កង្ហារ	ម៉ាស៊ីនត្រជាក់	រថយន្តធុនតូច/ទេសចរណ៍	រថយន្តធុនធំ/ដឹកទំនិញ	ទូក/កាណូត	ត្រាក់ទ័រធុនតូច/ធំ
16	17	18	19	20	21	22	23	24	25	26	27	28	29	30
|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|	|___|___|

សំណួរគ្រួសារផ្នែក ៤ ស្ថានភាពលំនៅដ្ឋាន ផ្ទះសម្បែង និងបរិស្ថាន

គោលបំណង៖ ដើម្បីវាយតម្លៃចំណេះដឹង ឥរិយាបថ និងការអនុវត្ត និងកត្តាហានិភ័យសម្រាប់ជំងឺមិនឆ្លង និងរបួសសំខាន់ៗ។ សំណួរគួរត្រូវបានសួរទៅកាន់គ្រួសារដែលមានស្ត្រីមានផ្ទៃពោះ កុមារ និងក្មេងជំទង់ដែលមានអាយុចន្លោះពី 0-18 ឆ្នាំ។ កម្រងសំណួរគួរចំណាយពេលអតិបរមា 15 នាទីក្នុងមួយគ្រួសារ/អ្នកឆ្លើយ។

លេខរៀង	សំណួរ	សូមគូសរង្វង់លេខកូដចម្លើយសមស្រប
31	តើគ្រួសារអ្នកមានទីតាំងនៅជិតកន្លែងណាមួយដូចខាងក្រោមដែរឬទេ? (ជ្រើសរើសចម្លើយបានច្រើន)	1-ឧស្សាហកម្ម/រោងចក្រ 2-តំបន់មានចរាចរច្រើន 3-កសិកម្ម/ដីស្រែចំការ 4- ប្រភពទឹក (ទន្លេ បឹង ស្រះ អូរ ប្រឡាយ ។ល។) 5-កន្លែងជីករ៉ែ 6- កន្លែងចោលសំរាម (រួមទាំងសំណល់គ្រួសារ សំណល់វេជ្ជសាស្ត្រ និងសំណល់អេឡិចត្រូនិច) 7-ផ្សេងទៀត (បញ្ជាក់) 8-គ្មានខាងលើទេ
32	ឆ្នាំមុន តើមាននរណាម្នាក់ក្នុងគ្រួសារ អ្នកធ្វើការក្នុងឧស្សាហកម្មណាមួយក្នុងចំណោមឧស្សាហកម្មទាំងនេះទេ? (ជ្រើសរើសចម្លើយបានច្រើន)	1. ផលិតថ្ម 2 អេឡិចត្រូនិច 3. ផលិត/កែច្នៃគ្រឿងអលង្ការ 4. អាគុយអាស៊ីត និង/ឬ កែច្នៃកាកសំណល់អេឡិចត្រូនិច 5 ថ្ងៃដែក / សំណល់អេតចាយ 6. ក្រុមហ៊ុនវាយនភណ្ឌ 7. ឧស្សាហកម្មផ្សេងទៀត (បញ្ជាក់) 8. គ្មានខាងលើ
33	តើការចម្អិនអាហារជាទូទៅនៅក្នុងផ្ទះ ក្នុងអាគារដោចដោយឡែក ឬនៅខាងក្រៅផ្ទះ?	1. ក្នុងផ្ទះ/បន្ទប់ទទួលភ្ញៀវ ឬផ្ទះបាយ 2. អគារដាច់ដោយឡែក 3. ក្រៅ / កន្លែងបើកចំហ 4. កន្លែងផ្សេង (បញ្ជាក់)
34	តើការបំពុលប្រភេទណាដែលអ្នកគិតថាប៉ះពាល់ដល់សុខភាពកុមារ? (ជ្រើសរើសចម្លើយបានច្រើន)	1. ការបំពុលខ្យល់ 2. ការបំពុលទឹក 3. ការបំពុលដី 4. អាហារមានមេរោគ 5. លោហធាតុធ្ងន់/ពុល (សំណ បារត អាសេនិច កាដមីញ៉ូម ។ល។) 6. ថ្នាំសំលាប់សត្វល្អិត 7. គ្មានខាងលើទេ
35	តើផលប៉ះពាល់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុប្រភេទណាខ្លះដែលអ្នកព្រួយបារម្ភ? (ជ្រើសរើសចម្លើយបានច្រើន)	1-សីតុណ្ហភាពខ្ពស់ 2-ការកើនឡើងកម្រិតទឹកសមុទ្រ 3-ព្យុះ/ទឹកជំនន់ 4- ជំងឺទឹក 5-គ្រោះរាំងស្ងួត 6-ភ្លើងឆេះព្រៃ 7-ផលប៉ះពាល់លើវិស័យកសិកម្ម 8-ផលប៉ះពាល់លើសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី (ការថយចុះភាពចម្រុះ។ល។) 9-ផ្សេងទៀត (បញ្ជាក់) 10-គ្មានខាងលើទេ
36	តើអ្នកដឹងពីអ្វីដែលត្រូវធ្វើដើម្បីការពារខ្លួនអ្នក និងកូនរបស់អ្នកពីកំដៅ និងសីតុណ្ហភាពអាកាសធាតុខ្ពស់?	1-បាទ 2-ទេ 3-មិនប្រាកដ
37	(សួរសំណួរនេះទៅក្មេងអាយុពី 10-19 ឆ្នាំ បើគ្មាន សួរមេផ្ទះ/អ្នកឆ្លើយចំបង។ ប្រើមាត្រដ្ឋាន 1 ដល់ 10៖ 1 មិនខ្វល់ខ្វាយទាំងអស់ និង 10 ព្រួយបារម្ភខ្លាំង) តើអ្នកមានការព្រួយបារម្ភ ឬព្រួយបារម្ភយ៉ាងណាចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើអនាគតរបស់អ្នក?	**កត់ត្រាចម្លើយ (ដោយឱ្យពិន្ទុពី ១ ដល់ ១០)**
38	តើអ្នកគិតថា លោហធាតុធ្ងន់ (ឧទាហរណ៍ សំណ បារត កាដមីញ៉ូម អាសេនិច) អាចប៉ះពាល់ដល់សុខភាពកុមារទេ?	1-បាទ 2-ទេ 3-មិនដឹង/មិនប្រាកដ
39	តើកូនៗរបស់អ្នកលេងនៅជិតកន្លែងដូចរៀបរាប់នេះឬទេ?	1-កន្លែងជីករ៉ែ 2-កន្លែងចាក់សំរាម 3-កន្លែងកែច្នៃថ្ម 4-កន្លែងកាកសំណល់អេឡិចត្រូនិច 5-ផ្សេងទៀត (បញ្ជាក់) 6-គ្មានខាងលើទេ
40	(បើអ្នកឆ្លើយបានលើកឡើងពីកន្លែងណាមួយនៅក្នុង Q.39 សួរសំណួរខាងក្រោម។ បើមិនអញ្ចឹងទេ សូមរំលងទៅ Q.41) តើកូនរបស់អ្នកលេងនៅជិតកន្លែងនេះញឹកញាប់ប៉ុណ្ណា?	1-ប្រចាំថ្ងៃ 2-ច្រើនដងក្នុងមួយសប្តាហ៍ 3-ម្តងក្នុងមួយសប្តាហ៍ 4-ពីរបីដងក្នុងមួយខែ 5-កម្រ (ម្តងក្នុងមួយខែ ឬតិចជាងនេះ) 6-ផ្សេងទៀត (បញ្ជាក់) 7-មិនដឹង
41	តើកូនរបស់អ្នកបានប៉ះពាល់នឹងប្រភពណាមួយនៃការបំពុលខ្យល់ដែរឬទេ? (ជ្រើសរើសរាល់ចម្លើយទាំងអស់ដែលទាក់ទង)	1-ការដុតសំណល់ 2-ផ្សែងបារី 3-ការបំពុលបរិយាកាសដោយសារឧស្សាហកម្ម 4-ការបំពុលបរិយាកាសក្នុងផ្ទះ (ការអនុវត្តការចម្អិនអាហារបែបបុរាណ ប្រើជីវម៉ាសសម្រាប់ចម្អិនអាហារ) 5-ដង់ស៊ីតេចរាចរណ៍ខ្ពស់ 6-ភ្លើងឆេះព្រៃ 7-ការដុតដោយចំហរ 8- ផ្សេងទៀត (បញ្ជាក់) 9-មិនដឹង/មិនប្រាកដ 10-គ្មានខាងលើទេ
42	តើអ្នកបានកត់សម្គាល់ថា កូនរបស់អ្នកមានសញ្ញាផ្លូវដង្ហើមរយៈពេលវែង កើតមានម្តងហើយម្តងទៀត (ឧទា. ក្អក ហឺត) ឬទេ?	1-បាទ 2-ទេ 3-មិនដឹង/មិនប្រាកដ
43	តើមានកូនណាម្នាក់ក្នុងគ្រួសាររបស់អ្នកធ្លាប់មានរបួស ឬស្លាប់ដែលទាក់ទងនឹងផ្លូវទេ?	1-បាទ 2-ទេ 3-មិនដឹង
44	តើមានកូនណាម្នាក់ក្នុងគ្រួសាររបស់អ្នកធ្លាប់មានរបួស ឬស្លាប់ដោយសារលង់ទឹកដែរឬទេ?	1-បាទ 2-ទេ 3-មិនដឹង

សំណួរគ្រួសារផ្នែក ៥ ៖ មនុស្សស្លាប់នៅក្នុងគ្រួសារ

មនុស្សស្លាប់នៅក្នុងគ្រួសារ ក្នុងរយៈពេល 12 ខែកន្លងមក ចំនួនមនុស្សស្លាប់សរុប | | |

ព័ត៌មានអំពីអ្នកស្លាប់

លេខរៀង	នាមត្រកូល និងនាមខ្លួន	ភេទ 1= ប្រុស 2= ស្រី	ទំនាក់ទំនងជាមួយមេគ្រួសារ (ចុះលេខកូដ)	អាយុនៅពេលស្លាប់ មើលកំណត់សំគាល់ខាងក្រោម (ចុះលេខកូដ)	មូលហេតុនៃការស្លាប់ តើការស្លាប់បណ្តាលមកពីមូលហេតុអ្វី? (ចុះលេខកូដ)	ចុះសំបុត្រមរណភាព តើអ្នកបានចុះសំបុត្រមរណភាពអ្នកដែលស្លាប់ជាមួយអជ្ញាធរឃុំ/សង្កាត់ឬទេ? 1= បាទ/ចាស 2= ទេ	សម្រាប់តែស្ត្រីអាយុ 15 - 49 ឆ្នាំដែលបានស្លាប់ តើស្ត្រីបានស្លាប់នៅពេលមានផ្ទៃពោះ ឬអំឡុងពេលសម្រាលកូន ឬក្នុងរយៈពេល 42 ថ្ងៃក្រោយពេលសម្រាលកូនឬទេ? 1= បាទ/ចាស 2= ទេ	បើបាទ/ចាស នៅក្នុងបង្គោល 8(ក) តើស្លាប់នៅកន្លែងណា? (ចុះលេខកូដ)	បើបាទ/ចាស នៅក្នុងបង្គោល 8(ក) តើមានអ្នកជំនាញខាងសុខាភិបាលណាម្នាក់មានវត្តមានយកចិត្តទុកដាក់ចំពោះនាងមុនស្លាប់ដែរឬទេ? (ចុះលេខកូដ)
1	2	3	4	5	6	7	8(ក)	8(ខ)	8(គ)
1									
2									
3									
4									
5									
6									
7									
8									
9									
0									

លេខកូដបង្គោល 4

1= មេគ្រួសារ
2= ប្រពន្ធ/ប្តី
3= កូនប្រុស/កូនស្រី
4= ឪពុក/ម្តាយ
5= ចៅ
6= សាច់ញាតិផ្សេងទៀត
7= អ្នកមិនមែនជាសាច់ញាតិ

លេខកូដបង្គោល 5

ចុះអាយុជាឆ្នាំពេញនៅពេលស្លាប់
000= តិចជាង1ឆ្នាំ
001= 1 ឆ្នាំ
002= 2 ឆ្នាំ
....
....

លេខកូដបង្គោល 6 មូលហេតុនៃការស្លាប់

ជំងឺ		គ្រោះថ្នាក់	មិនដឹង
1= គ្រុនក្តៅ	7= តេតាណូស	13= មីនកប់ក្នុងដី	17= មិនដឹង
2= រាគ	8= អេដស៍	14= គ្រោះថ្នាក់ចរាចរណ៍	
3= របេង	9= បញ្ហាពេលមានផ្ទៃពោះ	15= លង់ទឹក	
4= ជំងឺបេះដូង	10= បញ្ហានៅពេលសម្រាលកូន	16= គ្រោះថ្នាក់ផ្សេងទៀត (សូមបញ្ជាក់)	
5= គ្រុនឈាម	11= ក្រោយពេលសម្រាល ៤២ ថ្ងៃ		
6= គ្រុនចាញ់	12= ជំងឺផ្សេងទៀត (សូមបញ្ជាក់)		

លេខកូដបង្គោល 8(ខ)

1= មន្ទីរពេទ្យ(រដ្ឋ និងឯកជន)
2= មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព
3= នៅផ្ទះ
4= ផ្សេងទៀត (សូមបញ្ជាក់)

លេខកូដបង្គោល 8(គ)

1= វេជ្ជបណ្ឌិត
2= គិលានុបដ្ឋាក/យិកា
3= ពេទ្យឆ្មប
4= ឆ្មបបុរាណ (TBA)
5= ផ្សេងទៀត (សូមបញ្ជាក់)
6= គ្មាន